លី ថៃលី

# វចនានុក្រម

# សុភាសិតខ្មែរ

# អធិប្បាយ



ស្រួសដើមទ្រូងប្រាំហត្ថ

ភាគ ២

PB....2013..........
398.959603
ថៃល
ភាគ ២

# វចនានុក្រម
# សុភាសិតខ្មែរអធិប្បាយ

ដោយ

## លី ថៃលី

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

## ភាគ ២

00025161

ពី "ន" ដល់ "អ"

ចំនួន ២៣៧ សុភាសិត

បោះពុម្ពលើកទី១ ចំនួន ២០០០ ច្បាប់
ក្រុងព្រះសីហនុ ថ្ងៃទី ១ ធ្នូ ២០១១

រក្សាសិទ្ធិ



លោកគ្រូធម្មបាល ខៀវ ជុំ

# វាចាខ្ញុំ

សៀវភៅនេះ មិនមែនជាសៀវភៅ "វេយ្យាករណ៍" រឺជាសៀវភៅ" សរសេរតាមអាន"ទេ ។ ដូច្នេះ ពាក្យពេចន៍ខ្លះ មិនស្របតាមវចនានុក្រមរបស់សម្តេចព្រះអគ្គបណ្ឌិតព្រះសង្ឃរាជ **ជួន ណាត** ទេ។ គឺខ្ញុំសុំសិទ្ធិប្រើបរិពាក្យខ្លះ ដូចជា ទំរើដំនើរ ចំនង សំនាង សំនល់ រឹងពឹង ជាដើម ។

ខ្ញុំសូមជំរាបថា សៀវភៅ "វចនានុក្រមសុភាសិតខ្មែរអធិប្បាយ" ទាំងពីរភាគនេះ ខ្ញុំព្យាយាមរៀបរៀងអស់រយះកាលប្រហែល៦ឆ្នាំ ទើបហើយស្រេច។ ព្រោះធ្វើផង ទុកចោលផង ពុំបានធ្វើជាប់លាប់ទេ ដោយបញ្ហាជីវភាពខ្សត់ខ្សោយ។ សៀវភៅភាគពីរនេះ ខ្ញុំហៀបតែនឹងទុកចោលទៅហើយ ព្រោះអស់សង្ឃឹម ដោយគិតថា គ្មានការគាំទ្រ។

បន្ទាប់មក ក៏ស្រាប់តែមានទូរស័ព្ទមកសំដែងការគាំទ្រ និងលើកទឹកចិត្តផងសួររកភាគពីរទៀតផង។ ជាមួយនឹងការគាំទ្រនេះ នៅមានរឿងមួយគួរអោយចង់សើច។ ព្រោះមានអស់លោកខ្លះ ភ័យខ្លាចខ្ញុំសរសេរភាគ២មិនទាន់ ព្រោះអាយុច្រើនណាស់ទៅហើយ ។

ការលើកទឹកចិត្ត និងគាំទ្រនេះហើយ ធ្វើអោយខ្ញុំឡើងជោរសន្ទឹក ខ្ញុំក៏ចាប់សរសេរភាគ២រហូតដល់បានចប់ជាស្ថាពរ ។

ប៉ុន្តែ...ជាពិសេស ខ្ញុំសូមជំរាបដោយស្មោះថា អ្នកដែលជួយជាកំលាំងចិត្តខ្ញុំខ្លាំងជាងគេ គឺ "គ្រួសារ"របស់ខ្ញុំតែម្តង។

ម្យ៉ាងទៀត ខ្ញុំក៏ដឹងច្បាស់ថា ការតាក់តែងសៀវភៅនេះឡើង ប្រាកដជាមាន

ភាពមិនច្បាស់ មិនសមស្រប មិនល្អ ប៉ុន្មានទេ។ ព្រោះទំរើអ្វីក៏ដោយ ដែលពុំមានយោបល់ជួយបំភ្លឺពីអ្នកផង ច្បាស់ជាពុំបានល្អឡើយ។ ប៉ុន្តែ បើពុំបានល្អ អស់ទាស់យ៉ាងណាក៏ដោយ ក៏វាគ្រាន់បើជាងគ្មានទៅដែរ។ គឺទុកវាដូចជា ពន្លឺភ្លើងទៀនដ៏តូចមួយ នៅក្នុងទីងងឹតដូច្នោះឯង។

មួយវិញទៀត ការតាក់តែង និងរៀបរៀងអោយបានជារូបរាងសៀវភៅនេះឡើង គឺធ្វើដោយមតិយោបល់ និងគំនិតរបស់ខ្ញុំផ្ទាល់ម្នាក់ឯងគត់ ឥតមានអ្នកដទៃណា ជាគំរប់ពីរឡើយ។ ម្ល៉ោះហើយ ការភ្លាំងភ្លាត់ កង្វះចន្លោះ ដោយចេតនាក្តី ដោយអចេតនាក្តី ប្រាកដជាមានមិនខានទេ។

ហេតុនេះ សូមសិក្ខាកាមទាំងឡាយមេត្តាកុំមើលបំនាំ គឺសូមជួយធ្វើការរិះគន់កែលម្អដោយក្តីអនុគ្រោះផងចុះ។

ប៉ុន្តែខ្ញុំជឿថាសៀវភៅនេះ បើមិនទាន់ល្អក៏ដោយ ក៏គង់មានអ្នកចាំចំលងយកទៅបំភ្លៃកែចុះ កែឡើង ដើម្បីធ្វើជាស្នាដៃរបស់ខ្លួនមិនខានឡើយ។

នៅទីបញ្ចប់នេះខ្ញុំសូមជំរាបថា បើជីវិតខ្ញុំនៅមិនទាន់គេត្រូវការទេ ខ្ញុំប្តេជ្ញាថានឹងធ្វើការដកស្រង់ ពាក្យស្លោកនៅក្នុង"ស្រីហិតោបទេស" របស់ព្រះតេជព្រះគុណវីរយបណ្ឌិតោ **ជាំង ខាត់** មកធ្វើការអធិប្បាយ ជូនអស់លោកសិក្ខាកាមបន្ត ទៀត៕

សូមអរគុណ

ក្រុងព្រះសីហនុ ថ្ងៃទី ១.៧.១១

លិខិតករ

**លី ថៃលី**

ទូរសព្ទ ០១៦ ៧៣ ១១ ៥១

# ប្រវត្តិនៃការបោះពុម្ពផ្សាយ

ខ្ញុំមានចិត្តសោមនស្សរីករាយខ្លាំងណាស់ ដែលបានអស់លោកសាស្ត្រាចារ្យ និងនិស្សិត មានចំនាប់អារម្មណ៍ចំពោះវណ្ណកម្មរបស់ខ្ញុំនេះ។ ដំបូងឡើយខ្ញុំមិននឹកស្មានថា មានសិក្ខាកាមគាំទ្រទន្ទូរស្នាដៃរបស់ខ្ញុំទេ។ ព្រោះកាលខ្ញុំសរសេរសៀវភៅនេះរួចខ្ញុំបានយកសំណៅដើមទៅបណ្ណាគារមួយនៅភ្នំពេញ ដើម្បីបោះពុម្ពផ្សាយ។ បណ្ណាគារនោះ បានអោយខ្ញុំកក់ថ្លៃក្រដាសពាក់កណ្ដាលសិន។ ប៉ុន្តែ អនិច្ចាអើយ! ខ្ញុំរកលុយគ្រាន់នឹង"រស់"នឹងគេ សឹងពុំបានផង តើមានលុយឯណាជាងមួយពាន់ដុល្លារនោះ។

ដូច្នេះ ដើម្បីអោយសៀវភៅនេះប្រសូតចេញរួច ខ្ញុំសុខចិត្តចំនាយពលកម្ម និងគំនិតបញ្ញារបស់ខ្ញុំក្នុងការព្យាយាមតាក់តែងសៀវភៅនេះទាំងអស់ គឺសុខចិត្តប្រគល់សំនៅដើមនេះ អោយទៅបណ្ណាគារនោះ ដោយមិនយកកំរៃមួយសេនឡើយ។ តែគេឆ្លើយថា បោះចេញពុំបានទេ ព្រោះសៀវភៅនេះ មិនដឹងជាមានគេអានវឺអត់ផង។ ទោះបីជាខ្ញុំខំនិយាយពន្យល់គេពីអត្ថប្រយោជន៍ និងខ្លឹមសារនៃសៀវភៅនេះយ៉ាងណាក៏ដោយ។ ទីបំផុត ខ្ញុំកាន់សំនៅនេះ ទៅអង្វរបណ្ណាគារមួយទៀតដោយរៀបរាប់ប្រាប់គេដូចមុន ព្រមទាំងសន្យាថា មិនទាមទារកំរៃអ្វីទេ។ ពេលនោះចាត់ទុកថាជាសំនាងរបស់ខ្ញុំទៅចុះ គឺគេព្រមទទួលបោះពុម្ពផ្សាយចំនួនពីរពាន់ច្បាប់។ ចំនែកខ្ញុំ នៅតែពុំបានទទួលលទ្ធផលអ្វីដដែល។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយក៏ខ្ញុំសប្បាយចិត្តយ៉ាងក្រៃលែង។ ព្រោះខ្ញុំបានឃើញស្នាដៃរបស់ខ្ញុំចេញផ្សាយ បំរើសិក្ខាកាម តាមបំនងប្រាថ្នារបស់ខ្ញុំមកជាយូរហើយ។ ជាពិសេសទៅទៀត ខ្ញុំសែន

សប្បាយចិត្តឥតឧបមា ដោយបានឃើញស្នាដៃរបស់ខ្លួនចេញបំរើលោក អ្នកនាងទាន់ភ្នែកខ្ញុំនៅមើលឃើញ ។

ខ្ញុំសូមជំរាបដោយស្មោះថា នៅពេលដែលមានសភាពតានតឹងក្នុងការបោះពុម្ពផ្សាយដូច្នេះ ខ្ញុំមានការធ្លាក់ទឹកចិត្តជាខ្លាំង ។

ដូច្នេះ កិច្ចការដែលត្រូវធ្វើបញ្ចប់ភាគពីរទៀតនោះ ខ្ញុំក៏បោះបង់វាចោលនៅពាក់កណ្ដាលផ្លូវតែម្ដងទៅ ។

ប៉ុន្តែ បន្ទាប់មកទៀត គឺនៅពេលមួយគ្រូសារខ្ញុំសួរថា ម៉េចមិនឃើញសរសេរសៀវភៅទៀត? ខ្ញុំឆ្លើយប្រាប់គេហើហូរហែសព្វគ្រប់ ។ គេហ៏ថា ធ្វើអីចឹងមិនត្រូវទេ! ត្រូវ "ប្រមូល" សំនៅទាំងអស់ មកសរសេរឡើងវិញទៅ! ។

ពេលនោះ ខ្ញុំស្រាប់តែមានកំលាំងចិត្តនឹកចង់សរសេរឡើងវិញភ្លាម ។ មួយវិញទៀត ខ្ញុំក៏នឹកឃើញដល់ពាក្យស្លោកបារាំងមួយឃ្លាថា "Ni dame, ni demoiselle au monde, les hommes seraient moins braves នៅក្នុងពិភពលោកនេះ បើគ្មានស្ត្រីទេ បុរសគ្មានសេចក្តីក្លាហានឡើយ" ។

ពេលហ្នឹង ខ្ញុំសារភាពថា "ស្ត្រីគឺជាកំលាំងចិត្តដ៏មហិមារបស់បុរស" ។

ទីបំផុត ខ្ញុំក៏ព្យាយាមតាក់តែង "ភាគពីរ" បានចប់សព្វគ្រប់ រួចយកទៅប្រគល់អោយរោងពុម្ព "ពេជ្រណៃត" បោះពុម្ពផ្សាយទៅ ៕

ក្រុងព្រះសីហនុ ថ្ងៃទី ៤.៧.១១

លិខិតករ

**លី ថៃលី**

ទូរសព្ទ ០១៦ ៧៣ ១១ ៥១

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំសូមឱនកាយថ្វាយបង្គំចំពោះព្រះសង្ឃ និងសំដែងនូវគារវកិច្ចចំពោះអស់លោកសាស្ត្រាចារ្យ និងសិស្ស និស្សិត ដែលបានទូរសព្ទមកលើកទឹកចិត្ត និងថ្លែងអំណរអបអរសាទរ ក្រោយពីបានអាន "*វចនានុក្រម សុភាសិតខ្មែរ អធិប្បាយ*" ជាពិសេសបានសួររក "ភាគពីរ" តើធ្វើចប់ហើយរឺនៅ? ព្រោះមានការទន្ទឹងរង់ចាំ ។

កត្តាទាំងអស់នេះហើយ ដែលធ្វើអោយខ្ញុំមានកំលាំងចិត្ត និងឡើងជំនោរជាខ្លាំង ។

ខាងក្រោមនេះ គឺជាព្រះនាម និងនាមអស់លោកសិក្ខាកាម ដែលបានទូរសព្ទមកខ្ញុំ ។

1. ព្រះតេជគុណ ព្រះអនុគណ **ម៉ូ ពិសិដ្ឋ** វត្តសាមគ្គីគីរីសិរីទ្ធ ឃុំអូរអណ្តូង ស្រុកសាលាក្រៅ ខេត្តប៉ៃលិន 015 / 092 44 55 54
2. លោកសាស្ត្រាចារ្យ **ទឹម ហួរ** សាកលវិទ្យាល័យភូមិន្ទភ្នំពេញ 081901416
3. លោកវេជ្ជបណ្ឌិត **ស៊ីន ឌុច** នាយកដ្ឋានមន្ទីរពេទ្យក្រសួងសុខាភិបាល 012 335579
4. និស្សិត U M E ស្នាក់នៅឃ្លាំងលើ សង្កាត់១ ក្រុងព្រះសីហនុ 081 64 75 40
5. ព្រះតេជព្រះគុណ **នឹម រ៉ាច័ន្ទ** វត្តទ្រៀលស្រុកបារាយណ៏កំពង់ធំ081 592520
6. ព្រះតេជព្រះគុណ **មិន ជឿន** វត្តព្រៃកសំរោង ស.ក តាខ្មៅ ក្រុងតាខ្មៅ (និស្សិតមហាវិទ្យាល័យ សេដ្ឋកិច្ច) 015 57 05 75
7. ព្រះតេជព្រះគុណ **ហែម ហន** វត្តជ្រៃហោពៅ ឃុំវាល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ 092 212720
8. ព្រះតេជព្រះគុណ**សឿង ម៉េងហួ** វត្តទ្រៀលស្រុកបារាយណ៏កំពង់ធំ016949784
9. កញ្ញា **យឹម ថាវី** សិស្សសាលាអន្តរជាតិ AET អង់គ្លេសកុំព្យូទ័រ ភ្នំពេញ 081725228
10. លោកគ្រូ **ឃ្លោក សុផា** សាលាបឋមសិក្សាកំពង់ស្លែង ឃុំរការក្រៅ ស្រុកដូនកែវ ខេត្តតាកែវ 081 677 814

11. លោកសាស្ត្រាចារ្យ **អេង ឡុង** វិទ្យាល័យមិត្តភាព សង្កាត់៤ ក្រុងព្រះសីហនុ 016236253 បានធ្វើអំណោយកុំព្យូទ័រមួយគ្រឿង និងជួយវាយអក្សរបញ្ចប់ការសរសេរសៀវភៅភាគ២របស់ខ្ញុំ
12. លោក**ហ៊ី សាវណ្ណ** ប្រធានការិ.វិវាទនិងនីតិកម្មពន្ធដារក្រុងព្រះសីហនុ016511326
13. លោក **ផូ ធរ** នាយកសាលាក្រាំងលាវ ឃុំអង្គ-រមាស ស្រុកដងទង់ ខេត្តកំពត 012585281
14. លោក **ហងៃ្ស ណារិទ្ធ** អាជីវករ ផ្សារលើ ខេត្តព្រះសីហនុ 016 867 515
15. លោកសាស្ត្រាចារ្យ **ឈុន លីស** វិទ្យាល័យបុរី១០០ខ្នងភ្នំពេញ 011 71 46 33
16. អ្នកស្រី **ចៅ នីថា** ធ្វើអំណោយសៀវភៅ"វចនានុក្រម ថៃ-ខ្មែរ" មួយក្បាល
17. អ្នកស្រី **ខៀវ ដានី** អាជីវករ ផ្សារអូរឫស្សី ភ្នំពេញ ធ្វើអំណោយ "វចនានុក្រមខ្មែរ តូចធំ" ពីរក្បាល និងវចនានុក្រម អង់គ្លេស-ខ្មែរ
18. អ្នកស្រី **ប៉ៃ ណែត** អាជីវករ ផ្សារអូរឫស្សី ភ្នំពេញ ធ្វើអំណោយ "វចនានុក្រមខ្មែរធំ" មួយក្បាល
19. អ្នកស្រី **សាំង សុន្ធរី** ហៅ**ម៉ុម** អាជីវករ ផ្សារអូរឫស្សី ភ្នំពេញ ធ្វើអំណោយ "វចនានុក្រម អង់គ្លេស ខ្មែរ" មួយក្បាល

សូមអរគុណយ៉ាងជ្រាលជ្រៅបំផុត

១៦.៧.១១

លិខិតករ

**លី ថៃលី** ០១៦ ៧៣ ១១ ៥១

# ឧទ្ទិសកថា

ខ្ញុំសូមឧទ្ទិសផលានិសង្ស ដែលកើតឡើងពីការព្យាយាមតាក់តែងនូវវណ្ណកម្មនេះ ប្រគេនព្រះសព ព្រះតេជព្រះគុណ ព្រះធម្មបាល ***ខៀវ ជុំ*** ជាគ្រូទ្រឹស្តីរបស់ខ្ញុំ និងជូនសពលោកសាស្ត្រាចារ្យ ***កែវ ច័ន្ទសាក់*** ជាគ្រូអក្សរសិល្ប៍របស់ខ្ញុំ និង ជូនសពលោកគ្រូ ***លី សាលី*** ។

សូមលោកគ្រូទាំងពីរ ទទួលនូវបុញ្ញកុសលដែលបានឧទ្ទិសប្រគេន និងជូនពីកូនសិស្សកំសត់នេះ។ សូមលោកគ្រូទាំងពីររីករាយចុះ ព្រោះសព្វថ្ងៃនេះ ខ្ញុំឃើញគេយកទ្រឹស្តីរបស់លោកទាំងពីរមកប្រើមួយមួយដោយស្ងៀមស្ងាត់។

## កំនត់ចំនាំ

- ព្រះធម្មបាល ***ខៀវ ជុំ*** មានលក្ខណៈពិសេស គឺមិន"សើច" គ្រាន់តែ "ញញឹម"ប៉ុណ្ណោះ។
- លោកសាស្ត្រាចារ្យ ***កែវ ច័ន្ទសាក់*** មិន"រើសអើង"ទាល់តែសោះ សូម្បីតែសត្វឆ្កែក្នុងសាលា ក៏មានបាយស្រួបមួយឆ្នាំងធំ យកមកដាក់អោយស៊ី រាល់ថ្ងៃ មុនចូលបង្រៀន ។
- ពាក្យ"***ឧស្សនវិជ្ជា*** "បង្កើតដោយព្រះធម្មបាល ***ខៀវ ជុំ*** ។ ពាក្យ "***អក្សរសិល្ប៍***" បង្កើតដោយលោក ***កែវ ច័ន្ទសាក់*** ។

# វត្ថុនាម

ទំព័រ

ន

២១០ នៅតូចមួយខាកមួយស្ដោះធំឡើងដុះដោះ មួយអើត ពីរអើត.....២៧៦
២១១ នំមិនធំជាងនាឡិ............................................................២៧៨
២១២ នៅផ្ទះម្ដាយទីទៃ នៅព្រៃម្ដាយជាមួយ.......................................២៧៩
២១៣ នៅផ្ទះឱ្យស្រាស់បន្លា អារសាច់ជូនខ្លាទើបនៅស្រុកបាន.............. ២៨០
២១៤ នឹងលើ រង្កើក្រោម............................................................២៨២
២១៥ និយាយយប់បន្ទប់ព្រៃ និយាយថ្ងៃជញ្ជាំងមានត្រចៀក............. ២៨៣
២១៦ នាងរត់រកអ្នក មេខាតលក្សណ៍រត់រកអាបាក់ទន្សា.................... ២៨៤
២១៧ នាងតីស្នាតាងស៊ីរះសងខាងមិនឱ្យឃ្មើសចិត្ត ...............................២៨៦

ប

២១៨ ប្រុសដើមទ្រូងប្រាំហត្ថ.......................................................២៨៨
២១៩ ប្រាជ្ញចុះរណ្ដៅ ខ្លៅឡើងស្ថានសួគ៌........................................ ២៩០
២២០ បង់បោយមិនមើលប្រាណ ដាំជើងក្រានមិនប្រមាណផ្កាំង .......... ២៩១
២២១ បាតដែក៏សាច់ ខ្នងដែក៏សាច់............................................. ២៩២
២២២ បើល្ងង់កុំចង់ធ្វើចេះ បើអត់ដំរេះកុំចង់ធ្វើធំ ............................ ២៩៤
២២៣ បើមិនជួយចូកចែវ កុំយកជើងរាទឹក....................................... ២៩៦
២២៤ បានបាបមិនឆ្អាបមាត់.........................................................២៩៧
២២៥ ប្រពន្ធល្អ ច្រើនចាញ់ប្ដី ........................................................ ២៩៨
២២៦ បាយបិណ្ឌជាបាយបាត្រ......................................................២៩៩
២២៧ បួងនៅនឹងមាត់ បន្ទាត់នៅនឹងភ្នែក.........................................៣០០
២២៨ បានពីក្អែកចែកតាវៅ......................................................... ៣០១
២២៩ ប្រហែសបាត់ ប្រយ័ត្នគង់.................................................... ៣០២

២៣០ បានស្វាយណាយក្រូច ......................................................... ៣០៣
២៣១ ប្រាក់ក៏បង់ ថង់ក៏ដាច ......................................................... ៣០៤
២៣២ បាចអង្កាមច្រាសខ្យល់ ......................................................... ៣០៥
២៣៣ បានតែពាក្យ ត្រគាកស្លាប់ឈឹង ......................................................... ៣០៦
២៣៤ ប្រាជ្ញមិនស្មើប្រប បាក់ស្លឹកត្រចៀកខ្លបមិនស្មើអាឡេមឡឹម...... ៣០៧
២៣៥ បន្លាមុត យកបន្លាជោះ ......................................................... ៣០៩
២៣៦ បញ្ញើ ស្មើបំនុល ......................................................... ៣១១
២៣៧ បុណ្យក៏ធ្វើ ឈើក៏កាប់ ......................................................... ៣១២
២៣៨ បានមាស ខ្វះក្រដាសខ្ចប់ ......................................................... ៣១៣
២៣៩ បណ្ដាក់គ្នាដូចខ្សែង ......................................................... ៣១៤
២៤០ ប្រដៅខ្លួនឯងឱ្យបានបទសឹមប្រដៅអ្នកដទៃ ......................................................... ៣១៦
២៤១ ប្រដៅក្មេងមិនបាច់រកឱកាសប្រដៅចាស់ត្រូវរកពេលវេលា....... ៣១៧
២៤២ បើគេបបួលកុំឱ្យខាន បើគេបានកុំឱ្យសុំ ......................................................... ៣១៩
២៤៣ ប្រពន្ធរកបានឆាប់ ឆាប់មានសហាយ ប្រាក់រកបានងាយ....... ៣២០
២៤៤ បើចាញ់បានលុយ បើឈ្នះបានដី ......................................................... ៣២២
២៤៥ ប្រុសពេញដី ស្រីពេញនគរ ......................................................... ៣២៤
២៤៦ ប្រពន្ធដើមដូចស្រូវជង្រុក ប្រពន្ធចុងកំប៉ិកកំប៉ុកដូចអង្ករកំប៉ុង... ៣២៥
២៤៧ បញ្ឆោតឱ្យខ្លាចេញពីព្រៃ ......................................................... ៣២៧
២៤៨ ប្រាជ្ញាបុណ្យផងកើតដោយប្រណិប័តន៍ ......................................................... ៣២៩
២៤៩ ប៉ោតទទេលើសូរខ្លាំង ......................................................... ៣៣០

**ផ**

២៥០ ផ្លែឈើជ្រុះមិនឆ្ងាយពីគល់ ......................................................... ៣៣២
២៥១ ផ្គរលាន់មិនដែលភ្លៀង ......................................................... ៣៣៤
២៥២ ផ្ទះក្បឿងផ្ទះស្បូវ រលត់ភ្លើងទៅងងឹតដូចគ្នា ......................................................... ៣៣៥

២៥៣ ផ្លែឈើច្រើន ច្រើនចាញ់ស្អីក..........................................៣៣៧
២៥៤ ផ្លូវវៀចកុំបោះបង់ ផ្លូវណាត្រង់កុំដើរហោង..........................៣៣៨
២៥៥ ផ្លូវវែង មាត់វែងជាងផ្លូវ..............................................៣៤០
២៥៦ ផ្ដាច់ពីមាត់ ពង្រាត់ពី-ក..............................................៣៤១

ព

២៥៧ ពេលឈឺយកដីរបន់ ជម្ងឺស្រន់ពងមាន់ស្ដាយ............................៣៤២
២៥៨ ពុតសិស្សគ្រូបី ពុតស្រីប្ដីលែង ពុតឆ្កែបង់ម្ចាស់ ......................៣៤៤
២៥៩ ពៅក្នុងថ្នក់ ទំពក់ក្នុងដៃ..............................................៣៤៦
២៦០ ពុតគ្រូកុំគ្រាប់ ច្បាប់គ្រូឱ្យយក..........................................៣៤៧
២៦១ ពងមាន់កុំជល់នឹងថ្ម....................................................៣៤៨
២៦២ ពាក្យពិតវែងស្លែងពុំពិរោះថា បណ្ដិបមេបាវែងថាពុំគាប់...................៣៥០
២៦៣ ពស់ប្រឹងលេប កង្កែបប្រឹងលោត..........................................៣៥១
២៦៤ ពាក្យសង្ឃ ពាក្យសត្យ....................................................៣៥២
២៦៥ ព្រួញមួយបាញ់បានសត្វពីរ..............................................៣៥៣
២៦៦ ពុះទ្រូងរូងយកថ្លើម......................................................៣៥៤
២៦៧ ពាក្យពិត ជាពាក្យមិនស្លាប់..............................................៣៥៦
២៦៨ ពិបាកដូចសុំភ្លើងយក្ស..................................................៣៥៧
២៦៩ ព្រហ្មវិហារធម៌ចំពោះកូន................................................៣៥៨
២៧០ ពស់វែកដីបូកមួយស្រែ ពស់វែកស្រងែមួយព្យាម............................៣៦០
២៧១ ព្យៀររំងាប់ដោយការមិនចងព្យៀរ..........................................៣៦២

ភ

២៧២ ភូតនៅហោរ ចោរនៅជាង..................................................៣៦៣
២៧៣ ភូតច្រើន ច្រើនចាញ់អាត្មា..............................................៣៦៥
២៧៤ ភ្លើងឆេះពីសំរាម........................................................៣៦៦

ម

២៧៥ មានផ្ទះអត់មនុស្សនៅ មានផ្លូវអត់មនុស្សដើរ ........................ ៣៦៨
២៧៦ មនុស្សល្ងង់កុំប្រើឱ្យនិយាយការ មនុស្សមានប្រាជ្ញាកុំប្រើឱ្យរែកពុន.... ៣៧០
២៧៧ ម្នាំ១យកដំរព្នៅត្បៀតក្បៀក.................................................. ៣៧២
២៧៨ មីះ១កេះឆ្នាំងធ្លុះ ................................................................ ៣៧៣
២៧៩ មនុស្សគេយកសំដី ដំរីគេយកភ្លុក............................................ ៣៧៤
២៨០ មាន់ពងលើស្រូវ តែងស៊ីស្រូវ .................................................. ៣៧៥
២៨១ មនុស្សឈ្លោះគ្នាមិនគិត ទៅគិតឯស្គរកំបែកមាត់..................... ៣៧៧
២៨២ មុជមិនជ្រៅ ទៅមិនឆ្ងាយ ........................................................ ៣៧៨
២៨៣ មិនជឿពាក្យចាស់ ស្រលះដៃធេង.............................................. ៣៧៩
២៨៤ មាត់ចាប មាត់ព្រាប................................................................ ៣៨០
២៨៥ មេម៉ាយកូនមួយដូចត្រួយលំពស់............................................ ៣៨១
២៨៦ មុននឹងជួយគេ ត្រូវជួយខ្លួនឯងសិន........................................ ៣៨២
២៨៧ មានប្រលាយទើបទឹកវាហូរ មានសំរាមទើបឆ្កែវាជុះ ............... ៣៨៣
២៨៨ មាន់ព្រៃកំចាយមាន់ស្រុក...................................................... ៣៨៥
២៨៩ មានប្រាក់ទិញយក្សប្រើ.......................................................... ៣៨៦
២៩០ មានដំបៅរុយរោម.................................................................. ៣៨៨
២៩១ មានភ្លើង ទើបមានផ្សែង........................................................ ៣៩០
២៩២ មេម៉ាយ ចំនាយពាក្យ ............................................................. ៣៩១
២៩៣ ម៉ែឪថែកូនដូចចង្វាប្រដេញ កូនថែម៉ែវិញដូចព្រះប្រែក្រោយ...... ៣៩២
២៩៤ មាសទឹកដប់មិនខ្លាចភ្លើង...................................................... ៣៩៤
២៩៥ មិនទាន់ឃើញក្ការមឈូស មិនទាន់ស្រក់ទឹកភ្នែក..................... ៣៩៥
២៩៦ ម៉្វៃកាត់ ម៉្វៃកោរ ................................................................... ៣៩៧
២៩៧ មាន់ណាខ្គត មាន់នោះពង....................................................... ៣៩៨

២៩៨ មេម៉ាយចាយរាង............................................................ ៣៩៩
២៩៩ មានអ្វី មិនស្មើមានចិត្ត................................................................៤០០
៣០០ មុខឆ្អែ ស្រែជំរៅ................................................................ ៤០២
៣០១ មេមិនដែលនៅក្រោមពង................................................................៤០៣
៣០២ មាត់ជាផ្លូវ................................................................៤០៤
៣០៣ មានកូនក្រមុំបីនាក់ ដូចមានប្រហុកបីពាង................................................................៤០៥
៣០៤ ម្នាក់ឯងជិះទូកពីរ................................................................៤០៦
៣០៥ មួយចានទឹក មួយចានគោក................................................................ ៤០៧
៣០៦ មកអត់គេហៅ ទៅអត់គេរក................................................................ ៤០៩
៣០៧ មានសត្រូវជាបណ្ឌិត ប្រសើរជាងមានមិត្រល្ងង់ខ្លៅ.................. ៤១០

យ

៣០៨ យុត្តិធម៌ ជាគ្រឹះនៃសាមគ្គីធម៌................................................................៤១២
៣០៩ យល់ញាតិ ឃ្លាតច្បាប់................................................................ ៤១៣
៣១០ យក.កទៅ.លអន្ទាក់................................................................ ៤១៤
៣១១ យកមេឃទ្រាប់ក្ដិតអង្គុយ................................................................ ៤១៥
៣១២ យីអ៊ុនដាក់ អារក្សជាន់................................................................ ៤១៦
៣១៣ យកអន្ទង់ទៅចំហុងនឹងភក់................................................................៤១៧
៣១៤ យល់សប្តិក្លាយជាការណ៍ពិត................................................................ ៤១៨
៣១៥ យកប្រពន្ធស្រុកឆ្ងាយស៊ីបាយដែលឆ្នា................................................................ ៤១៩
៣១៦ យកបន្លាស្រោសមុខផ្ទះ................................................................ ៤២០
៣១៧ យុវជនរស់ក្នុងក្ដីសង្ឃឹម ចាស់រស់ក្នុងក្ដីស្រមៃ................................................................៤២១
៣១៨ យុត្តិធម៌នៅឯណា ? ................................................................ ៤២៣

រ

៣១៩ រោគអ្វីមិនស្មើនឹងរោគឃ្លាន................................................................ ៤២៥

៣២០ រពីសដៃ ផ្ទៃឆ្អែត..........៤២៧
៣២១ រកអុសប្រទះឈើងាប់..........៤២៨
៣២២ រស់នៅក៏គាប់ ស្លាប់ទៅក៏គួរ..........៤៣០
៣២៣ រនាបបាក់ហាក់បានជួស សំដីហួសជ្រុះអស់មាសប្រាក់..........៤៣១
៣២៤ រទេះបាក់កន្លែងណា ខ្ទេចស្នៅកន្លែងនោះ..........៤៣២
៣២៥ រងថ្មបាក់..........៤៣៤
៣២៦ រូងមួយ គ្មានខ្លាឈ្មោលពីរទេ..........៤៣៥
៣២៧ រលកក្រោយរុញច្រានរលកមុខ..........៤៣៧

**ល**

៣២៨ លួចគេធ្លាប់ដៃ ដេកថ្ងៃធ្លាប់ភ្នែក..........៤៣៨
៣២៩ លួចគេបានវាគ្រាន់ បើគេទាន់វាក្រែល..........៤៤០
៣៣០ លើកស្នា បង្ការភ្នែក..........៤៤១
៣៣១ លីផ្គរ កុំអាលចាក់ទឹកចោល..........៤៤៣
៣៣២ លើកកញ្ជើដើរ..........៤៤៥
៣៣៣ លេងក្មេងអាប់យស លេងពស់ខាំដៃ..........៤៤៦
៣៣៤ លិចកញ្ចង់ លង់កញ្ជើ..........៤៤៧
៣៣៥ លូកប្រហុក លូកឱ្យកប់ក្លៀក..........៤៤៨
៣៣៦ លួចស្រលាញ់លួចកើតទុក្ខ..........៤៥០
៣៣៧ លើកក្ដោង ទាន់មានខ្យល់..........៤៥២
៣៣៨ លោកថាឆ្កួតបី..........៤៥៣
៣៣៩ លក្ខណៈមនុស្ស៤ពួក កម្លោះឱ្យមើលជ្រុង ក្រមុំឱ្យ..........៤៥៦

**វ**

៣៤០ វាយឆ្កែឱ្យមើលម្ចាស់..........៤៦០
៣៤១ វត្ថុមួយសង្គ្រោជពីរ ទីមិនស្អាត..........៤៦២

៣៤២ វះពោះបង្ហាញក្អែក..........................................៤៦៣
៣៤៣ វែងលែងដឹង ខ្លីក្រញ៉ែងលីដឹងចូលព្រៃ..........................................៤៦៥
៣៤៤ វាស់ជំរៅទឹកសមុទ្របាន វាស់ទឹកចិត្តមនុស្សមិនបាន..........................................៤៦៧
៣៤៥ វាយក្បាល បកចេកបញ្ចុក..........................................៤៦៩
៣៤៦ វរវីក ទទឹកស្ងួត..........................................៤៧០
៣៤៧ វិទ្យាសាស្ត្រ ជាអាវុធមុខពីរ..........................................៤៧២

**ស**

៣៤៨ សាបមួយដៃ ប្រៃមួយចឹប..........................................៤៧៣
៣៤៩ ស្លឱ្យសាប អង្គុយឱ្យទាប ប្រាជ្ញាឱ្យវៃ..........................................៤៧៥
៣៥០ សាច់មិនបានស៊ី យកឆ្អឹងព្យួរ-ក..........................................៤៧៧
៣៥១ សុខចិត្តហូបសៀង គ្រាន់បើជាងយល់សប្តិហូបសាច់គោ..........................................៤៧៨
៣៥២ ស៊ីព្រោះលោះកំលាំង..........................................៤៨០
៣៥៣ សង្សារបានខ្លួនមិនសូវអានិត សង្សារបានចិត្ត..........................................៤៨១
៣៥៤ ស្នេហ៍មិនស្មើស្និទ្ធ..........................................៤៨២
៣៥៥ សន្សឹមកុំបំបោល ក្រែងពុំដល់ដូចប្រាថ្នា..........................................៤៨៣
៣៥៦ ស្រលាញ់កុំទៅញឹក រលឹកសឹមទៅម្តង..........................................៤៨៥
៣៥៧ សំដីជាឯក លេខជាទោ..........................................៤៨៦
៣៥៨ សំនាបយោងដី ស្រីយោងប្រុស..........................................៤៨៨
៣៥៩ សត្វបរោក្ខា ទុំមែកពោធិ ស៊ីផ្លែជ្រៃ..........................................៤៩០
៣៦០ សូវអោយសាច់ កុំបង្ហាញព្រៃ..........................................៤៩២
៣៦១ ស្រីខ្មៅដូចក្អិតអម្បែង ចេះតុបចេះតែងប្តីលែងមិនរួច..........................................៤៩៣
៣៦២ សូវយកស្រីខូចធ្វើប្រពន្ធ កុំយកប្រពន្ធធ្វើស្រីខូច..........................................៤៩៤
៣៦៣ សម្បត្តិកំចាត់ព្រួយ មានគេជួយមិនបាច់ហៅរក..........................................៤៩៥
៣៦៤ សម្បត្តិច្រើន ចំរើនបុណ្យ ប្រពន្ធល្អសម្បូរមិត្រ..........................................៤៩៦

៣៦៥ ស្អាតតែរូប ម្ហូបមិនឆ្ងាញ់ ..................................... ៤៩៧
៣៦៦ ស៊ូស្លាប់ក្នុងកិត្តិយស កុំឱ្យដុះពោះក្នុងការបំផ្លាញជាតិ .................. ៤៩៨
៣៦៧ ស្រុកសង្គ្រាមត្រូវការអ្នកក្លាហាន ស្រុកសាន្តត្រាណត្រូវការអ្នកចេះដឹង..... ៤៩៩
៣៦៨ ស្រី១បង្វិលចង្ក្រានមិនជុំ..................................... ៥០១
៣៦៩ ស្លូតស្លាប់ វៀចវេរមានភព្វអាយុយឺនយូរ............................ ៥០២
៣៧០ សម្តីសរជាតិ មារយាទសរត្រកូល.................................. ៥០៤
៣៧១ ស្រលាញ់មេ បំពេកូន ............................................ ៥០៥
៣៧២ ស្រលាញ់ខ្លួនឱ្យស្ងួនចំនី ស្រលាញ់ស្រីឱ្យស្ងួនចិត្ត ........................ ៥០៧
៣៧៣ សូវស្តួច កុំឱ្យដាច់.............................................. ៥០៨
៣៧៤ សេះដាច់យកសេះតាម ............................................ ៥០៩
៣៧៥ ស្រមោចនៅជិតស្ករ............................................... ៥១១
៣៧៦ ស្អប់អាចម៍ជិះដំរី ស្អប់ក្តីឡើងចុងត្នោត............................. ៥១២
៣៧៧ សូវចង្អៀតផ្ទះ កុំឱ្យចង្អៀតចិត្ត.................................... ៥១៤
៣៧៨ ស៊ីពងរងសំបុក................................................... ៥១៦
៣៧៩ ស្លៀកស្បង់មិនកោរសក់ ឆ្លុះកញ្ចក់ធ្មេចនេត្រា............................ ៥១៧
៣៨០ សីលជាស្ពាន ទានជាស្បៀង........................................ ៥១៩
៣៨១ ស្រលាញ់កូនមួយតៅ ស្រលាញ់ចៅមួយថាំង........................... ៥២០
៣៨២ ស្វា១ អម្រែក២.................................................. ៥២២
៣៨៣ សាមគ្គីជាកម្លាំង................................................. ៥២៣
៣៨៤ ស្ពោះទឹកមាត់លើទ្រូងឯង.......................................... ៥២៤
៣៨៥ សំលមិនឆ្ងាញ់ ឱ្យតែនៅក្តៅ ប្រពន្ធខ្មៅ ឱ្យតែនៅក្មេង ............. ៥២៥
៣៨៦ ស្អប់កុំឱ្យបាញ់ ស្រលាញ់កុំឱ្យខ្ចី....................................... ៥២៧
៣៨៧ ស៊ីលៀសរអៀសខ្លួន.............................................. ៥២៩
៣៨៨ ស្រលាញ់ពេញប្រាស ស្អប់ជិតពប់លើ.................................. ៥៣០

៣៨៩ សំនាងពីអតីត គំនិតបច្ចុប្បន្ន.................................................. ៥៣១
៣៩០ សងសឹកជាការកំឡៅ.................................................. ៥៣២
៣៩១ ស៊ីបាយបោកឆ្នាំង.................................................. ៥៣៣
៣៩២ សំពត់រហែក កុំហែកថែម.................................................. ៥៣៤
៣៩៣ សូវស្លាប់បា កុំឱ្យស្លាប់មេ.................................................. ៥៣៦
៣៩៤ ស្លាប់មិនដូរឈ្មោះ រស់មិនដូរត្រកូល.................................................. ៥៣៧
៣៩៥ សូវលិចទូកកណ្ដាលទន្លេ កុំឱ្យតែភ្លើងឆេះផ្ទះ.................................................. ៥៣៨
៣៩៦ សេចក្ដីព្យាយាមគង់បានសម្រេចដូចប្រាថ្នា.................................................. ៥៣៩
៣៩៧ សូវស្រក់ឈាម មិនឱ្យស្រក់ទឹកភ្នែក.................................................. ៥៤០
៣៩៨ សុ-ចិ-បុ-លិ.................................................. ៥៤១
៣៩៩ សេចក្ដីស្រលាញ់ស្មើខ្លួនមិនមាន.................................................. ៥៤៣
៤០០ ស្ទាងតឹង ស្រវឹងធូរ.................................................. ៥៤៤
៤០១ ស៊ីត្រង់ណា ជុះត្រង់នោះ.................................................. ៥៤៥
៤០២ ស្វាស៊ីបាយ លាបមាត់ពពែ.................................................. ៥៤៦
៤០៣ ស្លាប់ក្រោមកន្ទុយក្បិន.................................................. ៥៤៨
៤០៤ ស្រីមាយា១០០ជំពូក.................................................. ៥៤៩
៤០៥ ស្រីមាយាដកខ្ញី.................................................. ៥៥១
៤០៦ ស្រូវក្នុងជង្រុក ប្រហុកក្នុងពាង.................................................. ៥៥៣
៤០៧ ស្លាប់ទៅបិទភ្នែកមិនជិត.................................................. ៥៥៤
៤០៨ ស្រីក្លោកមាស.................................................. ៥៥៦
៤០៩ ស្លាប់ទាំងរស់ ស្អុយទាំងស្រស់.................................................. ៥៥៧

**ហ**

៤១០ ហាលេបស្លាក់ ហាខ្ជាក់ស្លែង.................................................. ៥៥៩
៤១១ ហុតទឹកសម្លឹងកាក ទាញច្រវាំខ្វាកសម្លឹងត្រើយ.................................................. ៥៦១

៤១២ ហីនយសព្រោះព្រហើន ..................................... ៥៦៣
៤១៣ ហុចអំបោះស្រនោះដៃ ..................................... ៥៦៤

ឡ

៤១៤ ឡើងខ្ពស់កប់ពពក ធ្លាក់មកជ្រកអាចម៍ជន្លេន ..................................... ៥៦៦

អ

៤១៥ អយតោ មលំ ខាទតិ ..................................... ៥៦៨
៤១៦ អួសទូកកុំឱ្យល្ហាន ចាប់ត្រីបានកុំឱ្យល្អក់ទឹក ..................................... ៥៧១
៤១៧ អឹមអៀម ស្មៀមជាងស្រដី ស៊ីចេកខ្ចីជាងមាត់ទទេ ..................................... ៥៧៣
៤១៨ អណ្តើកនៅជើង ចាំបាច់ក្តក់ឆ្អែ ..................................... ៥៧៥
៤១៩ អ្នកឡើងមិនបានបេះ អ្នកប្រលេះមិនបានស៊ី អ្នកនៅទំនេរស៊ីឆ្អែត .. ៥៧៧
៤២០ អ្នកប្រាជ្ញជាន់ចាស់ស្មៅដុះលើដី អ្នកប្រាជ្ញជាន់ថ្មីដីដុះលើស្មៅ ...... ៥៧៩
៤២១ អណ្តាតជាអាទីកន្លង បានសុខទុក្ខផងព្រោះអណ្តាត ..................................... ៥៨១
៤២២ អាវែក គេស៊ីក្រោមភ្នែក អាវែកមិនដឹង ..................................... ៥៨២
៤២៣ អួសសំរាស់ ប្រទះពាក្យ ..................................... ៥៨៣
៤២៤ អាវៀចធ្វើកង់ អាត្រង់ធ្វើកាំ ..................................... ៥៨៤
៤២៥ អង្គុយលើចង្អេរលើកខ្លួនឯង ..................................... ៥៨៥
៤២៦ អ្នកហ៊ានស្បែកដាច អ្នកខ្លាចស្បែកស្វិត ..................................... ៥៨៦
៤២៧ អន្ទង់វែង កុំរកឆ្នាំវែង ..................................... ៥៨៧
៤២៨ អាគមផ្សំអាយុ ..................................... ៥៨៩
៤២៩ អ្នកក្រត្រដររស់ក្បែរអ្នកមាន ..................................... ៥៩១
៤៣០ អាយុមិនអស់ មិនស្លាប់ ..................................... ៥៩២
៤៣១ អ្នកដទៃ បើស្និទ្ធទុកជាញាតិ ញាតិបើឃ្លាត ទុកជាជាតិអ្នកដទៃ... ៥៩៤
៤៣២ អង្ករក្លាយជាបាយ ..................................... ៥៩៦
៤៣៣ អ្នកក្រមិនហ៊ាន អ្នកមានមិនចូល ..................................... ៥៩៧

៤៣៤ អូសឬស្សីបញ្ច្រាសចុង ........................................ ៥៩៩
៤៣៥ អ្នកមានសក្តិ មិនស្មើអ្នកមានយស ........................................ ៦០០
៤៣៦ អ្នកមានរក្សាខ្សត់ ដូចសំពត់ព័ទ្ធពីក្រៅ អ្នកប្រាជ្ញរក្សាខ្លៅ .......... ៦០១
៤៣៧ អាមិនដឹងខ្យល់ ........................................ ៦០៣
៤៣៨ អំបិលកំពុងស្អុយ ........................................ ៦០៥
៤៣៩ អសារក្តីបី បណ្តាំមេ-ជី ព្រេងព្រឹទ្ធប្រដៅ អង្ករ-សសុទ្ធ ............ ៦០៧
៤៤០ អន្ទិតគោលោត ........................................ ៦១០
៤៤១ អក្តោធេន ជិនេ កោធំ ........................................ ៦១២
៤៤២ អំពិលអំពែកទំមែកពុទ្រា ព្រើត១គ្រប់គ្នា ថាឯងភ្លឺ .................. ៦១៣
៤៤៣ អ្នកមានរក្សាខ្សត់ ដូចសំពត់ព័ទ្ធពីក្រៅ អ្នកប្រាជ្ញរក្សាខ្លៅ .......... ៦១៨
៤៤៤ អោយត្រាប់កុកសាប់ កុំត្រាប់កុក-ស ........................................ ៦២០


## ទំព័របន្ថែម


កាន់តែខឹង កាន់តែញញឹម សំដីទន់ភ្លន់ បាតដៃត្រជាក់ តែបេះដូងក្តៅ..... ៦២៣
ផ្ទាញ់មនុស្សបីពួក ........................................ ៦២៥
កុំងឿងដោយខ្យល់ កុំឱនពាក្យពល ........................................ ៦២៨
ឈាម រត់រកឈាម ........................................ ៦៣១

# ២១០. នៅតូចមួយខាកមួយស្ពោះ ធំឡើងដុះដោះ មួយអើត ពីរអើត

**និយមន័យ**

សោភណភាពរបស់នារីពេញវ័យ

**អត្ថាធិប្បាយ**

ពាក្យទំនឹមទំនៀមខាងលើនេះ លោកចង់ពោលដោយចំពោះតែទៅលើក្មេងស្រីៗកាលពីសម័យដើម ។ ជាពិសេសទៅលើក្មេងស្រីក្នុងគ្រួសារក្រីក្រ ។ ព្រោះក្នុងគ្រួសារក្រីក្រ ឪពុកម្ដាយច្រើនបណ្ដោយឱ្យកូនតូចៗទោះជាស្រីក៏ដោយ ឱ្យលែងនៅដងខ្លួនទទេទទនលគក គ្មានគិតពីអនាម័យប៉ុន្មានទេ ។ ជួនគេឃើញក្មេងស្រីទាំងនោះមានពោះកំប៉ោង សំបោរហៀរកក្លាក់ យូរៗវាយកខ្នងដៃជូតសំបោរ រួចយកមកជូតត្រង់កំប៉េះគូទខ្លួនវា ។ ឯភ្នែកពព្រៀកមានសត្វមមង់ ឬរុយតាមរោមវា មើលទៅឃើញគួរឱ្យខ្ពើម ។ ប៉ុន្តែ ១៥ឆ្នាំក្រោយមក អ្វីៗក៏ត្រូវប្រែប្រួលដូរផ្លាស់ទៅតាមពេលវេលាអស់ហើយ គឺដើមទ្រូងដុះដោះមួយគូ រាងរៅសមសួន ដំណើរល្វតល្វន់គយគន់យូរៗទៅ ឃើញសមឡើង សមឡើង ។ ចំពោះអ្នកដែលខានឃើញនាងជាង១០ឆ្នាំមកហើយនោះ ពេលនេះច្បាស់ជាប្លែកភ្នែកលាន់មាត់ថា : *កណ្ដុំឆែប កង្កែបអាំងភ្នែក អញស្រវាំងទេដឹង?*

ដូច្នេះ យុវជនម្នាក់ៗចេះតែចង់ទៅអើតងើតមិនដាច់ពេល ។ ប្រសិនបើនាងនោះលក់ទឹកត្នោតជូរ មានសាច់ក្លែមផងនោះ ។ គេឃើញពួកយុវជនទៅអង្គុយផឹកស៊ីយ៉ាងត្រប៉ែអែអុកមិនចេះដាច់ ទោះបីទឹកត្នោតនោះផឹកទៅភាគរូសបន្តិចក៏ដោយ ។

ហ្នឹងហើយដែលចាស់លោកថា *នៅតូចកុំអាលស្អប់ខ្ចើមនាងឱ្យសោះ ប្រយ័ត្នតែទ្រូងគេដុះដោះ កំលោះ កំលោះៗនាំគ្នាឆ្កួត ៕*

*ថ្ងៃទី ២៧-០៤-០៩*

✿✿✿✿




បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

# ២១១. នំមិនធំជាងនាឡិ

**និយមន័យ**

កូនចៅត្រូវស្ថិតក្នុងអំណាចមេបា

❖ **អត្ថានុរូប**

**នាឡិ :** គឺជារង្វាស់ ឬពុម្ពសំរាប់ធ្វើនំ ឬចាក់នំ គឺលោកសំដៅយកពែង កែវ ឬកន្ទោង សំរាប់ចាក់នំអាកោរ ចាហួយ ។ល ។

ក្នុងន័យនេះ លោកមិននិយាយយោងទៅដល់នំដែលដាក់ "មេ"ពេលត្រូវក្តៅ វាឡើងធំជាងពែងនោះទេ ។

ហេតុនេះហើយ បានជាលោកពោលថា : នំទាំងអស់មិនធំជាងរង្វាល់របស់វាទេ ។

❖ **អត្ថប្បដិរូប**

ន័យរបស់សុភាសិតនេះ លោកពោលដោយចំពោះតែទៅលើការទុកដាក់កូនចៅឱ្យមានគ្រួសារប៉ុណ្ណោះ ។

ទំនៀមទម្លាប់ជាប្រពៃណីខ្មែរ តាំងពីបុរាណកាលមក ការទុកដាក់កូនចៅឱ្យមានគ្រួសារ ។ មាតាបិតា ឬអាណាព្យាបាលតែងមានសិទ្ធិសំរេចលើគាត់ទាំងស្រុង ។ ទោះបីកូនចៅមិនពេញចិត្តនឹងគូគ្រងរបស់ខ្លួនក៏ដោយក៏មិនហ៊ានប្រកែកដែរ ។ ដូច្នេះ កូនចៅ ត្រូវតែគោរពតាមសេចក្តីសម្រេចរបស់មេបាចាស់ទុំទាំងអស់ ។

បើមានកូនចៅណាម្នាក់ ហ៊ានប្រកែកនឹងបំនងរបស់គាត់ៗតែងពោលថា : *នំមិនធំជាងនាឡិទេវើយ* ៕

*ថ្ងៃទី ១៥-១០-០៦*

❁❁❁❁

# ២១២. នៅផ្ទះម្ដាយទីទៃ នៅព្រៃម្ដាយជាមួយ

**និយមន័យ**

ត្រូវចេះស្រលាញ់គ្នា នៅពេលឃ្លាតឆ្ងាយពីផ្ទះ

## អត្ថាធិប្បាយ

ការរស់នៅក្នុងគ្រួសារនិមួយៗ តែងមានឪពុកម្ដាយទីទៃរៀងៗខ្លួន ។

ប៉ុន្តែនៅពេលដែលគេត្រូវឃ្លាតឆ្ងាយពីផ្ទះ ឬពីគ្រួសារទៅជួបគ្នានៅកន្លែងណាមួយ ដូចជាទៅរស់នៅក្នុងវត្តដើម្បីរៀនសូត្រ ឬទៅនៅស្រុកគេដើម្បីទៅរកស៊ី លោកទុកដូចជាទៅនៅព្រៃ ។

ក្នុងករណីបែបនេះ លោកអប់រំថា ត្រូវចេះស្រលាញ់គ្នារាប់អានគ្នា ហាក់ដូចសាច់ឈាមបងប្អូនបង្កើតដែលមានឪពុកម្ដាយរួមគ្នា ។

ព្រោះគំលាតឆ្ងាយពីគ្រួសារបែបនេះ បើមានអាសន្នអន់ក្រដូចម្ដេចម្ដាគ្មានឪពុកម្ដាយ ឬបងប្អូនឯណាដឹងទេ មានតែគ្នាឯងដែលនៅជិតខាងហ្នឹងឯងហើយដែលជួយទុក្ខធុរៈគ្នា ឬជួយយកអាសារគ្នាបានភ្លាមៗ ៕

*ថ្ងៃទី ១៦-១០-០៦*

❀❀❀❀

# ២១៣. នៅផ្ទះឱ្យស្រាស់បន្លា អារសាច់ជូនខ្លាទើបនៅស្រុកបាន

**និយមន័យ**

កិច្ចការពារខ្លួន និង មធ្យោបាយរកសុវត្ថិភាព

**អត្ថាធិប្បាយ**

- **នៅផ្ទះឱ្យស្រាស់បន្លា :**

បន្លានៅពេលនេះ លោកប្រៀបទៅនឹងសម្ព័ន្ធមេត្រីភាពរវាងញាតិមិត្តជិតខាងភូមិផងរបងជាមួយ ។

ការតាំងទីលំនៅត្រង់កន្លែងណាមួយ លោកឱ្យចងមេត្រីទំនាក់ទំនងនឹងញាតិមិត្រជិតខាងផងគ្នាឱ្យបានជិតស្និទ្ធ ។ ព្រោះថាអ្នកនៅជុំវិញផ្ទះហ្នឹងហើយដែលលោកចាត់ទុកដូចជាបន្លាសំរាប់ធ្វើរបងការពារសុវត្ថិភាពផ្ទះសំបែង ។

ផ្ទុយមកវិញ បើផ្ទះនោះហ៊ុំព័ទ្ធដោយសំអប់ ផ្ទះនោះទុកដូចជាគ្មានរបងការពារម្ល៉ោះហើយរមែងរងនូវការមើលងាយពីបច្ចាមិត្រ និងជាពិសេសពីពួកចោរឃ្មួញគ្រប់ ទិស ។

ប្រសិនបើអ្នកនៅជុំវិញ សុទ្ធសឹងតែជាមិត្រដ៏ល្អឈ្មោះថា គេមានរបងយ៉ាងមាំសំរាប់ការពារហើយ ។

- **អារសាច់ជូនខ្លាទើបនៅស្រុកបាន :**

ខ្លានេះនៅពេលនេះ លោកប្រៀបប្រដូចទៅនឹង អ្នកមានអំនាច ឬ អ្នកគ្រប់គ្រងណាម្នាក់ ។

ប្រសិនបើគេទៅនៅក្នុងស្រុក-ភូមិណាមួយហើយ គេមិនបានត្រូវដងត្រូវផ្លែជាមួយអ្នកមានអំនាច រឺអ្នកគ្រប់គ្រងនោះទេ ។ គឺគេប្រាកដជាពុំអាចរស់នៅបានសុខសាន្តឡើយ ជាពិសេស គឺអ្នករកស៊ីតែម្តង ។ ដូច្នេះ គេត្រូវអារសាច់ជូនខ្លា គឺត្រូវនាំផលប្រយោជន៍ រឺនាំស្បួយសារអាករជាជំនូនចូលទៅលោកអ្នកធំនោះ ។ សមដូចពាក្យគេថា *អារសាច់ជូនខ្លាទើបរកស៊ីស្រុកផ្សារបាន* ៕

*ថ្ងៃទី ១៦-១០-០៦*

✿✿✿✿



# ២១៤. នឹងលើ រង្គើក្រោម

## និយមន័យ

គំនិតលាក់ពុត របស់ជនខិលខូច

## អត្ថាធិប្បាយ

មនុស្សដែលមានពុតត្បុតខិលខូច តែងលាក់គំនិតអាក្រក់របស់ខ្លួន និងប្រើគ្រប់ឥរិយាបថរបស់ខ្លួន ។

ក្នុងន័យខាងលើនេះ ជនលាក់ពុតធ្វើឫកនឹងធឹងសុភាពរាបសា ទន់ភ្លន់ ត្រឹមត្រូវ ដើម្បីក្លែងបន្លំភ្នែកសាធារណៈជនឱ្យជឿឱ្យទុកចិត្តលើគេថា ជាមនុស្សប្រកបដោយគុណធម៌ខ្ពស់ ។

គេសង្កេត ឃើញអ្នកខ្លះស្លៀកស-ពាក់ស ខ្លះ ក៏ធ្វើឫករាបរមទម្យស្រគត់ស្រគំបន្លំភ្នែកបរិស័ទឱ្យគេ យល់ច្រឡំថាខ្លួនជាអ្នកប្រព្រឹត្តនូវព្រហ្មចរិយធម៌ ។ ប៉ុន្តែការណ៍ពិត គេជាមនុស្សពោរពេញទៅដោយការបោកប្រាស់ ទាក់ទាញយកផលប្រយោជន៍ ពីអ្នកណាដែលពុំបានត្រិះរិះពិចារណាឱ្យគ្រប់ជ្រុងជ្រោយ ។

ដូច្នេះហើយបានជាលោកថា ការវាយតំលៃមនុស្សត្រឹមតែសំបកក្រៅពិតជាពុំត្រឹមត្រូវឡើយ ៕

*ថ្ងៃទី ១៦-១០-០៦*

# ២១៥. និយាយយប់បន្ទប់ព្រៃ និយាយថ្ងៃជញ្ជាំងមានត្រចៀក

**និយមន័យ**

ត្រូវប្រយ័ត្នមាត់ក្នុងការនិយាយរឿងសម្ងាត់

**អត្ថាធិប្បាយ**

លោកពោលថា និយាយយប់បន្ទប់ព្រៃ គឺក្នុងន័យឱ្យប្រុងប្រយ័ត្នការនិយាយស្ដីកិច្ចការអាថ៌កំបាំងនៅក្នុងពេលយប់ ។ ព្រោះពេលយប់ងងឹត គេមិនអាចដឹងថាមានមនុស្សនៅឆ្ងាយ ឬជិតចាំលបស្ដាប់ការណ៍សំងាត់ដែលគេនិយាយនោះទេ ។

ហេតុនេះហើយបានជាលោកពោលថា បើនិយាយការណ៍សំងាត់ក្នុងពេលយប់ គឺដូចជាយកព្រៃធ្វើជាបន្ទប់ ។ ដូច្នេះគេមិនអាចបិទបាំងការណ៍សំងាត់នោះបានឡើយ ។

ផ្ទុយទៅវិញ បើគេនិយាយការណ៍សំងាត់នៅពេលថ្ងៃវិញ ក៏លោកឱ្យប្រយ័ត្នដែរ ។ ព្រោះគេមិនអាចដឹងបានថា នៅឯម្ខាងជញ្ជាំងអត់មនុស្ស ឬមានមនុស្សចាំលបស្ដាប់កិច្ចការអាថិកំបាំង ឬមានគេឮនូវរឿងដែលយើងនិយាយ ។

ដូច្នេះ ទោះគេនិយាយពេលយប់ក្ដី ពេលថ្ងៃក្ដី លោកឱ្យរវាំងប្រុងប្រយ័ត្នទាំងអស់ ៕

*ថ្ងៃទី ១៦-១០-០៦*

# ២១៦. នាងវត់រកអ្នក
# មេខាតលក្សណ៍វត់រកអាបាក់ទន្សា

**និយមន័យ**

ប្ដី ប្រពន្ធ ដែលមាននិស្ស័យកម្មត្រូវគ្នា

**អត្ថាធិប្បាយ**

ពាក្យទំនឹមទំនៀមបុរាណនេះ លោកចង់ពោលទៅដល់គូប្ដី-ប្រពន្ធណាដែលមានកិរិយាមារយាទសមស្របគ្នា ។ ធម្មតាមនុស្សដែលមានចិត្តគំនិតប្រហាក់ប្រហែលគ្នា និស្ស័យកម្មក៏ប្រហាក់ប្រហែលគ្នាដែរ ។ ដូច្នេះ គេតែងតែវត់រកគ្នារួចចងស្ពានមេត្រីនឹងគ្នាទៅ ។

**▫ នាងវត់រកអ្នក**

ស្ត្រីដែលប្រកបដោយចរិយាមារយាទល្អ រមែងគាប់ចិត្តនឹងបុរសណាដែលមានគុណធម៌ខ្ពស់ និងឧត្តមគតិល្អប្រសើរ គឺជាសភាពបុរសដែលមានកិរិយាមារយាទថ្លៃថ្នូរ ។ ឯសភាពបុរសវិញ ក៏តែងគាប់អធ្យាស្រ័យនឹងសភាពនារីដូចខាងលើនេះដែរ ។ ហេតុនេះហើយបានជាលោកពោលថា *នាងវត់រកអ្នក* ។

**▫ មីខាតលក្សណ៍វត់រកអាបាក់ទន្សា**

ស្ត្រីដែលមានកិរិយាមារយាទមិនល្អ គ្មានសណ្ដាប់ធ្នាប់ ខ្ជះខ្ជាយក្នុងការងារ

រឡេះរឡោះពុំសមរម្យខ្លួន ជាស្រីដែលចាស់ទុំតែងដេរថា ស្រីកញ្ជើធ្លុះ ។ ស្រីដែលមានលក្ខណៈបែបនេះតែងពេញចិត្តនឹងបុរសកញ្ជើធ្លាយ ដែលលោកប្រៀបប្រដូចទៅនឹងកាំបិតបាក់ទន្សា ។ ព្រោះកាំបិតបាក់ទន្សាមិនមានពន្លួញដាក់ដងកើតទេ ។ ធម្មតាកាំបិតដែលគ្មានដង ទោះបីកាប់អ្វីៗក៏ពុំកើតដែរ បើកាប់បានបន្តិចបន្តួចក៏ទាំងត្រដាបត្រដួស ។

អត្ថចរិត បុគ្គលិកលក្ខណៈរបស់មនុស្សដែលមាននិស្ស័យប្រហាក់ប្រហែលគ្នាតែងតែរត់រកគ្នាជានិច្ច ៕

*ថ្ងៃទី ០៣-០១-០៦*

❀❀❀❀

| | |
|---|---|
| នារីមានលក្ខណ៍តែងប្រាថ្នា | នូវបុរសណាល្អពណ្ណរាយ |
| ស្រីកញ្ជើធ្លុះប្រុសកញ្ជើធ្លាយ | តែងវេចសម្លាយរត់រកគ្នា ។ |
| | លី ថៃលី |

# ២១៧. នាងតីស្នាគាង ស៊ីរះសងខាងមិនឱ្យឃ្លើសចិត្ត

**និយមន័យ**

ល្បិចស្រី ដែលយកប្ដីម្ដងពីរ

**អត្ថាធិប្បាយ**

ពាក្យទំនឹមទំនៀមនេះ លោកពោលសំដៅទៅលើស្ត្រីម្នាក់ដែលយកប្ដីម្ដងពីរ ហើយចេះផ្គាប់ផ្គុនប្ដីទាំងពីរនាក់នោះ មិនឱ្យទាស់ទែងខ្វែងគំនិតគ្នាបាន ។

តាមធម្មតាប្រុសម្នាក់យកប្រពន្ធម្ដងពីរ គេកម្រឃើញប្រពន្ធទាំងពីរនោះសុខកាយសប្បាយចិត្តសិទ្ធស្នាលយកគ្នាជាមិត្តបានណាស់ ។ ទោះបីនៅផ្ទះដាច់ដោយឡែកពីគ្នា និងទំនុកបំរុងជាប្រាក់កាស ឬសំភារៈយ៉ាងគ្រប់គ្រាន់ដូចម្ដេចក៏ដោយ ។

ផ្ទុយទៅវិញ បើស្ត្រីម្នាក់យកប្ដីម្ដងពីរ គេតែងឃើញប្ដីទាំងពីរនាក់នោះល្អូកល្អឺនស្រលាញ់គ្នាជាមិត្ត ។ ជួនគេឃើញប្ដីទាំងពីរនាក់នោះរកស៊ីជាមួយគ្នាទៀតផង ។

កត្តាដែលនាំឱ្យប្ដីទាំងពីរស្រលាញ់គ្នាបាន គឺមកពីកាយវិការយ៉ាងប៉ិនប្រសប់និងឆ្លាតវាងវៃរបស់នាងស្រីជាប្រពន្ធ ។ ដូចជាចេះផ្គាប់ចិត្តប្ដីទាំងសងខាងទៅតាមចំនង់ចំនូលចិត្តរបស់ប្ដីនិមួយៗ ។ ព្រោះប្រុសម្នាក់ៗតែងមានចំណុចខ្សោយ បើកាលណាស្ត្រីនោះឯងឆ្លាត ចេះបំពេញត្រង់ចំណុចខ្សោយរបស់បុរសនោះបានហើយ ។

បុរសនោះឯងតែងលុតជង្គង់ចំពោះមុខស្ត្រីនោះជាពិតប្រាកដ ។

ហេតុនេះហើយបានជាបណ្ឌិតពោលថា ល្បិចកលមាយាស្ត្រី គឺជាឱសថទិព្វ រឺជាអាវុធពិសេសដែលសំលាប់បុរសទាំងឡាយឱ្យស្លាប់ដោយស្ងៀមស្ងាត់ និងដោយគ្មានទោសពៃរ៍ទៀតផង ៕

*ថ្ងៃទី ១៣-០៥-០៩*

✿✿✿✿

✳ **នច សោ នច អញ្ញោ**

អ្នកដែលទៅកើតថ្មីទៀត មិនមែនយើងទេ, តែក៏គ្មានអ្នកណាក្រៅពីយើងដែរ ។

✳ ដើមស្វាយថ្មីដែលដុះឡើង មិនមែនដើមស្វាយចាស់ទេ, តែក៏គ្មានដើមស្វាយណា ក្រៅពីដើមស្វាយចាស់ជាបច្ច័យដែរ ។ ព្រោះ បើគ្មានស្វាយចាស់ ស្វាយថ្មីក៏គ្មានដែរ ។

✳ បើ "នេះ" ពុំមាន "នោះ" ក៏ពុំមានដែរ ។

*ព្រះពុទ្ធ*

# ២១៨. ប្រុសដើមទ្រូងប្រាំហត្ថ

**និយមន័យ**

កាតព្វកិច្ច អ្នកដែលបានបួសជាភិក្ខុភាវៈ

## អត្ថាធិប្បាយ

ពាក្យថា ប្រុសដើមទ្រូង៥ហត្ថនេះជាពាក្យទំនឹមទំនៀមខ្មែរមានមកជាយូរហើយ ។ ពាក្យនេះ លោកមិនមែនសំដៅយកមនុស្សប្រុសគ្រប់ទាំងអស់ទេ គឺលោកចុចសំដៅចំពោះតែបុរសណាដែលបានឧបសម្បទាជាភិក្ខុប៉ុណ្ណោះ ។

ព្រោះភិក្ខុសង្ឃតាមពុទ្ធប្បញ្ញត្តិ តំរូវឱ្យមានវត្ថពន្ធទ្រូងសំរាប់ចងក្រវាត់ទ្រូងពីលើសង្ឃាដីកុំឱ្យធ្លាក់រយីករយាក ។

វត្ថពន្ធទ្រូងនេះ តាមពុទ្ធប្បញ្ញត្តិតំរូវឱ្យធ្វើទទឹងប្រហែលបីចំអាមព្រះសុគត និងបណ្តោយប្រវែង ៥ហត្ថ ។

តាមការបកស្រាយរបស់លោកគ្រូធម្មាចារ្យខ្លះ បានឱ្យដឹងថា ៥ហត្ថនេះជាតំនាងឱ្យបុគ្គល៥ពួកគឺ មាតា១, បិតា១, គ្រូ១ ( គ្រូឧបជ្ឈាយ៍ និងគ្រូលេខអក្សរ), ប្រពន្ធ១, កូន១ ។

មូលហេតុដែលនាំឱ្យលោកធ្វើបំណកស្រាយបែបនេះ ព្រោះលោកចាត់ទុកថាអ្នកដែលបានបួសជាភិក្ខុភាវៈមានការចេះច្បាប់គតិលោកគតិធម៌ជ្រៅជ្រះ ។

ដូច្នេះ នៅពេលដែលគេលាចាកសិក្ខាបទមកជាគ្រហស្ថវិញ គេត្រូវដឹងនូវឧបការគុណ មាតា, បិតា, គ្រូ, និងសង្គ្រោះប្រពន្ធ, កូនដែលជាប្រពៃណីដ៏ល្អរបស់ខ្មែរ ។

*ថ្ងៃទី ១៦-១០-០៦*



# ២១៩. ប្រាជ្ញចុះរណ្ដៅ ខ្លៅឡើងស្ថានសួគ៌

**និយមន័យ**

បរិយាកាសពុករលួយ និងបដិវត្តន៍ ធ្វើឱ្យអ្វីៗត្រលប់ធាតុទាំងអស់ ។

**អត្ថាធិប្បាយ**

នៅក្នុងបរិយាកាសពុករលួយដល់ឆ្អឹង គេពុំសូវគិតគូពីគុណសម្បត្តិប៉ុន្មានទេ ។ គឺគេយកសំភារៈ ឬលុយ កាក់ជាធំជាចំបងលើសអ្វីៗទាំងអស់ ។ ដូច្នេះមនុស្សអវិជ្ជាក៏ដោយឱ្យតែមានលុយ គឺអាចទិញសញ្ញាប័ត្រ បុណ្យ សក្តិ ឬមុខតំណែងខ្ពស់បាន ។ រីឯអ្នកចេះដឹង គឺពួកអ្នកប្រាជ្ញបញ្ញវន្តដោយអាងមានចំនេះដឹង និងសមត្ថភាពពេញខ្លួន មិនចាំបាច់សូកប៉ាន់គេនោះ ច្បាស់ជាអង្គុយកេះក្រចកនៅកៀនជញ្ជាំងដែលលោកថា អ្នកប្រាជ្ញចុះរណ្ដៅ ហើយពេលហ្នឹង ។

ម្យ៉ាងទៀតនៅពេលប្រទេសជាតិមានបដិវត្តន៍ម្តងៗអ្វីៗត្រូវប្រែប្រួលត្រលប់ត្រលិនខុសទម្លាប់ទាំងអស់ ។ ដូចជាគេយកមនុស្សចេះដឹង បញ្ញវន្ត បណ្ឌិត វិស្វករ ។ល ។ ទៅសំលាប់ពេញៗរណ្ដៅ ។ រួចហើយពួកវាបន្តុបមនុស្សអវិជ្ជា ចោរបហារយដែលធ្លាប់តែលួចគោ ទៅលក់ឱ្យបរទេសឱ្យឡើងកាន់តំណែងធំខ្ពស់ ។ល។ ព្រោះពួកទមិឡឥតសាសនា នេះឥតត្រូវការអ្នកចេះដឹងទេ មានពួកខ្មែរក្រហមជាដើម ។

ហេតុនេះហើយបានជាលោកថា *ប្រាជ្ញចុះរណ្ដៅ ខ្លៅឡើងស្ថានសួគ៌* ។

*ថ្ងៃទី ១៦-១០-០៦*

# ២២០. បង់បោយមិនមើលប្រាណ ដាំជើងក្រានមិនប្រមាណផ្លាំង

**និយមន័យ**

ទំរើ និងកិរិយាបថមិនសមស្របនឹងឋានៈខ្លួន

**អត្ថាធិប្បាយ**

## 🕮 បង់បោយមិនមើលប្រាណ

មនុស្សខ្លះ ធ្វើអ្វីៗមិនចេះគិតគូឱ្យសមស្របនឹងឋានៈរបស់ខ្លួនទេ ដូចជាខ្លួនមានឋានៈតូចទាបតែធ្វើឬកដូចជាមេកោយគេ។ ការនិយាយស្តីទៀតសោត ក៏ពុំសមស្រប ទៅនឹងឋានៈខ្លួនដែរ។ បើគេនិយាយពីច្បាប់ គេហាក់ធ្វើដូចខ្លួនបណ្ឌិតច្បាប់ បើនិយាយពីការសាងសង់ គេធ្វើហាក់ដូចខ្លួនជាវិស្វករសំនង់ ។

បើមានពិធីអ្វីៗផ្សេងៗ ចូលចិត្តធ្វើខ្លួនឱ្យគេមើលមកថា ខ្លួនជាអ្នកមុខអ្នកការរៀបចាត់ចែងកម្មវិធី ។

## 🕮 ដាំជើងក្រានមិនប្រមាណផ្លាំង

ក្នុងន័យនេះ ក៏មានខ្លឹមសារដូចខាងលើដែរ គ្រាន់តែលោកពោលប្រៀបធៀបបែបជាអត្ថប្បដិរូបប៉ុណ្ណោះ ព្រោះអ្នកដែលរៀបកំនល់ធ្វើជើងក្រានមិនបានគិតទៅដល់ទំហំផ្លាំងតូច ឬធំនោះ គឺជាមនុស្សល្ងង់ខ្លៅមិនចេះប្រមាណក្នុងការងារ ៕

*ថ្ងៃទី ១៧-១០-០៦*

បណ្ណាល័យ ហ៊ុន សែន HUN SEN LIBRARY R.U.P.P. សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

# ២២១. បាតដៃក៏សាច់ ខ្នងដៃក៏សាច់

**និយមន័យ**

សម្រេចសេចក្ដីមិនបាន ព្រោះញាតិទាំងពីរខាង

**អត្ថាធិប្បាយ**

**📖អត្ថានុរូប**

"**សាច់**" គឺជាបរិធាតុនៃរាងកាយរបស់មនុស្ស និងសត្វ បន្ទាប់ពីស្បែកទៅស្រោបឆ្អឹង ។

ដូច្នេះ បើគេលើកបាតដៃឡើងមើល គេឃើញថា : បាតដៃក៏មានសាច់, ខ្នងដៃក៏មានសាច់ ។

ម្យ៉ាងទៀត "សាច់" ក៏ជាសញ្ញាណសំគាល់នូវញាតិពន្ធផងដែរ ដូចជា : សាច់ញាតិ, សាច់សារលោហិត ជាដើម ។

**📖 អត្ថប្បដិរូប**

ពាក្យថា "**សាច់**" នៅពេលនេះ សំដៅយកសាច់ញាតិ រឺសាច់សារលោហិត ។ ខ្លឹមសារក្នុងនិយមន័យខាងលើនេះ បំនងលោកអ្នកបង្កើតពាក្យនេះឡើង គឺក្នុងការអ្វីដែលនិយាយមិនចេញ និងកាត់សេចក្ដី រឺសំរេចសេចក្ដីឱ្យទៅជាយ៉ាងណាពុំកើត ។ ដោយសារតែទើសទាល់ ។ ព្រោះខាងស្ដាំក៏បងប្អូន, ខាងឆ្វេងក៏បងប្អូន រឺថា ខាងនេះ

ក៏សាច់ ខាងនោះក៏សាច់ ។ ដូច្នេះ មិនដឹងជាត្រូវថា : ឱ្យខាងណាត្រូវ ខាងណាខុស បានឡើយ ។

ម្យ៉ាងទៀតប្រសិនបើដឹងថា ខាងនេះត្រូវ ខាងនោះខុស ក៏នៅតែសំរេចសេចក្ដីឱ្យខាងណាត្រូវ ខាងណាខុសពុំបានដែរ ។

ករណីបែបនេះហើយ ដែលលោកពោលថា : **បាតដៃក៏សាច់ ខ្នងដៃក៏សាច់** ៕

*ថ្ងៃទី ០២-០៣-១១*

✿✿✿✿

### 📖ជីវះស្នៅភ្លួខថ្លាលអក្សរសិល្ប៍

✳ *ងាប់* ប្រើបានចំពោះតែសត្វតិរច្ឆាន, រុក្ខជាតិ និងសំភារៈប្រើប្រាស់ ។

ឧ. ឆ្កែងាប់, ដើមឈើងាប់ នាឡិកាងាប់ ........

☞បើយកពាក្យ( *ងាប់*)មកប្រើនឹងមនុស្សគឺជាការមើលងាយ រឺអសីលធម៌ ។

✳ *ស្លាប់* អ្នកដែលសូន្យសង្ខារទាំងអស់ គឺមិនមានការគោរព រឺសីលធម៌ ។ ពាក្យសមរម្យតាមឋានៈ ឧ. ព្រះសង្ឃ : អនិច្ចធម្ម, ព្រះរាជា : សោយទីវង្គត, គ្រហស្ថ : អនិច្ចកម្ម, មរណភាព........

✳ *សណ្ដាប់( ស្ដាប់)*កិ. ប្រើបានចំពោះតែព្រះមហាក្សត្រ រឺ ព្រះសង្ឃ ។

✳ *រាជានិយម* មកពី : រាជ = ស្ដេច + អនិយម = មិនចូលចិត្ត រឺ ប្រឆាំង, រាជានិយម = អ្នកប្រឆាំងនឹងស្ដេច ។ ពាក្យត្រូវ *រាជនិយម* ។

# ២២២. បើល្ងង់កុំចង់ធ្វើចេះ បើអត់ជំរេះកុំចង់ធ្វើធំ

**និយមន័យ**

កុំចង់ធ្វើអ្វីឱ្យហួសសមត្ថភាពខ្លួន

**អត្ថាធិប្បាយ**

📖 **បើល្ងង់កុំចង់ធ្វើចេះ**

សឹងតែជាការធម្មតាទៅហើយ មនុស្សល្ងង់មិនដែលដឹងថាខ្លួនឯងល្ងង់ទេ បើសិនជាដឹងក៏ព្យាយាមបិទបាំងនូវភាពអវិជ្ជារបស់ខ្លួនដោយខំប្រឹងធ្វើឫកជាអ្នកណាស់ ។ ការនិយាយស្ដីក៏ខំប្រឹងបញ្ចេញនូវវោហារសព្ទ ម៉េតប្រាយឱ្យគេអួតថាខ្លួនគ្រាន់បើពូកែនិយាយមិនចេះអស់ពាក្យ ។ ប៉ុន្តែអ្នកដែលគេចេះដឹងច្រើនជាង គេស្ដាប់ទៅគេដឹងភ្លាមថា មនុស្សនេះនិយាយគ្មានវគ្គ គ្មានឃ្លា វិលវល់ដដែលៗដូចគេអុំទូកក្នុងបឹង ។ ដូច្នេះវាគ្មានចេះអីវាទេ មុននឹងវានិយាយបានប៉ុណ្ណឹង គឺវាសួរគេច្រើនាក់ណាស់ហើយ ខំប្រឹងទន្ទេញមិនស្ទើរដែរ ។

📖 **បើអត់ជំរេះកុំចង់ធ្វើធំ**

ខ្លឹមសារនៃពំនោលនេះ ក៏មានន័យប្រហាក់ប្រហែលនឹងពំនោលខាងលើដែរ គឺលោកពោលទប់ស្កាត់ មនុស្សអវិជ្ជា កុំឱ្យជ្រួលច្របល់ចង់ធ្វើធំមិនស្គាល់សមត្ថភាព

ខ្លួនខ្លាំងពេក ។ ព្រោះមនុស្សអវិជ្ជាតែងមានមហិច្ឆតា ស៊ុះស្មារត្រហេបត្រហប ចង់បាន សក្តិ ឬមុខតំណែងធំណាស់ ។ ប្រសិនបើបានធ្វើធំហើយ គឺក្រាញនៀលតោងស្អិត ខាំស្មៅមិនងាយរបេះទេ ។ ព្រោះដឹងខ្លួនថា បើឱ្យរបេះក៏មិនងាយឡើងវិញបានដែរ ៕

*ថ្ងៃទី ១៧-១០-០៦*

❀❀❀❀



# ២២៣. បើមិនជួយចូកចែវ កុំយកជើងរាទឹក

**និយមន័យ**

បើមិនបានជួយធ្វើការគេ កុំមកធ្វើឱ្យយឺតការងារគេ

**អត្ថាធិប្បាយ**

❀ **អត្ថានុរូប**

ទូកតូចធំ កាលណាធ្វើដំនើរទៅមុខបាន លុះត្រាតែគេដោល គេអុំ ឬចែវ ។ ដូច្នេះ អ្នកដែលត្រូវធ្វើឱ្យទូកមានចលនាទៅមុខបាន គឺប្រឹងបញ្ចេញពលកម្មខ្លាំងណាស់ និងហត់ខ្លាំងណាស់ដែរ ។

ឯអ្នកដែលនៅស្ងៀមកណ្ដាលទូក កុំយកជើងដាក់ក្នុងទឹកនាំឱ្យស្ទះ ឬកាត់បន្ថយល្បឿនរបស់ទូក ។

❀ **អត្ថប្បដិរូប**

ទំរើអ្វីមួយដែលគេកំពុងធ្វើ បើមិនបានជួយធ្វើគេទេ កុំទៅមានយោបល់ជំទាស់កិច្ចការគេ ទុកឱ្យគេធ្វើតាមដំនើរគេទៅចុះ ។ ដូចជា :

- អ្នកខ្លះពេលគេធ្វើកិច្ចការរួចរាល់ហើយ ទើបទៅនិយាយថាធ្វើបែបនេះមិនល្អ មិនត្រូវ គឺខុសយ៉ាងនេះយ៉ាងនោះ ។

- ខ្លះទៀតពេលគេកំពុងធ្វើ ដើរទៅឈររបៀបជាបន្ទោសគេថា ធ្វើខុសបែបបទ បើធ្វើបែបនេះវិញ ទើបត្រឹមត្រូវ ។

ករណីទាំងអស់នេះ សុទ្ធតែបន្ទុចបង្អាក់ ធ្វើឱ្យរាំងស្ទះ និងយឺតដំនើរការងារគេ ដែលលោកហៅថា *បើមិនជួយចូកចែវ កុំមកគ្រេងគ្រាងយកជើងរាទឹក* ៕

*ថ្ងៃទី ១៧-១០-០៦*

# ២២៤. បានបាបមិនឆ្អាបមាត់

## និយមន័យ

ធ្វើបាបកម្ម តែមិនបានទទួលផល ឬមិនបានធ្វើបាបកម្ម ត្រលប់ជារងបាបកម្មវិញ។

## អត្ថាធិប្បាយ

ការប្រព្រឹត្តនូវបាបកម្មមួយដោយមានបំនងនឹងយកផល ប៉ុន្តែផលប្រយោជន៍នោះពុំបានផ្តល់មកឱ្យអ្នកធ្វើនោះវិញទេ ត្រលប់ជាបានទៅអ្នកដទៃវិញ ។ ដូច្នេះ អ្នកធ្វើបានត្រឹមតែទទួលនូវបាបកម្មប៉ុណ្ណោះ ។ ដូចជា :

- ព្រានប្រមាញ់ម្នាក់បាញ់សត្វឈ្លូសមួយក្បាល ។ ប៉ុន្តែឈ្លូសនោះ ពុំបានងាប់ភ្លាមទេ វារត់ទៅដេកងាប់ក្នុងព្រៃបាត់ទៅ ។ ដូច្នេះ ព្រានប្រមាញ់នោះ បានត្រឹមតែធ្វើបាបកម្មប៉ុណ្ណោះ គេឥតទទួលបានផលពីអំពើបាបនោះឡើយ ។
- នៅក្នុងអង្គភាពមួយ អ្នកដឹកនាំប្រព្រឹត្តអំពើពុករលួយស៊ីសំណូកគ្មានប្រណី ។ លុះដល់មានបញ្ហា ផលអាក្រក់នេះ ធ្លាក់ទៅលើសហការីដែលគ្មានឥតបានដឹងអ្វីបន្តិចសោះ ។

ទាំងអស់នេះ សុទ្ធតែបានបាបមិនឆ្អាបមាត់ ព្រោះអត់បានស៊ី ៕

*ថ្ងៃទី ១៧-១០-០៦*

❀❀❀❀

# ២២៥. ប្រពន្ធល្អ ច្រើនចាញ់ប្ដី

**និយមន័យ**

ប្រពន្ធដែលមានលក្ខណៈ៥យ៉ាងភាគច្រើនប្ដីចាញ់

**អត្ថាធិប្បាយ**

ក្នុងន័យប្រពន្ធល្អនៅពេលនេះ លោកពោលសំដៅយកស្ត្រីដែលមានលក្ខណៈសម្បូទ ៥យ៉ាង ។

ឯពាក្យថា ច្រើនចាញ់ប្ដី គឺប្ដីភាគច្រើនទេជាអ្នកចាញ់ ។ បានជាលោកប្រើពាក្យ "ច្រើន" នោះ ព្រោះគង់នៅមានប្ដីអវិជ្ជាខ្លះ មិនព្រមចាញ់ប្រពន្ធដែលមានលក្ខណៈសម្បូទទាំង៥យ៉ាងបែបនេះ មកពីភាពល្ងង់ខ្លៅរបស់គេដូចជា គេបានមាសហើយមិនស្គាល់មាសដូច្នោះឯង ។

ពាក្យថា លម្អដោយលក្ខណៈសម្បូទ៥យ៉ាងនោះគឺ :

- មានរូបស្អាតស្រស់ត្រកាល គួរជាទីគយគន់
- មានទ្រព្យធនធានច្រើន មិនភ័យព្រួយពីរឿងខ្វះខាត
- មានកិត្តិយសថ្លៃថ្នូរ ទោះទៅទីណាក៏មានគេស្រលាញ់រាប់អានច្រើន
- មានសីលធមិខ្ពស់ មានចរិយាសម្បូទជានារីប្រកបដោយគន្លងធមិ
- មានបុត្រ ដែលជាមរតកស្នងត្រកូល

បើប្រពន្ធមានលក្ខណៈសម្បូទ ៥យ៉ាងនេះហើយ ប្ដីសឹងតែទាំងអស់ត្រូវតែខ្លាច និងចាញ់ប្រពន្ធដោយស្វ័យប្រវត្តិ តួយ៉ាងដូចជានាង វិសាខា ក្នុងពុទ្ធសម័យជាភស្តុតាងស្រាប់ គឺប្ដីលុតជង្គង់ចាញ់នាងវិសាខា ហើយលើកតម្កើងប្រពន្ធទុកដូចម្ដាយ (មាតុភរិយា) ៕

កំណើត លី គឹមហួ *ថ្ងៃទី ១០-០៧-០៨*

# ២២៦. បាយបិណ្ឌជាបាយបាត្រ

**និយមន័យ**

ភាពមិនប្រាកដនិយម

## អត្ថាធិប្បាយ

***បាយបិណ្ឌ** លោកសំដៅយកបាយដែលពុទ្ធបរិស័ទនាំយកទៅធ្វើទានដល់វត្តអារាមក្នុងរយៈកាល ១៥ ថ្ងៃ(១រោចដល់ ១៥រោច) ។

***បាយបាត្រ** លោកសំដៅយកបាយដែលព្រះសង្ឃនិមន្តទៅទ្រង់បាត្រតាមមូលដ្ឋាន គឺទៅដល់ផ្ទះសំបែងពុទ្ធបរិស័ទ ។

ការដែលលោកលើកពាក្យនេះមកពោលគឺ លោកចង់ដៅទៅដល់កិច្ចការណា ឬទំរើណាដែលមានភាពច្របូកច្របល់ត្រលប់ត្រលិនសារចុះសារឡើងមិនច្បាស់-លាស់ជាអ្វី ។

ដូច្នេះពាក្យនេះ ពុំមែនជាពាក្យប្រៀនប្រដៅអ្វីទេ គឺជាពាក្យសំរាប់បន្ទោសទៅលើអ្នកណាម្នាក់ ដែលធ្វើកិច្ចការអ្វីមួយមិនច្បាស់លាស់មិនប្រាកដប្រជា ដូចជា :

ប្រធានម្នាក់ បញ្ជាឱ្យសហការីធ្វើកិច្ចការអ្វីមួយ ដែលជិតរួចរាល់ទៅហើយ ស្រាប់តែ បញ្ជាឱ្យកែប្រែ បែបយ៉ាងនេះយ៉ាងនោះទៅវិញ កែចុះកែឡើងមិនច្បាស់ជាយ៉ាងណា ។

ករណីបែបនេះ លោកថាច្របូកច្របល់ត្រលប់ត្រលិន *បាយបិណ្ឌជាបាយបាត្រ* យកជាការពុំបាន ៕

*ថ្ងៃទី ១៧-១០-០៦*

# ២២៧. ប្លង់នៅនឹងមាត់ បន្ទាត់នៅនឹងភ្នែក

**និយមន័យ**

ទំរើគ្មានក្រិត្យក្រម

## អត្ថាធិប្បាយ

ធម្មតាការសាងសង់ រឺទំរើអ្វីមួយ គេតែងធ្វើគំរោង រឺប្លង់ដែលមានឧបករណ៍ និងក្បួនខ្នាតយ៉ាងត្រឹមត្រូវ ទើបគេចាប់ផ្ដើមការសាងសង់ទៅតាមលក្ខណៈបច្ចេកទេសតាមក្រោយ ។

ចំនែកអ្នកដែលធ្វើប្លង់ធ្វើគំរោងដោយមាត់នោះ មិនប្រាកដជាបានត្រឹមត្រូវទាំងអស់ទេ គឺជួនត្រូវ ជួនខុស ។ ព្រោះការនិយាយថាភ្លាមៗមិនបានពិចារណាឱ្យម៉ត់ចត់ឡើយ ។

ឯបន្ទាត់នៅនឹងភ្នែកក៏ដូចគ្នាដែរ គឺគេមើលទិស មើលទីវាស់តំរង់នឹងភ្នែកម្ខាងដោយឥតប្រើឧបករណ៍ ខ្សែបន្ទាត់ រឺកែវស្ទង់ ។ ទំរើបែបនេះ ក៏ពុំប្រាកដជាត្រង់ រឺស្មើល្អដែរ ។ ព្រោះភ្នែកមនុស្សមានល្មៀងឆ្វេង-ស្ដាំ លើ ក្រោមជាធម្មតា ។ម្យ៉ាងទៀត បើភ្នែកមនុស្ស តំរង់ធ្វើជាខ្សែបន្ទាត់បានត្រឹមត្រូវមែននោះ ម្ល៉េះសមអ្នកបច្ចេកទេសមិនបង្កើតកែវស្ទង់ជាឧបករណ៍សំរាប់ស្ទង់មកធ្វើអ្វីទេ ។

ហេតុនេះហើយបានជាលោកតែងបន្ទោសថា អ្នកដែលយកមាត់ធ្វើប្លង់យកភ្នែកធ្វើខ្សែបន្ទាត់តំរង់ គឺជាមនុស្សខ្ជិល រឺខ្ជីខ្ជា ព្រោះវាមិននាំមកនូវភាពសុក្រិត្យឡើយ ៕

*ថ្ងៃទី ១៨-១០-០៦*

# ២២៨. បានពីក្អែកចែកតាវៅ

**និយមន័យ**

ការចែកចាយបន្តគ្នា

## អត្ថាធិប្បាយ

ការដែលលោកពោលពាក្យនេះឡើង ក្នុងបំនងប្រាប់ឱ្យដឹងថាការដែលទទួលបាននូវវត្ថុអ្វីមួយហើយ ។ គេមិនបានទុករបស់នោះស៊ីចុក រឺប្រើប្រាស់ម្នាក់ឯងទេ ។ គេតែងបែងចែករំលែកឱ្យទៅអ្នកដទៃបន្ត ទៀត ។ ដូចជា :

- អ្នករកស៊ីដឹកទំនិញពីខេត្តតាមម៉ូតូម្នាក់ ។ គាត់គិតថា បានចំនេញគ្រាន់រស់ដែរ ។ ប៉ុន្តែពេលធ្វើដំនើរចូលទីក្រុង ត្រូវអ្នកឈរតាមផ្លូវបណ្តាក់គ្នាដូចខ្សែងចាំសួរសុខទុក្ខគាត់ ។ ហេតុនេះហើយពេលមានគេសួរ គាត់ពីផលចំនេញ។ គាត់តែងនិយាយថា មិនបានចំនេញប៉ុន្មានទេ គឺតិចតួចស្តួចស្តើងណាស់ ។ ព្រោះបានពីក្អែកចែកតាវៅស៊ីផង ។

- អ្នករកស៊ីកំប៉ិកកំប៉ុកតាមឆ្នេរសមុទ្រទាំងត្រដាបត្រដួស ។ ពេលបានកំរៃបន្តិចបន្តួចមកសង្ឃឹមថាបានរស់មួយថ្ងៃហើយ ។ ប៉ុន្តែចាំបាច់ត្រូវបែងចែកទៅឱ្យរំពេរឆ្នេរសមុទ្រទៀតទោះចង់មិនចង់ក៏ដោយ ។

- ហេតុការណ៍នេះហើយបានជាលោកពោលថា : *បានពីក្អែកចែកតោវៅ* រឺចែករំពេរសមុទ្រទៀត បើ មិនចែកច្បាស់ជាមិនបានសុខឡើយ ៕

*ថ្ងៃទី ១៨-១០-០៦*

❀❀❀❀

# ២២៩. ប្រហែសបាត់ ប្រយ័ត្នគង់

**និយមន័យ**

លទ្ធផលនៃការធ្វេសប្រហែស និងកិច្ចការពារ

## អត្ថាធិប្បាយ

ពំនោលនេះ គ្មានអ្វីតុបតិនទេ គឺលោកប្រាប់ត្រង់ៗតែម្តង ។ ព្រោះអ្វីក៏ដោយ បើកាលណាគេធ្វេសប្រហែសដាក់ចោលផ្តេសផ្តាសប្រាកដជាបាត់មិនខាន។ បើមិនបាត់ដោយសារដៃមនុស្ស ក៏បាត់ដោយសារឆ្កែឆ្មា ពាំយកទៅបាត់ចាកផុតពីកន្លែងដើម រឺក៏បាត់បង់ដោយសារធម្មជាតិមានខ្យល់កួចបើុងផាត់យកបាត់ទៅ ។

ឯការប្រុងប្រយ័ត្នដោយម៉ត់ចត់វិញ របស់នោះនឹងស្ថិតនៅជាពិតប្រាកដ ។

ពំនោលខាងលើនេះ គេតែងឮអ្នកនិយាយបញ្ច្រាសផ្ទុយត្រលប់មកវិញថា ប្រហែសក៏មិនបាត់ ប្រយ័ត្នក៏មិនគង់ ក្នុងន័យនេះគឺគេចង់និយាយថា **ជម្ងឺ** បើគេធ្វេសប្រហែសយ៉ាងណា ក៏មិនបាត់ទៅណាដែរ គឺវាចេះតែកើត មានឡើងជានិច្ច ។ ឯការប្រុងប្រយ័ត្នយ៉ាងម៉ត់ចត់នៅតែមិនគង់វង់នោះ គឺសំដៅយករបស់ខ្លះមាន **ធ្មេញ** ជាដើម ធ្មេញនេះបើទោះបីជាគេខំប្រឹងការពារយ៉ាងណាក៏ដោយ ក៏នៅទីបំផុតវានឹងបាក់អស់នៅសល់តែអណ្តាតខ្វៅៗ យ៉ាងអាក្រក់មើល ៕

*ថ្ងៃទី ១៨-១០-០៦*

# ២៣០. បានស្វាយណាយក្រូច

**និយមន័យ**

បានថ្មីចោលចាស់

## អត្ថាធិប្បាយ

ពាក្យពំនោលនេះ លោកចង់និយាយពីចិត្តមនុស្សបុថុជ្ជនគ្រប់រូបដែលមានចិត្តគំនិតសឹងតែប្រហាក់ប្រ ហែលគ្នាទាំងអស់ ។

ព្រោះធម្មតារបស់ថ្មី គេចាត់ទុកថាជារបស់ប្លែកដែលគេតែងចង់ដឹង ចង់ស្គាល់គុណភាពជានិច្ច ។ ដូចជា :

-មនុស្សដែលធ្លាប់ទទួលទានផ្លែក្រូចជាញឹកញាប់ហើយតែងជិនណាយ កាលបើបានផ្លែស្វាយមកគេតែង ចង់ដឹង ចង់ស្គាល់ ចង់ភ្លក្សរសជាតិ ។

- អ្នកដែលធ្លាប់ប្រើម៉ូតូម៉ាកស៊ុយ លុះបានម៉ូតូម៉ាកសង់ គេតែងទុកអាស៊ុយមួយអន្លើសិន ទៅណាមកណា អូសតែអាសង់ជិះជូនដំនើរម្តងវិញ ។

- គូសង្សារខ្លះតែងបន្ទោសគ្នាទេវិញទៅមកថា ម៉េច! បានអាថ្មី ចោលអាចាស់ហើយហ្នឹង? ភ្លេចគ្រាកំសត់កម្រពីកាលណោះដែលញ៉ាំបាយលាយដំឡូងលាយគល់ចេក លាយក្តួចអស់ហើយឬ? ។

*ថ្ងៃទី ១៨-១០-០៦*

# ២៣១. ប្រាក់ក៏បង់ ថង់ក៏ដាច

**និយមន័យ**

ខូចខាត រឺបាត់បង់ទាំងពីរផ្លូវ

**អត្ថាធិប្បាយ**

ទំរើខ្លះ រឺការងារខ្លះដែលគេធ្វើទៅហើយដោយនឹកសង្ឃឹមថា គេនឹងបាន ទទួលផលត្រលប់មកវិញ ។ ប៉ុន្តែអ្វីដែលគេនឹកសង្ឃឹមនោះ ត្រលប់ជាត្រូវទទួលនូវ កំហាកចិត្តយ៉ាងខ្លោចផ្សាទៅវិញ ។ ដូចជា :

- អ្នករកស៊ីចងការប្រាក់ម្នាក់ បានចងការប្រាក់ឱ្យគេជាច្រើន ។ នៅឯចុង ចប់កូនបំនុលមិនបានសងការប្រាក់ ថែមទាំងរត់បាត់ទាំងប្រាក់ដើមទៅទៀត ។ ដូច្នេះ គេត្រូវខាតទាំងចុងខាតទាំងដើម ។

- អ្នករកស៊ីរត់ពន្ធម្នាក់ ត្រូវសមត្ថកិច្ចចាប់យកអីវ៉ាន់អស់ រួចហើយពិន័យ ថែមទៀត ។ ដូច្នេះ គេត្រូវខាតទាំងពីរយ៉ាង ។

- អ្នកប្រមឹកម្នាក់ វាយគេបែកក្បាល ត្រូវចេញថ្លៃព្យាបាលឱ្យគេផង និងសង ជម្ងឺចិត្តឱ្យគេផង ហើយខ្លួនត្រូវជាប់ឃុំទៀត ។

- ស្រីស្រស់ម្នាក់ បានបូជាខ្លួនចំពោះគូស្នេហ៍រួចហើយ ត្រូវគូស្នេហ៍ល្បួងលួង លោមយកមាស-ប្រាក់មួយចំនួន រួចក៏ភៀសខ្លួនបាត់ស្រមោលតែម្តង ។ ដូច្នេះខ្លួន ក៏អស់របស់ក៏ខូច ។

ក្នុងករណីនេះ សុទ្ធតែបាត់បង់ទ្រព្យសម្បត្តិហើយ បាត់បង់កិត្តិយសទៀត ៕

*ថ្ងៃទី ១៨-១០-០៦*

# ២៣២. បាចអង្កាមប្រាសខ្យល់

**និយមន័យ**

រងផលវិបាកដោយសារសម្ដី រឺទំរើខ្លួនឯង

## អត្ថាធិប្បាយ

### ☞ អត្ថានុរូប

**"អង្កាម"** គឺជាសំបកផ្លែស្រូវដែលមានទំងន់ស្រាល ។ ដូច្នេះបើគេចាប់មួយដៃបាចបញ្ច្រាសខ្យល់ ។ អង្កាមនោះ នឹងប៉ើងត្រលប់មករកអ្នកបាចវិញមិនខាន ។ វានឹងធ្វើឱ្យមានការរំខានដូចជាហុយលំអងចូលភ្នែក ចូលច្រមុះ និងធ្វើឱ្យស្មៀបរមាស់ ខ្លួនទៀតផង ។

### ☞ អត្ថប្បដិរូប

ន័យខាងលើនេះលោកប្រៀនប្រដៅអនុជនជំនាន់ក្រោយថា ធ្វើការអ្វីក៏ដោយត្រូវពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយជាមុនសិន ។ ក្រែងវាមានផលលំបាកស្រោចត្រលប់មករកម្ចាស់ដើមវិញ ។ ដូចជា :

- សត្វមេអំបៅមួយបានដៀលដង្កូវដែលកំពុងវារលើត្របកផ្កាថា ចូរឯងចៀសចេញ ឯងជាសត្វគួរឱ្យស្អប់ខ្ពើមមិនសមនៅលើផ្កានេះទេ ។ ដង្កូវតបវិញថា កាលពីម្សិលមិញឯងក៏ជាដង្កូវដូចអញដែរ ទើបតែថ្ងៃនេះទេឯង បានក្លាយជាសត្វមេអំបៅ ម្ដេចក៏ឆាប់ភ្លេចជាតិកំនើតខ្លួនម្ល៉េះ?

- នាយ ក និងនាយ ខ នៅផ្ទះជិតគ្នា ។ ថ្ងៃមួយនាយ ក ទៅរាំងច្រកផ្លូវមិនឱ្យនាយ ខ ដើរតាមរបៀងផ្ទះ របស់ខ្លួន ។ នាយ ខ មិនសប្បាយចិត្តក៏កាត់បណ្ដាច់ខ្សែភ្លើងដែលនាយ ក ទាញកាត់លើដំបូលផ្ទះរបស់ខ្លួនវិញដែរ ៕

*ថ្ងៃទី ១៩-១០-០៦*

# ២៣៣. បានតែពាក្យ ត្រគាកស្លាប់ឈឹង

**និយមន័យ**

ទ្រឹស្ដីចាក់ចារ ការងារចាក់ថយ

## អត្ថាធិប្បាយ

មនុស្សខ្លះមានឥរិយាបថស្ងៀមស្ងាត់ តែធ្វើការយ៉ាងសកម្ម ហើយស្អាតទៀត ។ ផ្ទុយទៅវិញ អ្នកខ្លះទៀតបានវោហារម៉ែតប្រាយបង្គាប់បញ្ជាគេធ្វើឬកបែបហំហាន ខ្លាំងណាស់ ។ ប៉ុន្តែការងារសព្វសារពើធ្វើមិន កើតចេញជារូបរាងអ្វីមួយសោះ ។

មានអ្នកខ្លះទៀត ពូកែខ្លាំងណាស់ខាងទ្រឹស្ដី ហានិយាយកាលណាសុទ្ធតែខ្លួនធ្លាប់ធ្វើកិច្ចការនៅកន្លែងនេះ នៅកន្លែងនោះរាប់មិនអស់ គឺគេនិយាយតែកន្លែងណាដែលគេមិនដែលស្គាល់ មិនដែលដឹង ។ ប៉ុន្តែតាមការណ៍ពិតទៅ គេគ្មានបានធ្វើអ្វីមួយកើតទេ ។

ត្រង់នេះហើយ ដែលគេតែងតែកត់សំគាល់ថា មនុស្សដែលបានវោហារ ច្រើនធ្វើអ្វីពុំកើតទេ ដូចសំបក ប៉ោតដែលគ្មានទឹក តែងឮម៉ូងម៉ាំងដូច្នោះឯង ៕

*ថ្ងៃទី ១៩-១០-០៦*

# ២៣៤. ប្រាជ្ញមិនស្មើប្រប បាក់ស្លឹកត្រចៀកខ្លួប មិនស្មើអាឡេមឡឹម

**និយមន័យ**

អត្តចរិតអ្នកស្មោះត្រង់ និងអ្នកប្រចុប

**អត្ថាធិប្បាយ**

**- ប្រាជ្ញមិនស្មើប្រប**

ប្រាជ្ញនៅពេលនេះ លោកសំដៅយកអ្នកដែលមានវោហារសព្វពូកែនិយាយស្ដីប្រាជ្ញព្រោកដើម្បីឱ្យគេស្គាល់ខ្លួន ។

ក្នុងន័យនេះ លោកចង់និយាយពីមនុស្សដែលប៉ិនប្រសប់និយាយស្ដីម៉េតប្រាយដើម្បីឱ្យបានស្និទ្ធនឹងអ្នកធំណាម្នាក់ ។ ប៉ុន្តែលោកថា ទោះជាយ៉ាងណាក៏ដោយក៏វាមិនស្មើនឹងអ្នកដែលនៅអែបអង្គប្របខាងជិតស្និទ្ធនឹងអ្នកធំនោះទេ ។ ព្រោះ អ្នកនៅប្របខាងអ្នកធំតែងស្គាល់គេជារាល់ថ្ងៃ ។

**-បាក់ស្លឹកត្រចៀកខ្លួប មិនស្មើអាឡេមឡឹម**

អ្នកបាក់ស្លឹកត្រចៀកខ្លួប គឺមនុស្សដែលរណោបរណើបដៃក្ដោបតែប្រដាប់ ចាំតែឆ្លើយថា *បាទទាន-បាទទាន* កាយវិការខ្ទីបចុះខ្ទីបឡើងបែបនេះក៏ក្នុងគោលបំណងចង់ឱ្យគាប់ចិត្តនឹងអ្នកធំ រឺធ្វើឱ្យអ្នកធំស្គាល់រាប់អានដូចគ្នា ។ ប៉ុន្តែលោកថា បើទុកណា

ជាខំត្រូន១ឱន១យ៉ាងណាក៏ដោយក៏មិនបានស្និទ្ធស្មើនឹងអាឡេមឡឹមដែរ ។ ព្រោះអាឡេមឡឹម វាចេះប្រចុបប្រចែង, លើកដាក់ធ្វើហាក់ដូចខ្លាច ។ តែការណ៍ពិតវាឥតខ្លាចទេ ។

ករណីនេះ បញ្ជាក់ឱ្យឃើញថា ល្បិចកិច្ចកលមនុស្សប្រចុបមានប្រសិទ្ធិភាពជាងមនុស្សឱនលំទោន ៕

*ថ្ងៃទី ២០-១០-០៦*

✿✿✿✿



# ២៣៥. បន្លាមុត យកបន្លាដោះ

## និយមន័យ

មានបញ្ហា ត្រូវយកបញ្ហាដូចគ្នាមកដោះស្រាយ

## អត្ថាធិប្បាយ

### ☞ អត្ថានុរូប

បើបាទជើងគេត្រូវមុតដោយបន្លា គេត្រូវយកបន្លាដូចគ្នាមកជោះចាក់ឆ្កឹះរកបន្លាដែលមុតនោះដកយកចេញមកវិញ ។

### ☞ អត្ថប្បដិរូប

ប្រសិនបើគេមានបញ្ហាអ្វីមួយកើតឡើង គេត្រូវយកបញ្ហាដូចគ្នាទៅដោះស្រាយ ។ តែពុំមែនគ្រប់ករណីទាំងអស់ទេមានករណីខ្លះ គេត្រូវយកករណីផ្សេងទៅដោះស្រាយបានដែរ ។

ប៉ុន្តែ ក្នុងន័យខាងលើនេះលោកនិយាយតែពីអ្វីដែលត្រូវយកករណីដូចគ្នាទៅដោះស្រាយ ។ ដូចជា :

- មានបញ្ហាគេរំលោភព្រំដែន គេត្រូវយកផែនទីស្តីពីព្រំដែនទៅដោះស្រាយ ។
- បើចង់ចាប់ចោរ ត្រូវយកចោរធ្វើធ្នាក់ គឺយកចោរចាប់ចោរ ។
- បើខ្មាំងវាយប្រហារដោយកាំភ្លើង ត្រូវយកកាំភ្លើងទៅទប់ទល់ ។

- អ្នកបោកបែនស្រូវកណ្តាលវាលស្រែ បើមានភ្លើងឆេះព្រៃរាលមក ត្រូវដុតភ្លើងស្រុកឱ្យឆេះរាលទៅទប់ទល់ ។

- ត្រីប្រឡាក់ រឺឆៃប៉ូវប្រៃពេក ត្រូវយកទៅត្រាំក្នុងទឹកអំបិលប្រៃខ្លាំង វានឹងកាត់បន្ថយជាតិប្រៃក្នុងត្រី, ក្នុងឆៃប៉ូវ ។

នេះជាន័យខាងលើ តែមិនយោងដល់កំហាតប្រាក់ដោយចាញ់ល្បែង ត្រូវយកប្រាក់ពីផ្ទះទៅទប់ទល់ទេ ៕

*ថ្ងៃទី ២០-១០-០៦*





# ២៣៦. បញ្ញើ ស្មើបំនុល

**និយមន័យ**

ការទទួលបញ្ញើ ទុកដូចជំពាក់បំនុលគេ ស្មើនឹងតំលៃបញ្ញើ

**អត្ថាធិប្បាយ**

ការដែលបានទទួលនូវរបស់អ្វីដែលគេផ្ញើទៅអ្នកណាម្នាក់ លោកថាទុកដូចជាជំពាក់បំនុលគេដែលមានតម្លៃស្មើនឹងតវ៉ាន់នោះដែរ ។ ការណ៍ដែលលោកពោល ដូច្នេះគឺក្នុងគំនិតថា ប្រសិនបើរបស់នោះត្រូវបែកបាក់ រឺត្រូវបាត់បង់ដោយប្រការ ណាមួយ អ្នកទទួលបញ្ញើត្រូវជួសជុល រឺត្រូវសងតាមតំលៃរបស់នោះទាំងស្រុង ព្រោះបើសងត្រឹមពាក់កណ្តាលគឺគេមិនព្រមជាដាច់ខាត ដោយគេជឿថាអ្នកទទួលបញ្ញើនោះក្លែងធ្វើឱ្យបាត់របស់គេដោយចេតនា។ ដូច្នេះ ទោះចង់មិនចង់ក៏ដោយ ក៏ត្រូវតែសងគេពេញថ្លៃ។

ករណីដូចខាងលើនេះហើយ បានជាលោកពោលថា បើអ្នកបានទទួលបញ្ញើគេមានតម្លៃប៉ុណ្ណា គឺទុកដូចជាជំពាក់បំនុលគេស្មើនឹងតំលៃបញ្ញើនោះដែរ ៕

*ថ្ងៃទី ២០-១០-០៦*

❀❀❀❀

# ២៣៧. បុណ្យក៏ធ្វើ ឈើក៏កាប់

**និយមន័យ**

ធ្វើបុណ្យផង ធ្វើបាបផង

## អត្ថាធិប្បាយ

មនុស្សខ្លះ ខំប្រឹងព្យាយាមកំចាត់បង់នូវកម្មជាអកុសល ដោយគេខំប្រឹងធ្វើបុណ្យសុន្ទរទានជារឿយៗ ទោះបីជាគេដឹងថាខ្លួនមិនទាន់បានឈានទៅដល់ក៏រិតខ្ពស់ក៏ដោយ ។

មនុស្សខ្លះ បានថ្វាយខ្លួនជាឧបាសក-ឧបាសិកាចំពោះព្រះរតនត្រ័យគោរពប្រតិបត្តិតាមធម៌វិន័យរបស់ព្រះពុទ្ធជាម្ចាស់ ។

ប៉ុន្តែនៅមានមនុស្សមួយពួកទៀត ដែលគេហៅថាទាយក-ទាយិកា ។ ពួកជននេះ ក៏ជាអ្នកគោរពប្រតិបត្តិព្រះពុទ្ធសាសនាដែរ ។ គ្រាន់តែមិនទាន់បានថ្វាយខ្លួនដាច់ខាតចំពោះព្រះពុទ្ធសាសនាប៉ុណ្ណោះ ។ ពីព្រោះ គេនៅប្រកបអាជីវកម្មផ្សេងៗទៀតដូចជា : សំលាប់គោ, ជ្រូក, មាន់, ទា, ត្រី ។ល ។ ប៉ុន្តែនៅពេលប្រារព្ធពិធីបុណ្យទានក្នុងសាសនាវិញ គេធ្វើមិនដែលខានទេ ជួនកាលហ៊ានចំនាយធនធានច្រើនសន្ធឹកសន្ធាប់ទៀតផង ។

ដោយសារគេជាអ្នកថ្វាយទានដល់សាសនា តែមិនទាន់បានថ្វាយខ្លួន ដូច្នេះហើយទើបលោកពោលថា **បុណ្យក៏ធ្វើ ឈើក៏កាប់** ៕

*ថ្ងៃទី ២០-១០-០៦*

❁❁❁❁

# ២៣៨. បានមាស ខ្វះក្រដាសខ្ចប់

**និយមន័យ**

កង្វះកិរិយាមារយាទរៀបចំដាក់ទុក

## អត្ថាធិប្បាយ

ក្រដាសនៅពេលនេះ លោកប្រៀបទុកជាគំនិតកិរិយាមារយាទ ចេះរៀបចំទុកដាក់ឱ្យមានរបៀបរៀបរយត្រឹមត្រូវ ។

ដូច្នេះ ការណ៍ដែលលោកពោលថា បានមាសខ្វះក្រដាសខ្ចប់ គឺសំដៅយកមនុស្សដែលខ្វះគំនិតរៀបចំទុកដាក់របស់របរដែលខំប្រឹងរកពីក្រៅបានមកហើយ យកមកដាក់ចោលអារាត់អារាយក្នុងផ្ទះ ។ គឺគ្មានគំនិតចេះ រៀបចំទុកដាក់ឱ្យគង់វង់ រឺអោយមានសណ្តាប់ធ្នាប់ត្រឹមត្រូវ ។

ម្យ៉ាងទៀត ការដែលចេះរកប្រាក់កាសដោយមធ្យោបាយផ្សេងៗបានមកទុកជាគុណសម្បត្តិមួយហើយ តែបើមិនចេះសន្សំសំចៃត្បិតត្បៀតក្នុងការចាយវាយ ខ្ជះខ្ជាយឥតគិតដល់កម្លាំងញើសដែលខំប្រឹងរកមកសោះនោះ ក៏លោកពោលថា ខ្វះក្រដាសខ្ចប់ដែរ ។ ដូចជាយកលុយទៅចំនាយដែលមិនចាំបាច់ក្នុងគ្រួសារ មានដើរលេងស៊ីផឹក រឺលេងល្បែងស៊ីសងផ្សេងៗជាដើម ៕

*ថ្ងៃទី២០-១០-០៦*

❀❀❀❀

# ២៣៩. បណ្ដាក់គ្នាដូចខ្យង

**និយមន័យ**

អ្នកទន់ខ្សោយ ក៏អាចផ្ចាញ់អ្នកខ្លាំងបានដែរ អោយតែមានប្រាជ្ញា ។

**អត្ថាធិប្បាយ**

ពាក្យទំនឹមទំនៀមនេះ មានន័យថាអ្នកខ្លាំងពូកែ រឺអ្នកមានអំនាច មិនត្រូវមើលងាយអ្នកទន់ខ្សោយ ថាគ្មានប្រាជ្ញាសោះនោះទេ ។ម្យ៉ាងទៀតលោកទូន្មានថាកុំឡើងអំនួតអួតអាងថាមានតែអញទេដែលមានបញ្ញាបាធីខ្លាំងជាងគេគ្មានអ្នកស្មើ ។ អញចង់ធ្វើអ្វីក៏មានប្រៀបលើអ្នកទន់ខ្សោយដែរ ។

ទាក់ទងនឹងន័យខាងលើនេះ លោកបានលើកជាល្បើកនិទានដូចតទៅ :

- ថ្ងៃមួយ សត្វទន្សាយបានចុះទៅផឹកទឹកក្នុងត្រពាំង ។ ពេលនោះសត្វខ្យងក៏មកសួរថា អ្នកឯងមានអំនាចអីបានជាហ៊ានមកចុះផឹកទឹកត្រពាំងនេះ ។ បើអ្នកឯងចង់ផឹកទឹកត្រពាំងនេះ លុះត្រាតែអ្នកឯងអាចរត់ប្រនាំងឈ្នះយើង ។ ទន្សាយគិតថា អាសត្វខ្យងគើមៗនៅតែមួយកន្លែងយ៉ាងនេះ រឿងអីមករត់ប្រនាំងឈ្នះអញ ។ ភាគីទាំងពីរសន្យារត់ប្រណាំងគ្នានៅថ្ងៃស្អែក ។

ពេលនោះ សត្វខ្យងបានប្រមូលគ្នាមកប្រាប់ថា ថ្ងៃស្អែកនេះយើងនឹងបណ្ដាក់គ្នាក្នុងទឹកហូរហែតាមមាត់ត្រពាំង ។ កាលណាទន្សាយស្រែកហៅត្រូវឱ្យអ្នកនៅខាង

មុខឆ្លើយថា *តូក* ។ ឯទន្សាយលុះដល់ពេលណាត់ហើយ ក៏មករត់ប្រនាំងនឹងខ្យង ។ ទន្សាយក៏ចាប់ផ្ដើមរត់តាមទីកំនត់ ។ លុះរត់បានបន្ដិច ទន្សាយក៏ហៅខ្យង ។ ខ្យងដែលនៅខាងមុខក៏ឆ្លើយ *តូក* ។ ទន្សាយប្រឹងរត់លឿនជាងមុន ។ ប៉ុន្តែ ពេលហៅទន្សាយចេះតែឮខ្យងនៅ ខាងមុខឆ្លើយរហូត ។

ទីបំផុតទន្សាយក៏ចុះចាញ់សត្វខ្យង ដោយសន្យាថាលែងមកផឹកទឹកត្រពាំងទៀត សុខចិត្តលិទ្ធទឹកសន្សើម ដែលជាប់តាមស្លឹកឈើជារៀងរហូតមកដល់សព្វថ្ងៃនេះ ។

អាស្រ័យហេតុនេះហើយ បានជាអ្នករកស៊ីដឹកទំនិញពីខេត្តចូលក្រុងតែងត្អូញត្អែរថា រកស៊ីសព្វថ្ងៃសឹងតែមិនគ្រប់មាត់ ។ ព្រោះអស់លោកតាមផ្លូវ *បណ្ដាក់គ្នាដូចខ្យង* ៕

*ថ្ងៃទី ២៧-០៨-០៧*

❀❀❀❀

✳ ក្នុងពិភពលោកយើងនេះ គ្មានកន្លែងណាស្ងាត់កំបាំងទេ,
បុគ្គលប្រព្រឹត្តនូវកម្ម បើគ្មានគេដឹង គេឃើញ ក៏ខ្លួនឯងដឹង និងឃើញដែរ ។

*ព្រះពុទ្ធ*

# ២៤០. ប្រដៅខ្លួនឯងឱ្យបានបទ សឹមប្រដៅអ្នកដទៃ

**និយមន័យ**

មុនអប់រំគេ តោងអប់រំខ្លួនឯងសិន

**អត្ថាធិប្បាយ**

មានមនុស្សមួយចំនួន ចូលចិត្តតាំងខ្លួនជាអ្នកប្រដៅគេ និងអប់រំគេ ។ ប៉ុន្តែ គេភ្លេចគិតថា ខ្លួនឯងមានសមត្ថភាពគ្រប់គ្រាន់ហើយរឺនៅ? មានចំនេះដឹងផ្នែកខាងការអប់រំរឺទេ?

អាស្រ័យហេតុនេះហើយបានជាលោកហាមដូច្នេះ ព្រោះបើចង់តាំងខ្លួនជាអ្នកប្រដៅគេ, អប់រំគេ តោងអប់រំខ្លួងឯងឱ្យមានចំនេះដឹង, មានបទពិសោធន៍, មានគុណកោសល្យឱ្យបានម៉ត់ចត់ជាមុនសិន ទើបអប់រំនិងប្រដៅគេបាន ។ ព្រោះបើខ្លួនឯងជាមនុស្សអវិជ្ជា បើទៅដឹកនាំគេ ក៏ដឹកនាំទៅរកហាយនភាពដែរ ដូចពួកខ្មែរក្រហមជាដើម ។

- អ្នកខ្លះទីទ័លក្ររកអង្ករច្រកឆ្នាំងគ្មាន ខំប្រឹងដឹកនាំឱ្យគេធ្វើស្រែចំការ ។ កាលណាធ្វើទៅខុស គេថា ដកពិសោធន៍ ។ តួយ៉ាងដូចខ្មែរក្រហមជាដើម ។

- អ្នកខ្លះដឹកនាំ និងគ្រប់គ្រងគ្រួសារខ្លួនឯងមិនកើតផង តែចិត្តមហិច្ឆតាចង់ដឹកនាំ និងគ្រប់គ្រងប្រជាសហគមន៍ ៕

*ថ្ងៃទី ២១-១០-០៦*

❀❀❀❀

# ២៤១. ប្រដៅក្មេងមិនបាច់រកឱកាស ប្រដៅចាស់ត្រូវរកពេលវេលា

**និយមន័យ**

ការទូន្មានមនុស្សត្រូវរកពេលវេលាសមស្របតាមវ័យ

**អត្ថាធិប្បាយ**

ការប្រៀនប្រដៅ, ការអប់រំមនុស្ស ពុំមែនចេះតែធ្វើបានផលគ្រប់ពេលទេ ។ សូម្បីតែព្រះពុទ្ធបរមគ្រូ មុននឹងយាងទៅប្រោសមនុស្សក៏ព្រះអង្គប្រមើលមើលនូវឧបនិស្ស័យរបស់សត្វលោកដែរ ។

ហេតុនេះហើយបានជាលោកឱ្យជ្រើសរើសរកពេលវេលា ។

📖 **ប្រដៅក្មេងមិនបាច់រកឱកាស**

**ក្មេង** ស្ថិតនៅក្នុងថ្នាក់បឋមវ័យដែលពុំទាន់មានអស្មិមានះរឹងត្អឹងប៉ុន្មានទេ គឺប្រៀបបានទៅនឹងដើមឈើ ដែលនៅខ្ចី នៅទន់នៅឡើយដែរ ។ ម្ល៉ោះហើយការអប់រំ, ការទូន្មានប្រៀនប្រដៅចង់ធ្វើនៅពេលណាក៏បានដែរ មិនចាំបាច់រកឱកាសឡើយ ឱ្យតែអ្នកទូន្មានប្រៀនប្រដៅមានវិធីសាស្ត្រក្នុងការអប់រំគ្រប់គ្រាន់ ។

📖 **ប្រដៅចាស់ត្រូវរកពេលវេលា**

ការប្រៀនប្រដៅ រឺការអប់រំមនុស្សចាស់នេះ គឺជាការលំបាកក្រៃលែង គេ

តោងរើសរកពេលវេលាឱ្យបានសមស្រប និងឱ្យបានល្អជាទីបំផុត ។ ព្រោះមនុស្ស កាន់តែចាស់ កាន់តែមានអស្មិមានះ អាត្មានិយមកាន់តែខ្លាំង ប្រៀបដូចដើមឈើកាន់តែចាស់ កាន់តែមានភាពស្វិតរឹងមាំកាន់តែខ្លាំងដែរ បើប៉ះដើមឈើណាមានខ្លឹមទៀត ការពត់លែងធ្វើកើតសោះតែម្តង ។ ឯមនុស្សចាស់វិញបើជាមនុស្ស អវិជ្ជាទៀតនោះ មានទិដ្ឋិរឹងត្អឹងដូចឈើខ្លឹមដែរ គឺការអប់រំទូន្មានសឹងតែគ្មានប្រសិទ្ធិភាពដូចគ្នា ។

ហេតុនេះហើយ បានជាលោកប្រាប់ថា ការប្រដៅមនុស្សចាស់ចាំបាច់ត្រូវរកពេលវេលាឱ្យសមស្របទើបបាន ៕

*ថ្ងៃទី ២១.១០.០៦*

❀❀❀❀

**ចម្ងល់** ចំពោះវចនានុក្រមខ្មែរ

☞ **សណ្តាប់** : សរសេរបាន ហេតុអ្វី **សណ្តាន** សរសេរមិនបាន ?

☞ **តាទៅ** : គ្មាន "ធ្មេញកណ្តុរ"ទេ ហេតុអ្វី "តរ៉ៅ" មាន ?

☞ **វត្តអារាម**: គ្មាន "ធ្មេញកណ្តុរ"ទេ ហេតុអ្វី "ចចាមអារ៉ាម" មាន ?

☞ **ទុកដាក់** :កិ. លុះទៅជាគុ. ម្តេចមានជើង"ខ"ពីណាមក ? ប្រទុក្ខប្រដាក់

# ២៤២. បើគេបបួលកុំឱ្យខាន បើគេបានកុំឱ្យសុំ

**និយមន័យ**

កំចាត់បង់នូវភាពខ្ជិលច្រអូស

**អត្ថាធិប្បាយ**

នេះគឺជាការអប់រំមួយ ដើម្បីកំចាត់បង់នូវកំជិលរបស់មនុស្សខ្លះដែលស្ពឹកស្រពន់មិនចង់ចេញទៅរកស៊ីចាំតែសុំគេ ។

**□ បើគេបបួលកុំឱ្យខាន**

ក្នុងន័យនេះ លោកចង់ទូន្មានថា បើមានគេមកបបួលចេញទៅរកស៊ី, ចេញទៅនេសាទ, ចេញទៅប្រមាញ់ ។ល ។ លោកថាត្រូវតែទៅប្រកបការងារជាមួយគេ កុំនៅខ្ជិលច្រអូស រឺនៅដើរស៊ីផឹកសប្បាយមិនគិតដល់ជីវភាពខ្លួន ។ ម្យ៉ាងទៀតការដែលគេមកបបួលទៅរកស៊ីនេះ ចាត់ទុកជាភក្តីមេត្រីភាពខ្ពស់ណាស់ ត្រូវតែទៅកុំឱ្យខាន... ។ តែអោយស្របច្បាប់ផង ។

**□ បើគេបានកុំឱ្យសុំ**

ដើម្បីចៀសវាងភាពអាម៉ាស់មុខ ពេលដែលគេបបួលមិនទៅ លោកប្រាប់ថាបើឃើញគេទៅរកបាន រឺរកស៊ីបានផលចំនេញ កុំទៅសុំគេឱ្យសោះ ។ ព្រោះការសុំគេនេះជាការបង្ហាញនូវភាពកំសោយ និងគួរឱ្យខ្មាស់អៀនជាទីបំផុត ។ ម្យ៉ាងទៀតនាំឱ្យគេមើលងាយ មើលថោកទៀតផង ៕

*ថ្ងៃទី ២១-១០-០៦*

❀❀❀❀

# ២៤៣. ប្រពន្ធរកបានឆាប់ ឆាប់មានសហាយ ប្រាក់រកបានងាយ ងាយចាយឆាប់អស់

**និយមន័យ**

អ្វីដែលចូលមកដោយធូរ ចេញទៅវិញក៏ធូរដែរ

**អត្ថាធិប្បាយ**

**ក. ប្រពន្ធរកបានឆាប់ៗមានសហាយ**

មនុស្សស្រីណា ដែលប្រុសទៅលួងលោមយកមកធ្វើជាប្រពន្ធបានដោយងាយពេក, ឆាប់ពេក និងរហ័សពេក ច្រើនតែជាស្ត្រីដែលពុំសូវមានគំនិតចេះគិតឱ្យបានម៉ត់ចត់ និងពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយទេ គឺឱ្យតែមានគេមកនិយាយផ្អែមល្ហែមលួងលោមតែបន្តិច ក៏ទោរទន់បាក់ចិត្តស្រលាញ់គេភ្លាម, វេចបង្វេចទៅតាមគេភ្លាមគ្មានសួរពិគ្រោះយោបល់នឹងញាតិមិត្តណាម្នាក់ឡើយ ។

ដូច្នេះស្រីប្រភេទងាយនេះ លោកថាដល់ពេលចេញទៅវិញក៏ឆាប់ដូចគ្នានឹងពេលចូលមកដែរ ។ លោកប្រៀបប្រដូចរឿងនេះទៅនឹងដើមឈើដែលដុះងាយដុះរហ័ស ដល់ពេលងាប់ក៏ឆាប់ ក៏រហ័សដូចគ្នា ដូចជា : ដើមជី, ម្ទេស, ប៉េងប៉ោះ ។ល ។

**ខ. ប្រាក់រកបានងាយៗចាយឆាប់អស់**

ខ្លឹមសារនេះ ក៏មានន័យដូចខាងលើដែរ ព្រោះប្រាក់ដែលរកបានមកងាយៗ

ដល់ពេលចាយទៅវិញក៏ងាយៗដែរ ដោយគេពុំសូវបានគិតគូរឱ្យបានម៉ត់ចត់ទេ ។ ព្រោះគេយល់ថា ប្រាក់បានមកដោយមិនបែកញើស ដូចជា ប្រាក់ឈ្នះល្បែង. រើសបានរឺត្រូវឆ្នោតជាដើម ។

ដូច្នេះអ្វីៗដែលចូលមកដោយឆាប់រហ័សនឹងងាយពេក លុះដល់ពេលចេញទៅវិញ ក៏ឆាប់រហ័ស និងងាយពេកដូចគ្នាដែរ ៕

*ថ្ងៃទី ១៤.០៥.០៩*

❀❀❀❀

| | | |
|---|---|---|
| ពាក្យគ្រូរែងរឹង | ស្រាវែងស្រវឹង | ពុំដែលពិសា |
| ពាក្យពិតរែងស្លែង | ពុំពិរោះថា | បណ្ឌិតមេធា |
| | រែងថាពុំគាប់ ។ | |

*ព្រះរាជសម្ភារ*

# ២៤៤. បើចាញ់បានលុយ បើឈ្នះបានដី

**និយមន័យ**

ការតវ៉ា ដើម្បីការពារផលប្រយោជន៍

**អត្ថាធិប្បាយ**

នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ ២០០០ គេតែងជួបប្រទះភាពចំរូងចំរាស់រវាង ភាគីរដ្ឋ, ពួកវិនិយោគិន, ឧកញ៉ា និងពួកអ្នកមានលុយច្រើន ជាមួយនឹងប្រជារាស្ត្រ ។

ភាពចំរូងចំរាស់នេះកើតឡើងដោយពួកមហាសេដ្ឋី និងពួកលោភលន់ដែលមានលុយច្រើនសន្ធឹកសន្ធាប់មកទិញដីរាប់ពាន់ហិចតាក្រោមផ្លាកអភិវឌ្ឍន៍ ។ ដូចជា :

វិនិយោគិនម្នាក់ចង់ទិញដី ដើម្បីដាំកាហ្វេ, ដាំកៅស៊ូ ។ល ។ ក៏ឃុបឃិតជាមួយអាជ្ញាធរពុករលួយ ។ ដោយមហិច្ឆតាលោភលន់ អាជ្ញាធរនោះក៏ទៅវាស់ដីយក រឺធ្វើប្លង់ជាន់គ្នាទៅលើដីរបស់ប្រជាពលរដ្ឋ ។ ជួនកាល ដីមួយដុំមានប្លង់ពីរ-បី ។

កាលបើបញ្ហាកើតឡើងចំលើផលប្រយោជន៍របស់ខ្លួន ប្រជារាស្ត្រនាំគ្នាក្រោកឡើងតវ៉ា ។

- បើតវ៉ាទៅហើយចាញ់ អ្នកមានលុយ រឺមានអំនាចគេឱ្យលុយខ្លះ ទោះបីសមស្របក្តី មិនសមស្របក្តី ។
- បើតវ៉ាទៅបានឈ្នះ គេអាចនៅគ្រប់គ្រងនូវដីកម្មសិទ្ធិបន្តទៅទៀត ។

ប៉ុន្តែ បើមិនតវ៉ាសោះ ប្រាកដជាស្លាប់អត់អំបិលប្រលាក់ហើយ ។ ម្យ៉ាងទៀត នៅក្នុងន័យនេះដដែលនេះ ក៏មានជនកំហិលខ្លះដើរតែចាប់ដីយ៉ាងអនាធិបតេយ្យ ដោយឥតគិតថាដីនោះជារបស់លោកអ្នកណាទេ ។

លុះដល់ម្ចាស់គេដេញចេញ ក៏នាំគ្នាធ្វើបាតុកម្មតវ៉ាយ៉ាងគគ្រឹកគគ្រេងឡើង ។ ជួនកាលម្ចាស់ដីជាអ្នកមានធំ គេខ្ជិលរឿងរ៉ាវវែងឆ្ងាយ គេឱ្យលុយខ្លះដើម្បីឱ្យដើរចេញទៅ ។ ជួនកាលទៀតប៉ះលើអ្នកចិត្តបុណ្យទាល់ច្រក ក៏សុខចិត្តកាត់ដីចែកឱ្យម្នាក់មួយដុំទៅ ។

ត្រង់នេះហើយ ដែលគេពោលថា **បើចាញ់បានលុយ បើឈ្នះបានដី** ។

*ថ្ងៃទី ១៤.០៤.០៧*

ចូលឆ្នាំកុរ នព្វស័ក ១២ : ៤០ នាទី

❀❀❀❀

| | |
|---|---|
| មើលមេឃធំធេងវែងរលីក | មើលទឹករលករលាមសាយ |
| មើលដី-ដីដុះវែងអន្លាយ | មើលស្រីឃ្លាតឆ្ងាយពីទ្រូងបង ។ |

# ២៤៥. ប្រុសពេញដី ស្រីពេញនគរ

**និយមន័យ**

សំដីសំរាប់កាត់បន្ថយអារម្មណ៍ទាល់ច្រកក្នុងរឿងស្នេហា

**អត្ថាធិប្បាយ**

ពាក្យទំនឹមទំនៀមនេះ លោកលើកឡើងពោលចំពោះអ្នកទាល់ច្រកក្នុងរឿងស្នេហា។ ក្នុងរឿងស្នេហា បើមិនទាន់មានវិបត្តិផ្លូវចិត្តទេ គេមិនដែលនឹកឃើញពាក្យនេះសោះឡើយ គឺគេនឹកឃើញតែពាក្យម្យ៉ាងថា"**ស្នេហាស្មោះស្ម័គ្រមួយទល់ នឹងមួយ**" ។

ប៉ុន្តែ ចំពោះស្នេហាមានវិបត្តិដូចជា : តួអង្គប្រុសបែកចិត្តចោល តួអង្គស្រីមានអារម្មណ៍ក្តុកក្តួលក្នុងចិត្តជាខ្លាំង ។ ដូច្នេះ ដើម្បីកាត់បន្ថយភាពតានតឹងក្នុងផ្លូវចិត្ត តួអង្គស្រីតែងពោលថា : *មិនថ្វីទេអ្នកឯងចង់ទៅងាប់តាយហោង ឯណាក៏ទៅចុះ អញក៏មិនខ្វីកើតទុក្ខនាំឱ្យមុខជ្រួញទាំពិបាកលាបឡេទេ ម៉ាអាប្រុសពេញដី រឺថាប្រុសកៀវនឹងជើង ។*

ការណ៍ដែលពោលយ៉ាងហ្នឹង មកពីមានកំហឹងខ្លាំងពេក ។ ផ្ទុយទៅវិញបើក្នុងរឿងនេះតួអង្គស្រីបែកចិត្ត ព្រាត់ប្រាស់ចោលគូស្នេហ៍ប្រុសវិញនោះ អ្នកប្រុសអភព្វនេះក៏ពោលពាក្យទាំងកំហឹងថា : *មិនអីទេបើវាប្រញាប់ ទៅស្លូឈាមឯណា ក៏តាមចិត្តចើកវាចុះ អញក៏មិនខ្វះប្រពន្ធដែរ ម៉ាអាស្រីពេញនគរនោះ !* ។

រឿងរ៉ាវវិបត្តិស្នេហ៍អប្រិយនេះហើយ ដែលបណ្តាលឱ្យកើតពាក្យដូចខាងលើនេះឡើង ៕

*ថ្ងៃទី ១៥.០៥.០៩*

# ២៤៦. ប្រពន្ធដើមដូចស្រូវជន្លក ប្រពន្ធចុងកំប៉ិកកំប៉ុកដូចអន្ករកំប៉ុង

**និយមន័យ**

បំរៀបធៀបតំលៃប្រពន្ធដើម និងប្រពន្ធចុង

**អត្ថាធិប្បាយ**

នេះជាពាក្យពំនោលរបស់អ្នកលេងសំដី ដើម្បីបង្កើតបរិយាកាសសើចលេងឱ្យបានសប្បាយរីករាយផង និងសំរាប់ដោះស្រាយការពារទំរើរបស់ខ្លួន កុំឱ្យគេបង្អាប់ខ្លាំងពេកផងដូចជា :

-បុរសសំបូរស្នេហ៍ម្នាក់មានប្រពន្ធរួចហើយ ស្រាប់តែទៅនាយអាយនឹងនាងខារ៉ាអូខេម្នាក់ដែលមានរូបស្រស់ត្រកាល ។ ដំបូងគេគិតថា នេះគ្រាន់តែជាការណ៍មួយកែអផ្សុកទេ ។ ប៉ុន្តែយូរបន្តិចទៅ គេកាន់តែយល់ចិត្តគ្នា ភាពជិតស្និទ្ធជិតអារម្មណ៍កាន់តែខ្លាំង ដកលែងរួច ។ ពេលនោះមានមិត្តស្និទ្ធស្នាលម្នាក់សួរថា :

- ឯងលែងប្រពន្ធដើមរួចរាល់ហើយឬនៅ ?

- ទេ! បដិវត្តន៍គេធ្វើពីតិចទៅច្រើន រឿងលែងគ្មានមានតែយកថែម ។

- អូហ៍ ឯងធ្វើដូច្នេះ មិនខ្លាចខុសនឹងច្បាប់ទេឬ ?

- មានរឿងអីត្រូវខុស គេថាបង្កបង្កើនផលគឺស្នេហាជាតិ យកប្រពន្ធមួយ

ថែមទៀតគឺស្នេហាប្រជាជន ។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏គេនៅតែឱ្យតំលៃប្រពន្ធដើមដែលធ្លាប់កំសត់កម្រយូរមកហើយថា ប្រពន្ធដើមគឺជាស្រូវជង្រុក និងជាកន្លែងសិន្និធិស្តុកភ័ស្តុភារប្រចាំគ្រួសារ ឯប្រពន្ធចុងប្រៀបបានត្រឹមតែអង្ករកំប៉ុង រឺថាដូចកាហ្វេ. គុយទាវ. បង្អែមប៉ុណ្ណោះ ៕

*ថ្ងៃទី ១៦.០៥.០៩*

✿✿✿✿

# ២៤៧. បញ្ឆោតឱ្យខ្លាចេញពីព្រៃ

**និយមន័យ**

កលល្បិចបោកប្រាស់ឱ្យបច្ចាមិត្រភ្លាត់ស្មារតី

## អត្ថាធិប្បាយ

➢ **អត្ថានុរូប**

ព្រានព្រៃវៃឆ្លាតម្នាក់ បានដឹងថានៅក្នុងព្រៃស្កុកនោះ មានសត្វខ្លាមួយក្បាល ។ តែគេមិនហ៊ានចូលទៅជិតព្រៃនោះទេ ។ ព្រោះគេក៏មិនប្រាកដថា ខ្លានោះនៅត្រង់ម្តុំណា ។ ដូច្នេះគេក៏ព្រលែងឆ្កែប្រមាញ់ពីរ-បីក្បាលឱ្យដើរជិតៗព្រៃនោះ ។ ខ្លាឃើញដូច្នោះក៏ដើរចេញលបៗដើម្បីចាប់ឆ្កែ ។ ប៉ុន្តែ ក៏ត្រូវព្រានបាញ់ប្រហារងាប់ភ្លាម ។

➢ **អត្ថប្បដិរូប**

អ្នកនយោបាយ គឺជាអ្នកបោកប្រាស់ ។ អ្នកណាបោកប្រាស់បានសមជាងគេ ។ គេថាអ្នកនោះពូកែធ្វើនយោបាយ ។ ធម្មតាអ្នកនយោបាយតែងមានល្បិចកាច់កុងគ្នា ។ អ្នកខ្លះអួតថា ខ្លួនពូកែកំពូលគ្មានអ្នកណាស្មើ ឯគេសុទ្ធតែនៅស្ទើរណាស់មិនច្បាស់ដូចខ្លួនឡើយ ។

ប៉ុន្តែការណ៍ពិត មិនមែនពូកែនៅត្រង់អំនួតថាខ្លួនឯងកំពូល ឯគេសុទ្ធតែកំពោតនោះទេ វាស្រេចតែនៅលើគេមានល្បិច ។ ដូចជាអ្នកប្រដាល់ខ្លះ ជន្លឆ្វេង-វៃស្តាំ.

ជន្លដៃ វៃជើង រឺស៊ីញ៉ូស្តាំ បត់ឆ្វេងក៏មាន ។ ជាញយដង គេតែងឃើញអ្នកពូកែអួត ក្លាយជាអ្នកពូកែអន់ ។ ក្នុងន័យនេះដែរ គេឃើញអ្នកនយោបាយជើងចាស់ ច្រើននៅស្ងៀមស្ងាត់ រង់ចាំឱកាសល្អហុចឱ្យ គេវាយប្រហារតែមួយដៃគឺចំគោលដៅតែម្តង ។ អ្នកនយោបាយខ្លះ គ្រាន់តែគេជន្លលេងបន្តិច ស្រាប់តែលោតរបូតខោធ្វើឱ្យគេទះដៃសើចលាន់ ។ ព្រោះអ្វីដែលគេចង់បាន គឺបានហើយនៅពេលនេះ ។

បំរៀបធៀបម្យ៉ាងទៀតថា អ្នកលេងល្បែងអុក រឺអ្នកលេងរែកដំរៃឆ្លាត គេដាក់កូនអុកឱ្យគេស៊ីធ្វើបែបុភ្លើ ។ប៉ុន្តែការណ៍ពិតគេសម្លឹងឃើញក្រលាស៊ីអាធំរួចទៅហើយ ។ គេបញ្ឆោតចុះ បញ្ឆោតឡើង ភាគីអួតភ្លាត់ស្មៀតដួលអុកក្តិតទាំងមិនដឹងខ្លួន ។

ហេតុនេះហើយ បានជាគេថា " អ្នកនយោបាយ គឺជាអ្នកបោកប្រាស់ " បើមិនចេះបោកប្រាស់ទេ គួរកុំធ្វើនយោបាយអី ។ អ្នកអួត និងអ្នកជោរ ឃើញតែចាញ់ល្បិចគេ ៕

*ថ្ងៃទី ១៨.០៩.០៩*

✿✿✿✿

| |
|---|
| **នត្ថិ សន្តិ បរំ សុខំ** ៈ គ្មានក្តីសុខណាស្មើក្តីស្ងប់ *ព្រះពុទ្ធ* |

# ២៤៨. ត្រាជ្ញាបុណ្យផងកើតដោយប្រណិប័តន៍

**និយមន័យ**

បុណ្យសក្តិ ចំនេះវិជ្ជា កើតឡើងដោយការចេះគោរពគ្រូ

**អត្ថាធិប្បាយ**

សឹងតែក្លាយជាប្រពៃណីរបស់ខ្មែរទៅហើយ កាលពីសម័យដើម បើមានសិស្សណាចង់ចូលទៅស្វែងចំនេះ វិជ្ជាអ្វីមួយដូចជា : សិល្បសាស្ត្រ, វិជ្ជាការ, មន្តអាគមអូមអាម រឹក្បាច់ប្រយុទ្ធ និងក្បាច់គុនប្រដាល់ផ្សេងៗ ។

គ្រូតែងសង្កេតមើលសិស្សណាយកចិត្តទុកដាក់ និងគោរពប្រណិប័តន៍គ្រូដូចជា បំរើទឹកក្តៅទឹកត្រជាក់ដល់គ្រូៗតែងមានមនោសញ្ចេតនាជិតអារម្មណ៍នឹងសិស្សនោះខ្លាំងជាងគេ ។ ដូចនេះ គ្រូតែងយកចិត្តទុកដាក់ក្នុងការបង្រៀនដល់សិស្សនោះច្រើនជាងគេដែរ ។ មិនតែប៉ុណ្ណោះគ្រូបានតំលើងឋានៈសិស្សនោះឱ្យទៅជាសិស្សរៀមច្បងជួយបង្រៀនសិស្សក្រោយៗទៀតផង ។ ពិសេសទៅទៀត ប្រសិនបើគ្រូមានកូនក្រមុំ ជួនកាលគាត់ក៏រៀបផ្សំផ្គុំឱ្យបានជាគ្រួសារទៀតផង ។

នេះហើយដែលជាអត្ថរសរបស់ន័យខាងលើនេះ ។

លុះដល់សម័យក្រោយៗមក ការសិក្សាដូចកាលនោះប្រែក្លាយមកជាការសិក្សាអក្សរសិល្ប៍, វិទ្យាសាស្ត្រ ។ល ។ វិញក៏ដោយ ក៏អត្ថរសនៃពាក្យខាងលើនេះនៅតែមានតំលៃដដែល ៕

*ថ្ងៃទី ២១.១០.០៦*

# ២៤៩. ប៉ោតទទេលឺសូរខ្លាំង

**និយមន័យ**

មនុស្សអវិជ្ជាតែងមានអំនួតខ្លាំង

**អត្ថាធិប្បាយ**

ស្របនឹងពំនោលខាងលើនេះ មានពាក្យពីរផ្សេងគ្នាគឺ សំបើមដូចសំបកប៉ោត និងដូចទឹកកន្លះក្អម ប៉ុន្តែ មានន័យ និងខ្លឹមសារតែមួយ ។

- **អត្ថានុរូប**

សំបកប៉ោតក្តី ទឹកកន្លះក្អមក្តី រមែងតែងមានសូរខ្លាំងជាងប៉ោត រឺក្អម ដែលមានទឹកពេញ ។ ព្រោះសំបកប៉ោតជាតិដែកស្តើង បើគេគោះវាៗឮសូរម៉ាងៗ ។ ឯក្អមជាតិដីគោះមិនឮសូរទេ តែបើមានទឹកកន្លះវិញ កាលណាគេញ៉ឹងយួរទៅទឹកនោះក្រឡកលឺសូរក្លុកក្លាក់ៗ ឯក្អមមានទឹកពេញមិនលឺសូរទេ ។

- **អត្ថប្បដិរូប**

មនុស្សអវិជ្ជាមួយចំនួន លោកប្រៀបដូចសំបកប៉ោត រឺទឹកកន្លះក្អម ។ ព្រោះមនុស្សជំពូកនេះ ពូកែខាងអួតក្អេងក្អាងសំបើមណាស់ ហានិយាយឡើងកាលណា សុទ្ធតែអួតថាខ្លួនធ្លាប់មានបទពិសោធន៍ក្នុងការងារគ្មានខ្វះចន្លោះ និងគ្មានអ្នកណាស្មើ ។ ដូចជា :

- ពេទ្យខ្មែរក្រហមតែងអួតថា ដុកទ័រចក្រព័ត្ររៀនដល់ស្រុកបារាំងរាប់

ឆ្នាំទើបចេះចាក់ថ្នាំ ចំនែកអញរៀនក្រោមដើមឈើតែមួយអាទិត្យចេះចាក់ថ្នាំដូចគ្នា។

- ពួកអវិជ្ជាខ្លះអួតថា អញមិនចេះអក្សរទេ តែចេះដឹកនាំអ្នកចេះអក្សរឱ្យធ្វើស្រែបាន ។

- អ្នកខ្លះអួតថា អញល្ងង់មែនពិត តែចេះដឹកនាំ ។

ការអួតក្អេងក្អាងដូចខាងលើនេះហើយ ដែលលោកថា *សំបើមដូចសំបកប៉ោត រឺដូចទឹកកន្លះក្អម* ។

*ថ្ងៃទី ២១-១០-០៦*

| | | |
|---|---|---|
| ចង់បុណ្យបានបាប | ចចើងចង់លាភ | វែងបាត់ធនទៅ |
| មានះបាត់មិត្រ | ឥតអ្នកជាផៅ | ក្រេវក្រោធឃោរឃៅ |
| | រមែងបាត់អង្គ ។ | |

*ព្រះរាជសម្ភារ*

# ២៥០. ផ្លែឈើជ្រុះមិនឆ្ងាយពីគល់

**និយមន័យ**

ឪពុកម្ដាយយ៉ាងណា កូនយ៉ាងនោះ

## អត្ថាធិប្បាយ

### ➢ អត្ថានុរូប

ដើមឈើណាក៏ដូចដើមឈើណាដែរ កាលណាមានផ្លែទុំ ផ្លែនោះតែងជ្រុះក្បែរៗគល់ ទោះផ្លែនោះតូចក៏ដោយធំក៏ដោយ ។ ប៉ុន្តែ នៅមានផ្លែមួយចំនួនតូចអាចជ្រុះឆ្ងាយពីគល់ដែរ ដូចជា ផ្លែត្រាច, ផ្លែគគី ។ ផ្លែពួកនេះ មានស្លាបកង្ហារវិលទៅតាមចរន្តខ្យល់ខ្លាំង រឺខ្សោយ វាអាចជ្រុះនៅជិត រឺឆ្ងាយបាន ។ មានផ្លែមួយចំនួនទៀតអាចជ្រុះទៅឆ្ងាយៗបាន ដោយសារសត្វជ្រើងពាំយកទៅស៊ី រួចក៏ជុះគ្រាប់ខ្លះវាក៏ដុះឡើង ដូចជា ផ្លែពោធិ, ផ្លែក្រខុប, ផ្លែមៀន, ផ្លែត្របែក និងផ្លែល្មុតជាដើម ។

### ➢ អត្ថប្បដិរូប

ឪពុកម្ដាយលោកឧបមាដូចដើមឈើមួយដើម ។ បើឪពុកម្ដាយមានលក្ខណៈយ៉ាងម្ដេចម្ដា កូនភាគច្រើនតែងមានបុគ្គលិកលក្ខណៈដូចឪពុកម្ដាយដែរ ។ ព្រោះកូនកើតឡើងតែងតែឃើញគ្រប់សកម្មភាពរបស់ឪពុកម្ដាយគ្រប់ដង្ហើមចេញចូលតាំង ពី

តូចរហូតដល់ធំ ។ ម្ល៉ោះហើយកូនតែងមានអារម្មណ៍ជិតជាប់ធ្វើត្រាប់តាម ព្រោះស្មារតី ក្មេងប្រៀបបាននឹងក្រដាស "ស" មួយសន្លឹក ។ បើផាត់ពណ៌អ្វី វានឹងជិតជាប់ច្បាស់ល្អណាស់ ។ ដូចជា ឪពុកធ្វើ មន្ត្រី កូនក៏ធ្វើមន្ត្រីដែរ (ដោយឪពុកផ្គុំផ្តើម), ឪពុកធ្វើជាង កូនធ្វើជាង, ឪពុកធ្វើកសិកម្ម កូនធ្វើកសិកម្ម, ឪពុក ធ្វើចោរ កូនធ្វើចោរ ។ល ។

ករណីបែបនេះហើយដែលលោកថា **ផ្លែឈើជ្រុះមិនឆ្ងាយពីគល់** ។ ប៉ុន្តែនៅមានករណីមួយទៀតដែលមានគំលាតឆ្ងាយពីគល់ដែរ ដែលលោកប្រៀបដូចសត្វជ្រើងពាំគ្រាប់ពូជទៅឆ្ងាយពីគល់ដូចជា ៈ ឪពុកធ្វើចោរ កូនធ្វើប៉ូលិសចាប់ចោរ, ឪពុកធ្វើអាចារ្យ កូនធ្វើអាចោរ ។ ឪពុកអវិជ្ជា កូនជាមន្ត្រីបណ្ឌិតច្បាប់, ជាវិស្វករ ។ល ។

ករណីនេះ លោកប្រៀបដូចសត្វជ្រើងពាំទៅឆ្ងាយពីគល់ គឺការសេពគប់ដឹកនាំទៅរកផ្លូវល្អ ៕

*ថ្ងៃទី ២២.១០.០៦*

❀❀❀❀

# ២៥១. ផ្គរលាន់មិនដែលភ្លៀង

## និយមន័យ

ពាក្យសំដី រឺដំនឹងដែលឮមុន ច្រើនឥតបានការ

## អត្ថាធិប្បាយ

➢ **អត្ថានុរូប**

ផ្គរលាន់គឺជាបាតុភូតធម្មជាតិ ដែលគេតែងតែឮឡើងនៅពេលមុនភ្លៀង ។ ប៉ុន្តែ ជួនកាលគេតែងសង្កេត និងចំនាំឃើញថា បើកាលណាមិនទាន់មានភ្លៀង ស្រាប់តែឮមានស្នូរផ្គរលាន់ លោកថា ឥតមានភ្លៀងទេ ។

➢ **អត្ថប្បដិរូប**

ផ្គរលាន់ លោកប្រៀបដូចពាក្យគេនិយាយ រឺដំនឹងដែលឮស្នូរមកថា បន្តិចទៀតគេយកអំនោយមកចែក, គេមកជីកអណ្តូង, មកសង់សាលារៀន, មកធ្វើផ្លូវ, មកធ្វើស្ពាន ។ ជាពិសេសគេយកពូជស្រូវមកចែកឱ្យ ។

ដំនឹងទាំងអស់នេះ ច្រើនតែឮស្នូរដូចផ្គរលាន់ដែរ ។ តែការណ៍ពិត មិនឃើញមានអ្វីលេចចេញជារូបរាងសោះ ។

*ថ្ងៃទី ២២.១០.០៦*

❀❀❀❀

# ២៥២. ផ្ទះក្បឿងផ្ទះស្បូវ រលត់ភ្លើងទៅឯទីតដូចគ្នា

**និយមន័យ**

អ្នកមាន និងអ្នកក្រ នៅឯចុងចប់គឺដូចគ្នា

**អត្ថាធិប្បាយ**

បំរៀបធៀបនេះ លោកពោលសំដៅដល់អ្នកមាន និងអ្នកក្រដែលមានសភាពផ្ទុយគ្នាស្រឡះ ។ ព្រោះអ្នកមាន មានទ្រព្យសម្បត្តិមហាសាលមានប្រាក់កាសចាយ មិនអស់ មានភូមិគ្រឹះគ្រប់ទីកន្លែង, មានដីរាប់ពាន់ហិចតា មានឡានគ្រប់ប្រភេទ, មានឡានគ្រប់ប្រពន្ធ-កូន, របស់ប្រើប្រាស់សុទ្ធតែទំនើប នេះមិននិយាយដល់មាស-ពេជ្រ កែវ-កងពិទូរ្យសូរ្យកាន្តផងទេ ។

ចំណែកអ្នកក្រ គឺក្ររកអង្ករច្រកឆ្នាំងគ្មាន កុំនិយាយឡើយដល់ទៅរបស់ប្រើ ប្រាស់, ផ្ទះសំបែង, ដីធ្លី ។ល ។

ក្នុងន័យដដែលនេះ លោកធ្វើការប្រៀបធៀបទៅដល់អ្នកដែលមានបុណ្យ សក្តិ ខ្ពស់, មានអំនាចទើសមេឃ និងអ្នកដែលមានឋានៈតូចតាចអំនាចក៏គ្មានផងដែរ ។

ភូមិត្រឹះក្តី ខ្ទមកំព្រូកក្តី ពេលដែលរលត់ភ្លើងទៅគឺងងឹតសូន្យឈឹងដូចគ្នា ។ ន័យនេះលោកចង់ប្រៀបថា មហាសេដ្ឋីក្តី អ្នកក្ររហេមរហាមក្តី ពេលដែលរលត់ភ្លើង ធាតុទៅ មួយណាក៏ស្អុយគគ្រុកដូចគ្នា, ដង្កូវចុះដូចគ្នា បើយកទៅកប់ក្នុងដីជន្លេនរុក ដូចគ្នា ៕

*ថ្ងៃទី ២២.១០.០៦*



# ២៥៣. ផ្លែឈើច្រើន ច្រើនចាញ់ស្លឹក

**និយមន័យ**

មានទ្រព្យច្រើន ព្រួយនឹងរក្សា

## អត្ថាធិប្បាយ

➤ **អត្ថានុរូប**

គេតែងសំគាល់ឃើញថា ដើមឈើណាដែលមានផ្លែច្រើនដូចជា ដើមស្វាយជាដើម ។ គេឃើញស្លឹកវាដាច់ដោចជ្រុះរាយប៉ាយពាសពេញដី ។ ពីព្រោះមនុស្សត្រូវការផ្លែ ម្ល៉ោះហើយគេយកទំពក់ថ្កក់មួលយកផ្លែដោយទាំងស្លឹកមកជាមួយផង. អ្នកខ្លះគប់នឹងដំបងបណ្តាច់យកផ្លែ ក៏រឹតតែធ្វើឱ្យស្លឹកដាច់រប៉ាត់រប៉ាយច្រើនទៀត ។

➤ **អត្ថប្បដិរូប**

**ផ្លែឈើច្រើន**លោកប្រៀបដូចអ្នកមានទ្រព្យសម្បត្តិច្រើន ឯស្លឹកលោកប្រៀបដូចមនុស្សអ្នកថែរក្សាការពារ គឺជាម្ចាស់របស់ទ្រព្យ ។ ព្រោះស្លឹកក៏ជាអ្នកជួយផ្តល់សារធាតុចិញ្ចឹមផ្លែដូចមនុស្សជាអ្នករក និងគ្រប់គ្រងរបស់ទ្រព្យដូចគ្នាដែរ ។ ជាការធម្មតា អ្នកដែលខំរកទ្រព្យសម្បត្តិបានមក តោងជាអ្នកការពារថែរក្សាទ្រព្យសម្បត្តិនោះ ។ ដូចនេះអ្នកការពារ និងថែរក្សារមែងទុក្ខព្រួយកង្វល់ដេកមិនលក់បក់មិនល្ហើយព្រោះតែទ្រព្យសម្បត្តិច្រើនពេក ដូចជាមានដីច្រើនពេក ព្រួយបារម្ភខ្លាចគេយកដី. មានលុយច្រើនពេក ភ័យខ្លាចចោរប្លន់ ចោរចាប់ជំរិត.....

ការព្រួយកង្វល់នេះហើយ ដែលលោកចាត់ទុកដូចជាចាញ់ទ្រព្យដូចផ្លែឈើច្រើនស្លឹកចាញ់អន្តរាយដូច្នោះដែរ ៕

*ថ្ងៃទី ២២.១០.០៦*

# ២៥៤. ផ្លូវវៀចកុំបោះបង់ ផ្លូវណាត្រង់កុំដើរហោង

**និយមន័យ**

ក្នុងផ្លូវពាណិជ្ជកម្ម កុំដើរផ្លូវត្រង់

## អត្ថាធិប្បាយ

ន័យនិងខ្លឹមសារខាងលើនេះ ដកស្រង់ចេញពីច្បាប់កេរ្តិ៍កាល ស្តីពីសេដ្ឋីផ្តាំកូនឱ្យចេះរកស៊ី និងសាងអំពើសុចរិត ដូចមានពាក្យផ្តើមបទថា *"កេរ្តិ៍កាលពីព្រេងព្រឹទ្ធ សាងសុចរិតទ្បេងទុកនៅ សេដ្ឋីផ្តាំប្រដៅ បុត្រសង្សារទុក ក្រោយហោង..."* ។

ក្នុងន័យនេះ បញ្ជាក់ឱ្យឃើញថា លោកផ្តាំឱ្យប្រព្រឹត្តតែសេចក្តីល្អទ្បេងត្រង់ជានិច្ច គឺលោកហាមមិនឱ្យកេងប្រវ័ញ្ចគេ ដូចជា បន្លំភ្នែកជញ្ជីង មួយគីឡូនៅសល់តែប្រាំបីខាំ, បន្លំរបស់ខូចគុណភាពដោយបិទផ្លាកថ្មី, បើវាល់អង្ករលក់ កុំលួចកាត់មាត់កំប៉ុង រឺបុកគូទកំប៉ុងឱ្យប៉ោងឡើង និងដាក់បាតកំប៉ុងពីរជាន់ជាដើម ។

មានឃ្លាមួយទៀតលោកពោលថា **"ផ្លូវវៀចកុំបោះបង់ ផ្លូវណាត្រង់កុំដើរហោង ដើរដោយផ្លូវគន្លង តម្រាយអ្នកចាស់បុរាណ"** ។

ក្នុងន័យនេះ លោកប្រាប់ថា ផ្លូវវៀចកុំបោះបង់ ដូចជារបស់ទិញចូលតំលៃ ៥០០រៀល ដល់លក់ចេញវិញ ត្រូវលក់លើសតំលៃទិញចូល ។ នេះហើយដែលលោកថា ផ្លូវវៀចកុំបោះបង់ ។ ព្រោះថា ក្នុងការរកស៊ីលក់ដូរ ត្រូវតែមានកំរៃខ្លះ ។ នេះគឺជា

ក្រិត្យក្រមរបស់អ្នករកស៊ីលក់ដូរ ។

តាមន័យនេះដែរ អ្នកស្មាទានសីលក៏អាចរកស៊ីលក់ដូរបានដូចគ្នា គ្រាន់តែកុំនិយាយកុហកគេ មិនមានប៉ះពាល់ដល់សិក្ខាបទទី ៤ ទេ។ ទោះបីគេនិយាយថា តំលៃលក់ចេញថ្លៃជាងតំលៃទិញចូលបន្តិចក៏ដោយ គឺគេនិយាយត្រង់ៗ ។

មា្យ៉ាងទៀត បើតំលៃដើម ៥០០រៀល លក់ចេញតំលៃ ៥២០រៀល រួចប្រាប់គេថាលក់ថ្លៃដើមជូន... ក៏នៅ តែមិនប៉ះពាល់ដល់សិក្ខាបទទី ៤ដែរ ។ ព្រោះកំរៃ ២០រៀលគិតទាំងថ្លៃពន្ធ, ថ្លៃដឹកនាំ, តំលៃពលកម្ម និងកំរៃដែលអ្នករកស៊ីត្រូវបានខ្លះ ៕

*ថ្ងៃទី ២៣.១០.០៦*

❁❁❁❁

| |
|---|
| **លតាវល្លិ៍** ៈតូច និងទន់ភ្លន់ អាចឡើងខ្ពស់បាន អាស្រ័យវារតោងដើមឈើធំ<br>*លី ថៃលី* |

# ២៥៥. ផ្លូវវែង មាត់វែងជាងផ្លូវ

**និយមន័យ**

ការនិយាយបន្តគ្នា គ្មានទីបញ្ចប់

**អត្ថាធិប្បាយ**

លោកថា ផ្លូវមានប្រវែងវែងឆ្ងាយណាស់ ព្រោះផ្លូវនោះទោះនៅចុងកាត់មាត់ញកណាក៏ដោយ ក៏ជាបណ្តាញជាប់គ្នាពីមួយទៅមួយទាំងអស់ ។

ប៉ុន្តែ ទោះបីជាផ្លូវមានប្រវែងដល់ណាក៏ដោយក៏នៅតែមានព្រំដែន។ ឯសំដីមនុស្សគ្មានព្រំដែនទេ ។ ដូច្នេះ ការនិយាយស្តីដែលគ្មានគិតគូរដល់ក្រិត្យក្រមដល់តក្កភាពក៏គ្មានព្រំដែនដែរ ។ ដូចជានាយ "ក" ខ្សឹបរឿង មួយប្រាប់នាយ"ខ" រួចខ្សឹបថាកុំប្រាប់អ្នកណាឱ្យសោះព្រោះរឿងនេះសំងាត់ណាស់ ។ នាយ"ខ" ខ្សឹបប្រាប់មីង"គ". មីង"គ" ក៏ខ្សឹបបន្ត រួចក៏បន្ត.... ទាល់តែគ្មានទីបញ្ចប់ ។ ប្រសិនបើចប់នៅស្រុកខ្មែរក៏គង់តែធ្លាយបន្តទៅដល់ បរទេសជិតឆ្ងាយទៀត។

ការនិយាយតគ្នាឥតព្រំដែននេះ អាស្រ័យមកពីតណ្ហាមនុស្សឥតព្រំដែនដែរ ។

ដូច្នេះហើយ បានជាលោកថា ផ្លូវវែងអីប៉ុណ្ណឹង មាត់មនុស្សវែងជាងផ្លូវទៅទៀត ហើយដែលគេពុំបានដឹងថាតើត្រូវបញ្ចប់នៅថ្ងៃណា ឬទីណាទៀតផង ។

*ថ្ងៃទី ២៣.១០.០៦*

ខួបទិវាសន្ធិសញ្ញារកសន្តិភាពសំរាប់ ប្រទេសកម្ពុជានៅទីក្រុងប៉ារីស

# ២៥៦. ផ្តាច់ពីមាត់ ពង្រាត់ពី-ក

## និយមន័យ

ដោយក្តី មេត្តា ករុណា ស៊ូលះបង់

## អត្ថាធិប្បាយ

ពំនោលនេះ លោកចង់និយាយពីមនោសញ្ចេតនារបស់មនុស្សខ្លះដែលប្រកបដោយក្តីស្រលាញ់ទៅលើជនណាម្នាក់ ។ គឺនៅពេលណាដែលគេបានអ្វីឆ្ងាញ់បន្តិច គេតែងនឹកឃើញទៅដល់ជននោះភ្លាម ។ បើនៅចំពោះមុខ គេក៏រំលែក ឬបែងចែកម្ហូបម្ហាឬនំចំនីឱ្យដល់ជននោះ ។ ដូចជា :

- ឪពុកម្តាយ កំពុងពិសានំ ស្រាប់តែឃើញកូនមកដល់ គាត់ក៏ឈប់ពិសាភ្លាម រួចហុចនំ ចំនីដែលនៅសល់ ទៅឱ្យកូនទាំងអស់ ។ ព្រោះគាត់លេបលែងចូលហើយ ។

- សំលាញ់ម្នាក់កំពុងជក់បារី ពេលឃើញមិត្តម្នាក់កំពុងចង់ជក់បារីដែរចូលមកដល់ ក៏ហុចកំណាត់បារីឱ្យទៅភ្លាម ។

ហ្នឹងហើយដែលលោកពោលថា ស៊ូផ្តាច់ពីមាត់ ពង្រាត់ពី-ក ។

ន័យខាងលើនេះ លោកនិយាយតែពីគ្រឿងបរិភោគទេ ឥតនិយាយយោងទៅដល់របស់ប្រើប្រាស់ផងឡើយ ៕

*ថ្ងៃទី ២៣.១០.០៦*

❀❀❀❀

# ២៥៧. ពេលឈឺយកដីរបន់ ជម្ងឺស្រន់ពងមាន់ស្ពាយ

**និយមន័យ**

ពេលមានអាសន្នហ៊ានចំនាយ ពេលសប្បាយត្បិតត្បៀត

**អត្ថាធិប្បាយ**

ព្រះពុទ្ធអង្គទ្រង់មានបន្ទូលថា **នត្ថិ អត្ត សមំ បេមំ** សេចក្ដីស្រលាញ់ឯណាស្មើនឹងខ្លួនមិនមានឡើយៈ ។

ហេតុនេះហើយ បានជានៅពេលមានភ័យអាសន្នអន់ក្រមនុស្សតែងដង្ហោយហៅជំនួយពីខាងក្រៅមកជួយ ។

**📖អត្ថានុរូប**

ពេលឈឺធ្ងន់ម្ដងៗ មនុស្សមានការភិតភ័យខ្លាចក្ដីស្លាប់ខ្លាំងណាស់ ។ នៅពេលនេះ គេក៏មិនខ្លាចនឹងចំនាយធនធានដែលមានដូចជា លក់ក្បាលដី, ផ្ទះសម្បែង ។ ជួនគេហ៊ានយកកូនទៅឱ្យស៊ីឈ្នួលបំរើគេ ដើម្បីយកប្រាក់មកសង្គ្រោះជីវិតគេក៏មាន ។

**📖អត្ថប្បដិរូប**

កាលណាមនុស្សមានភាពអាសន្នអន់ក្រ ដូចជាលិចទូកកណ្ដាលទន្លេ រឺសមុទ្ទ ។ គេខំបន់ស្រន់ដល់គុណវត្ថុសក្ដិសិទ្ធិក្នុងលោក មានគុណលោកយាយម៉ៅជាដើម ។ នៅ

ពេលភ័យស្លន់ស្លោតក្កមាបែបនេះ គេហ៊ានបន់ថ្វាយដំរីមួយ ឱ្យតែគុណលោកជួយសង្គ្រោះជីវិតគេ ឱ្យរួចផុតពីគ្រោះមហន្តរាយនេះ ។

ប៉ុន្តែលុះដល់គេបានរួចផុតពីមរណៈហើយ គេយកត្រឹមតែពងមាន់មួយគ្រាប់ទៅថ្វាយទាំងស្តាយស្រនោះទៀតផង ។ ជួនកាលដើម្បីកុំឱ្យខុសមាត់ខ្លាំងពេកគេយកដំរីជ័រ រឺដីទៅថ្វាយក៏មាន តែលោកតាសេពសោយអត់កើត ៕

*ថ្ងៃទី ២៣.១០.០៦*

❀❀❀❀

| |
|---|
| បើស្រលាញ់ស្រីឱ្យបួស បើស្រលាញ់ផ្ទួសឱ្យសិក្ស<br>*ប៊ុត - សាវង្ស* |

# ២៥៨. ពុតសិស្សគ្រូបី ពុតស្រីប្ដីលែង ពុតឆ្កែបង់ម្ចាស់ ពុតគោជ្រោះជ្រលង

**និយមន័យ**

កំនត់សំគាល់មើលពុតត្បុតមនុស្ស និងសត្វ

**អត្ថាធិប្បាយ**

## - ពុតសិស្សគ្រូបី

កាលពីសម័យដើម គឺក្នុងទសវត្សរ៍ឆ្នាំ ៤០ សាលារៀនមួយចំនួនមាននៅតែក្នុងវត្ត និងមានព្រះសង្ឃជាគ្រូបង្រៀន។ ជួនវត្តខ្លះ ពុំមានសាលារៀនទៀតផង។ ប៉ុន្តែទោះមានក្ដីមិនមានក្ដី ក៏ឧបាសកទាយកជើងវត្តតែងយកកូនចៅទៅផ្ញើនឹងលោកគ្រូសង្ក្រាជ ដើម្បីសុំឱ្យលោកជួយបង្រៀនលេខ, អក្សរ និងនៅបំរើព្រះសង្ឃយក បុណ្យផង ។ ពេលយកកូនចៅទៅផ្ញើនឹងព្រះសង្ឃដោយទូលផ្ដាំថា សុំតែភ្នែក និងឆ្អឹងទេ គឺវាយយ៉ាងណាកុំឱ្យខ្វាក់ភ្នែក និងបាក់ឆ្អឹង សមនឹងព្រះសង្ឃជាគ្រូជំនាន់នោះកាចៗខ្លាំងណាស់ ។

ពេលថ្ងៃលោកបង្រៀនអក្សរ សិស្សស្រែកឡូងៗ ពេលយប់លោកបង្រៀនធមិថ្វាយបង្គំ និងធមិបួស ទោះបានបួស រឺមិនបានក្ដី ។

ប្រសិនបើកូននៅរៀនវត្តនោះ ពុំចេះអ្វីសោះឪពុកម្ដាយផ្លាស់កូនឱ្យទៅនៅរៀនវត្តមួយផ្សេងទៀត ។ បើផ្លាស់ប្ដូរបីវត្តហើយកូននោះនៅតែរៀនធមិ និង

អក្សរមិនចេះទេ ។ លោកថា កូននោះមានពុតត្បុតហើយ មិនមែនមកពីគ្រូទេ ។ ព្រោះ វត្តមួយលោកទុកដូចជាគ្រូម្នាក់ ។

**- ពុតស្រីប្ដីលែង**

លោកឱ្យសំគាល់មើលស្រីនោះល្អ រឺមានពុតត្បុតយ៉ាងណាគឺនៅត្រង់ស្រីនោះប្ដីស្លាប់ រឺលែងប្ដី រឺក៏ប្ដីលែង ។ បើឃើញថាស្រីនោះត្រូវប្ដីលែងចោល គឺ *ស្រីនោះមានពុតត្បុតអាក្រក់ហើយ* ។

**- ពុតឆ្កែបង់ម្ចាស់**

សត្វឆ្កែ ក៏លោកឱ្យមើលសកម្មភាពវាដូចមនុស្សដែរ ។ គឺលោកឱ្យមើលឆ្កែណាដែលរត់ចោលម្ចាស់ រឺបង់ម្ចាស់ដើរផ្ដេសផ្ដាសគ្មានទិសដៅ ។ ឆ្កែបែបនេះលោកថាមិនល្អទេ *វាមានពុតត្បុតហើយ* ។

**- ពុតគោជ្រោះជ្រលង**

សត្វគោ ក៏មានពុតត្បុតដូចមនុស្សដែរ ។ លោកឱ្យសំគាល់មើលនៅពេលគេបររទេះទៅដល់ជ្រោះជ្រលងដងអូរ ។ ពេលវាឡើងមាត់ច្រាំងមាត់ជ្រោះជ្រលង រឺទីទួល ។ បើវាខំប្រឹងទាញប្រឹងអូសរទេះ លោកថាគោល្អហើយ ។ ប៉ុន្ដែ បើវាមិនខំប្រឹងអូសរទេះទេ វាធ្វើជាស្ទុះស្ទារកាច់-កនឹម រឺធ្វើជាដួលក្រោកមិនរួច លោកថា *គោនេះមានពុតត្បុតហើយ* ៕

*ថ្ងៃទី ២៤.១០.០៦*

# ២៥៩. ពៅក្នុងថ្នក់ ទំពក់ក្នុងដៃ

**និយមន័យ**

ជនលួចដែលមានភស្តុតាងសព្វគ្រប់ក្នុងដៃ

**អត្ថាធិប្បាយ**

ចោរដែលគេចាប់បានដោយគ្រាន់តែសង្ស័យ ច្បាប់មិនអាចឱ្យចោទប្រកាន់ជាផ្លូវការបានទេ គឺមិនត្រូវកាត់ទោសឱ្យជាប់គុកជាយ៉ាងណាបានឡើយ ។

ប៉ុន្តែ បើចាប់បានវត្ថុតាងជាក់ស្តែងក្នុងដៃ ព្រមទាំងឧបករណ៍សំរាប់សំរួលក្នុងការលួចនោះ ។ ដូចជា :

- ជនលួចម្នាក់ជិះម៉ូតូទាំងយប់អធ្រាត្រ ។ សមត្ថកិច្ចសង្ស័យក៏ឃាត់ឆែកឆេរ គេគ្មានឃើញសញ្ញាណអ្វីទាំងអស់ ។ តែគេរកឃើញកន្ត្រៃកាត់ដែក និងដែកអក្សរ "តេ" នៅក្នុងថង់ទេវិញ ។

- ចោរលួចចេកម្នាក់ លីចេកមួយស្ទងដើរក្បែរចំការចេកគេ ។ ពេលម្ចាស់គេសង្ស័យ ក៏ចាប់យកស្ទងចេកទៅដាក់ផ្គុំនឹងគល់ស្ទង ឃើញថាត្រូវតាមគន្លាក់វាឥតល្អៀង ។

វត្ថុតាងដែលមាននៅក្នុងដៃ និងសមស្របជាក់ស្តែងបែបនេះ លោកថា *ពៅក្នុងថ្នក់ ទំពក់ក្នុងដៃ* ៕

*ថ្ងៃទី ២៤.១០.០៦*

❀❀❀❀

# ២៦០. ពុតគ្រូកុំគ្រាប់ ច្បាប់គ្រូឱ្យយក

**និយមន័យ**

ជ្រើសយកតែគុណសម្ប័ទរបស់គ្រូមកដាក់ខ្លួន

**អត្ថាធិប្បាយ**

ពុតគ្រូនៅពេលនេះ លោកសំដៅយកអំពើអ្វីដែលជាគុណវិបត្តិរបស់គ្រូ ដូចជាគ្រូប្រព្រឹត្តល្បែងស៊ីសង វឺសេពសុរាជាដើម ។

អំពើទាំងនេះ លោកប្រាប់ថាកុំឱ្យយកមកកដាក់ខ្លួន ។ ព្រោះធម្មតាបុថុជ្ជនកម្រនរកបានមនុស្សណាដែលល្អគ្រប់ដប់ណាស់ ។ ដូច្នេះ គប្បីជ្រើសយកតែអ្វីដែលជាគុណសម្ប័ទរបស់គ្រូ ។ ដូចជាពេលបង្រៀន និងអប់រំសិស្ស លោកឥតបានបង្រៀនឱ្យសិស្សប្រព្រឹត្តអំពើអាក្រក់មានការស៊ីផឹកប៉ោឡែ វឺលេងល្បែងពាលាដូចគាត់ទេ ។

ករណីនេះ លោកប្រៀបដូចផ្លែស្វាយទុំមួយដែលមានសភាពរលួយនៅកន្ទុយ ។ លោកឱ្យកាត់ចុងកន្ទុយចោល ហើយចិតយកខាងក្បាលផ្នែកល្អបរិភោគទៅ ៕

*ថ្ងៃទី ២៤.១០.០៦*

✿✿✿✿

# ២៦១. ពងមាន់កុំជល់នឹងថ្ម

**និយមន័យ**

អ្នកទន់ខ្សោយកុំប្រឆាំងនឹងអ្នកមានអំនាច

**អត្ថាធិប្បាយ**

**📖អត្ថានុរូប**

"**ពងមាន់** "ជារបស់ដែលមានសំបកស្តើងស្រួយងាយបែកអន្តរាយណាស់ ។

"**ថ្ម** "ជាវត្ថុរឹងធ្ងន់ មិនងាយបែកផ្តេសផ្តាសទេ ។

ដោយសារជំនាប់រវាងរបស់ទាំងពីរនេះខុសគ្នាឆ្ងាយយ៉ាងនេះ ទើបលោកប្រាប់ថា កុំយកពងមាន់ទៅជល់នឹងថ្ម ព្រោះថ្មមិនបែកទេ គឺបែកពងមាន់អន្តរាយអស់ ។

**📖អត្ថប្បដិរូប**

លោកប្រៀបពងមាន់នេះទៅនឹងអ្នកទន់ខ្សោយ រឺប្រជារាស្ត្រតូចតាច គឺអ្នកមានធនធានតិច និងអ្នកមានបុណ្យសក្តិតូច ។

ឯថ្ម លោកប្រៀបទៅនឹងអ្នកមានអំនាច រឺមន្ត្រីធំណាម្នាក់ រឺក៏អ្នកមានធនធានច្រើន ។

បើមានវិវាទកើតឡើងរវាងអ្នកខ្សោយនឹងអ្នកខ្លាំងនេះ លោកប្រាប់ថា អ្នកខ្សោយកុំទៅប៉ះនឹងអ្នកខ្លាំងឱ្យសោះ ។ ព្រោះពុំដែលឃើញឈ្នះគេទេ ផ្ទុយទៅវិញ

ឃើញតែទឹកភ្នែក និងបង់ប្រាក់ឱ្យគេថែមទៀត រឺរុះផ្ទះរត់ចោលស្រុក បើសំនាងអាក្រក់ អាចជាប់គុកពីរអាយុសទៀតផង ។

ម្យ៉ាងទៀតកុំអាងតុលាការពេក ព្រោះតុលាការភាគច្រើនពាក់វ៉ែនតាខ្មៅម៉្លោះហើយមើលមិនសូវឃើញច្បាស់ទេ ។

នេះជាបំនងរបស់ន័យខាងលើនេះ ៕

*ថ្ងៃទី ២៤.១០.០៦*

ប្រទេសថ្មើងប្លែក សប្បាយតែភ្នែក ក្នុងចិត្តរងកម្ម ។

*ក្រម ង៉ុយ*

# ២៦២. ពាក្យពិតវែងស្លែងពុំពិរោះថា បណ្ឌិបមេបាវែងថាពុំគាប់

## និយមន័យ

ពាក្យពិតខ្លះពុំគួរនិយាយ, ពាក្យទូន្មានពុំសូវពិរោះស្តាប់ទេ

## អត្ថាធិប្បាយ

### 🕮 ពាក្យពិតវែងស្លែងពុំពិរោះថា

ព្រះរាជសម្ភារ ទ្រង់ត្រាស់សំដៅទៅលើរឿងណាដែលមានមែនពិត ប៉ុន្តែជារឿងអាស្រូវរបស់អ្នកណាម្នាក់ ជាពិសេសអ្នកមានអំនាច រឺអ្នកធំ ។ ទ្រង់បានហាមថាពុំពិរោះថា គឺពុំគួរនិយាយទេ ។ ព្រោះវាអាចចូលក្នុងបទបរិហារនិយាយដើមគេ វាស្លែងណាស់ក្រែងមានបញ្ហា ។

### 🕮 បណ្ឌិបមេបាវែងថាពុំគាប់

ពាក្យ **បណ្ឌិបមេបា**នេះ មានន័យថា ការទូន្មានប្រៀនប្រដៅរបស់មាតាបិតា ។

ជាការធម្មតា ពាក្យប្រៀនប្រដៅរបស់មាតាបិតាពុំសូវមានការពិរោះពិសាប៉ុន្មានទេ តែងតែមានការព្រមានខ្លះ, គំរាមខ្លះ, សំលុតខ្លះ បើប៉ះលើគាត់កំពុងខឹងខ្លាំងទៀតផងនោះ ការប្រៀនប្រដៅរបស់គាត់រឹតតែរមុាំងរម៉ោក ពិបាកស្តាប់ខ្លាំងណាស់ទៅទៀត ។

ហេតុនេះហើយបានជាទ្រង់ត្រាស់ថា បណ្ឌិបមេបាតែងតែពោលពាក្យពុំគួរគាប់ពិរោះស្តាប់ប៉ុន្មានឡើយ ៕

*ថ្ងៃទី ២៥.១០.០៦*

# ២៦៣. ពស់ប្រឹងលេប កង្កែបប្រឹងលោត

**និយមន័យ**

ម្នាក់ប្រឹងចង ម្នាក់ប្រឹងស្រាយ

**អត្ថាធិប្បាយ**

**📖អត្ថានុរូប**

"ពស់"នៅពេលនេះ លោកសំដៅយកពស់សំលាប់កង្កែប។ ឯសត្វកង្កែបជាចំនីរបស់ពស់ ។ ដូច្នេះពេលវាឃើញកង្កែប វាស្ទុះទៅខាំកង្កែបបានភ្លាម ។ ឯសត្វកង្កែបក៏ប្រឹងលោតដើម្បីរំដោះជីវិតពីមាត់ពស់ ។ ចំណែកពស់វិញចេះតែខំប្រឹងលេបចំនី ។

**📖អត្ថប្បដិរូប**

ន័យនេះ លោកនិយាយប្រៀបធៀបយោងទៅលើភាគីដើមចោទ និងចុងចោទ ។ អ្នកដើមចោទ ចេះតែ ខំប្រឹងរកភស្តុតាងយកមកសង្កត់-កចុងចោទ ដើម្បីចាប់ពិរុទ្ធ ។ ឯអ្នកចុងចោទចេះតែខំប្រឹងរើបំរះលោតឱ្យផុតចេញ ពីចំនោទដែលគេចេះតែប្រឹងសង្គ្រប់មក ។

ត្រង់នេះហើយ ដែលលោកថា *ពស់ក៏ប្រឹង កង្កែបក៏ប្រឹង* ៕

*ថ្ងៃទី ២៥.១០.០៦*

# ២៦៤. ពាក្យសង្ឃ ពាក្យសត្យ

**និយមន័យ**

ការនិយាយអះអាងរកសច្ចភាព

**អត្ថាធិប្បាយ**

ជាពាក្យទំនឹមទំនៀម មិនមែនជាពាក្យប្រៀនប្រដៅអ្វីទេ គឺជាពាក្យដែលនិយាយគ្នា ដើម្បីរកអំនះអំនាងឱ្យភាគីម្ខាងទៀតជឿនូវសម្ដីខ្លួនថាជា ការណ៍ពិតប្រាកដប៉ុណ្ណោះ ។

ក្នុងន័យខាងលើនេះ គេទុកព្រះសង្ឃក្នុងព្រះពុទ្ធសាសនាជាតំនាងឱ្យភាវៈល្អត្រឹមត្រូវទាំងផ្លូវកាយ, ទាំងផ្លូវចិត្ត, ទាំងផ្លូវវាចា។ ហេតុនេះហើយបានជាគេយកពាក្យសង្ឃដែលមិនចេះភូតកុហកភ្ជាប់នឹងពាក្យសត្យដែលមានន័យថា **សច្ចភាព** ។

ឧទាហរណ៍ :

- គួចរចារតែងនិយាយគ្នាថា : ហ្នឹងហើយ ! យើងនិយាយគ្នានៅពេលនេះគឺជាពាក្យសង្ឃពាក្យសត្យ ម៉ាត់ណា ម៉ាត់ហ្នឹង ថាស្អែកនេះអ្នកឯងយកលុយមកសងខ្ញុំកុំខាន ។

- យើងទាំងពីរនាក់សូមសច្ចាយកពាក្យសង្ឃពាក្យសត្យមកធ្វើអំនះអំនាងថាយើងមិនក្បត់ចិត្តមិនកុហកគ្នាទេ ៕

*ថ្ងៃទី ២៥.១០.០៦*

# ២៦៥. ព្រួញមួយបាញ់បានសត្វពីរ

**និយមន័យ**

ប្របហារមួយករណី ត្រូវបានពីរករណី

**អត្ថាធិប្បាយ**

**📖អត្ថានុរូប**

សត្វកង្កែប ធម្មជាតិវាមិនចេះកាយរូងធ្វើជំរកនៅទេ វាចាំតែដើរនៅជាមួយគេ ។

សត្វក្ដាមវាមិនចេះមាត់-កអ្វីទេ តែចេះកាយរូងបាននៅ ។ ឯសត្វកង្កែបពេលឃើញរូងក្ដាមក៏ចូលទៅនៅជាមួយគេ ។

ឯមនុស្សពេលឃើញរូងក្ដាមក៏យកកង្វាទៅខ្វារ ។ គេខ្វារបានទាំងកង្កែបបានទាំងក្ដាម ។ ដូចនេះ ឃើញថាកង្វារមួយ ខ្វារបានសត្វពីរ ។

**📖អត្ថប្បដិរូប**

ករណីណាដែលគេលើកឡើងតែមួយរឿងទេ ប៉ុន្តែលទ្ធផលបានដល់ទៅពីររឿង ។ ដូចជា:

- ប៉ូលិសចាប់ឡានមួយគ្រឿងឥតមានផ្លាកលេខ ។ ពេលចាប់មកស្រាប់តែឃើញក្នុងឡាននោះមានសុទ្ធតែឈើប្រណិត ប៉ូលិសសួរថា : អ្នកឯងដឹកឈើយកទៅណា?

- បាទលោកខ្ញុំដឹកឱ្យគេ ។

- កណ្ដុំឆែប ដឹកឱ្យគេ ចុះម៉េចក៏មិនដឹកឱ្យខ្ញុំ។ ប៉ុន្តែ មិនអីទេចាំខ្ញុំបញ្ជូនទៅថ្នាក់លើ ។ ថ្ងៃនេះអ្នកឯងច្បាស់ជាស៊ីយធំ ឯខ្ញុំច្បាស់ជាឡើង បុណ្យ ។ ប៉ុន្តែកុំភ្លេចបង់ពិន័យផ្លាកលេខឱ្យខ្ញុំសិន ៕

*ថ្ងៃទី ២៥.១០.០៦*

# ២៦៦. ព្រះខ្នងរងយកថ្លើម

## និយមន័យ

• ស្នេហា ដែលគេឆក់ដណ្ដើមយកទៅបាត់

## អត្ថាធិប្បាយ

ល្បែងស៊ីសងគ្រប់ប្រភេទ, ចាប់តាំងពីពីរនាក់ឡើងទៅ គេអាចលេងបានទាំងអស់ ។ ព្រោះគេឥតមានកំរិតចំនួនទេ កាលណាបានចំនួនគ្នាកាន់តែច្រើន កាន់តែប្រសើរ ។ ប៉ុន្តែចំពោះល្បែងស្នេហាវិញ គេអាចលេងបានតែពីរនាក់គត់ បើហ៊ានលេងដល់បីនាក់ ដែលគេហៅថាស្នេហាត្រីកោណនោះ តោងមានម្នាក់អង្គុយយំសង្រោកសង្រេងខ្សឹកខ្សួលអួលអាក់ ។ ជួនកាលអាចរហូតដល់ស្លាប់ខ្លួនទៀតក៏សឹងមាន ។ ដូចជា :

- គូស្នេហ៍មួយគូ ដែលកំពុងតែទទួលនូវអារម្មណ៍ថាសុខ ស្រាប់តែថ្ងៃមួយតួអង្គប្រុស បានទទួលដំណឹងថា តួអង្គស្រីត្រូវបានអ្នកមានម្នាក់មកពីបរទេសចូលដណ្ដឹង រៀបការយកធ្វើប្រពន្ធបាត់ទៅហើយ ។ តួអង្គប្រុសនឹកតូចចិត្តមកពីខ្លួនឯងក្របានជា គេបែកចិត្ត ។ ក៏លេបថ្នាំធ្វើអត្តឃាតស្លាប់បាត់ទៅ ។

- កាលពីឆ្នាំ ១៩៨៨ កូនក្រមុំតែងខ្លួនបំរុងចេញទទួលភ្ញៀវក្នុងថ្ងៃអាពាហ៍ពិពាហ៍ស្រាប់តែបានទទួលដំនឹងថា កូនកំលោះនោះត្រូវបាននារីម្នាក់ មកកញ្ឆក់យកទៅបាត់ហើយ ។

- កាលដើមឆ្នាំ ២០០៧ មានស្វាមីកំសត់ម្នាក់ត្រូវអ្នកជើងល្អ មកលួងលោមតាមរយៈដុល្លារ ឆក់ប្រពន្ធកំសត់កម្រទៅបាត់ ដោយទុកឱ្យស្វាមីអភព្វនៅកណ្តោចកណ្តែងដូចខ្លែងដាច់ខ្សែ ។

ទាំងអស់នេះហើយ សុទ្ធសឹងតែជាទារុណកម្មស្នេហ៍ដែលត្រូវជនពាលអន្យត្ថិយមកពុះទ្រូងរូងយកថ្លើមទៅស៊ីទាំងភ្នែកស្រស់ទាំងអស់ ៕

*ថ្ងៃទី ២៨-០៤-០៧*

❀❀❀❀

📖**ចម្ងល់ និង ឥទ្ធិពលពាក្យ**

✳ *នរណាហ្ន៎ ?*បង្កើតពាក្យថា : "**បខ**"អោយស្ត្រីហៅ "បុរស" ដែលមានអក្សរតែពីរតួ គ្មានស្រះកំដរទេ, ប៉ុន្តែ អីក៏មានឥទ្ធិពល ចាក់យ៉ាងសែនជ្រៅទៅក្នុងបេះដូងបុរស គ្មានទីបំផុត ។

✳ ប្រសិនបើគេត្រលប់តួរអក្សរនៃពាក្យនេះពីមុខទៅក្រោយ ពីក្រោយមកមុខ, រួចសុំខ្ចី "បន្តក់" តូចមួយមកដាក់ពីលើ "តួ-ប" បានពាក្យថា "**ខប់**" មានន័យថា ឈ្លក់ វិឆ្កួតវង្វេង ។

ល-ថ-ល

# ២៦៧. ពាក្យពិត ជាពាក្យមិនស្លាប់

**និយមន័យ**

ពាក្យពោលត្រូវ ស្ថិតនៅជាអមតៈ

**អត្ថាធិប្បាយ**

ព្រះពុទ្ធអង្គទ្រង់ត្រាស់ថា *សច្ចំ វេ អមតា វាចា=ពាក្យពិតជាពាក្យមិនស្លាប់*។

**ពាក្យពិត** គឺជាពាក្យណាដែលពោលត្រូវគ្រប់កាលសម័យ និងគ្រប់ជាតិសាសន៍ ។ ដូចជា :

- ធ្វើល្អបានល្អ, ធ្វើអាក្រក់បានអាក្រក់, ចេះពីរៀនមានពីរក, អ្នកណាជាន់ភ្លើងអ្នកហ្នឹងរលាក ។ល ។

ពំនោលទាំងនេះ តើមានជាតិសាសន៍ណា ហ៊ានបដិសេធថា មិនត្រូវ រឺមិនពិតទេ?

បើគ្មានទេ ពាក្យនេះជាពាក្យពិតប្រាកដ ត្រូវគ្រប់ជំនាន់ គ្រប់និន្នាការ ។

ដូច្នេះ ពាក្យនេះជាពាក្យមិនស្លាប់ មិនសាបសូន្យ គឺត្រូវតែស្ថិតនៅជាអមតៈតរៀងរហូតទៅ ៕

*ថ្ងៃទី២៥.១០.០៦*

❀❀❀❀

# ២៦៨. ពិបាកដូចសុំភ្លើងយក្ស

**និយមន័យ**

អ្វីដែលតឹងតែងពេក

## អត្ថាធិប្បាយ

នៅក្នុងអក្សរសិល្ប៍ខ្មែរ គ្រួសារយក្សជាតំនាងឱ្យភាវៈចិត្តអាក្រក់ ។ យក្សមានប្រុសមានស្រី តែគេមិនដែលឮថាពួកយក្សរៀបអាពាហ៍ពិពាហ៍សោះ ។ គេឆ្ងល់ថា តើយក្សកើតមកពីណា? ភាគច្រើនសុទ្ធតែប្រុស១ យូរ១មានស្រីម្នាក់ហៅថាយក្ខិនី មាននាង **សន្ធិមា** និងនាង **កន្ធិយតិយ** ជាដើម ។ ទោះបីស្រីក៏ដោយ ក៏សុទ្ធតែកាច១ និងចិត្តអាក្រក់ជាមួយមនុស្សដូចគ្នា ។ ឯកូនក្រមុំយក្សវិញសុទ្ធតែយកកូនស្រីមនុស្សទៅចិញ្ចឹម ដូចជា **នាងកង្រី** ជាដើម ។ ម្យ៉ាងទៀតកូនក្រមុំយក្សសុទ្ធតែយកប្ដីមនុស្សដូចជា **កម្លោះពុទ្ធិសែន** ជាដើម ។ គេមិនដែលឮថាយក ប្ដីយក្សគ្នាឯងទេប្រហែលខ្លាចយក្សធំពេកទេដឹង? ។

ដោយសារយក្សប្រុស និងយក្សស្រីសុទ្ធតែកាច១ កំនាញ់ទ្រឹស្ដីរជាមួយនឹងមនុស្សដូច្នេះហើយបានជាលោកពោលថា ការងារណាដែលទៅពឹងគេ តឹងតែងពេកលោកពោលថា ពិបាកដូចទៅសុំភ្លើងយក្ស ។

ម្យ៉ាងទៀត ដោយសាសន៍យក្សទាំងប្រុសទាំងស្រីកំនាញ់ស្វិតចិត្តអាក្រក់ដូច្នេះហើយ បានជាគេមិនដែលឃើញមានអ្នកណាម្នាក់ទៅសុំភ្លើងយក្សដុតបារី ឬដាំបាយបានឡើយ ។ ម្យ៉ាងវិញទៀត គេក៏មិនដឹងថា មានយក្សនៅទីណា ក្រៅពីយក្សសិប្បនិមិត្តដែលច្បាំងគ្នានឹងមនុស្សឡើងរង្គើរោងល្ខោនបាសាក់នោះឯងទេ ៕

*ថ្ងៃទី ០៩-១១-០៦*

# ២៦៩. ព្រហ្មវិហារធម៌ចំពោះកូន

**និយមន័យ**

ធម៌សំរាប់មាតាបិតាសង្គ្រោះដល់កូន

**អត្ថាធិប្បាយ**

នេះគឺជាពាក្យស្លោករបស់ព្រះពុទ្ធជាម្ចាស់ ដែលទ្រង់ត្រាស់បញ្ញត្តិទុកមកដល់វេនេយ្យជន គឺជនដែលអាចទូន្មានបានថា : មាតាបិតាត្រូវមានធម៌ ៤យ៉ាង សង្គ្រោះដល់កូនប្រុសស្រីគ្រប់ៗគ្នាគឺ : មេត្តា, ករុណា, មុទិតា, ឧបេក្ខា ។

- **មេត្តា** : (ការរាប់អានគ្នាស្និទ្ធស្នាល, មេត្រីភាព, នាំសេចក្តីទុក្ខចេញ)

ពេលកូននៅតូចត្រូវឃុំគ្រង ថ្នាក់ថ្នម បីបាច់ថែរក្សា ។ រកសេចក្តីសុខឱ្យកូនទៅតាមលទ្ធភាពដូចជា : មានរបស់ជាល្បែងលេងកំសាន្ត, ស្លៀកពាក់ស្អាត, មានចំនីចំនុកម្ហូបម្ហា, ផ្គត់ផ្គង់ឱ្យរៀនសូត្រ ។ ពេលកូនធំ ជួយ រកវិជ្ជាជីវៈ, រកមុខរបរ, រកគូស្រករ និងចែកកេរអាករតាមលទ្ធភាព ។ល ។

- **ករុណា** : (សេចក្តីអាណិតអាសូរ, នាំសេចក្តីទុក្ខចេញ )

ពេលកូននៅតូច ត្រូវជួយកំចាត់ជម្ងឺដំកាត់ផ្សេងៗដូចជា បើកូនមានឈឺថ្កាត់ត្រូវរកគ្រូព្យាបាល ។

- **មុទិតា** : (ជួយត្រេកអរ និងជួយរំលែកទុក្ខ)

ពេលកូនធំចេញផុតពីការគ្រប់គ្រង កាលបើកូនរកស៊ីមានបាន, មានអាជីព ត្រឹមត្រូវ, មានបុណ្យសក្តិ, មានកិត្តិយសត្រូវជួយអបអរសាទរ ។ ផ្ទុយទៅវិញបើ កូនមានទុក្ខព្រួយកង្វល់កង្វាយអ្វីមួយត្រូវជួយរំលែកទុក្ខតាមផ្លូវមនោសញ្ចេតនា ។

- **ឧបេក្ខា** : (តាំងចិត្តជាកណ្តាលស្មើៗធម្មតា) មិនរំភើបញាប់ញ័រ, មិនតក់ស្លុត, ហើៗ ព្រងើយៗ ។ ចិត្តជាឧបេក្ខា ៕

*ថ្ងៃទី ២៧-០៥-០៩*

មាលាទៅរស់នៅអូស្ត្រាលី

❀❀❀❀

## លោកធម៌ទាំងប្រាំបី

- មានលាភ *ជាគូនឹង* ឥតលាភ
- មានយស *ជាគូនឹង* ឥតយស
- សរសើរ *ជាគូនឹង* និន្ទា
- សុខ *ជាគូនឹង* ទុក្ខ

# ២៧០. ពស់វែកជិបូកមួយស្រែ ពស់វែកស្រវែងមួយព្យាម ពស់ទ្រូងរនាម ប៉កព្រួស

**និយមន័យ**

ឥទ្ធិពលពិសពស់កំនាចទាំងបីប្រភេទ

**អត្ថាធិប្បាយ**

ពាក្យនេះ មិនមែនជាពាក្យសុភាសិតទេ ហើយក៏មិនមែនជាពាក្យទំនឹមទំនៀមដែរ គឺជាពាក្យស្លោករបស់ អ្នករកស៊ីចាប់ពស់នៅឃុំម្សាក្រង ស្រុកស្ទោង ខេត្រកំពង់ធំ ដែលតែងតែជិនាលប្រាប់កូនចៅជាយូរមកហើយៗ ដែលយើងមិនគួរខាននឹងលើកយកមកធ្វើអធិប្បាយដែរ ។

**🕮 ពស់វែកជិបូកមួយស្រែ**

បើពស់ប្រភេទនេះចឹកភ្លាម គេអាចដើរបានត្រឹមចម្ងាយប្រហែលមួយស្រែប៉ុណ្ណោះ គេនឹងដួលភ្លាម ព្រោះឥទ្ធិពលពិសឡើងដល់កំរិត ។

**🕮 ពស់វែកស្រវែងមួយព្យាម**

ពស់ប្រភេទនេះ រឹតតែមានពិសខ្លាំងក្លាណាស់ទៅទៀត បើអភព្វត្រូវវាចឹក គេអាចដើរបានតែមួយព្យាម ឬបីបួនជំហានតែប៉ុណ្ណោះ។ គេនឹងដួលដេកលើធរណីភ្លាម ព្រោះពិសវារត់សព្វខ្លួនប្រាណ ។

## 🕮ពស់វែករនាម ប៉ក់ព្រួស

ពស់នេះរឹតតែមានពិសយ៉ាងសាហាវខ្លាំងណាស់ទៅទៀត ។ បើកាលណាវាចឹកហើយជនរងគ្រោះមិនពិបាកដើរឆ្ងាយនាំហត់ទេ គឺចឹកប៉ក់ដួលព្រួសតែម្តង។ ពីព្រោះវាកើតក្នុងព្រៃរនាម ម៉្លោះហើយពិសវាមានឥទ្ធិពល គ្មានអ្វីប្រៀប សូម្បីតែអ្នកសិក្សាស្រាវជ្រាវអន្តរជាតិក៏ទទួលស្គាល់ថា វាមានពិសខ្លាំងជាងគេទាំងអស់ក្នុងពិភពលោក ៕

*ថ្ងៃទី ២៨-១២-០៦*

✿✿✿✿

## ថ្នាំពស់ចឹក

→ បើពស់ចឹក ទោះបីប្រភេទណា មានឥទ្ធិពលខ្លាំងយ៉ាងណាក៏ដោយ ចូរយកលោហិតរដូវនារី មកលាបពីលើមុខរបួសភ្លាម នឹងបាត់ចុកចាប់ភ្លាម ក្រោកដើរមួយរំពេជភ្លាម ។

→ បើគ្មានអាស្រស់ យកអាក្រៀមដែលជាប់នឹងសំលីអនាម័យជ្រើមទឹកបន្តិច បិទពីលើមុខរបួស ។

→ បើប្រថុចញ៉ុច អាស្រស់ក៏គ្មាន អាក្រៀមក៏គ្មាន លូកឆៅ លាបឆៅ ។

# ២៧១. ពៀររំងាប់ដោយការមិនចងពៀរ

**និយមន័យ**

ការលើកអភ័យ គឺជាការបញ្ចប់នូវការសងសឹកគ្នា

**អត្ថាធិប្បាយ**

ព្រះពុទ្ធបរមគ្រូត្រាស់ថា : **អវេរេនច វេរានិ សម្មន្តិ** ពៀររំងាប់ដោយការមិនចងពៀរ រឺថា ការប្រទូស្តរាយគ្នា បញ្ចប់ដោយការមិនសងសឹកគ្នា ។

ក្នុងន័យនេះ ការព្យាបាទគ្នា, ការសងសឹកគ្នា, ការចងពៀរគ្នា គេមិនអាចរំងាប់ រឺបញ្ចប់ទៅបានដោយយកអំពើទាំងអស់នេះទៅសងវិញនោះទេ ។ ព្រោះមនុស្សបុថុជ្ជន កាលណាមានគេធ្វើអ្វីមិនល្អមកលើខ្លួន ។ គេតែងតបតទៅវិញភ្លាម ។ បើថ្ងៃនេះសងសឹកមិនបាន គេចិញ្ចឹមគំនុំទុកទៅថ្ងៃក្រោយទៀត ។ កាលណាគេសងសឹកបានទើបសប្បាយចិត្ត ។ ប៉ុន្តែភាគីម្ខាងទៀតមិនសប្បាយចិត្តម្តងវិញ ។ ម្ល៉ោះហើយការសងទៅសងមកគ្មានទីបញ្ចប់ទេ ។

ហេតុនេះ បានជាព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា បើចង់បញ្ចប់ពៀរ ចូរកុំយកពៀរទៅស៊ីសងគ្នា ត្រូវយកខន្តីធម៌ទៅសងទើបចប់ ។

ប៉ុន្តែក្នុងន័យនេះ មិនស៊ីជំរៅទៅដល់សង្គ្រាមរវាងជាតិ ដែលរំលោភឈ្លានពានមកលើបូរណភាពទឹកដី និងអធិបតេយ្យជាតិ រួចយើងដេកស្ងៀមនោះទេ ៕

*ថ្ងៃទី ២៦-១០-០៦*

❀❀❀❀

## ២៧២. ភូតនៅហោរ ចោរនៅជាង

**និយមន័យ**

ការទស្សន៍ទាយក្តី ការធ្វើជាងក្តី ពុំត្រឹមត្រូវទាំងអស់ទេ

**អត្ថាធិប្បាយ**

📖 **ភូតនៅហោរ**

"**ហោរ**" គឺជាអ្នកទស្សន៍ទាយនូវជោគជតារាសីឱ្យមនុស្សប្រុសស្រី ទៅតាមក្បួនតម្រា ដែលកើតឡើងពីកំនត់សំគាល់របស់បុព្វបុរសជិនាន់មុនរួមផ្សំនឹងវោហារសាស្រ្តផង ។ ម្ល៉ោះហើយគ្មានភស្តុតាងអ្វីយកមកអះអាងថា ត្រឹមត្រូវឥតខ្ចោះនោះទេ ។

ហេតុនេះហើយ បានជាគេឃើញគ្រូហោរពីរនាក់កាន់ក្បួនតែមួយ តែទស្សន៍ទាយខុសគ្នា គឺម្នាក់ទាយត្រូវបានប្រហែល ៦០ភាគរយ, ម្នាក់ទៀតត្រូវបានប្រហែល ៤០ភាគរយប៉ុណ្ណោះ ។

ដូច្នេះហើយបានជាលោកពោលថា *ភូតនៅហោរ* ។

📖 **ចោរនៅជាង**

"**ចោរ**" គឺអ្នកដែលយករបស់គេដោយមិនឱ្យគេដឹង ទោះបន្តិចបន្តួចក៏ដោយ លោកហៅថា"ចោរ"ទាំងអស់ ។ ដូចជា :

- ជាងកាត់ដេរម្នាក់មានគេយកកំណាត់សំពត់ទៅកាត់អាវ ។ លុះកាត់រួច ជាងប្រគល់ឱ្យតែអាវប៉ុណ្ណោះ ឯកំណាត់នៅសល់បន្តិចបន្តួចនៅលើជាងទាំងអស់ ។

- ជាងធ្វើតុ-ទូម្នាក់មានគេយកកំណាត់ឈើទៅឱ្យធ្វើទូមួយ ។ លុះធ្វើរួច ជាងប្រគល់ឱ្យតែទូប៉ុណ្ណោះ ឯកំណាត់ឈើដែលនៅសល់បន្តិចបន្តួច នៅលើជាងទាំងអស់ ។

- ជាងមាសម្នាក់ គេយកមាសឱ្យទៅធ្វើជាខ្សែ-ក ។ លុះធ្វើរួចជាងប្រគល់ឱ្យតែខ្សែ-កប៉ុណ្ណោះ ។ ឯកំទេចមាសបន្តិចបន្តួចនៅលើជាងទាំងអស់ ពិតមែនតែជាងថ្លឹងឱ្យមើលឃើញថាត្រឹមត្រូវហើយក៏ដោយ ៕

*ថ្ងៃទី ២៦-១០-០៦*

❀❀❀❀

ល្ពីកណាមិនទាន់ជាប់ផុងម្តង
សត្វដីរីតែងយល់ថា ភក់ខ្សោយ

*លី ថៃលី*

# ២៧៣. ភូតច្រើន ច្រើនចាញ់អាត្មា

**និយមន័យ**

អ្នកភូត-ភរច្រើន តែងអន្តរាយខ្លួន

**អត្ថាធិប្បាយ**

ខ្លឹមសារពាក្យទំនឹមទំនៀមនេះ លោកបានប្រាប់ត្រង់ៗតែម្ដង ។ ព្រោះមានមនុស្សខ្លះមាននិស្ស័យចូលចិត្តនិយាយភូត-ភរ កុហកធ្វើជាល្បែងកំសាន្តសើចលេងសប្បាយ ។ មនុស្សប្រភេទនេះ ឥតគិតពីផលវិបាកដែល កើតឡើងដោយសារតែសំដីភូតកុហកលេងសើចរបស់ខ្លួនទេ ។

កាលណាមានមហាជនដឹងថា អ្នកនោះជាមនុស្សដែលនិយាយគ្មានបានការ គេក៏ពុំសូវរាប់អានយកជាគ្នាដែរ ។ ព្រោះគេចាត់ទុកជាមនុស្សគ្មានតំលៃ ។

ទីបំផុតមនុស្សនេះ ដើរត្រូនៗទៅរកគេ ។ ហ្នឹងហើយដែលលោកថា ចាញ់ខ្លួនដោយខ្លួនឯង មិនចាំបាច់អ្នកណាមកផ្ចាញ់ធ្វើអ្វីផង ។

ម្យ៉ាងទៀតមនុស្សម្នាក់ឈ្មោះ ចូច ថ្ងៃមួយបានស្រែកផ្អើលគេជិតខាងថា លោកអើយជួយផង ចោរលួចម៉ូតូខ្ញុំហើយ ។ លុះដល់អ្នកជិតខាងផ្អើលឈ្លូធរមកជួយ ស្រាប់តែមនុស្សកំភូតនេះ សើចកាច់-ក ហើយថា ខ្ញុំនិយាយលេងទេមានចោរឯណាលួចស្អី ។ អ្នកមកជួយត្រលប់ទៅវិញទាំងខឹងសម្បា ។ ថ្ងៃក្រោយមកទៀតមាន ចោរចូលមកលួចឥវ៉ាន់មែនទែន ។ ពេលនោះ ទោះបីជនកំភនេះស្រែកបែកបំពង់-ក ក៏គ្មានអ្នកណាម្នាក់អើតមុខមកជួយដែរ ។

ហ្នឹងហើយ អ្នកភូត-ភរច្រើន ច្រើនចាញ់ខ្លួនឯង ដោយខ្លួនឯង ដូច្នេះឯង ៕

*ថ្ងៃទី ២៦-១០-០៦*

# ២៧៤. ភ្លើងឆេះពីសំរាម

## និយមន័យ

ភ្លើងកំហឹងកើតឡើង សុទ្ធតែផ្ដើមចេញពីរឿងតូចតាច

## អត្ថាធិប្បាយ

### ☞ អត្ថានុរូប

ធម្មតា ភ្លើងដែលឆេះសន្ធោសន្ធៅបំផ្លាញផ្ទះសំបែងអស់រាប់រយខ្នង, បំផ្លាញព្រៃឈើអស់រាប់សិបហិកតា សុទ្ធតែផ្ដើមចេញពីសំរាមកំទេចកំទី មានភ្លើងកន្ទុយបារីជាដើម។ កាលណាភ្លើងឆេះកាត់បានបន្តិចហើយ ទើបរាលដាលទៅរកទំហំធំតែម្ដង ។

### ☞ អត្ថប្បដិរូប

រឿងរ៉ាវវិវាទគ្រប់ករណី សុទ្ធតែផ្ដើមឡើងពីរឿងតូចតាចបន្តិចបន្តួចរួចឈានទៅដល់ការកាប់សំលាប់គ្នាយ៉ាងសាហាវតែម្ដង ។ ព្រោះម្នាក់ៗសុទ្ធតែកាន់ចិត្តអាត្មានិយមទៅតាមភាវៈមនុស្សបុថុជ្ជន ។ អ្នកខ្លះថា សុខចិត្តចាញ់លុយ កុំឱ្យចាញ់ចិត្ត ។ ដូចជា :

-កូនក្មេងឈ្លោះគ្នា ប្រវាយប្រតប់គ្នាតាមកំលាំងក្មេង ។ រួចរាលដាលដល់មនុស្សធំ គឺឪពុកម្ដាយទាំងសងខាង។ ទីបំផុតមនុស្សចាស់ប្រហារគ្នាតាមកំលាំងចាស់។ បើប៉ះលើមនុស្សអវិជ្ជាទៀត ច្បាស់ជាមានដឹកចូលមន្ទីរពេទ្យមិនខាន។ ដូចជា :

- ដើមត្នោតមួយដើមដុះត្រង់ព្រំដី ដណ្ដើមគ្នារហូតដល់ឡើងសាលាក្ដី ។

- ដំបូលផ្ទះជិតគ្នា ពេលភ្លៀងមកទឹកសាចប៉ះពាល់ដល់អ្នកម្ខាងទៀត ។ ជំលោះ កើតឡើងរហូតដល់ឡើងប៉ុស្តិ៍ប៉ូលិស ៕

*ថ្ងៃទី ២៦-១០-០៦*

❀❀❀❀



# ២៧៥. មានផ្ទះអត់មនុស្សនៅ មានផ្លូវអត់មនុស្សដើរ

**និយមន័យ**

វិនាសកម្ម ក្នុងបរិយាកាសស្រុកកើតសង្គ្រាម រឺមានបដិវត្តន៍ឆ្កួតលីលា

**អត្ថាធិប្បាយ**

នៅពេលស្រុកមានភាពអសន្តិសុខ ឬស្រុកមានសង្គ្រាម អ្វីៗក៏ត្រូវប្រែប្រួលទាំងអស់ គឺប្រែប្រួលពីស្រស់បំព្រងមកស្ងិតស្រពោន ។

ដូច្នេះ ពេលស្រុកមានបរិយាកាសដូចខាងលើ មនុស្សម្នាមហាជនតែងភៀសខ្លួនពីតំបន់អសន្តិសុខ ទៅរកតំបន់មានសុវត្ថិភាព ។ ហេតុនេះផ្ទះសំបែង និងផ្លូវថ្នល់ត្រូវស្ងាត់ជ្រងំ ព្រោះគ្មានមនុស្សដើរ ។

ម្យ៉ាងទៀត កាលបដិវត្តន៍ឆ្កួតលីលារបស់ខ្មែរក្រហមក្រោមការញ្ញាក់បរទេស វាចាប់ព្រះសង្ឃផ្សឹកអស់ស្ងាត់វត្ត ។ វាយកព្រះវិហារធ្វើគុក ធ្វើទ្រុងជ្រូក, សំលាប់បញ្ញវន្ត លើកដំកើងមនុស្សអវិជ្ជា ។ វាដេញប្រជាពលរដ្ឋពីទីក្រុងឱ្យទៅធ្វើស្រែចំការចោល ផ្ទះសម្បែងទាំងក្រុង, ទាំងស្រុក, ទាំងភូមិស្ងាត់ឈឹង ។

ករណីបែបនេះហើយបានជាលោកពោលថា មានផ្ទះអត់មនុស្សនៅ ។ ឯផ្លូវមិនបាច់និយាយក៏បានដែរ បើមនុស្សត្រូវពួកទមិឡឥតសាសនាជន្លៀសអស់ និងកាប់សំលាប់គ្មានអាសូរ តើមានមនុស្សឯណាមកដើរទៀត បើគ្រាន់តែឆ្កែឆ្មា ១ក្បាល ក៏ត្រូវពួកវាសំលាប់ស៊ីគ្មានសល់ដែរនោះ ៕

*ថ្ងៃទី ២៧-១០-០៦*



# ២៧៦. មនុស្សល្ងង់កុំប្រើឱ្យនិយាយការ មនុស្សមានប្រាជ្ញាកុំប្រើឱ្យរែកពុន

**និយមន័យ**

ត្រូវប្រើមនុស្សទៅតាមសមត្ថភាព និងជំនាញ

**អត្ថាធិប្បាយ**

- **មនុស្សល្ងង់កុំប្រើឱ្យនិយាយការ**

ការប្រើមនុស្សឱ្យធ្វើអ្វីមួយ ត្រូវមើលសមត្ថភាពសិនដូចជា បើគេយកមនុស្សមានសមត្ថភាពខាងជាងឈើធ្វើផ្ទះ ទៅឱ្យជួសជុលឡាន, ម៉ូតូ ឬកុំព្យូទ័រ ។ល ។ គឺពុំបានផលឡើយ ។ ឯមនុស្សដែលមិនសូវមានចំនេះដឹង ឬគ្មានជំនាញអ្វីមួយ គេពុំគួរយកមនុស្សប្រភេទនេះឱ្យទៅនិយាយការអ្វីដែលសំខាន់ ដូចជាចូលទៅនិយាយការជាមួយអស់លោកមន្ត្រីតូច-ធំ ឬឡើងទៅថ្លែងការណ៍នៅមុខមីក្រូក្នុងអង្គប្រជុំឡើយ ។

- **មនុស្សមានប្រាជ្ញាកុំប្រើឱ្យរែកពុន**

មនុស្សមានប្រាជ្ញា គឺមនុស្សដែលមានចំនេះដឹងជ្រៅជ្រះ ។ មនុស្សប្រភេទនេះ ក៏គេមិនគប្បីប្រើឱ្យរែក ពុន លីសែងដែរ ។ គេគួរប្រើទៅតាមសមត្ថភាព រឺជំនាញរបស់គេ ។ ព្រោះបើគេប្រើមនុស្សមិនត្រូវសមត្ថភាព គឺ ច្របូកច្របល់គ្នា

ការងារនោះមិនរីកចំរើនទេ ដូចជានៅសម័យវាលពិឃាតខ្មែរក្រហម គេយកបញ្ញវន្ត ឱ្យរែក, ពុន, លី, សែង និងកាប់ដី យកពួកខ្មោចគ្មានដឹងខ្យល់អីឱ្យធ្វើធំ និងដឹកនាំគេ ។

ទីបំផុត គ្មានរីកចំរើនអ្វីបន្តិចសោះ មានតែការហិនហោចខ្លោចចម្រុះ ៕

*ថ្ងៃទី ២៦-១០-០៦*

✿✿✿✿

✳ **ចូររៀបការ** នឹងអ្នកដែលស្រលាញ់យើង ។
កុំរៀបការនឹងអ្នកដែលយើងស្រលាញ់ ។

# ២៧៧. ម្លៀវយកជ័រខ្លៅតៀ្បតក្លៀក

**និយមន័យ**

នៅស្ងៀមមិននៅ យករឿងមកដាក់ខ្លួន

**អត្ថាធិប្បាយ**

☞ **អត្ថានុរូប**

"**ផ្លែខ្លៅ**" មានជ័រស្អិតនៅរុំគ្រាប់ ដែលគេប្រើជាការបិទក្រដាសបាន ។ បើកាលណាគេកាន់ជ័រវាដោយម្រាមពីរ វានឹងតោងស្អិត ។ បើគេយកជ័រវាមកតៀ្បតក្លៀក វាធ្វើឱ្យក្លៀកស្អិតជាប់គ្នាពិបាកបង្ហើប និងធ្វើឱ្យរំខានក្នុងការជំរះជ័រវា ។

☞ **អត្ថប្បដិរូប**

"**ជ័រខ្លៅ**" នៅពេលនេះលោកប្រៀបដូចជារឿងរ៉ាវផ្សេងៗ ដែលនាំមកនូវទុក្ខទោសដល់ខ្លួនដោយសារតែ កង្វះខាតការពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយ ។ ដូចជា :

- គេឈ្លោះគ្នាតែគេសោះ មិននៅឱ្យស្ងៀមទេ ខំដើរទៅជួយកាត់ក្ដីឱ្យគេ ។ ទីបំផុតបានឡើងសាលាក្ដីធ្វើសាក្សីឱ្យគេទៅ ។

- មានមិត្តម្នាក់យកម៉ូតូមកផ្ញើ បីម៉ោងក្រោយមកប៉ូលិសមករឹបអូសយកម៉ូតូនោះទៅវិញ ។ ព្រោះចោរលួចយកមក បន្ទាប់មកក៏មានបញ្ហានឹងគេទៅ ។

- គ្រួសារមួយ សុំកូនគេយកមកចិញ្ចឹម ។ កូននោះឈឺរហូត អស់ប្រាក់ព្យាបាលជាច្រើន ។

ករណីអស់នេះហើយដែលលោកពោលថា : "**នៅមិននៅ ដើរទៅយក ជ័រខ្លៅមកតៀ្បតក្លៀក** " ៕

*ថ្ងៃទី ១៧-១២-០៦*

# ២៧៨. មឹះៗកេះឆ្លាំងផ្ទះ

**និយមន័យ**

មនុស្សធ្វើឫកទុយមុយ ច្រើនមានពុតត្បុត

**អត្ថាធិប្បាយ**

គេមិនអាចវាយតំលៃមនុស្សត្រឹមតែសំបកក្រៅបានទេ ។ ព្រោះឫកពាមនុស្សមានមនោកម្ម, វចីកម្ម និងកាយកម្មពុំស្របគ្នាទាំងអស់ទេ ។ មនុស្សខ្លះមើលឃើញកាយវិការហាក់ដូចពុំសូវសមរម្យបន្តិចមែន តែចិត្តល្អ ។ ខ្លះទៀតធ្វើឫកពាសមរម្យគួរឱ្យរាប់អាន តែចិត្តខ្មៅអប្រិយ ។

នៅក្នុងន័យខាងលើនេះ លោកពោលសង្កត់ទៅលើមនុស្សដែលមានសភាពទុយមុយ មឹះៗរុយទំមិនបក់ ។ មនុស្សបែបនេះ ច្រើនតែជាមនុស្សលាក់ពុតត្បុតគំនិតខិលខូច ។ កាលណា មានអ្នកភាន់ច្រលំយល់ខុសថាជាមនុស្សមានសីលមានធមិប្រាកដជាខកចិត្ត ឬខកខ្លួនមិនខាន ។ ដូចជា :

- អ្នកមេម៉ាយម្នាក់ យល់ដោយភាន់ច្រឡំថាជាមនុស្សល្អត្រឹមត្រូវ, ជាសភាពបុរស បានឱ្យផ្ទះស្នាក់មួយយប់ ស្រាប់តែយប់ហ្នឹងខ្ទេចទាំងអស់ ។
- អ្នកខ្លះទុកចិត្តឱ្យនៅផ្ទះស្ងាត់ៗជាមួយកូនក្រមុំ មានអីខ្ទេចដូចគ្នា ។

ហេតុនេះហើយបានជាមានពាក្យស្លោកមួយថែងថា :

*មឹះៗធ្វើមុខរាបរមទម្យ កេះកៀវក្រមុំក្នុងទីស្ងាត់*
*ឆ្មាំងបាយកកាយយកទៅបាត់ ផ្ទះធ្លាយប្រយ័ត្នមនុស្សធុនហ្នឹង ៕*

*ថ្ងៃទី ២៧-១០-០៦*

# ២៧៩. មនុស្សគេយកសំដី ដំរីគេយកភ្លុក

## និយមន័យ

តំលៃរបស់មនុស្ស និងសត្វ

### អត្ថាធិប្បាយ

☞ **មនុស្សគេយកសំដី**

គោលបំនងរបស់ខ្លឹមសារនេះ លោកមិនសំដៅយកមនុស្សចេះដឹង ឬល្ងង់ខ្លៅអ្វីទេ គឺលោកយកពាក្យសំដីរបស់មនុស្សដែលប្រកបដោយគតិបណ្ឌិត, និយាយពាក្យថ្លៃថ្នូរប្រាកដនិយម មានសច្ចភាពមិនបាតដៃជាខ្នងដៃ ។ ទោះបីមនុស្សនោះល្ងង់ខ្លៅក៏ដោយឱ្យតែប្រកាន់ខ្ជាប់នូវពាក្យសំដីរបស់ខ្លួនឱ្យបានប្រាកដប្រជា ក៏លោកចាត់ទុកថាជាសំដីយកជាការបានដែរ ។ ផ្ទុយទៅវិញ បើមនុស្សដែលមានចំនេះដឹងច្រើន ។ ប៉ុន្តែសំដីនិយាយគ្មានសច្ចភាព បាយបិណ្ឌជាបាយបាត្រលោកថា សំដីនេះគ្មានតំលៃអ្វីបន្តិចទេ ។

☞ **ដំរីគេយកភ្លុក**

ពាក្យចាស់លោកពោលថា មួយតួខ្លួនដំរីគ្មានកន្លែងត្រង់ណា មានតំលៃស្មើនឹងភ្លុកវាទេ ។

ដោយសារយ៉ាងនេះហើយ បានជាគេឃើញព្រានប្រមាញ់ដើរស្វែងរកសត្វដំរីណាដែលមានភ្លុកធំល្អ ។ ព្រោះឈ្មួញហ៊ានឱ្យតំលៃខ្ពស់ណាស់ ដោយសារគេយកទៅរចនាជាក្បាច់ក្បូរដាក់តាំងលម្អក្នុងគេហដ្ឋានពួកអភិជន ។

អាស្រ័យយ៉ាងនេះហើយ ទើបលោកថា *ដំរីគេយកភ្លុក* ៕

*ថ្ងៃទី ២៦-១០-០៦*

# ២៨០. មាន់ពងលើស្រូវ តែងស៊ីស្រូវ

**និយមន័យ**

កាន់ការងារអ្វី តែងកេងយកផលប្រយោជន៍ពីការងារនោះ

**អត្ថាធិប្បាយ**

**ꕥ អត្ថានុរូប**

សត្វមាន់តែងពងក្នុងសំបុក តែសំបុកដែលវាចូលចិត្តជាងគេគឺនៅក្នុងដោក ឬក្នុងជង្រុកស្រូវ ។ ព្រោះស្រូវអាចជួយសំរួលក្នុងការភ្ញាស់កូនផង ជួយសំរួលក្នុងការចិញ្ចឹមជីវិតផង ។

ក្នុងរយៈកាលក្រាបពង ២១ថ្ងៃនេះ វាមិនចុះទៅណាផ្តេសផ្តាសទេ ។ ព្រោះដើម្បីបង្កចកំដៅភ្ញាស់កូន ។ យូរៗវាចុះទៅរកចំនីម្តង ។ ប៉ុន្តែ បើមានស្រូវជាចំនីហើយវាមិនចុះទេ គឺវាស៊ីស្រូវនោះតែម្តង ។

**ꕥ អត្ថប្បដិរូប**

"មាន់" លោកប្រៀបដូចមនុស្សខ្លះដែលកាន់ការនៅកន្លែងណាមួយ កាលណាគេស្ទាបស្ទង់ដឹងក្រលុកក្រលៀត គឺគេដឹងថាត្រង់ណាអាចទាញយកផលប្រយោជន៍បាន គេក៏បេះបោចកេងយកប្រយោជន៍កន្លែងនោះ ។ ដូចជា :

- អ្នកគ្រប់គ្រងពូជស្រូវរដ្ឋ គេចេះធ្វើបញ្ជីចេញ-ចូល ចុះឡើង-ចុះឡើង គេក៏

លៃលករកកំរៃក្រៅបាន ។

- អ្នកកាន់លុយឥណទានខេត្ត-ក្រុង គេចេះធ្វើបញ្ជីបង្វិលចុះបង្វិលឡើង គេក៏មានជីវភាពធូរធារគ្រាន់បើដែរ ។

- អ្នកកាន់ឃ្លាំងសម្ភារៈកងឯកភាព ។ គេឃើញសម្ភារៈនោះលក់នៅទីផ្សារព្រោងព្រាត ។

ករណីនេះហើយ ដែលលោកថា *នៅត្រង់ណាស៊ីត្រង់នោះ* ៕

*ថ្ងៃទី ៣០-១០-០៦*

✿✿✿✿



# ២៨១. មនុស្សឈ្លោះគ្នាមិនគិត ទៅគិតឯស្គរកំបែកមាត់

**និយមន័យ**

ត្រូវគិតដោះស្រាយរឿងធំមុនរឿងតូច

**អត្ថាធិប្បាយ**

▣ **អត្ថានុរូប**

"**ស្គរកំបែកមាត់**" នៅពេលនេះ លោកទុកដូចជា "ករណី" តូចតាច កំប៉ិកកំប៉ុក ។

ធម្មតាមនុស្សឈ្លោះគ្នា ជួនកាលក៏ងាយដោះស្រាយ ជួនកាលក៏ពិបាកដោះស្រាយ ដូចជាការវិវាទបង្កឱ្យមានរបួសស្នាម ឬដឹកចូលមន្ទីរពេទ្យ ។

ដូចនេះ លោកឱ្យគិតគូរឿងមនុស្សធំៗឈ្លោះគ្នាសិនសឹមទៅគិតរឿងក្មេងៗ ឈ្លោះគ្នា ឬរឿងចោរលួចចេក លួចមាន់ជាក្រោយ ។

▣ **អត្ថប្បដិរូប**

ពំនោលនេះ លោកចង់និយាយពីរឿងរ៉ាវណាដែលស្មុគស្មាញដូចជា ករណីសន្តិសុខសង្គមមានចោរកម្ម ចោរប្លន់, ឃាតកម្ម, ជួញដូរមនុស្ស, ការកាប់បំផ្លាញព្រៃឈើ, បញ្ហាសាងសង់មន្ទីរពេទ្យ, សង់សាលារៀន, ស្ពានស្ពាន, ផ្លូវថ្នល់ និងធារាសាស្ត្រ ។ល ។

បញ្ហាអស់ទាំងនេះ អាជ្ញាធរត្រូវតែគិតគូរដោះស្រាយជាមុន ។ ឯរឿងណាដែលអាចពន្យាបានគួរទុកដោះស្រាយទៅថ្ងៃក្រោយដូចជា ជម្លោះប្ដឹងផ្ដល់គ្នាពីរឿងព្រំដីប្រវែងមួយចំអាម, ពីរចំអាម និងដណ្ដើមដើមត្នោតមួយដើមនៅត្រង់ព្រំដីជាដើម ៕

*ថ្ងៃទី ២៨-១២-០៦*

# ២៨២. មុជមិនជ្រៅ ទៅមិនឆ្ងាយ

**និយមន័យ**

មនុស្សល្ងង់ ប្រាជ្ញាអាប់

## អត្ថាធិប្បាយ

មនុស្សដែលមានលក្ខណៈដូចពំនោលថា មុជមិនជ្រៅ ទៅមិនឆ្ងាយនេះច្រើនជាមនុស្សល្ងង់ ។ មនុស្សល្ងង់ប្រភេទនេះ ទោះនឹងធ្វើការងារអ្វីក៏មិនស៊ីជំរៅដែរ ។ គេធ្វើការងារណាដែលគេបង្គាប់ឱ្យធ្វើ ។ ជួនកាលការងារខ្លះ គេប្រាប់គេពន្យល់ យ៉ាងណាក៏នៅតែធ្វើពុំកើតដែរ ។ ព្រោះគេគ្មានគំនិតចេះត្រិះរិះពិចារណា ជួយច្នៃប្រឌិតផ្សំផងទេ ។

បើត្រូវចេញទៅរកស៊ីនៅឆ្ងាយវិញ គឺគេទៅលែងបានតែម្ដង គេសុខចិត្តតែពីនៅខ្ចិចខ្ចិល-ខ្ចិចខ្ចិលក្បែរផ្ទះរហូត ។ ប្រសិនបើគេមានប្រពន្ធវិញ គឺគេសុខចិត្តឱ្យប្រពន្ធធ្វើមេបញ្ជាការចុះ ឯខ្លួនគេ គឺជាកូនទាហានដ៏ស្មោះត្រង់ម្នាក់ដែលរង់ចាំតែទទួលបញ្ជា ។

មនុស្សប្រភេទនេះ ច្រើនតែជាមនុស្សល្ងង់មានចរិតស្លូតបូតដូចសំលោកថែងថា *ស្លូតស្លាប់* ។ ប៉ុន្តែ បើបែរជាកាចយង់ឃ្នងវិញ គឺឆ្កួតសោះតែម្ដង ៕

*ថ្ងៃទី ០១-១០-០៦*

❁❁❁❁

# ២៨៣. មិនជឿពាក្យចាស់ ស្រលះដៃធេង

**និយមន័យ**

មនុស្សចាស់ឆ្លងកាត់បទពិសោធន៍ច្រើន

**អត្ថាធិប្បាយ**

ពាក្យនេះ ជាពាក្យសំរាប់ព្រមានអ្នកណាម្នាក់ធ្វើអ្វីមួយដែលមនុស្សចាស់មើលទៅឃើញថា អាចនឹងមាន ផលវិបាកកើតឡើងដោយប្រការណាមួយ ។

ឧទាហរណ៍ :

យុវជនពីរ-បីនាក់ បបួលគ្នាទៅរកស៊ីរត់ពន្ធប្រេងសាំង ។

ចាស់ៗបានដឹងហើយក៏ឃាត់មិនឱ្យទៅ ។ ប៉ុន្តែក្មេងៗទាំងនោះមិនស្តាប់ទេ ខ្លះគ្មានលុយប្រឹងខ្ចីមិត្តភក្ត្រ, ខ្លះទៀតខ្ចះកកាយពីម៉ែឪ ។ លុះទៅទិញសាំងបានមកនាំគ្នាសប្បាយចិត្តណាស់ ព្រោះគិតថាបានចំនេញគ្រាន់នឹងទិញសៀវភៅរៀន ។ ពេលមកដល់កន្លែងឆែកឆេរ គេចាប់យកអស់ ទោះជាខំអង្វរ-ក គេយ៉ាងណាក៏ដោយ ។

ដូច្នេះ គេមកផ្ទះវិញទាំងហេវហត់ជាពិសេសគេអស់រលីងពីខ្លួន គឺនៅតែបាតដៃទទេ។

ចាស់ៗដឹងហើយក៏បន្ទោសថា ហ្នឹងហើយអញថាកុំទៅវាមិនជឿពាក្យចាស់ ឥលូវស្រលះដៃធេង អីចឹងក៏ស្រួលម្យ៉ាងដែរ វាមិនពិបាកយួរសាំងមកផ្ទះនាំធ្ងន់ ៕

*ថ្ងៃទី ០២-១១-០៦*

❀❀❀❀

# ២៨៤. មាត់ចាប មាត់ព្រាប

**និយមន័យ**

ការនិយាយបន្តគ្នាពីមាត់មួយទៅមាត់មួយ និងគ្មានប្រភពច្បាស់ការណ៍

**អត្ថាធិប្បាយ**

ពាក្យទំនឹមទំនៀមនេះ គឺជាពាក្យដែលលោកចង់ពោលថា ពតិមានខ្លះគ្មានប្រភពច្បាស់ការណ៍ទេ ចេះតែឮត១គ្នាមកក៏មាន ។ គេមិនអាចដឹងបានថាមនុស្សមួយណាឈ្មោះអីនិយាយទេ ។ ដោយមិនច្បាស់ដូច្នេះ គេក៏ទំលាក់ទៅលើមាត់ចាបផងមាត់ព្រាបផងទៅ ។

ម្យ៉ាងទៀតក្នុងន័យនេះដដែល លោកចង់ពោលថាទំរើអាក្រក់ដែលគេប្រឹងលាក់មិនងាយលាក់ជិតទេ ។ ព្រោះមាត់ចាប មាត់ព្រាប ចេះតែនិយាយត១គ្នាឮឆ្ងាយណាស់ មិនយូរប៉ុន្មានគង់គេដឹងសុះសាយមិនខាន ។

រឿងខ្សិប, រឿងសំងាត់ ដែលគេខំលាក់បិទបាំងមនុស្សលោកតែងចង់ដឹង, ចង់ស្តាប់, ចង់ឃើញ និងចង់ស្ទាបណាស់ ។

ដូច្នេះមាត់ចាប មាត់ព្រាប លោកសំដៅយករឿងណាដែលមនុស្សនិយាយតែរកមុខអ្នកនិយាយមួយណា ឱ្យច្បាស់ពិតប្រាកដមិនឃើញ ៕

*ថ្ងៃទី ០២-១១-០៦*

❀❀❀❀

# ២៨៥. មេម៉ាយកូនមួយដូចត្រួយលំពស់

**និយមន័យ**

សោភណភាពអ្នកមេម៉ាយកូនមួយ

**អត្ថាធិប្បាយ**

"**លំពស់**" គឺជាឈើតូចមួយប្រភេទ ដើមស្មើរវល្លិ ស្លឹកស្រួចស្តើង ត្រួយវាប្រើជារបោយ ឬអន្លក់បានឥតមានរសជាតិចត់, ល្វីងទេ ។

ពាក្យទំនឹមទំនៀមនេះ ជាពាក្យកំប្លែងសំរាប់និយាយសើចលេងចំអែចំអន់ឱ្យអ្នកមេម៉ាយកូនមួយដែលមានរូបសម្ផស្សស្រស់ត្រកាល ។

តាមទំលាប់មកគេតែងនិយាយថា ស្រីក្រមុំប្រៀបដូចផ្កាក្រពុំ ឯមេម៉ាយកូនមួយប្រៀបដូចផ្កាកំពុងរីក ។ ម្លោះហើយផ្កាក្រពុំនឹងផ្ការីក គេឃើញផ្កាកំពុងរីកស្រស់ស្អាតជាង និងមានក្លិនពិដោរក្រអូបផង ។ គេថាអ្នកមេម៉ាយកូនមួយកំពុងបែកសាច់លេចចេញរូបរាងមើលឃើញគួរឱ្យខ្នាញ់ ។ ប៉ុន្តែ លោកដូចជាមិនឃើញសរសើរអ្នកមេម៉ាយកូនពីរផង ប្រហែលជាលោកភ្លេច ឬក៏យល់ថាហួសដេឡេក៏មិនដឹង ។

នេះជាមតិយោបល់ក្នុងនិយមន័យខាងលើ ឯអ្នកមានមតិផ្ទុយស្រេចលើគេចុះ ៕

*ថ្ងៃទី ០២-១១-០៦*

❀❀❀❀

# ២៨៦. មុននឹងជួយគេ ត្រូវជួយខ្លួនឯងសិន

## និយមន័យ

គិតប្រយោជន៍ខ្លួនឯងសិន សឹមគិតប្រយោជន៍គេ

## អត្ថាធិប្បាយ

បុរាណាចារ្យបានទូន្មានថា បើអ្នកមានសមានចិត្តខ្ពស់ចង់ជួយទុក្ខធុរៈដល់អ្នកដទៃឱ្យមានបានប្រកបដោយផាសុកភាព ។ អ្នកគប្បីគិតគូរដល់ជីវភាពខ្លួនអ្នកឱ្យបានប្រសើរជាមុនសិន ។ គឺឱ្យមានផ្ទះសំបែងត្រឹមត្រូវ និងផ្គត់ផ្គង់ប្រពន្ធកូនឱ្យមានជីវភាពសមរម្យ សឹមយកកំលាំងកាយ កំលាំងប្រាជ្ញាទៅជួយអ្នកដទៃទើបជាការគួរ ។ ព្រោះ បើខ្លួនឯងបានព្រឹកខ្វះល្ងាច តើមានប្រយោជន៍អ្វីដើរទៅជួយគេ ។

មានបេក្ខជនតំណាងរាស្ត្រខ្លះឃោសនាថា ខ្លួនគេសុខចិត្តលះបង់ប្រយោជន៍ខ្លួនដើម្បីទៅបំរើប្រយោជន៍រាស្ត្រ ។ សំដីនេះមានតែមនុស្សអវិជ្ជាទេដែលមានជឿខ្លះ។ ការណ៍ពិត ជួយខ្លួនឯងម្នាក់មិនបានផង ទំរាំទៅជួយគេជាច្រើននាក់ទៀតនោះ ។

ករណីជួយខ្លួនឯងមុននេះ សូម្បីតែព្រះបរមគ្រូក៏ព្រះអង្គជួយខ្លួនព្រះអង្គមុនដែរ ដូចជាទ្រង់ជួយខ្លួនព្រះអង្គ ឱ្យដល់នូវអនុត្តរសម្មាសម្ពោធិញ្ញាណ គឺត្រាស់ដឹងនូវចតុរារិយសច្ចរួចហើយ ទើបព្រះអង្គយាងទៅប្រោសបញ្ចវគ្គិយភិក្ខុជាក្រោយ ៕

*ថ្ងៃទី ០៣-១១-០៦*

❀❀❀❀

# ២៨៧. មានប្រឡាយទើបទឹកវាហូរ មានសំរាមទើបឆ្កែវាជុះ

**និយមន័យ**

មានហេតុ ទើបមានផល

## អត្ថាធិប្បាយ

### ◻ អត្ថានុរូប

ទឹកហូរពីទីខ្ពស់ទៅកាន់ទីទាបតាមប្រឡាយ ឬរង្វះទឹក ។ បើពុំមានចង្អូរ រឺគន្លងនាំទឹកឱ្យហូរបានទេ ទឹកនឹងដក់នៅមួយកន្លែង ។

ឯឆ្កែចូលចិត្តជុះនៅកន្លែងណាដែលមានសំរាម ព្រោះមានក្លិនស្អុយ ។ ប៉ុន្តែឆ្កែឥលូវនេះ ត្រង់ណាក៏ជុះបានដែរ ។

### ◻ អត្ថប្បដិរូប

ន័យខាងលើនេះ លោកយក **ផល** ភ្ជាប់ទៅនឹង **ហេតុ** ព្រោះផលកើតមានឡើងក៏អាស្រ័យនឹងហេតុ ។ បើគ្មានហេតុ-ផលក៏គ្មានដែរ ។ ដូចជា :

- គ្រោះថ្នាក់ចរាចរណ៍ជាហេតុ ។ ដឹកចូលមន្ទីរពេទ្យ ឬចូលប៉ាឆាជាផល ។

សំរាម លោកប្រៀបទៅនឹងរឿងអាស្រូវភាស ។ ឆ្កែជុះដាក់ គឺសំអប់របស់មហាជន ។ ដូចជា :

- មន្ត្រីម្នាក់ប្រព្រឹត្តអំពើពុករលួយរមែងទទួលបាននូវការជេរប្រទេចផ្ដាសាពីសំនាក់មហាជនគ្រប់មជ្ឈដ្ឋាន ។

- អ្នកអគតិ, អ្នកអយុត្តិធម៌, អ្នកពុករលួយ គឺជាសំរាម ។ កាលណាមានទោសទណ្ឌ, អ្នកតូចតាចតែងចោមរោមនាំគ្នាសាធុ គឺដូចជានាំគ្នាជុះអាចម៍ដាក់ក្បាលបន្ថែមទៀតដូច្នោះឯង ៕

*ថ្ងៃទី ០៥-១១-០៦*

✿✿✿✿



# ២៨៨. មាន់ព្រៃកំចាយមាន់ស្រុក

**និយមន័យ**

អ្នកក្រៅ ឬអ្នកចំនូលថ្មីចូលមកជំនួសអ្នកមូលដ្ឋាន

**អត្ថាធិប្បាយ**

ពាក្យនេះ ពុំមែនជាពាក្យអប់រំ ឬប្រៀនប្រដៅអ្វីទេ គឺជាពាក្យកើតឡើងដោយក្ដីខឹងក្រេវក្រោធរបស់អ្នករងគ្រោះ ។

មាន់ព្រៃលោកប្រៀបទុកដូចអ្នកក្រៅអង្គភាព រឺអ្នកចំនូលថ្មី ឯមាន់ស្រុកលោកប្រៀបដូចអ្នកមូលដ្ឋាន ។ ដូចជា :

- នៅក្នុងអង្គភាពមួយមានអ្នកចំនូលថ្មីផ្លាស់មក ។ អ្នកថ្មីនេះបានខ្សឹបខ្សៀវនឹងលោកប្រធានឱ្យដកបុគ្គលិកចាស់ម្នាក់ចេញដើម្បីខ្លួនចូលធ្វើការជំនួសវិញ ។

- ប្រធានអង្គភាពរដ្ឋបាលម្នាក់ធ្វើការយូរមកហើយបានត្រូវអ្នកក្រៅអង្គភាពចូលមកដេញថ្លៃយកតួនាទីប្រធាននេះបាត់ទៅ ។

- អ្នកចំនូលស្រុកម្នាក់បានចូលមកបំបែកបំបាក់អ្នកមូលដ្ឋាន ដើម្បីខ្លួនធ្វើជាអ្នកមុខអ្នកការក្នុងទីនោះ ។

ការដែលលោកប្រៀបធៀបដូចមាន់ព្រៃកំចាយមាន់ស្រុកនេះ សុទ្ធតែចូលមកតាមរយៈមនោសញ្ចេតនាជាបងប្អូន ឬមិត្តភក្ដិ ។ ជាពិសេស ចូលតាមផ្លូវងងឹតទើបកំចាយមាន់ស្រុកបាន ។

ការចូលដោយខុសធម្មតានេះហើយ ទើបកើតពាក្យនេះឡើង ៕

*ថ្ងៃទី ០៦-១១-០៦*

# ២៨៩. មានប្រាក់ទិញយក្សប្រើ

**និយមន័យ**

ឥទ្ធិពលរបស់ទឹកប្រាក់

**អត្ថាធិប្បាយ**

នេះមិនមែនជាពាក្យសុភាសិតបុរាណាចារ្យ ហើយក៏មិនមែនជាពាក្យទំនឹមទំនៀមមានយូរហើយនោះដែរ ។ គឺជាពាក្យពំនោលដែលម្នាក់ៗបង្កើតឡើងដោយចាញ់អំនាចទឹកប្រាក់ ។

គោលបំនងអ្នកទាំងអស់គ្នាដែលពោលពាក្យនេះឡើង ក៏ដោយសារតែមានការស្ងើចសរសើរនូវឥទ្ធិពលទឹកប្រាក់ថា ជាអាទិទេពដែលអាចជបនូវរបស់អ្វីៗបានសមតាមបំនងប្រាថ្នា ។

ហេតុនេះហើយ បានជាអ្នកទាំងអស់គ្នាពោលពាក្យនេះដូចៗគ្នាគ្រប់មជ្ឈដ្ឋានថាឱ្យតែមានលុយយកសង្សារបិសាចក្រមុំក៏បានដែរ ។

ការណ៍ពិត លុយអាចជួយសំរេចបំនងបានដូចចិត្តពិតប្រាកដមែន ប៉ុន្តែលុយមិនអាចទិញទឹកចិត្តស្នេហាបានទេ ។ ដូចជា :

- មហាសេដ្ឋីម្នាក់មានសម្បត្តិមហាសាលអាយុជាង ៨០ឆ្នាំទៅហើយ គាត់ទៅយកបវរកញ្ញាអាយុ ១៨ឆ្នាំមកធ្វើប្រពន្ធ ។ នាងនោះសុខចិត្តមកធ្វើជាប្រពន្ធបង្កើត

បានកូនពូនជាចៅមែន ។ ប៉ុន្តែ ទឹកចិត្តស្នេហាទៅលើតានោះគ្មានទេ ។ ហេតុនេះហើយ បានជានៅពេលសមស្រប នាងចេះតែឆក់ឱកាសទៅជួបប្រុសស្អាតកំពុងពេញវ័យជាញឹកញាប់ ។

ករណីនេះ បញ្ជាក់ឱ្យឃើញថាលុយ ឬសម្បត្តិមហាសាលពុំប្រាកដថាមានសុភមង្គលទាំងអស់ទេ ៕

*ថ្ងៃទី ០៦-១១-០៦*

✿✿✿✿



# ២៩០. មានដំបៅរុយរោម

## និយមន័យ

មនុស្សមានកំហុស តែងហ៊ុំព័ទ្ធដោយបញ្ហាចោទ

## អត្ថាធិប្បាយ

### ៣ អត្ថានុរូប

"**ដំបៅ**" គឺជាសាច់ស្អុយរលួយដែលមាននៅលើសាច់ល្អរបស់មនុស្ស ឬសត្វ ។ កាលណាគោ ឬមនុស្សមានដំបៅតែងធុំក្លិនស្អុយ ។ សំអុយ គឺជាការទាក់ទាញឱ្យរុយមកចោមរោម ។

### ៣ អត្ថប្បដិរូប

មនុស្ស កាលណាបានប្រព្រឹត្តអំពើទុច្ចរិតលាមកអ្វីមួយហើយ មហាជនតែងនាំគ្នាស្អប់ខ្ពើម ឬនាំគ្នាចោមរោម ចោទកំហុសទំលាក់បន្ថែមជាច្រើនទៀត ។ ដូចជា :

- ចោរដែលសមត្ថកិច្ចចាប់បានពីបទលួច ឬប្លន់ម៉ូតូគេ ។ មហាជនដែលបាត់ម៉ូតូ នាំគ្នាមកចោមរោមចោទ ប្រកាន់ពីលើមូលទោសនេះបន្ថែមទៀត ។

- មន្ត្រីពុករលួយម្នាក់ដែលស៊ីសំនូកគ្មានរើសមុខ តែគ្មាននរណាម្នាក់ហ៊ានចេញមុខប្ដឹង ឬតវ៉ាទេ ព្រោះខ្លាចអំនាច ។ ថ្ងៃមួយសមត្ថកិច្ចចាប់បាន រួចបកសក្តិចេញ ។ ពេលនោះ អ្នករងគ្រោះទាំងប៉ុន្មាន នាំគ្នាមកចោមរោមចោទប្រកាន់ត្រួតពីលើ

មូលទោស របស់ជនកំហូចនេះបន្ថែមទៀត ។

ដូច្នេះហើយបានជាលោកថា មនុស្សអាក្រក់ពេលណាមានពិរុទ្ធកម្មដែលលោកទុកដូចជាដំបៅស្អុយ តែងមានរុយគឺអ្នករងគ្រោះមកចោមរោមជាច្រើន ដើម្បីចោទប្រកាន់បន្ថែមទៀត ៕

*ថ្ងៃទី ០៦-១១-០៦*

❀❀❀❀



# ២៩១. មានភ្លើង ទើបមានផ្សែង

**និយមន័យ**

ពាក្យចចាមអារ៉ាមភ្ជាប់ទៅនឹងមូលហេតុ

## អត្ថាធិប្បាយ

កាលណាមានផ្សែង គឺមានធាតុភ្លើងជាដើមហេតុ ។ ក្នុងន័យនេះ លោកចង់ពោលថា រឿងរ៉ាវអ្វីក៏ដោយ ដែលលេចឮត១គ្នាពុំទាន់ពិតប្រាកដថាចេញពីប្រភពណា លោកទុកដូចជាផ្សែង ។

គោលបំនងរបស់លោកចង់ពោលថា កាលណាមានពាក្យចចាមអារ៉ាម ពិតមែនតែមិនទាន់ច្បាស់ក៏ដោយ ក៏លោកសន្មត់ថាច្បាស់ជាមានមូលហេតុជាដើមភ្លើងមិនខាន ។ ឧទាហរណ៍ :

- មុនឆ្នាំ ៧៥ មានពាក្យចចាមអារ៉ាមថា បន្តិចទៀតប្រទេសខ្មែរនឹងក្លាយទៅជាប្រទេសកុំមុយនីស្តហើយ គេលែងចាយលុយហើយ. គ្មានទេព្រះសង្ឃ. គេរៀបការម្តងពី ៥០ទៅ ៦០គូ... ម្នាក់១នាំគ្នាសើចហួសចិត្ត គឺមិនជឿទាល់តែសោះ ។

លុះថ្ងៃ ១៧ មេសា សុបិនក្លាយជាការណ៍ពិត ។

- នៅចុងឆ្នាំ ៧៨ មានពាក្យខ្សឹបខ្សៀវថា ខ្មែរយើងជិតរួចផុតពីនរកលោកិយហើយ ។

លុះដល់ថ្ងៃ ៧ មករា ៧៩ ខ្មែរបានរួចផុតពីនរក បីឆ្នាំប្រាំមីខែដប់ប្រាំបួនថ្ងៃ ១២ម៉ោង និងសាមសិបនាទីពីពួកទមិឡឥតសាសនាខ្មែរក្រហមមែន ៕

*ថ្ងៃទី ០៧-១១-០៦*

# ២៩២. មេម៉ាយ ចំនាយពាក្យ

**និយមន័យ**

ស្ត្រីមេម៉ាយតែងទទួលរងនូវពាក្យលែបខាយពីភេទផ្ទុយ

**អត្ថាធិប្បាយ**

ពាក្យទំនឹមទំនៀមនេះ លោកពោលចំពោះទៅលើស្ត្រីមេម៉ាយ ។ ព្រោះស្ត្រីមេម៉ាយគឺជាស្ត្រីដែលបើករបាំងមុខរួចហើយ ផ្ទុយពីស្ត្រីក្រមុំដែលនៅមានប្រពៃណីទំនៀមទំលាប់ការពារ ។

ម្ល៉ោះហើយ ពួកប្រុសៗចាស់ក្មេងតែងហ៊ាននិយាយលេងបែបឡកឡឺយញ៉េះញ៉ោះនាយអោយពុំសូវគិតក្រែងចិត្តប៉ុន្មានទេ ។ បើនាងមេម៉ាយនោះនៅក្មេង ប្រកបដោយសោភណភាពស្រស់បស់ថែមទៀតផងនោះ អន្ទិតប្រុសៗរឹតតែចែចប់ប្រែលែបខាយនាយអោយមិនចេះចប់ ។

ម្យ៉ាងទៀត បើនាងមានភាពស្និទ្ធស្នាលនឹងបុរសណាម្នាក់ដោយស្មោះត្រង់ក៏ដោយ រមែងមានពាក្យដៀមដាមរិះគន់ពីមជ្ឈដ្ឋានផ្សេងៗថាអ៊ីចេះអ៊ីចុះជានិច្ច ។

មួយវិញទៀត បើមានពាក្យផ្ដេផ្ដាចំអែចំអន់មករកនាងបែបរាងខ្លាំងបន្តិចនាងតែងមានប្រតិកម្មតបវិញខ្លះៗ មិនខាន ។

ការដែលមានពាក្យលែបខាយមកលើនាង និងពាក្យប្រតិកម្មតប វិញនេះហើយដែលលោកថា *មេម៉ាយចំនាយពាក្យ* ៕

*ថ្ងៃទី ០៨-១១-០៦*

# ២៩៣. ម៉ែឪថែកូនដូចចង្ហាប្រដេញ កូនថែម៉ែឪវិញដូចព្រះប្រែក្រោយ

**និយមន័យ**

ទឹកចិត្តម៉ែឪចិញ្ចឹមកូន និងទឹកចិត្តកូនចិញ្ចឹមម៉ែឪ

**អត្ថាធិប្បាយ**

- **ម៉ែឪថែកូនដូចចង្ហាប្រដេញ**

"**ចង្ហា**" គឺជាត្រីតូចៗមានស្រកា ។ បើគេបោះដុំបាយមួយដុំទៅ វាតែងស្ទុះរហាន់ដើម្បីដណ្តើមគ្នាស៊ី ។ ប៉ុន្តែ បើគេធ្វើឱ្យវាផ្អើលតែបន្តិចវាហែលស្ទុះប្រដេញគ្នាយ៉ាងរញ៊ីករញ៉ៃពាក់ពពូនគ្នាប្រសេចប្រសាចទៅបាត់អស់ភ្លាមដែរ ។

ត្រង់នេះហើយ ដែលលោកលើកយកមកធ្វើការប្រៀបធៀបដូចមានចែងខាងលើថា ឪពុកម្តាយចិញ្ចឹមកូន, ស្រលាញ់កូន និង ថែថ្នាក់ថ្នមកូនប្រៀបដូចត្រីចង្ហាប្រដេញគ្នា ។

ម្យ៉ាងទៀតបើគាត់មានកូនច្រើនចំនួន ១០នាក់ក៏ដោយក៏គាត់ចិញ្ចឹមរស់ដែរ ។ ព្រោះគាត់យល់ថានេះគឺ ជាកូនឯកជនរបស់គាត់ទាំងពីរនាក់ប៉ុណ្ណោះ ។

- **កូនថែម៉ែឪវិញដូចព្រះប្រែក្រោយ**

"**ព្រះប្រែក្រោយ**" លោកពោលថាព្រះពុទ្ធបដិមាដែលគេតម្កល់ក្នុងព្រះវិហារក្តី ក្នុងទីសក្ការៈនានាក្តី គេមិនដែលឃើញព្រះបដិមាទាំងអស់អង្គនោះចេះបែរប្រែក្រោយឡើយ ។

ហេតុនេះហើយទើបលោកយកន័យប្រៀបធៀបថា ពេលកូនថែរក្សា និង ចិញ្ចឹមម៉ែឪវិញបែបរាងតឹងមិនដូចកាលគាត់ចិញ្ចឹម និង ថែរក្សាកូនទេ គឺប្រៀបដូចព្រះពុទ្ធបដិមាមិនចេះប្រែត្រលប់មកក្រោយដូច្នោះឯង ។

ការណ៍នេះ មកពីគេយល់ថា ខ្លួនគេក៏ជាប់ចិញ្ចឹមកូនគេដែរ ម្យ៉ាងទៀតគេគិតថា ការណ៍ដែលម៉ែឪចិញ្ចឹមកូន គឺជាភារកិច្ចដែលត្រូវតែចិញ្ចឹមតៗគ្នា អ្នកណាបង្កើតកូនត្រូវតែចិញ្ចឹមកូនដូច្នោះឯងហើយ គ្មានគុណស្រ័យអ្វីទេ ។

ការណ៍ពិតម្យ៉ាងទៀត មកពីកូនៗទាំងអស់នោះប្រចាំជើងគ្នា ព្រោះគេយល់ថា មិនមែនម៉ែឪតែម្នាក់អញទេ គឺជាម៉ែឪសម្ហូហភាព ។ ត្រង់នេះហើយដែលលោកថា *កូន១០នាក់ចិញ្ចឹមម៉ែឪមិនរស់ទេ* ៕

*ថ្ងៃទី ០៤-១២-០៦*

ចៅ នីថា ចូលគេងមន្ទីរពេទ្យចំការចេកក្រុងព្រះសីហនុ

- កាលម៉ែនៅក្រមុំ ម៉ែខ្មាសអៀនណាស់
  ដល់ម៉ែមានកូន ម៉ែសើយអាវឱ្យកូនបៅទីណាក៏បាន
- កាលម៉ែនៅក្រមុំ អ្នកណាធ្វើឱ្យប្រឡាក់សំពត់ម៉ែតែបន្តិច ម៉ែខឹងណាស់
  ដល់ម៉ែមានកូន កូនជុះដាក់សំពត់ម៉ែ ម៉ែអត់ខឹងទេ ។

*ព្រះវិរិយបណ្ឌិតោ* ***ឆាំង ខាត់***

# ២៩៤. មាសទឹកដប់មិនខ្លាចភ្លើង

## និយមន័យ

អំនះអំនាងពីភាពបរិសុទ្ធរបស់ខ្លួន

## អត្ថាធិប្បាយ

### ◫ អត្ថានុរូប

ការណ៏ដែលលោកពោលថា មាសទឹកដប់មិនខ្លាចភ្លើងនោះ ព្រោះថាមាសដែលមានល្បាយសារធាតុផ្សេងៗ កាលណាត្រូវភ្លើងក្ដៅ សារធាតុល្បាយទាំងនោះតែងរត់ចេញពីមាស នាំឱ្យគេដឹងថាមាសនោះមិនសុទ្ធទេ ។ ផ្ទុយទៅវិញ បើមាសទឹកដប់ពិតប្រាកដវិញ បើគេបញ្ចេះភ្លើងដល់កំរិតប៉ុន្មានអង្សាក៏ដោយក៏មាសទឹកដប់នៅតែទឹកដប់ដដែល ។ ដូច្នេះវាឥតខ្លាចភ្លើងឡើយ ។

### ◫ អត្ថប្បដិរូប

មនុស្សសុចរិតទៀងត្រង់ពិតប្រាកដប្រព្រឹត្តតែអំពើល្អ គ្មានពាក់ព័ន្ធនឹងបទល្មើសផ្សេងៗដែលផ្ទុយនឹងច្បាប់រដ្ឋ រមែងរស់នៅជាសុខស្រួលគ្មានការព្រួយបារម្ភពីសុវត្ថិភាពរបស់ខ្លួនឡើយ ។

មនុស្សបែបនេះ លោកប្រៀបដូចមាសទឹកដប់ ។ ម្យ៉ាងទៀតមនុស្សប្រភេទនេះឥតខ្លាចតុលាការទេ វៀរលែងតែតុលាការពុករលួយ ៕

*ថ្ងៃទី ០៤-១២-០៦*

មន្ទីរពេទ្យចំការចេក, ក្រុងព្រះសីហនុ

# ២៩៥. មិនទាន់ឃើញក្តារមឈូស មិនទាន់ស្រក់ទឹកភ្នែក

**និយមន័យ**

គ្រោះថ្នាក់មិនទាន់មកដល់ ជនប្រមាទ ឬជនអំនួត តែងមើលងាយ

**អត្ថាធិប្បាយ**

ចំពោះអ្នកគិតខ្លីមើលមិនឃើញឆ្ងាយ តែងតែមានអំនួតក្អេងក្អាងពុំខ្លាច រឺកោតញញើតអ្វីទាំងអស់ ។ មួយថ្ងៃៗគេតែងសំដែង ឬកពាក្រអឺតក្រទមឱ្យគេកោតខ្លាចថាខ្លួនឯងជាអ្នកខ្លាំងប្រចាំប្រវត្តិសាស្ត្រ ។ ដូចពាក្យគេតែងនិយាយថា គ្មានអ្នកណាខ្លាំងជាងអញទេ "*ក្រៅពីអញគឺមានតែអញ*" ។ ដូចជា :

- អ្នកប្រមឹកម្នាក់ឈ្មោះ ម៉ុក ពេលស្រវឹងគេតែងឡូឡាថា គ្មានអាណាខ្លាំងនិងធំជាងម៉ុកទេ នៅលើម៉ុកមានតែមួក នៅលើមួកមានតែមេឃ... រួចក៏បង្ករបួសស្នាមដល់អ្នកជិតខាង ។ សមត្ថកិច្ចក៏ចាប់យកទៅញាត់គុក ។ លុះឃើញគុកទើបស្រក់ទឹកភ្នែក ។

- អ្នកប្រមឹកម្នាក់ទៀត ទោះបីគេប្រាប់យ៉ាងណាក៏មិនស្តាប់ដែរ ។ ថ្ងៃមួយឈឺខ្លាំងពេទ្យប្រាប់ថាក្រពះអ្នកឯងខូចអស់ហើយ ហួសសមត្ថភាពពេទ្យព្យាបាលហើយ ចូលត្រលប់ទៅផ្ទះវិញ សូត្រធម៌រំលឹកគុណព្រះទៅ ។ ពេលនោះស្រាប់តែគេស្រក់ទឹកភ្នែក តក់...។

- ពួកស្មាវអន្ធពាល នាំគ្នាប្រនាំងរថយន្តកណ្ដាលទីក្រុង ។ សមត្ថកិច្ចបានចាប់ព្រមានយ៉ាងណាក៏ពួកវាមិនគោរពតាម ។ ពេលមួយវាបើកបុកគល់អំពិលមួយដើមធំ គ្រោះថ្នាក់ជាទំងន់ទាំងអស់គ្នា ។ វាស្រែកយំថា ខ្ញុំរាងហើយ ខ្ញុំរាងហើយ ព្រោះវាឃើញ គេសែងក្ដារមឈូសគ្រប់ចំនួនគ្នាវា ។

- អ្នកដឹកនាំផ្ដាច់ការម្នាក់ប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍ ។ ពេលសវនាការកាត់ទោសវា វាធ្វើឫកក្លាហានណាស់ វាទះតុផ្ទូងផាំងចង្អុលមុខមន្ត្រីតុលាការ។ ពេលតុលាការកាត់ទោសព្យួរ-ក ។ គេនៅតែធ្វើឫកគ្រាន់បើញញឹមចំអក ឱ្យតុលាការទៀត ។

លុះដល់ថ្ងៃគេអនុវត្តសាលក្រមប្រហារជីវិត ។ គេក៏បណ្ដើរវាទៅដល់បង្គោលឈើឆ្កោកដែលមានខ្សែពួររឹត-ក ។ ស្រាប់តែពេលនោះ មុខវាគ្មានឈាមមួយតំនក់សោះ ។ វាក៏ស្រក់ទឹកភ្នែកយំ អានិតខ្លួនពេលនោះតែម្ដងទៅ ។

ហ្នឹងហើយនាទីចុងក្រោយរបស់អ្នកអំនួត និងអ្នកក្អេងក្អាង ទាល់តែឃើញក្ដារមឈូសច្រងាងទើបស្រក់ទឹកភ្នែក ៕

ថ្ងៃព្យួរ-កសាដាំ ហុស្សេន *ថ្ងៃទី ៣០-១២-០៦*

❀❀❀❀

# ២៩៦. ម៉្ងៃកាត់ ម៉្ងៃកោរ

**និយមន័យ**

ពេលខ្លះធូរស្រាល ពេលខ្លះធ្ងន់ធ្ងរ

**អត្ថាធិប្បាយ**

ពាក្យទំនឹមទំនៀមនេះ លោកពោលសំដៅចំពោះតែទៅលើអ្នកជំងឺដែលមានស្ថានភាពសុខភាពពុំប្រក្រតី គឺពុំមានការទៀងទាត់ពិតប្រាកដជាយ៉ាងណា ។

ពាក្យថា **ម៉្ងៃកាត់** លោកនិយាយប្រៀបទៅនឹងសក់ដែលដុះវែងអាចកាត់ឱ្យស្អាតបាន គឺមានន័យថាជម្ងឺនោះ នៅថ្ងៃខ្លះហាក់ដូចជាបានធូរស្រាលគ្រាន់បើ ។ ព្រោះអ្នកជម្ងឺ អាចក្រោកអង្គុយនិយាយប្រាស្រ័យជាមួយនឹងញាតិមិត្រដែលទៅសួរសុខទុក្ខបាន និងទាររកបបរហូបបានជាដើម ។

ឯពាក្យ **ម៉្ងៃកោរ** លោកនិយាយប្រៀបធៀបទៅនឹងសក់ដែល គេកោរអស់រលីងពីក្បាល គឺមានន័យថា ជម្ងឺនោះ នៅថ្ងៃខ្លះហាក់ដូចជាធ្ងន់ពាប់ដាបខ្លាំង មិនបើកភ្នែក មិនចង់និយាយស្ដីរកអ្នកណា ហុចបាយ-បបរនំចំណីទៅគ្រវីតែក្បាល ។ ញាតិមិត្រដែលមកសួរសុខទុក្ខក៏មិននិយាយរកដែរ ។

អាការៈជម្ងឺបែបខាងលើនេះ លោកថា *ម៉្ងៃកាត់ ម៉្ងៃកោរ* ៕

*ថ្ងៃទី ១៥-១២-០៦*

❀❀❀❀

# ២៩៧. មាន់ណាខ្ពត មាន់នោះពង

## និយមន័យ

ពាក្យដោះសារការពារខ្លួន

## អត្ថាធិប្បាយ

ពាក្យទំនឹមទំនៀមនេះ គឺជាពាក្យសំរាប់និយាយដោះសារដើម្បីគ្រាន់តែជាការបិទបាំងនូវអំពើអាក្រក់របស់ខ្លួនកុំឱ្យខ្មាសគេខ្លាំងពេកប៉ុណ្ណោះ រឺជាពាក្យសំរាប់អ្នកលេងសំដី ។

### ៙ អត្ថានុរូប·

ធម្មតាមេមាន់ កាលណាពងរួចវាក៏ខ្ពតជាសញ្ញាឱ្យដឹងថាវាពងរួចហើយ ។ ឯមាន់ឈ្មោលឮហើយវាក៏ខ្ពតជួយបន្ទរឡើងអឺងអាប់ដែរ ដើម្បីជួយអបអរសាទរនឹងមាន់ញីដែលពងរួចហាក់ដូចជាគេសប្បាយរីករាយនឹងការឆ្លងទន្លេរួចរបស់មនុស្សដែរ ។

### ៙ អត្ថប្បដិរូប

ខ្លឹមសារន័យខាងលើនេះ លោកចង់ធ្វើការប្រៀបធៀបថា មនុស្សដែលប្រព្រឹត្តអំពើខុសឆ្គងណាមួយតែងតែព្យាយាមបិទបាំងនូវអំពើអាក្រក់របស់ខ្លួនជានិច្ច ។ មិនតែប៉ុណ្ណោះ គេថែមទាំងរកពាក្យសំរាប់ដោះសារទៀតផង ។ ដូចជាខ្លួនគេស៊ីសំនូក បើមានគេដឹងរួចគេចោទថា អ្នកឯងជាអ្នកពុករលួយស៊ីសំនូក ។ ជនពុករលួយតែងឆ្លើយជាបន្ទាន់តបទៅគេវិញថា មាន់ណាខ្ពតមាន់នោះពង គឺគេចង់និយាយថា អ្នកណានិយាយអ្នកនោះឯងពុករលួយ ។ ប៉ុន្តែ អ្នកចោទឆ្លើយវិញថា មាន់ឈ្មោលខ្ពតមែន តែឥតពងទេ ៕

*ថ្ងៃទី ១២-១២-០៦*

# ២៩៨. មេម៉ាយចាយរាង

**និយមន័យ**

ភាពរួសរាយ និងការតុបតែងខ្លួនរបស់ស្ត្រីមេម៉ាយ

**អត្ថាធិប្បាយ**

ធម្មតាស្ត្រីមេម៉ាយតែងមានឥរិយាបថផ្ទុយពីស្ត្រីក្រមុំ ។ ស្ត្រីក្រមុំស្ថិតនៅក្នុងឃ្នាបប្រពៃណីទំនៀមទំលាប់ និងជាពិសេសគឺនៅក្នុង " **ច័យរន់ចារ** " ។ ឯវ័យមេម៉ាយលែងនៅរង់ចាំទៀតហើយ *គឺជាវ័យរំពៃមើលឱកាសហុចឱ្យ* ។ ប្រៀបដូចអ្នកស្ទូចត្រីរំពៃមើលត្រីមកស៊ីនុយ ។ កាលណាមានត្រីមកស៊ីនុយ គេវាត់យកភ្លាម ។

ដូច្នេះស្ត្រីមេម៉ាយ ចាស់ទុំពុំសូវប្រកាន់ពីឥរិយាបថប៉ុន្មានទេ ។ គេអាចនិយាយលេងសើចជាមួយបុរសប្រភេទណាក៏បាន កុំឱ្យតែហួសព្រំដែនពេក ។

ម្យ៉ាងទៀត សំលៀកបំពាក់, ការតុបតែងខ្លួន គេអាចប្រើពណ៌សំបុរឆើតឆាយ ឬខើចលើខើចក្រោម បន្តិចក៏គ្មានអ្នកណារិះគន់ដែរ ។

ឥរិយាបថខាងលើនេះហើយ ដែលអ្នកមាត់ដាចតែងនិយាយចំអន់ថា *មេម៉ាយចាយរាង* គឺចាយរាងដើម្បីរកលោះលោះគ្រាន់កំដរបរិយាកាសទៀតហើយ ។

ការណ៍ពិត ប្រហែលជាដូចពាក្យគេថាមែនហើយ ។ ព្រោះថាអ្វីក៏ដោយឱ្យតែសល់ពីគេត្រូវតែផ្សាយពាណិជ្ជកម្មបន្តិចអីចឹងហើយ ។

ផ្ទុយទៅវិញ បើមេម៉ាយហើយកំនាញ់រាងទៀត ជាពិសេសកាចឆ្នាស បន្ថែមទៀតផងនោះ ច្បាស់ជាចាយមិនដាច់ទេដឹង ? បើដាច់ក៏ចង់ហួសដេឡៃ រឺក៏ថយគុណភាពបន្តិចដែរ ៕

មន្ទីរពេទ្យចំការចេក ក្រុងព្រះសីហនុ *ថ្ងៃទី ០៤-១២-០៦*

# ២៩៩. មានអ្វី មិនស្មើមានចិត្ត

**និយមន័យ**

ចិត្ត ជាកុសលរបស់មនុស្ស

## អត្ថាធិប្បាយ

អ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាប្រធានតែងពោលថាចិត្ត(មនោ) គឺជាវត្ថុចម្បងយ៉ាងឯករបស់មនុស្ស ។ ព្រោះថាទំរើអ្វីក៏ដោយទោះល្អ ឬអាក្រក់ក្តីសុទ្ធសឹងសំរេច ឬកើតឡើងអាស្រ័យពីចិត្តជាមេដឹកនាំទាំងអស់ ។ សមដូចព្រះពុទ្ធ គាថា ថា :

**"មនោ បុព្វង្គមា ធម្មា, មនោសេដ្ឋា, មនោមយា"**

**"ចិត្ត"** នៅពេលនេះ លោកសំដៅយកចិត្តជាកុសល ។ មនុស្សមានចិត្តជាកុសល នេះមានគុណប្រយោជន៍ខ្ពស់ណាស់ ។ ព្រោះគេអាចញ៉ាំងកុសលកម្មឱ្យកើតឡើងបាន ដូចជា បំពេញកុសលក្នុងសាសនាមានការធ្វើបុណ្យសុន្ទរ៍ទាន, ចែកអំនោយដោយសុទ្ធចិត្តចំពោះអ្នកទីទ័លក្រពិតប្រាកដ ដោយឥតសំលឹងឃើញផលប្រយោជន៍ត្រលប់មកវិញទេ ។

នៅក្នុងសហគមន៍ ទំរើអ្វីដែលជាប្រយោជន៍សាធារណៈមានការកសាងសមិទ្ធិផលផ្សេងៗគេតែងមានចិត្តជួយផ្តល់ជាវិភាគទានតាមលទ្ធភាព ។

ម្យ៉ាងទៀត មនុស្សមានចិត្តនេះមិនចេះមើលបំណាំគេទេ បើឃើញគេធ្វើអ្វី

ដែលជាប្រយោជន៍សាធារណៈ តែងលាត់ដៃអាវចូលជួយធ្វើគេជានិច្ចដោយមិនចាំបាច់ឱ្យគេហៅរកទាន់ទេ ។ និយាយដោយហោចទៅ សូម្បីតែគេឃើញដុំថ្ម ឬសំបកដូងនៅកណ្ដាលថ្នល់ក៏គេមិនដើររំលងដែរ គឺគេតែងរើស ឬទាត់ឱ្យទៅខាងដែរ ។

*ហ្នឹងហើយជាគុណសម្បត្តិរបស់អ្នកមានចិត្ត* ៕

មន្ទីរពេទ្យចំការចេក, ក្រុងព្រះសីហនុ *ថ្ងៃទី ០៤-១២-០៦*

❀❀❀❀



# ៣០០. មុខឆ្អែ ស្រែជំរៅ

## និយមន័យ

ខ្មាសត្រួតលើខ្មាស

## អត្ថាធិប្បាយ

**"ស្រែជំរៅ"** គឺជាស្រែដែលនៅទីទំនាបជិតមាត់បឹង ។ ស្រែនេះគេសំរាប់ព្រោះស្រូវធ្ងន់ដែលមានរយៈកាលពីប្រាំពីរទៅប្រាំបីខែទើបបានច្រូតកាត់ ។

ដូច្នេះ ការណ៍ដែលលោកលើកយកពាក្យនេះមកប្រៀបធៀបនឹងអ្វីដែលនាំឱ្យអាប់មុខដូចមុខឆ្អែ គឺវាអន់អាប់ពេកទៅហើយ ថែមស្រែជំរៅមួយទៀត ដែលជាស្រែធ្ងន់ក្របានច្រូត គឺវាអន់ចង់ ថែមមួយកម្រិតទៀត ។ ដូចជា គេដើរទៅជាន់ដុំថ្មក្រលាច់ជើងដួលព្រួសនៅមុខមនុស្សម្នា ។ បើគ្រាន់តែដួលអុកគូទ គេអាចក្រោកឡើងដើរទៅមុខទៀតធ្វើមិនដឹង ខ្មាសគេល្មមៗទេ ។ ប៉ុន្តែ ចង្រៃថែដន្យអាក្រក់ថែមទាំងលេចពងទៅទៀត ។ ដូច្នេះគេត្រូវរងនូវភាពអាម៉ាស់ដល់ទៅពីរដង គឺខ្មាសត្រួតលើខ្មាស ឬខ្មាសគេខ្លាំង ។ ហេតុនេះហើយបានជាលោកថា ខ្មាសគេឡើងស្លឹកមុខ *គឺមុខដូចឆ្អែ ស្រែជំរៅអីចឹង* ៕

*ថ្ងៃទី ០៣-០១-០៧*

❀❀❀❀

# ៣០១. មេមិនដែលនៅក្រោមពង

## និយមន័យ

មេកោយ មិនចំនុះកូនចៅទេ

### អត្ថាធិប្បាយ

" **មេ** " នៅពេលនេះ លោកសំដៅយកអ្នកដែលអាណាព្យាបាល ឬអ្នកគ្រប់គ្រងលើគេដូចជា : មេបាចាស់-ទុំ, ឪពុកម្ដាយ, គ្រូបាអាចារ្យ, ប្រធាន រហូតដល់មេល្បែងស៊ីសង មានមេកាស៊ីណូ, មេអាប៉ោងជាដើម ។

"**ពង**" គឺកូនចៅ រឺសហការី។ ធម្មតាអ្នកជាមេគេ, អ្នកគ្រប់គ្រងគេ, អ្នកអាណាព្យាបាលគេ តែងប្រកាន់ យកនូវសិទ្ធអំនាច សិទ្ធសំរេច ឬកលល្បិចជាងកូនចៅជានិច្ច ។ ដូចជា :

- ឪពុកម្ដាយ តែងប្រកាន់យកអាទិភាពគ្រប់យ៉ាងលើកូនតូច-ធំ ។
- គ្រូ តែងប្រកាន់យកបុព្វសិទ្ធិធំជាងសិស្ស ។
- ប្រធាន តែងប្រើសិទ្ធិសំរេចកិច្ចការគ្រប់បែបយ៉ាងលើសហការីរបស់ខ្លួន ។
- និយោជក តែងប្រើប្រាស់សិទ្ធិសំរេចលើនិយោជិកជានិច្ច ។
- មេកែ តែងប្រើអំនាច សំរេចកិច្ចការគ្រប់យ៉ាងដោយអត្តនោម័ត និងមិនរណបកម្មករទេ។
- មេល្បែងស៊ីសងគ្រប់យ៉ាង តែងមានល្បិចកិច្ចកលពិសេសលើអ្នកចូលរួមលេងគ្រប់ៗគ្នា។

ហេតុនេះហើយទើបលោកពោលថា អ្នកលេងល្បែងភ្នាល់ស៊ីសង មិនខុសពីយកលុយទៅឱ្យមេឱ្យកាន់តែមានឡើង ។ ព្រោះមេមិនដែលនៅក្រោមពងទេ ទោះបីមេមានកាយវិការទន់ភ្លន់ក៏ដោយក៏ពុំមែនមានន័យថា មេមកចំនុះ ឬមករណបកូនចៅដែរ ៕

*ថ្ងៃទី ០១-១១-០៦*

# ៣០២. មាត់ជាផ្លូវ

**និយមន័យ**

ការសួររកគោលដៅដែលត្រូវទៅ

## អត្ថាធិប្បាយ

ពាក្យទំនឹមទំនៀមនេះ ពុំមានន័យអ្វីវែងឆ្ងាយទេ គឺលោកគ្រាន់តែចង់បញ្ជាក់ប្រាប់ថា សំដីជាប្រធានឯកក្នុងការសាកសួររកនូវអ្វីមួយដែលគេចង់ដឹង, ចង់យល់, ចង់ស្គាល់ និងជាកម្មវត្ថុដែលគេត្រូវទៅរក ដូចជា :

មនុស្សម្នាក់ចង់ទៅរកផ្ទះពូសុខ នៅក្នុងភូមិដែលគេមិនធ្លាប់ស្គាល់ទីកន្លែង ឬផ្ទះសំបែងគាត់សោះ ។ ដូច្នេះដើម្បីបានទៅដល់ផ្ទះគាត់ដែលជាគោលដៅនោះ គេត្រូវសួររកពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតដែលគេបានជួបជាហូរហែ ។

ទីបំផុត គេក៏បានទៅដល់ផ្ទះពូសុខដូចបំនង ។ ការណ៍នេះហើយបានជាលោកថា មាត់ជាផ្លូវដែលនាំឱ្យទៅដល់ផ្ទះពូសុខបាន ៕

*ថ្ងៃទី ០៨-០១-០៧*

❁❁❁❁

# ៣០៣. មានកូនក្រមុំបីនាក់ ដូចមានប្រហុកបីពាង

**និយមន័យ**

ការចោមរោមមើលកូនក្រមុំគេ ដូចរុយរោមប្រហុក

**អត្ថាធិប្បាយ**

ខ្លឹមសារនៅក្នុងនិយមន័យខាងលើនេះ លោកពុំមែនចង់ប្រៀបធៀបកូនក្រមុំទៅនឹងក្លិនប្រហុកនោះទេ គឺលោកចង់ប្រៀបប្រដូចការចោមរោមរបស់សត្វរុយ ។

ក្នុងគ្រួសារមួយដែលមានកូនក្រមុំម្នាក់ មិនសូវមានកំលោះៗចាប់អារម្មណ៍ប៉ុន្មានទេ។ ព្រោះវាជាការធម្មតា ។ តែបើមានពីរនាក់ធ្វើឱ្យកំលោះៗកន្ត្រាក់អារម្មណ៍ចង់ទៅមើលមុខគ្រាន់បើ ។ ប៉ុន្តែ បើមានដល់ទៅបីនាក់វិញ លោកថាកំលោះៗ ពិតជានៅស្ងៀមមិនកើតឡើយ ។ ព្រោះថា នៅក្នុងគ្រួសារមួយ តែមានរបស់ដែលជាកម្មវត្ថុរបស់ពួកកំលោះៗដល់ទៅបី ។ ម្ល៉ោះហើយធ្វើឱ្យកំលោះៗទៅអើតងើតមើលជា ហូរហែ ។ ព្រោះគេមើលតែម្ដង ចំនេញបានតំហើញដល់ទៅបីកម្មវត្ថុ រឺថាបាញ់ព្រួញមួយត្រូវបានសត្វបី ។ ដូច្នេះ គ្រួសារនេះមានគេដើរកាត់មុខផ្ទះមិនសូវដាច់ ។ ខ្លះចង់ឃើញនាងបង, ខ្លះនាងកណ្ដាល, ខ្លះនាងពៅ ។ លោកប្រៀបថា ផ្ទះណាមានប្រហុកមួយពាង រុយរោមតិច, បើមានពីរពាង រុយក៏កើនចំនួនទ្វេជាពីរដែរ ប៉ុន្តែបើមានដល់ទៅបីពាងវិញ រុយកើនចំនួនកុះករតែម្ដង ៕

*ថ្ងៃទី ២៥-០៤-០៩*

❀❀❀❀

# ៣០៤. ម្នាក់ឯងជិះទូកពីរ

**និយមន័យ**

មនុស្សមានមហិច្ឆតាលោភលន់

## អត្ថាធិប្បាយ

### ◻ អត្ថានុរូប

ក្នុងដំណើរតែមួយ មនុស្សម្នាក់បានយកទូកពីរមកអែបគ្នា រួចដាក់ជើងម្ខាងនៅលើទូកខាងស្ដាំ ជើងម្ខាងទៀតដាក់លើទូកខាងឆ្វេង ។ គេធ្វើដូច្នេះមកពីមានគំនិតថា បើទូកម្ខាងលិច គេអាងមានទូកម្ខាងទៀត ។ ប៉ុន្តែ គេធ្វើដំណើរទៅមុខក៏បានដោយលំបាកដែរ ។

### ◻ អត្ថប្បដិរូប

ក្នុងខ្លឹមសារខាងលើនេះ លោកចង់ចង្អុលបង្ហាញពីមនុស្សខ្លះ មានចិត្តចង់យកចំនេញខ្លាំងពេក គឺគេលែងគិតពីបញ្ហាដែលកើតឡើងជាយថាហេតុ ។ គេគិតតែពីស្វែងរកចំនីងពីរក្នុងពេលតែមួយ ដើម្បីកេងយកប្រយោជន៍ធំដូចជា :

- ស្ត្រីម្នាក់មានសង្សារពីនាក់ក្នុងរយៈកាលជាមួយគ្នា ដោយគេយល់ថាធ្វើដូច្នេះចំនេញព្រោះបានផលប្រយោជន៍ទាំងសងខាង ។ ម្យ៉ាងទៀតបើម្នាក់បែកចិត្តក៏នៅមានម្នាក់ទៀតដែរ ។

- អ្នករាជការម្នាក់ ធ្វើគ្រូផង ធ្វើប៉ូលិសផង គេបើកប្រាក់ខែទាំងពីរអង្គភាព ។

ទំរើដូចមានក្នុងករណីខាងលើនេះ គេឥតគិតពីផលវិបាកទៅថ្ងៃក្រោយថាជាយ៉ាងណាទេ ៕

*ថ្ងៃទី ១៩-០៥-០៩*

# ៣០៥. មួយចានទឹក មួយចានគោក

**និយមន័យ**

ទំរើផ្សងព្រេង ជួនបានផលល្អ ជួនបានផលអាក្រក់

## អត្ថាធិប្បាយ

### ▭ អត្ថានុរូប

ពាក្យទំនឹមទំនៀមក្នុងនិយមន័យខាងលើនេះ លោកលើកយកសំលពីរចានមកប្រៀបធៀប ដែលមានមួយចានមើលទៅសុទ្ធតែទឹករលីងរលោង សឹងតែរកបន្លែនិងសាច់មិនឃើញ ។ ឯមួយចានទៀតមើលទៅមិនឃើញមានទឹកទេ គេឃើញតែបន្លែ និងសាច់មានសំលឆាជាដើម ។

### ▭ អត្ថប្បដិរូប

ក្នុងន័យខាងលើនេះ លោកពោលប្រៀបធៀបទៅនឹងទំរើណាដែលមានការផ្សងព្រេងព្រមទាំងជឿជាក់ ថាបើធ្វើទៅអាចមានលទ្ធផលពីរផ្ទុយគ្នា គឺបើធ្វើទៅបានជោគជ័យ គេទទួលបានផលជាទីគាប់ចិត្ត ។ តែបើគេធ្វើទៅបរាជ័យ គេទទួលផលអាក្រក់ តួយ៉ាងដូចជា :

- អ្នករកស៊ីរត់ពន្ធសាំង បើគេចាប់មិនបានគ្រាន់បានស៊ីអាចរស់ចិញ្ចឹមប្រពន្ធ, កូនបាន ។ តែបើគេចាប់បានវិញ ប្រហែលនៅសល់តែគូទខោដើរមកផ្ទះ ។

- បេក្ខជនតំណាងរាស្ត្រ ចំនាយធនធានយ៉ាងធំសំបើម ដើម្បីបោះឆ្នោត បើជោគជ័យអាចស្តារសេដ្ឋកិច្ចគ្រួសារបានយ៉ាងឆ្វាញ់ តែបើបរាជ័យអាចរហេមរហាម ឬរត់ចោលស្រុក ឬក៏ប្រពន្ធរត់ចោល ។

- អ្នករត់ពន្ធគ្រឿងញៀន បើគេចាប់មិនបានអាចធ្វើសេដ្ឋី តែបើគេចាប់បាន ត្រូវជាប់គុក ឬរត់ទៅនៅបរលោក ។

- អ្នកនយោបាយធ្វើរដ្ឋប្រហារ បើជោគជ័យធ្វើទេវតា បើបរាជ័យត្រូវរត់ ចោលស្រុក ឬរត់ទៅនៅស្ថាននរក ។

ទំរើអ្វីដែលផ្សងព្រេងធ្វើហើយមានលទ្ធផលពីររង់ចាំទទួលបែបនេះ ។ លោក ពោលថា *មួយចានទឹក មួយចានគោក* ៕

*ថ្ងៃទី ២៤-០៨-០៩*

❀❀❀❀



# ៣០៦. មកអត់គេហៅ ទៅអត់គេរក

**និយមន័យ**

មនុស្សដែលគេមិនសូវនិយមរាប់អាន

**អត្ថាធិប្បាយ**

មនុស្សក្នុងនិយមន័យខាងលើនេះ មិនមែនមានន័យថា ជាមនុស្សទន់ខ្សោយ គ្មានចំនេះដឹងនោះទេ ។ លោកសំដៅយកមនុស្សដែលគេមិនសូវនិយមរាប់អាន ។ មនុស្សនេះទោះទៅទីណា ក៏អ្នកផងទាំងពួងមិនសូវចូលចិត្តយកជាមិត្រភក្តិអ្វីដែរ ។ ការណ៍ដែលគេមិនសូវរាប់រក ជួនកាលមកពីភាពជំលើយ ឬភាពក្រអឺតក្រទមដែលគេហៅថា វាយឬកធំគ្មានអ្នកស្មើក៏មាន ឬជាមនុស្សមិនសូវចុះសំរុងក្នុងសហគមន៍ក៏មាន ។

មនុស្សប្រភេទនេះ ប្រសិនបើមានពិធីបុណ្យសាធារណៈដូចជា បុណ្យផ្កា បុណ្យកឋិន រឺពិធីប្រជុំផ្សេងៗ បើមនុស្សនេះមកក៏មកទៅ គ្មានអ្នកណាហៅរក, រាក់ទាក់, សួរនាំ រឺយកចិត្តទុកដាក់អ្វីឡើយ ។ រួមសេចក្តីមកថា ចង់មកក៏មកទៅ ចង់ទៅវិញក៏ទៅ-ទៅ ។

ហេតុនេះហើយបានជាលោកពោលថា *មកអត់គេហៅ ទៅអត់គេរក* ៕

*ថ្ងៃទី ២០-០៥-០៩*

# ៣០៧. មានសត្រូវជាបណ្ឌិត ប្រសើរជាងមានមិត្រល្ងង់ខ្លៅ

## និយមន័យ

មនុស្សល្ងង់ឱ្យទោសខ្លាំងជាងមនុស្សចេះដឹង

## អត្ថាធិប្បាយ

ព្រះពុទ្ធដីកាទ្រង់ត្រាស់ថា មនុស្សដែលមិនជឿកម្មផលរមែងធ្វើនូវអំពើបាបដោយមិនញញើតដៃ ។ ឯអ្នកដែលជឿកម្មផល ទោះបីធ្វើអំពើបាបកម្មដូចគ្នា ក៏នៅមានចិត្តញញើតក្រែងបារម្ភនឹកដល់កម្មពៀរខ្លះៗ ។

ដូច្នេះ សឹងតែជាប្រពៃណីទៅហើយ មនុស្សដែលមានចំនេះដឹងខ្ពស់ ទោះបីជាខឹងក្រេវក្រោធនឹងអ្នកដែលជាសត្រូវក៏ដោយ ក៏តែងមានស្មារតី និងសតិសម្បជញ្ញៈខ្ពស់ដែរ។ គឺគេចេះគិតពិចារណានូវហេតុផលអាក្រក់ ដែលជាបច្ច័យកើតឡើងដោយសារទំរើរបស់ខ្លួន។ ម្យ៉ាងទៀតជនជំពូកនេះ មុននឹងធ្វើនូវកម្មណាមួយ គេតែងពិចារណាគ្រប់ជ្រុងជ្រោយពីផលដែលត្រូវត្រលប់មកវិញ ។ ម្ល៉ោះហើយ គេមិនងាយប្រព្រឹត្តនូវអំពើណាមួយដែលផ្ដេសផ្ដាសទេ ។

រីឯមនុស្សអវិជ្ជា គឺមនុស្សល្ងង់ខ្លៅវិញ គេពុំសូវចេះដឹងគិតគូពិចារណានូវហេតុផលល្អ អាក្រក់, គុណ ទោសអ្វីប៉ុន្មានទេ ។ ជួនកាលអំពើអាក្រក់សោះ គេបែរ

ជាយល់ថា ជាអំពើល្អទៅវិញ ។ ម្ល៉ោះហើយជាញឹកញយ គេតែងយករឿងអាស្រូវផ្សេងៗមកបកស្រាយប្រាប់មិត្រ ។ ដូចជាគេនិយាយថា អ្នកនេះ រឺអ្នកនោះ និយាយដើមសំលាញ់ឯង ។ បើមិត្រចិត្តស្រាលក៏ស្ទុះច្រលោតបង្កើតជារឿងធំក៏មាន ។ ជួនកាលទៀត គេបបួលឱ្យលេងល្បែង, ផឹកស៊ី, រត់ពន្ធ... ដប់ដងម្ដែដងគង់តែភ្លាត់ខ្លួនទៅលេងម្ដងមិនខាន ។

ហេតុការណ៍នេះហើយ បានជាអ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាប្រធានតែងពោលថា : "**អវិជ្ជា គឺជាឫសគល់ នៃបាបធម៌គ្រប់បែបយ៉ាង** " ៕

*ថ្ងៃទី ១៦-០៨-០៩*



ឃ

# ៣០៨. យុត្តិធម៌ ជាគ្រឹះនៃសាមគ្គីធម៌

**និយមន័យ**

ភាពសុចរិតត្រឹមត្រូវជាមូលដ្ឋាននៃការរួបរួមគ្នា

**អត្ថាធិប្បាយ**

**ព្រះធម្មបាល ខៀវ ជុំ** ព្រះអង្គមានថេរដីកាជាពាក្យទំនឹមទំនៀមនេះឡើង ក្នុងគោលបំណងបញ្ជាក់ប្រាប់ថា **សាមគ្គីធម៌** អាចកើតឡើងបានត្រូវអាស្រ័យនឹង **យុត្តិធម៌** គឺភាពត្រឹមត្រូវមិនប្រកាន់គ្នាដោយអគតិផ្សេងៗមិនរើសអើង, មិនពុករលួយ, មិនប្រកាន់បក្សពួក, មិនកេងប្រវ័ញ្ចជាដើម ។

ព្រោះថា ការរួបរួមចងបាច់គ្នា, ការស្រលាញ់រាប់អានគ្នា, ការចងក្រងបង្កើតជាសមាគម, ជាគណបក្សដែលអាចមានជីវិតស្ថិតស្ថេរនៅជាយូរអង្វែងទៅបាន សុទ្ធតែអាស្រ័យនឹងភាពយុត្តិធម៌ជាបច្ច័យទាំងអស់ ។ បើមានកង្វះខាតភាពស្មោះត្រង់ នឹងគ្នាហើយ គឺវាចូលក្នុងការក្បត់ចិត្តគ្នា និងការស៊ីកបកេងប្រវញ្ចលើគ្នា ។ បើមានការក្បត់ចិត្តគ្នាលែងស្មោះត្រង់នឹងគ្នាហើយ តើមានអ្នកណាគេចង់ទៅនៅក្នុងចង្កោម, ក្នុងអង្គការ, ក្នុងសមាគម និងក្នុងគណបក្សនេះតទៅទៀតបាន ។

ដូច្នេះ ដើម្បីឱ្យជីវិតក្រុម, សមាគម និងគណបក្សរស់នៅបានយូរ ម្នាក់ៗត្រូវប្រកាន់ខ្ជាប់នូវភាពស្មោះត្រង់ សុចរិត និងយុត្តិធម៌ជាមូលដ្ឋាន ៕

*ថ្ងៃទី ០៩-០១-០៧*

# ៣០៩. យល់ញាតិ ឃ្លាតច្បាប់

**និយមន័យ**

ការយោគយល់ញាតិសន្តានធ្វើឱ្យប្រាសចាកច្បាប់

**អត្ថាធិប្បាយ**

" **ច្បាប់** " គឺជាបទបញ្ញត្តិដែលអង្គការនីតិបញ្ញត្តិបានអនុម័តរួចហើយ ដើម្បីចាប់បង្ខំឱ្យប្រជាពលរដ្ឋខ្មែរគ្រប់គ្នា ចាប់តាំងពីថ្នាក់ទាបបំផុតរហូតដល់ថ្នាក់កំពូលបំផុតគោរព ប្រតិបត្តិគ្រប់ៗគ្នា ។

ដូច្នេះ " **ច្បាប់** " គ្មានមនុស្សខ្មែរណាម្នាក់មានសិទ្ធប្រកែកតវ៉ា មិនគោរពបានឡើយ ។

ប៉ុន្តែក្នុងន័យខាងលើនេះ លោកចង់និយាយពីមនោសញ្ចេតនារបស់ មនុស្សប្រព្រឹត្តិ ធ្វើឱ្យមានគំលាតច្បាប់ ។

ឧទាហរណ៍ : នគរបាលចរាចរម្នាក់មានតួនាទីចាំឆែកបណ្ណបើកបរ ។ លុះឆែកចំទៅលើបងប្អូន រីញាតិសន្តានគាត់ដែលគ្មានបណ្ណបើកបរគាត់មិនពិន័យទេ ។ គាត់គ្រាន់តែដេញទៅឱ្យឆាប់ៗ។

ការយោគយល់បែបនេះហើយដែលលោកថា *យល់ញាតិ ឃ្លាតច្បាប់* ៕

*ថ្ងៃទី ០៨-០១-០៧*

❀❀❀❀

# ៣១០. យក.កទៅ.លអន្ទាក់

**និយមន័យ**

ការចង់សាកល្បងនឹងកំហុសផ្លូវច្បាប់

**អត្ថាធិប្បាយ**

" **អន្ទាក់** " នៅពេលនេះ គឺជាបទបញ្ញត្តិដែលរដ្ឋបានហាមប្រាម ។ ធម្មតាបទបញ្ញត្តិ កាលណាមានមនុស្សធ្វើអ្វីឱ្យខុសនឹងបទបញ្ញត្តិ អ្នកនោះនឹងត្រូវរងនូវផលវិបាកផ្សេងៗទៅតាមទំរើដែលខ្លួនបានប្រព្រឹត្ត ។

ក្នុងន័យខាងលើនេះ មានមនុស្សខ្លះមិនមែនមិនដឹងទេ គឺដឹងច្បាស់ថា បើធ្វើអ្វីឱ្យខុសនឹងផ្លូវច្បាប់ ប្រាកដជាត្រូវទទួលទុក្ខទោសមិនខាន ។ ប៉ុន្តែ មហិច្ឆតាមនុស្សនៅតែចចេសចង់ធ្វើចង់ប្រព្រឹត្ត ព្រោះគិតថាប្រហែលអាជ្ញាធរមិនដឹងទេ ។

ឧទាហរណ៍ :

- ជនម្នាក់ឈ្មោះ វ៉ន បានលួចថ្លក់ខ្សែភ្លើងប្រើ ។ ឪពុកម្តាយបានហាមប្រាមថា : កុំយក-កទៅ-លអន្ទាក់ ប្រយ័ត្នអន្ទាក់វាត់ជាប់-ក ។ ទីបំផុត សមត្ថកិច្ចចាប់បាន ។ អន្ទាក់វាត់ជាប់-កមែន ។

- នាយតាំ តែងយករបស់គេចពន្ធ បង្កប់ក្នុងបាតទូកសាវម៉ាវពីស្រុកយួនចូលមក។ លុះដល់សមត្ថកិច្ច ចាប់បាន ក-ដៃគេត្រូវជាប់អន្ទាក់ គឺខ្មោះមែន ។

ការណ៍ដែលចចេសប្រថុយប្រថានស្មានថាគេមិនដឹងបែបនេះ លោកហៅថាសុទ្ធតែជាល្បែង*យក-កទៅ- លអន្ទាក់ទាំងអស់* ៕

*ថ្ងៃទី ០៨-០១-០៧*

# ៣១១. យកមេឃទ្រាប់ក្តិតអង្គុយ

**និយមន័យ**

មនុស្សកំពូលមហាសែនអួត

## អត្ថាធិប្បាយ

មនុស្សខ្លះ និយាយអួតអាងពីសមត្ថភាពខ្លួនថា គ្រាន់បើបែបនេះបែបនោះ ដើម្បីបោកប្រាស់គេយកបាយស៊ី ។ អំនួតនេះនៅគ្រាន់រកលេខដាក់បាន ។

ប៉ុន្តែនៅមានមនុស្សខ្លះទៀតដែលមានជីដូនជីតា ម៉ែឪមាននិស្ស័យកំពូលអួត គឺអួតយកមេឃទ្រាប់ក្តិតអង្គុយ ។ គេអួតសំបើមខ្លាំងណាស់ សូម្បីតែមេឃក៏គេថាយកមកទ្រាប់ក្តិតអង្គុយបណ្តែតអារម្មណ៍បានដែរ ។ ដូចជា :

- មនុស្សម្នាក់ ក្ររកតែបបរស៊ីសឹងពុំបាន គេហ៊ានអួតថា គេធ្លាប់មានលុយ. ឡាន. វីឡាជាច្រើន តែត្រូវគេយកជាជ័យភណ្ឌអស់ហើយ ។

- កាលពីសង្គមចាស់ មានបុរសម្នាក់ម្តងដើរតួជា ចៅកែត្បូងពេជ្រនៅប៉ៃលិន. ម្តងដើរតួជាអធិការប៉ូលិស ចុងក្រោយដើរតួជាព្រះអង្គម្ចាស់ ។

- នៅទសវត្សរ៍ឆ្នាំ ៦០ មានអ្នកដឹកនាំប្រទេសស្បែកខ្មៅម្នាក់បានអួតអាងថា ខ្លួនគេ ជាមនុស្សដែលព្រះអាទិទេពដាក់មកឱ្យដឹកនាំប្រទេស ដូច្នេះអ្វីៗគ្រប់យ៉ាងត្រូវតែស្តាប់បង្គាប់គេ។ ជាពិសេសទៅទៀត គេដេកសុទ្ធតែគ្រែមាស. មានប្រពន្ធដល់ទៅ៧នាក់ ។ នៅចុងទសវត្សរ៍ឆ្នាំ៦០ ប្រជាជនក្រោកឡើងតស៊ូវាយរំលំជនផ្តាច់ការនេះ ចោលទៅ ៕

*ថ្ងៃទី ០៩-០១-០៧*

# ៣១២. យីអ៊ុនជាក់ អារក្សជាន់

**និយមន័យ**

ជោគជតារាសីធ្លាក់ ខ្មោចបីសាចជាន់-កថែម

**អត្ថាធិប្បាយ**

" **យីអ៊ុន** " លោកសំដៅយកជោគជតារាសីរបស់មនុស្សម្នាក់ៗ ។

" **រាសី** " ខ្មែរប្រើសំគាល់ សម្រស់ជីវិត ។

" **អារក្ស** " ជាឈ្មោះខ្មោចល្បាក់សាដែលខ្មែរ ហៅសំគាល់ឈ្មោះខ្មោចមេមត់មួយដែលគេជឿថាជាបិសាចដែលថែរក្សាមនុស្សគ្រប់គ្នា ។

កាលណាមានបុគ្គលណាម្នាក់មានវិបត្តិហេតុដោយប្រការណាមួយ គេជឿថារាសីគេធ្លាក់ចុះហើយ ។ ចំពោះអ្នកដែលមានជំនឿខ្លាំង គេតែងទៅរកគ្រូស្រោចទឹករំដោះគ្រោះលើករាសីឡើងវិញ ។

នៅក្នុងន័យខាងលើនេះ គេជឿថា រាសីគេធ្លាក់ចុះ ខ្មោចបិសាចដែលថែរក្សាគេក៏មកជាន់-កបន្ថែមមួយត្រួតទៀត ដូចជា :

- បុរសម្នាក់រកស៊ីខាតហើយ ថែមត្រូវគេបោកលុយទៀត ។
- ខ្លះកូន-ចៅឈឺហើយ ថែមចោរលួចបាត់ម៉ូតូទៀត ។
- ខ្លះទៀត មិនបានឡើងបុណ្យសក្តិហើយ ថែមត្រូវគេផ្លាស់ទៅខេត្តឆ្ងាយទៀត ។

ការណ៍ដែលមានបញ្ហាមួយហើយ ថែមមានបញ្ហាមួយទៀតមកត្រួតសង្កត់ជាន់ពីលើបែបនេះគេថា *យីអ៊ុនក៏ធ្លាក់ អារក្សក៏ជាន់* ។

សុជានី ចូលគេងពេទ្យ *ថ្ងៃទី ១០-០១-០៧*

# ៣១៣. យកអន្ទង់ទៅចំហុងនឹងផុក

**និយមន័យ** យកទៅដាក់ចំកន្លែងឱ្យរស់ជីវិត

## អត្ថាធិប្បាយ

### 🕮 អត្ថានុរូប

សត្វអន្ទង់ជាពួកទីយជាតិ រាប់ចូលក្នុងពួកមច្ឆជាតិ វាចូលចិត្តរស់នៅក្នុងភក់និងដីល្បាប់ណាស់ ។ វាពូកែមុជត្បុលរុករុលក្នុងភក់ ដើម្បីជាជំរករស់នៅ ។ បើគេយកវាទៅចំហុងនឹងភក់ គឺយកវាទៅជ្រមុជ ក្នុងភក់នោះ គឺដូចជាយកវាទៅឱ្យរស់នៅយ៉ាងសុខស្រួលក្នុងទីសុវត្ថិភាពរបស់វា ។

### 🕮 អត្ថប្បដិរូប

ក្នុងន័យនេះ លោកធ្វើការប្រៀបធៀបទៅនឹងបុគ្គលិកម្នាក់ ដែលត្រូវនាយចៅហ្វាយខឹង ឬស្អប់ក៏ផ្លាស់ឱ្យទៅនៅតំបន់ឆ្ងាយដាច់ស្រយាល ។ គឺបំនងយកទៅធ្វើទណ្ឌកម្មសមនឹងកំហឹងចិត្តគាត់ ។ ប៉ុន្តែជាចៃដន្យល្អកន្លែងថ្មីនោះ ជាទីសុខមនោរម្យដែលអាចឱ្យគេរស់នៅបានសុខស្រួលជាងកន្លែងមុនទៅទៀត ។ តួយ៉ាងដូចជា :

- បុគ្គលិកម្នាក់ដែលនាយចៅហ្វាយពុំសូវចូលចិត្ត ក៏ផ្លាស់ឱ្យទៅនៅតំបន់ព្រៃ ។ បុគ្គលិកនោះក៏កើតគំនិតថ្មី រួចក៏ឆ្លៀតនាយអាយកាប់ឈើល្អៗលក់ ។ មិនយូរប៉ុន្មានគេឃើញជននោះជិះឡាន និងមានជីវភាពប្រសើរជាង មុនឆ្ងាយណាស់ ៕

*ថ្ងៃទី ២២-០១-០៧*

# ៣១៤. យល់សប្តិក្លាយជាការណ៍ពិត

**និយមន័យ**

ការស្រមើស្រមៃ ស្រាប់តែសំរេចបានដោយចៃដន្យ

**អត្ថាធិប្បាយ**

ការយល់សប្តិ រឺសុបិន សុទ្ធតែជាភាពស្រមើស្រមៃទាំងអស់ នឹងយកជាការណ៍ពិតពុំបាន ។ ព្រោះភាវៈទាំងអស់នេះ សុទ្ធតែកើតឡើងដោយមនោគតិរបស់មនុស្សរឺកើតឡើងដោយការកំរើកនៃសរសៃវិញ្ញាណទាំងអស់ ។

ដូចនេះ គេមិនអាចយកជាផ្លូវការបានឡើយ ។ ព្រោះការយល់សប្តិក៏មិនខុសពីការផ្សងព្រេងដែរ ។

ប៉ុន្តែក្នុងន័យខាងលើនេះ លោកចង់និយាយពីរឿងចៃដន្យថា : ជួនកាលរឿងស្រមើស្រមៃ ឬយល់សប្តិសោះ ស្រាប់តែអាចក្លាយជាការណ៍ពិតបានដែរ ។ ដូចជា :

- បុរសម្នាក់ផ្សងសុំឱ្យត្រូវឆ្នោតខ្ទង់ធំ ស្រាប់តែចៃដន្យត្រូវឆ្នោតបានអាខ្ទង់ធំដូចបំនងមែន ។

- បុរសម្នាក់ទៀត ដេកយល់សប្តិថាបានជួបបងប្អូន ដែលបែកគ្នាក្នុងសម័យវាលពិឃាត ។ ប្រាំថ្ងៃបន្ទាប់មក ស្រាប់តែបានជួបនឹងបងប្អូនដូចការយល់សប្តិមែន ។

ដូច្នេះ អ្វីដែលជាការស្រមើស្រមៃ ឬការយល់សប្តិសោះ ស្រាប់តែលេចចេញជារូបរាងជាក់ស្តែងមែន នោះលោកថា *យល់សប្តិក្លាយជាការណ៍ពិត* ៕

*ថ្ងៃទី ២២-០១-០៧*

# ៣១៥. យកប្រពន្ធស្រុកឆ្ងាយស៊ីបាយដែលឆ្អា

**និយមន័យ**

អ្វីដែលនៅឆ្ងាយ អាចមានការភាន់ច្រឡំ

**អត្ថាធិប្បាយ**

ខ្លឹមសារនៃពាក្យទំនឹមទំនៀមខាងលើនេះ ចាស់ទុំលើកយកមកប្រាប់កូនចៅជំនាន់ក្រោយ-តៗមកថា : បើចង់បានប្រពន្ធឱ្យយកនារីដែលនៅជិតៗ ឬភូមិជិតខាងផងគ្នាដែលគេអាចស្គាល់ច្បាស់នូវជីវប្រវត្តិពិតប្រាកដថា ល្អ ឬអាក្រក់បាន ។ ព្រោះតាមប្រពៃណីខ្មែរ គេតែងចង់បាននារីណាដែលមានគុណសម្បត្តិខ្ពស់ ប្រកបដោយភាពបរិសុទ្ធ គឺនារីក្រមុំព្រហ្មចារី ។ បើស្ត្រីនោះជាស្ត្រីមេម៉ាយ ឱ្យប្រាកដជាមេម៉ាយពិត មែន។

នេះគឺជាគោលបំណងរបស់ដូនតាខ្មែរ ។

ប៉ុន្តែតាមន័យខាងលើនេះ គឺលោកចង់និយាយថា បើយកប្រពន្ធស្រុកឆ្ងាយដែលគេមិនបានដឹងអំពីសាវតា ជាតិសាសន៍ និងជីវប្រវត្តិច្បាស់លាស់ថាល្អ ឬអាក្រក់ជាយ៉ាងណានោះ លោកប្រាប់ថា ប្រយ័ត្នប៉ះចំលើនារីដែលពុំមានភាពបរិសុទ្ធ ដែលលោកទុកដូចជាស៊ីបាយដែលឆ្អា គឺប៉ះលើនារីដែលត្រូវគេ កាត់ខ្សែបួរចទៅហើយ ៕

*ថ្ងៃទី ២៣-០១-០៧*

❀❀❀❀

# ៣១៦. យកបន្លាស្រាស់មុខផ្ទះ

**និយមន័យ**

ពាក្យសំដីគំរាមកំហែងពីជនកំនាច លើជនកំសោយ

**អត្ថាធិប្បាយ**

" **បន្លា ឬសំរាស់** " ជារបស់សំរាប់ស្រាស់រាំងផ្លូវមិនឱ្យគេចេញចូលបាន ។

**បន្លា** រឺសំរាស់នៅពេលនេះ លោកសំដៅយកពាក្យសំដីពោរពេញទៅដោយឥទ្ធិពលរបស់អ្នកមានអំនាច រឺរបស់ជនពាលកំនាចណាម្នាក់ដែលមានចិត្តគំនិតអាក្រក់ទៅលើជនកំសោយម្នាក់ណាដែលខ្លួនមានកំហឹងដោយប្រការណាមួយ ។ តួយ៉ាងដូចជា :

- មន្ត្រីម្នាក់ដែលមានអំនាចខ្លាំងក្លា បានទៅទំនាក់ទំនងនឹងឪពុកម្ដាយរបស់កូនស្រីម្នាក់ដែលមានជីវភាពខ្សត់ខ្សោយ ។ ជាពិសេសមិនមានបុណ្យសក្ដិ រឺក៏បុណ្យសក្ដិតូចទាប ដើម្បីយកមកធ្វើជាស្រីកំណាន់ ។ ប៉ុន្តែ ឪពុកម្ដាយមិនព្រម មន្ត្រីកំនាចនោះ ក៏បោះពាក្យសំដីថា មិនអីទេ! បើមិនព្រមក៏ហីចុះ ប៉ុន្តែនាងឯងក៏មិនអាចយកប្ដីបានដែរ ។ បើកាលណាហ៊ានយកប្ដី គឺដូចជាហ៊ានយក សេចក្ដីស្លាប់ចូលផ្ទះអីចឹង...

ដូច្នេះ ចាប់តាំងពីពេលនោះមក ទោះមានគេមកស្ដីដណ្ដឹងប៉ុន្មាននាក់ក៏ដោយក៏ឪពុកម្ដាយមិនហ៊ានឱ្យដែរ ។ ព្រោះគាត់បារម្ភដល់សុវត្ថិភាពក្នុងគ្រួសារដែលនឹងត្រូវកើតឡើងជាយថាហេតុដោយប្រការណានិមួយ ។

ហ្នឹងហើយ សំរាស់ពាក្យសំដីនៃអ្នកមានសក្ដានុភាព និងជនអន្ធពាលកំនាច ៕

*ថ្ងៃទី ២៧-០៤-០៩*

# ៣១៧. យុវជនរស់ក្នុងក្ដីសង្ឃឹម ចាស់រស់ក្នុងក្ដីស្រមៃ

**និយមន័យ**

ការស្រមើស្រមៃ អ្នកនៅមានអនាគត និង អ្នកអស់អនាគត

**អត្ថាធិប្បាយ**

☞ **យុវជនរស់ក្នុងក្ដីសង្ឃឹម**

ពាក្យ " **យុវជន** " សំដៅយកក្មេងប្រុស-ស្រីដែលនៅកំពុងពេញកំលាំង និងជាពិសេសគឺនៅ " **លីវ** " ។

យុវជន គឺជាមនុស្សដែលនៅមានអនាគតវែងឆ្ងាយទៅមុខទៀត ។ បើគេនៅកំពុងរៀនសូត្រ គេតែងនឹកឃើញអនាគតប្រកបដោយសេចក្ដីសង្ឃឹម និងមោទកភាព ។ បានជាគេចេះតែមានសេចក្ដីសង្ឃឹមយ៉ាងមុតមាំយ៉ាងនេះព្រោះអនាគតកាល រឺអ្វីដែលជាបំនងរបស់គេមិនទាន់មានមកដល់ ។ ដូច្នេះ អ្វីដែលមិនទាន់មានមកដល់មនុស្សចេះតែមានសេចក្ដីសង្ឃឹមជានិច្ច ។ ព្រោះគេនៅមិនទាន់ឃើញការណ៍ជាក់ស្ដែង ។ សេចក្ដី សង្ឃឹមនេះ ប្រៀបដូចអ្នកដែលមានសន្លឹកឆ្នោតមិនទាន់ផ្សៀង ។

☞ **ចាស់រស់ក្នុងក្ដីស្រមៃ**

ពាក្យថា " **ចាស់** " សំដៅយកអ្នកដែលឈប់រៀនហើយ, មានគ្រួសារហើយ, មានការងារធ្វើហើយ, មានអាជីវកម្មហើយ ។ មនុស្សប្រភេទនេះរមែងដឹងខ្លួនថា :

អ្វីដែលគេនឹកសង្ឃឹម និងអ្វីដែលជាបំណងរបស់ខ្លួនទាំងប៉ុន្មានហាក់ដូចជា ត្រូវចប់ត្រឹមប៉ុណ្ណោះ គឺប្រៀបដូចជាសន្លឹកឆ្នោតរបស់គេបានផ្ទៀងរួចហើយ ។ គ្រប់ការស្រមើស្រមៃទាំងប៉ុន្មានរបស់គេបានមកដល់ទីបញ្ចប់ ។

ប៉ុន្តែ តណ្ហារបស់មនុស្សនៅមិនទាន់ចប់ត្រឹមនេះទេ ។ ដូចជា ៖

- បើអ្នកធ្វើការរដ្ឋតែងនឹកស្រមៃថា គង់មានថ្ងៃល្អណាមួយគេនឹងបានឡើងបុណ្យសក្តិជាមន្ត្រីថ្នាក់នេះ ថ្នាក់នោះមិនខាន ។

- បើមន្ត្រីចូលនិវត្តន៍ក៏នៅតែនឹកស្រមៃថា គង់មានថ្ងៃណាគេនឹងហៅឱ្យជួយធ្វើការជាជំនួយនៅកន្លែងណាមួយ ។

- អ្នកចាស់ជរាខ្លះ បានបង្កើតរឿងប្រឌិតខ្លួនឯងរួចស្រមៃថា ខ្លួនឯងជាអ្នកដើរតួសំខាន់ក្នុងរឿងរវើរវាយនេះ ។

- អ្នកចាស់ជរាខ្លះទៀតនឹកស្រមៃថា គង់មានថ្ងៃណាទេវតានឹងប្រទានឱ្យគេបានជួបនឹងភព្វព្រេងវាសនា ល្អដូចជាត្រូវឆ្នោតជាដើម ៕

*ថ្ងៃទី ០១-០៦-០៩*

❀❀❀❀

# ៣១៨. យុត្តិធម៌នៅឯណា ?

**និយមន័យ**

ភាពសុក្រិត្យឥតខ្ចោះអាចរកឃើញទេ?

**អត្ថាធិប្បាយ**

ខ្លឹមសារពាក្យ " **ស្លោក = SLOGAN** " នេះគេទើបតែឮនៅក្នុងសម័យសម្ភារៈនិយមនេះឯង ។ ពាក្យនេះ គេច្រើននិយាយចំអកឱ្យអ្នកកាត់សេចក្ដីណាម្នាក់ដែលគេមិនពេញចិត្ត ។

តុលាការក្នុងលោកធ្វើសវនាការកាត់សេចក្ដីសព្វថ្ងៃនេះ គឺកាត់តាមច្បាប់ក្រមរដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌប៉ុណ្ណោះ ។ ដែលថា ឱ្យគេកាត់តាមគតិយុត្តិ គឺពុំមានទាល់តែសោះ ។ បើមានកាត់តាមគតិយុត្តិ គឺមានត្រឹមតែលើក្រដាស និងលើបបូរមាត់ប៉ុណ្ណោះឯង ។ ព្រោះច្បាប់សុទ្ធតែចាប់បង្ខំឱ្យភាគីម្ខាងឈ្នះ, ម្ខាងទៀតចាញ់ជាប្រពៃណីទៅហើយ ។ ឧទាហរណ៍ :

- ជីតា និងចៅ មានបង្អែមមួយចាន ។ ជីតាថា តាចាស់ណាស់ហើយ មិនអាចរស់នៅបានយូរប៉ុន្មានទេ ។ ដូច្នេះ បង្អែមនេះត្រូវបានតាហូប នឹងចាំតែសែនឱ្យនៅពេលស្លាប់ដឹងជាដល់ ឬមិនដល់ទេ ។ ឯចៅថា លោកតារស់នៅបានយូរណាស់ហើយ ពិសារក៏បានច្រើនដែរ ។ ចំនែកខ្ញុំ ទើបនឹងរស់បានជាង ១០ឆ្នាំប៉ុណ្ណោះដឹងជារស់នៅបានហូបយូរដូចលោកតា ឬក៏មិនបានផង ។ ដូច្នេះ ត្រូវបានខ្ញុំហូបទើបជាការគួរ ។

យោបល់ភាគីទាំងពីនេះសុទ្ធតែសមរម្យ និងប្រកបដោយតក្កភាព(Logique) ទាំងអស់ ។ បើដូច្នេះ តើត្រូវបានអ្នកណាហួបទើបយុត្តិធម៌?

- ឪពុក និងកូនតូច ថ្ងៃមួយកូនទារទិញការ៉េមញ៉ាំ ។ ឪពុកថាញ៉ាំមិនបានទេកូន វានាំឱ្យរាករូស ។ កូនថាថ្ងៃមុន ពេលប៉ាឯងដេកលក់ ខ្ញុំទិញញ៉ាំដល់ទៅពីរដុំម៉េចក៏មិនរាក ។ ឪពុកថា កាលណោះប៉ាដេកលក់ប៉ាអត់ដឹង ដឹងជាកូនឯងទិញការ៉េមអ្នកណា ។ កូនថាទិញការ៉េមពូហ្នឹង ។ ឪពុកថា កាលណោះគេធ្វើមានអនាម័យ ។ ថ្ងៃនេះប៉ាឃើញរុយរោមច្រើនណាស់ ។ កូនមិនសុខចិត្ត ក៏ប្រើអាវុធពិសេសគឺ "យំរំអុក " ។ ឪពុកក៏ទាញអាវុធពិសេស របស់គាត់ដែរគឺ "រំពាត់ " កូនឃើញរំពាត់ក៏នឹកដល់ " **ជំហឺ = ការឈឺ** " ក៏ឈប់យំ និងឈប់បានញ៉ាំដែរ ។

តើយុត្តិធម៌ ត្រូវបានទៅភាគីណា ?

*តើក្នុងលោកនេះ គេអាចរកយុត្តិធម៌ឃើញទេ?* ៕

*ថ្ងៃទី ១១-០៩-០៩*

❀❀❀❀

# ៣១៩. រោគអ្វីមិនស្មើនឹងរោគឃ្លាន

## និយមន័យ

គំលានជារោគធំចំបង

## អត្ថាធិប្បាយ

ព្រះពុទ្ធដីការបស់ព្រះបរមសាស្ត្រាចារ្យ ដែលមានបន្ទូលដូចពំនោលខាងលើនេះ គឺដើម្បីបង្រៀនដល់បរិស័ទទាំងអស់ឱ្យយល់ថា : រោគដែលធំចំបងលើសគេទាំងអស់នោះ គ្មានរោគអ្វីដែលខ្លាំងមហិមាជាងរោគឃ្លានឡើយ ។ ព្រោះរោគឃ្លាននេះហើយជាប្រភព និងជាមូលហេតុនៃបាបកម្មគ្រប់បែបយ៉ាង ។ ដោយសារមនុស្សគ្រប់រូបសុទ្ធ តែប្រាថ្នាចង់ឱ្យមានជីវិតគង់នៅឱ្យបានយឺនយូរ ។

ដូច្នេះ កាលបើម្នាក់ៗខ្វះជាតិអាហារហើយ គេនឹងដល់នូវសម្រេកឃ្លាន ។ បើគំលាននេះចេះតែប្រព្រឹត្តទៅយូរនឹងធ្វើឱ្យគេប្រឈមមុខនឹងការបាត់បង់ជីវិត ។ ហេតុនេះ គេត្រូវតែស្ទុះស្ទាររកច្រក " **រស់** " ។ ដើម្បីបានរស់គេត្រូវតែបង្ខំចិត្តហ៊ានប្រព្រឹត្តនូវអំពើបាបកម្មគ្រប់យ៉ាង ។ ដូចជា : ដើរបោកប្រាស់គេ, ដើរលួច ដើរឆក់, ដើរប្លន់សំលាប់គេ, ដើរចាប់ជីវិតគេ សំលាប់គោក្របី មាន់ទា ។ល ។

ម្យ៉ាងទៀត គំលាននេះវាយោងទៅដល់មហិច្ឆតារបស់មនុស្សទៀតផង ដូចជា : ឃ្លានអំនាច, ឃ្លានកេរ្តិ៍ឈ្មោះ, ឃ្លានបុណ្យសក្តិ ។ល ។ ដូច្នេះ ដើម្បីរក្សា

អំនាច និងតួនាទីឱ្យបាននៅគង់វង់ គេពុំញញើតប្រើអាជ្ញា និងប្រហារជីវិតអ្នកដែលមិនព្រមដង្ហែតាម ឬចូលក្នុងបក្សពួករបស់គេដែរ ។

នេះគឺជាទំនេសន៍របស់ព្រះពុទ្ធជាម្ចាស់បង្រៀនដល់បរិស័ទគ្រប់គ្នាថា: គ្មានរោគអ្វីកាចសាហាវជាងសម្រេកឃ្លានរបស់សត្វលោកដែលពោរពេញទៅដោយតណ្ហា នេះទេ ៕

*ថ្ងៃទី ២៣-០១-០៧*



# ៣២០. រពីសដៃ ផ្លែឆ្អែត

**និយមន័យ**

ហត្ថកម្ម នាំមកនូវចម្អែត

## អត្ថាធិប្បាយ

ពាំនោលនេះ លោកចង់ដឹកនាំឱ្យមនុស្សកុំនៅខ្ជិលទ្រមក់ត្រូវតែឧស្សាហ៍ធ្វើនេះធ្វើនោះ កុំទុកដៃឱ្យនៅស្ងៀមឥតប្រយោជន៍ដែលលោកទុកដូចជារពីសដៃដែរ ។ ដូចជាគេអផ្សុក ក៏យកចបទៅកាប់ដីដាំចេកបានពីរ-បី ដើម ។ បន្តិចមកគេទៅកាប់ដីលើកជារងដាំដំឡូង បន្ទាប់មកទៀតគេដើរឆ្កឹះកូនល្ហុងយកទៅដាំត្រង់កន្លែងណាចន្លោះគួរដាំបាន ។ល ។

មិនយូរប៉ុន្មាន ភ្លេច១ខ្លួនតែពីរខែកន្លះដំឡូងក៏ឱ្យផលឡើង ។ បន្តមកទៀតល្ហុងក៏ចេញផ្កា ឯចេកក៏ទំលាក់ត្រយូងទៀត ។

ពេលបានផល គេបេះយកទៅលក់ឯផ្សារ ។ គេបានកំរៃពីការរពីសដៃនេះគេទិញគ្រឿងបរិភោគ និង ឧបភោគតាមតម្រូវការដែលអាចល្បៀងជីពជន្មគេបានដោយសម្មាជីវោ ។

ប៉ុន្តែនៅក្បែរន័យខាងលើនេះដែរ លោកក៏ប្រាប់ដែរថា ប្រយ័ត្នរពីសដៃ ផ្លែមិនឆ្អែតបែរទៅជាប់ខ្នោះ រឺជាប់គុកវិញក៏មានដែរ ។ ដូចជា នៅស្ងៀមមិននៅរពីសដៃទៅអូសម៉ូតូអត់ប្រាប់ម្ចាស់គេ ។ រពីសដៃបែបនេះ លោកថាមិនល្អលេងទេ ៕

*ថ្ងៃទី ២៤-០១-០៧*

❀❀❀❀

# ៣២១. រកអុសប្រទះឈើទាប់

**និយមន័យ**

របស់កំពុងរក ស្រាប់តែចៃដន្យបានជួបប្រទះ

## អត្ថាធិប្បាយ

### 🕮 អត្ថានុរូប

បុរសម្នាក់បរទេះទៅរកអុសនៅក្នុងព្រៃ ដោយមានឧបករណ៍សំរាប់កាប់ ដូចជា កាំបិត, ពូថៅ, រណារ និងខ្សែចង ។

លុះចូលទៅដល់ក្នុងព្រៃ គេពុំបានរុករកយូរពេលពេកទេ ។ គេក៏បានជួបប្រទះនឹងដើមឈើធំមួយដើម មិនដឹងជារលំងាប់តាំងពីកាលណាមក ។ គេក៏អារកាត់-អារកាត់ លើកដាក់រទេះបរត្រលប់មកផ្ទះវិញរ៉ុយ ។

### 🕮 អត្ថប្បដិរូប

ពាក្យទំនឹមទំនៀមនេះ លោកនិយាយប្រៀបពីអ្វីមួយដែលគេកំពុងប៉ងប្រាថ្នា ចង់រកស្រាប់តែចៃដន្យគេបានរបស់នោះ ។ ជួនកាលគេបានជួបនឹងរបស់ផ្សេង តែមានសភាពប្រហាក់ប្រហែលគ្នា ឬក៏ល្អជាងក៏មាន ។ ដូចជា ៖

- ជនម្នាក់កំពុងដើររកទិញដី ស្រាប់តែជួបនឹងអ្នកដែលកំពុងចង់លក់ដី និង ផ្ទះ ។
- បុរសពោះម៉ាយម្នាក់កំពុងស្វែងរកប្រពន្ធ ស្រាប់តែជួបនឹងអ្នកមេម៉ាយ

ស្តុកម្នាក់ដែលកំពុងចង់បានប្តីដែរ ។

ការរករបស់អ្វី ស្រាប់តែជួបប្រទះរបស់នោះដូចការប៉ុនប៉ងលោកហៅថា *រក អុស ប្រទះឈើងាប់* ៕

*ថ្ងៃទី ២៥-០១-០៧*

❀❀❀❀

☞ បើលោក-អ្នក ចង់ដឹង "ជោគជតា" របស់ខ្លួនតាមរយៈ "ថ្ងៃ-ខែ-ឆ្នាំ សាកល " សូមទូរសព្ទទៅខ្ញុំ ។

# ៣២២. រស់នៅក៏គាប់ ស្លាប់ទៅក៏គួរ

**និយមន័យ**

មនុស្សដែលអស់សង្ឃឹម និងធុញថប់ក្នុងជីវិត

**អត្ថាធិប្បាយ**

ជាការណ៍ពិតណាស់ មនុស្សសត្វលោកគ្រប់រូបតែងតែមានចិត្តចង់រស់គ្រប់ៗគ្នាមិនថាក្មេង ឬចាស់ចំណាស់ណាទេ ។

ប៉ុន្តែ នៅមានមនុស្សមួយពួកទៀតដែលចង់ស្លាប់ ។ មនុស្សពួកនេះតែងជ្រើសយកការស្លាប់ដោយចង-ក, លេបថ្នាំ, លោតទឹក រឺលោតពីទីខ្ពស់ជាដើម ។

ជាយូរៗ គេបានប្រទះឃើញមនុស្សមួយចំនួនតូច ដែលពុំសូវមានតណ្ហាក្នុងការរស់ និងការស្លាប់ដែរ ។

ហេតុការណ៍នេះ ដោយសារគេតូចចិត្ត និងវាសនារបស់គេដែលគេចេះតែជួបប្រទះនូវវិបត្តិផ្សេងៗជាច្រើនផ្ទួនៗគ្នាក្នុងឆាកជីវិត ។ គេក៏ធ្លាប់ជាមនុស្ស លន្លង់លន្លោច, គេតែងមានអារម្មណ៍ថាខ្លួនគេជាមនុស្សអភព្វធំ ជាងអ្នកណាទាំងអស់ដូចជាៈ ប្រឡងធ្លាក់, បាត់បង់អាជីព, វិបត្តិស្នេហ៍ និងវិបត្តិគ្រួសារ រឺកូនចិត្តមិនបានជាដើម ។ អ្នកខ្លះទៀតមានជម្ងឺរ៉ាំរ៉ៃអស់ប្រាក់កាសព្យាបាល ។ កត្តាទាំងអស់នេះហើយបានញ៉ាំងឱ្យចិត្តរបស់គេក្លាយទៅជាឧបេក្ខាជន គឺជនដែលមានចិត្តស្មើៗក្នុងការរស់ និងការស្លាប់ ។ បានសេចក្ដីថា បើរឿងត្រូវរស់ក៏រស់ទៅ, បើរឿងត្រូវស្លាប់ ក៏ស្លាប់ទៅ ។ គឺគេគ្មានរំភើបក្នុងការរស់ និងគ្មានតក់ស្លុតក្នុងការស្លាប់ប៉ុន្មាន ។ គេបណ្ដោយឱ្យជីវិតគេប្រព្រឹត្តទៅតាមដំណើរយថាកម្មចុះ ៕

*ថ្ងៃទី ២៥-០១-០៧*

# ៣២៣. រនាបបាក់ហាក់បានជួស សំដីហួសជ្រុះអស់មាសប្រាក់

**និយមន័យ**

សំដីនិយាយជ្រុល មិនអាចលុបចោល រឺកែប្រែបានទេ

**អត្ថាធិប្បាយ**

រនាបផ្ទះ ឬរនាបគ្រែ បើមានបាក់បែកគេអាចជួសឱ្យល្អវិញបាន ។ ប៉ុន្តែក្នុងន័យខាងលើនេះ គឺលោកចង់ពោលពីពាក្យសំដីរបស់មនុស្សដែលនិយាយជ្រុលហួសទៅហើយ បើមានលើសលោះខុសឆ្គងខ្លាំងអាចចូលដល់ការប្រមាថមើលងាយ គឺប៉ះពាល់ដល់កិត្តិយសរបស់គេធ្វើឱ្យគេមានប្រតិកម្មខឹងក្រេវក្រោធរហូតដល់មានវិវាទឡើងដល់សាលាក្តី ។ ពេលនោះដើម្បីជួសជុលពាក្យសំដីដែលជ្រុសហួស និងព្យាបាលជំងឺចិត្តឱ្យគេស្ងប់អារម្មណ៍ទៅបានទាល់តែបង់ប្រាក់កាស ។

ម្យ៉ាងទៀត បើគេជ្រុលពាក្យសំដីឱ្យតំលៃរបស់អ្វីមួយដែលគេចង់ទិញហួសហាងឆេង(តំលៃលើទីផ្សារ) ។ គេមិនអាចកែប្រែក្រលះពាក្យសំដីវិញបានទេ គឺចាំបាច់ត្រូវតែបង់ខាតប្រាក់ឱ្យទៅគេ ដើម្បីរក្សាកិត្តិយសពាក្យ ដែលនិយាយជ្រុលហួសទៅហើយ ៕

*ថ្ងៃទី ២៥-០១-០៧*

# ៣២៤. ទេះបាក់កន្លែងណា ខ្ទេចស្នោកន្លែងនោះ

**និយមន័យ**

មានហេតុត្រង់ណា ត្រង់នោះតែងទទួលផលវិបាក

## អត្ថាធិប្បាយ

### 🕮 អត្ថានុរូប

ធម្មតារទេះក៏ដោយ យានយន្តក៏ដោយ បើខូចនៅត្រង់កន្លែងណាកន្លែងនោះត្រូវខ្ទេចអស់កូនឈើតូចធំ ដោយសារគេកាប់យកមកអបស្នបរទេះដែលបាក់ ។ ម្យ៉ាងទៀត ស្មៅកន្លែងនោះក៏ត្រូវទក់ខ្ទេចខ្ទីដោយសារជើងមនុស្សដើរចុះឡើងវីវក់ដើម្បីធ្វើការជួសជុល ។ បើគេជួសជុលយូរស្មៅត្រូវតែម៉ដ្ឋទៅជាដីមិនខាន ។ បើយានយន្តត្រូវជាប់ផុងវិញ គេកាប់កូនឈើក្បែរៗនោះអស់ហើយដើម្បីយកមកគាស់ ឬកល់ឱ្យយានយន្តបរទៅមុខបាន ។

### 🕮 អត្ថប្បដិរូប

បើមានហេតុការណ៍កើតឡើងនៅកន្លែងណា កន្លែងនោះត្រូវតែទទួលរងនូវបញ្ហាទៅតាមទំហំហេតុការណ៍ដែលកើតឡើងជាមិនខាន ។ ឧទាហរណ៍ :

- ព្រឹកមួយ នៅក្នុងបរិវេណផ្ទះពូសេក មានសាកសពបុរសម្នាក់មិនស្គាល់អត្តសញ្ញាណ ។ សមត្ថកិច្ចបានកោះហៅពូសេកទៅសាកសួរពតិមានម្តង ហើយម្តង

ទៀត ដែលជាហេតុនាំឱ្យគាត់ខាតបង់ពេលវេលា និងប្រាក់កាសធ្វើដំណើរចុះឡើង តែតាមការណ៍ពិតគាត់ឥតដឹងអីសោះ ។

- មានមនុស្សឈ្មោះគ្នានៅចំមុខផ្ទះពូសៅ ដែលបានបង្កឱ្យមានរបួសស្នាមយ៉ាងធ្ងន់ ។ ពូសៅ ត្រូវសមត្ថកិច្ចហៅទៅបំភ្លឺក្នុងករណីនេះជាញឹកញាប់ ធ្វើឱ្យរំខានដល់ការរស់នៅរបស់គាត់ ៕

*ថ្ងៃទី ២៦-០១-០៧*

✿✿✿✿

☞ **ព្រះសង្ឃ**គ្មានវិន័យ មិនល្អ **គ្រហស្ថ**គ្មានរបរ មិនថ្លៃថ្នូរ

*ប៉ិត - សាវង្ស*

# ៣២៥. រងថ្មបាក់

**និយមន័យ**

ទទួលរងនូវផលវិបាកជំនួសគេ

## អត្ថាធិប្បាយ

ពាក្យថា **រងថ្មបាក់** គឺជាការប្រៀបធៀបទៅនឹងអ្វីដែលត្រូវទទួលរងធ្វើជំនួសគេ ។ ឯផលវិបាកដែលធ្លាក់មកលើខ្លួននេះ គឺជាបន្ទុកមួយចៀសមិនរួច ទោះបីខ្លួនគ្មានការពាក់ព័ន្ធពីមុនមកក៏ដោយ ។ ដូចជា :

- ប្រធានអង្គភាពម្នាក់ផ្លាស់ចេញ ប្រធានថ្មីចូលមកកាន់ការបន្ត ។ ពេលគាត់ចូលមកទទួលការងាររួចហើយ ទើបបានដឹងថា អង្គភាពនេះជំពាក់បំនុលគេជាច្រើន ។ គាត់ក៏ខំប្រឹងរកលុយមកដោះបំនុលគេតាមដំនើរ ។

- ពូឆើតរៀបការនឹងអ្នកមេម៉ាយកូនបី ។ គាត់ត្រូវមានភារកិច្ចចិញ្ចឹមកូនមុនឱ្យរស់រានជាចំបាច់ ទោះគាត់មិនចង់ក៏ដោយ ក៏ត្រូវតែទទួលរកជំនួសគេដែរ ។

ការដែលទទួលរងនូវផលវិបាកដែលអ្នកមុនបន្សល់ទុកមកដូចមានករណីខាងលើនេះ លោកហៅថា *ការទទួលរងថ្មបាក់* ៕

សុជានី ចេញពីមន្ទីរពេទ្យ *ថ្ងៃទី ២៦-០១-០៧*

❀❀❀❀

# ៣២៦. រូងមួយ គ្មានខ្លាឈ្មោលពីរទេ

**និយមន័យ**

អ្នកខ្លាំង មិនអាចនៅជាមួយគ្នាបានទេ

## អត្ថាធិប្បាយ

### 🕮 អត្ថានុរូប

នៅក្នុងរូងភ្នំមួយ គេមិនដែលឃើញមានខ្លាឈ្មោលពីរទេ ។ ខ្លាឈ្មោល ក៏មិនខុសពីសត្វឈ្មោលឯទៀតៗដែរ តែងតែដណ្ដើមអំនាចគ្នាគ្រប់គ្រង ។ វាតែងវាយប្រហារគ្នារហូតទាល់តែមានអ្នកចាញ់ និងអ្នកឈ្នះ ។ អ្នកចាញ់ត្រូវបោះបង់ទីកន្លែងដែលធ្លាប់រស់នៅ ទៅរកទីកន្លែងថ្មីទៀត ។ ឯអ្នកឈ្នះត្រូវឡើងគ្រប់គ្រង ។

### 🕮 អត្ថប្បដិរូប

ខ្លាឈ្មោល លោកប្រៀបប្រដូចនាយកដឹកនាំ, ប្រធានសហគមន៍, ប្រធានអង្គភាព ។ល ។ ដែលមាន រហស្សនាមថា " បុរសខ្លាំង " ។ ធម្មតាបុរសខ្លាំង មិនអាចនៅក្នុងចង្កោម រឺក្នុងភូមិមួយពីរនាក់បានទេ ។ ប្រសិនបើនៅជាមួយគ្នាដោយចៃដន្យដូចជា : សហនាយក, សហប្រធាន, សហរដ្ឋមន្ត្រីជាដើមនោះ តោងមានម្នាក់រណបម្នាក់ ។ បើពុំដូច្នោះទេប្រាកដជាមានការប្រទាំងប្រទើសប្រទូស្តវាយគ្នាពុំបានសុខឡើយ ។ ទីបំផុតឈានទៅដល់ការវាយប្រហារគ្នាឱ្យបាក់ភាគីណាមួយមិនខាន ។

ម្យ៉ាងទៀត សូម្បីតែនៅក្នុងភូមិជាមួយគ្នា នៅផ្ទះដោយឡែកពីគ្នាសោះ ក៏ត្រូវតែកាច់បំបាក់ម្ខាងៗដែរ ។ ដូចជា :

- នៅក្នុងអំលុងទសវត្សរ៍ឆ្នាំ ៥០ នៅភូមិព្រែកអំបិល មានបុរសខ្លាំងពីរនាក់ ។ ម្នាក់នៅខាងជើង ម្នាក់នៅខាងត្បូង ។ អ្នកខ្លាំងទាំងពីរនាក់នេះ ចេះតែសន្ទ្រឹដាក់គ្នាជាប់ជានិច្ច ។ យប់មួយប្រមាណជាម៉ោងប្រាំបី, អ្នកខ្លាំងខាងជើង អង្គុយក្បែរមាត់ទ្វារផ្ទះខ្លួន (ផ្ទះក្រាលរនាបឬស្សី) ។ អ្នកខ្លាំងខាងត្បូងមកលបចូលក្រោមផ្ទះយកកាំបិតបន្ទោះបុករន្ធគូទ តែមិនចំល្អគ្រាន់តែជ្រិះ ។ មនុស្សម្នាផ្អើលឈូឆរ ឯជនល្មើសរត់គេចខ្លួនមួយភ្លែត ក៏ត្រលប់មកធ្វើជាជួយឈឺឆ្អាលវិញ ដោយទៅរកពន្លៃមកបុកបំពោករុំមុខរបួស និងជួយព្យាបាលរហូតជា ។

អ្នកខ្លាំងជើងភូមិមិនដឹងការណ៍ពិត ក៏សំរបខ្លួនរណបអ្នកត្បូងដោយគិតថា គេមានគុណ ។

ក្នុងន័យអ្នកខ្លាំងពីរនាក់ក្នុងចង្កោមជាមួយគ្នា សូម្បីតែប្ដីប្រពន្ធក៏តោងមានម្នាក់រណបម្នាក់ទើបបានសុខ ។ បើគេដណ្ដើមគ្នាធំតែរៀងខ្លួន ប្រាកដជាពុំបានសុខទេ ។

ហេតុនេះហើយបានជាលោកពោលថា *មិនអាចមានខ្លាឈ្មោលពីរក្នុងរូងតែមួយឡើយ* ៕

*ថ្ងៃទី ២៧-០១-០៧*

> រដ្ឋដេញចិន ចិនដេញខ្មែរ ខ្មែរដេញខ្មោច ។ ឥលូវ ខ្មែរគ្មានខ្មោចដេញ ក៏ដេញខ្លួនឯងឱ្យទៅជាខ្មោច ។
>
> ល.ថ.ល

# ៣២៧. រលកក្រោយរុញច្រានរលកមុខ

**និយមន័យ**

អ្នកថ្មីចូលមកជំនួស ហាក់ដូចជារុញច្រានអ្នកចាស់

## អត្ថាធិប្បាយ

### 🕮 អត្ថានុរូប

ភាពចន្លោះប្រហោងនៃលំហមេឃ ធ្វើឱ្យមានបន្លាស់ទីបរិយាកាស រួចក៏បង្កើតឱ្យបានជាចរន្តខ្យល់ឡើង ។ ចរន្តខ្យល់ក៏បណ្ដាលឱ្យមានកំលាំងសម្ពាធរុញច្រានវត្ថុនានាឱ្យប៉ើងរលំទៅបាន ។

ដូច្នេះ ទឹកដែលនៅក្រោមអំនាចសម្ពាធខ្យល់ដែរនោះក៏កំរើករំពើកឡើង បង្កើតបានជារលកតូច-ធំ ។ រលករលេញប្រដេញគ្នាពេញផ្ទៃជលសា រហូតដល់មាត់ច្រាំង ឬមាត់ឆ្នេរសមុទ្រ ។

### 🕮 អត្ថប្បដិរូប

អ្នកក្រោយឡើងមកគ្រប់គ្រង រឺទទួលតួនាទីជំនួសអ្នកមុនហាក់ដូចជារុញច្រានអ្នកមុនឱ្យឃ្លាតចេញ រឺឱ្យឆាប់ដល់ទីបញ្ចប់ ។ ដូចជា :

- អ្នកធ្វើការក្រោមចេះតែឡើងបុណ្យសក្តិបន្តគ្នាមក ហាក់ដូចជារុញច្រានអ្នកមុនបន្តគ្នារហូតដល់ទីចប់ ។

- កូនចេះតែធំឡើង ម៉ែឪចេះតែចាស់ទៅ ។ ទីបំផុតកូនក៏ឡើងមកគ្រប់គ្រងគ្រួសារជំនួសម៉ែឪ ហាក់ដូចជារុញច្រានគាត់ចេញដែរ ៕

*ថ្ងៃទី ២៨-០១-០៧*

❀❀❀❀

# ល

## ៣២៨. លួចគេធ្លាប់ដៃ ដេកថ្ងៃធ្លាប់ភ្នែក

### និយមន័យ

ទំលាប់មិនល្អ និងទំលាប់ឥតប្រយោជន៍

### អត្ថាធិប្បាយ

ទំនឹមទំនៀមនេះ មានពីរឃ្លា តែមានខ្លឹមសារប្រហាក់ប្រហែលគ្នា ។ គ្រាន់តែមានន័យថា មួយទំលាប់អាក្រក់ និងខុសច្បាប់, ទំលាប់មួយទៀតមិនខុសច្បាប់ តែឥតប្រយោជន៍ ។

- **លួចគេធ្លាប់ដៃ**

ក្នុងន័យខាងលើនេះ លោកនិយាយពីទំលាប់អាក្រក់ គឺទំលាប់លួច ។ ដំបូងឡើង គេរៀនលួចលុយបងប្អូនឯងសិន រួចឈានទៅលួចលុយឪពុកម្ដាយទៀត ។ ដល់ក្រោយមក គេប្រយ័ត្នគ្រប់គ្នាទៅលួចលែងបាន តែដៃធ្លាប់លួចទៅហើយ បើមិនបានលួចគឺនៅមិនសុខ ។ ដូច្នេះ គេក៏ឈានទៅលួចអ្នកក្រៅផ្ទះ ។

- **ដេកថ្ងៃធ្លាប់ភ្នែក**

ពេលបាយថ្ងៃត្រង់ គេសំរាកបន្តិចដើម្បីឱ្យអាហាររលាយបានល្អ ។ ប៉ុន្តែ មានមនុស្សមួយចំនួនពេលសំរាកឱ្យស្រកបាយនោះក៏លង់លក់ទៅ ។ លុះយូរៗទៅ ក៏ក្លាយ

ជាទំលាប់ខានដេកថ្ងៃមិនបាន បើខានគេថាឈឺក្បាល, មិនស្រួលខ្លួន ។

ទំលាប់ទាំងពីរនេះ លោកមិនចង់ឱ្យធ្លាប់ទេ ព្រោះវានាំឱ្យខូចកិរិយាមារយាទ និងខាតការងារ ៕

*ថ្ងៃទី ០៤-០២-០៧*

❀❀❀❀

☞ **ពិសេស** : ពាក្យពិសេស និយាយបានតែម្តងទេ, បើនិយាយចាប់ពីពីរដង លែងពិសេសហើយ ។

**អញ្ជើញ** + **ជំរាប** : ពាក្យនេះ សំរាប់យើង និយាយទៅរកគេ, បើនិយាយឱ្យគេមករកយើង គឺជាការមើលងាយគេ ។

# ៣២៩. លួចគេបានវាគ្រាន់ បើគេទាន់វាក្រៃល

**និយមន័យ**

លទ្ធផលនៃជនលួច

## អត្ថាធិប្បាយ

ខ្លឹមសារ លួចគេបានវាគ្រាន់នេះ ពុំមែនមានន័យថាលោកលើកទឹកចិត្តអ្នកលួចបានថាគ្រាន់បើ រឺល្អប្រសើរនោះទេ គឺលោកចង់និយាយពីការរងគ្រោះ ដោយសារគេវាយដំនោះឯង ។ ព្រោះធម្មតាអ្នកម្ចាស់របស់ទ្រព្យ កាលណាមានចោរមកលួចបែបនេះ គេតែងមានការក្តៅក្រហាយជាខ្លាំង ។ ប្រសិនបើគេមិនបានដឹង. មិនបានឃើញ ចាត់ទុកថាគ្រាន់បើទៅចុះ គឺគ្រាន់បើត្រង់មិនបានត្រូវព្រនង់ រឺដំបងបែកក្បាល ។ ប៉ុន្តែ បើគេទាន់វិញ ប្រាកដជាត្រូវគេកាប់ក្បាល រឺរបួសស្នាមជាទំងន់មិនខាន ។ ម្យ៉ាងទៀត បើមានអ្នកជិតខាងជួយខឹងជួយឈឺឆ្អាលទៀតផងនោះ គេនឹងមកជួយស្វាគមន៍ម្នាក់មួយដៃ.មួយជើង រឺមួយព្រនង់. រឺមួយដំបងបន្ថែមទៀតនោះប្រាកដជាដង្ហើមចង្រិតមិនខាន។ ជួនកាលអាចត្រូវធ្វើលិខិតឆ្លងដែនទៅកាន់បរលោកទៀតក៏មានដែរ ។

ហេតុនេះហើយ បានជាលោកថា *លួចគេបានវាគ្រាន់ តែបើគេទាន់វាក្រៃល* ។ ខ្លះទៀតថា បើគេទាន់វា គ្រប់គឺ គ្រប់ដៃ. គ្រប់ជើង. គ្រប់ព្រនង់. គ្រប់ដំបងនោះឯង ៕

*ថ្ងៃទី ០៥-០២-០៧*

# ៣៣០. លើកស្នា បង្ការក្អែក

## និយមន័យ

អាវុធបញ្ឆោត បន្លំក្អែកសត្រូវ

## អត្ថាធិប្បាយ

### 🕮 អត្ថានុរូប

" **ស្នា** " គឺជាអាវុធវាយប្រហារដោយព្រួញសំរាប់បាញ់សត្វស្លាប រឺសត្វជើងរជើង។

ក្នុងន័យខាងលើនេះ លោកចុចចំសត្វក្អែកធ្វើជាតួយ៉ាង ។ ធម្មតាសត្វក្អែក បើមានគេហាលត្រីប្រលាក់ធ្វើងៀតលើរាន, ក្អែកតែងតែចុះមកឆាបឆក់យកទៅស៊ី, បើវាមានគ្នាច្រើនវិញ វាចុះមកឆាបឆក់ទាល់តែអស់ ។ ប៉ុន្តែ វាខ្លាចស្នាណាស់ពិតមែន តែវាជាសត្វតិរច្ឆានរស់នៅក្នុងសភាវគតិ (INSTINCT) ក៏ដោយក៏វាចេះចំនាំបានដែរ ។

ហេតុនេះហើយ បានជាពេលគេហាលត្រីម្តងៗ ដើម្បីការពារត្រីហាល គេតែងយកស្នាមកចងនឹងបង្គោលរាន, ក្អែកឃើញស្នាមិនហ៊ានចុះមកទេ ។ ម្យ៉ាងទៀត បើគេមានស្លាបក្អែកដែលងាប់ពីមុន គេយកមកចងឱ្យក្អែកឃើញក៏បានដែរ ។ ព្រោះវាខ្លាចដូចគ្នា គឺវាមិនហ៊ានចុះមកទេ វានាំគ្នាស្រែកខ្វក-ខ្វក ទ្រហឹងអឹងអាប់លើអាកាស ។ បើគេយករំពាត់វាយវាត់ស្លាបក្អែកនោះថែមទៀតវារឹតស្រែកខ្វក-ខ្វករឹតតែខ្លាំងឡើងទៀត ហាក់ដូចជាគេវាយត្រូវខ្លួនវាពិតៗអ៊ីចឹង ។

## 🕮 អត្ថបដិរូប

កិច្ចការអ្វីគេត្រូវតែការពារ បើមិនបានការពារមែនទែន ក៏គេត្រូវការពារបញ្ឆោតដែរ ដើម្បីកំលាចសត្រូវឱ្យយល់ច្រឡំ ។ ដូចជា ៖

- កសិករម្នាក់ ធ្វើរូបទីងមោងដោតកណ្ដាលស្រែបញ្ឆោត សត្វចាបឱ្យស្មានថា មនុស្សវាមិនហ៊ានចុះស៊ីស្រូវទេ ។

- កសិករម្នាក់ទៀត យកទឹកនោមមនុស្សទៅស្រោចៗជុំវិញចំការដំនាំ ដើម្បីកុំឱ្យជ្រូកព្រៃចូលស៊ី ។ ព្រោះក្លិនទឹកនោមធ្វើឱ្យវាស្មានថា មានមនុស្សនៅជិតៗនេះ ។

- អ្នកចំការឪឡឹកម្នាក់ ដោយចោរចេះតែលួចញឹកញយពេក ក៏ទៅធ្វើរោងដេកចាំ យប់ឡើងគេចងមុងយ៉ាងត្រឹមត្រូវ ។ ប៉ុន្តែស្ងាត់ៗគេលួចដើរមកផ្ទះវិញបាត់ ដោយទុកឱ្យមុង និងខ្នើយឱបដេកចាំម្នាក់ឯងចុះ ។

កិច្ចការអ្វីក៏ដោយ ដែលគេធ្វើគ្រាន់តែបញ្ឆោត រឺបន្លំភ្នែក លោកពោលថា *លើកស្នា បង្ការភ្នែកទាំងអស់* ៕

*ថ្ងៃទី ០៨-០២-០៧*

❀❀❀❀

# ៣៣១. លឺផ្គរ កុំអាលចាក់ទឹកចោល

**និយមន័យ**

អ្វីដែលគ្រាន់តែឮគេថា កុំអាលបោះបង់ការងារចាស់

## អត្ថាធិប្បាយ

### 🕮 អត្ថានុរូប

បើគ្រាន់តែឮផ្គរលាន់មិនទាន់មានភ្លៀងបង្អុរមកទេ គេមិនត្រូវប្រញាប់ប្រញាល់ចាក់ទឹកដែលនៅសល់បន្តិចបន្តួចបាតពាងចោលទេ ។ ព្រោះជួនកាលផ្គរលាន់បញ្ឆោតក៏មាន បើគេប្រញាប់លាងពាងចាក់ទឹកចោល ។ គេប្រាកដជាខាតហើយ ។ ដូច្នេះគេត្រូវរង់ចាំទាល់តែមានភ្លៀងខ្លាំងសិន ។

### 🕮 អត្ថប្បដិរូប

បើបានឮពត៌មានដែលមិនទាន់មានប្រភពច្បាស់ការណ៍ គេមិនត្រូវស្ទុះស្ទារបោះបង់ការងារចាស់ចោលឡើយ ។

ម្យ៉ាងទៀតរបស់ប្រើប្រាស់ ទោះបីរខេករខាករយីករយាកពិបាកប្រើក៏ដោយ គេមិនត្រូវប្រញាប់ប្រញាល់គ្រវាត់ចោលដែរ ។ ល្គឹកណា គេមិនទាន់បានរបស់ថ្មីមកដល់ដៃជាជំនួស ។ ព្រោះបើគេប្រញាប់បោះបង់របស់ចាស់ចោល គេអាចខកចិត្តជាមិនខាន ។ ដូចជា :

- យុវជនម្នាក់ គ្រាន់តែបានឮថាឪពុកគិតទិញម៉ូតូថ្មីឱ្យ គេក៏យកម៉ូតូចាស់ទៅលក់បាត់ ។ បួន-ដប់ថ្ងៃហើយ ឪពុកមិនទាន់បានទិញឱ្យទេ ។ គេមានចិត្តកង្វល់កង្វាយជាខ្លាំង ។

- នយោជិតម្នាក់ បានដឹងថាគេរើសយកអ្នកបំរើការងារក្នុងផ្នែករដ្ឋបាល ។ គេក៏ពឹងពាក់អ្នករត់ការឱ្យដែលបានប្រាប់ថា ច្បាស់ជាបានសំរេចមួយរយភាគរយ ។ គេក៏លាឈប់ពីកន្លែងចាស់ ។ ប៉ុន្តែពីរ-បីខែហើយ គេមិនទាន់ត្រូវបានគេហៅឱ្យចូលធ្វើការសោះ ។ គេក៏ត្រូវខកចិត្តជាខ្លាំង ៕

*ថ្ងៃទី ០៨-០២-០៧*



# ៣៣២. លើកកញ្ជើដើរ

**និយមន័យ**

ការតាំងនៅមិននឹងនមួយកន្លែង

**អត្ថាធិប្បាយ**

ទំនឹមទំនៀមនេះ លោកពោលសំដៅដល់មនុស្សជំពូកខ្លះដែលពុំមានទីតាំងត្រង់កន្លែងណាមួយឱ្យពិតប្រាកដ, ឱ្យច្បាស់លាស់ ។ ដោយម្តងគេឃើញនៅត្រង់នេះ ម្តងឃើញនៅត្រង់នោះ ដែលគេហៅថាមនុស្សអណ្តែតត្រសែតដូចចករសាត់តាមទឹកដូច្នោះដែរ ។

ខ្លឹមសារខាងលើនេះ លោកក៏ស្តីយោងទៅដល់ជនខ្លះទៀត ដែលមានចិត្តសាវ៉ាមិនប្រាកដនិយម ម្តងគេឃើញធ្វើការនៅកន្លែងនេះ ម្តងនៅកន្លែងនោះ, ម្តងទៅរកស៊ីនៅកន្លែងនេះ ម្តងទៅកន្លែងនោះផងដែរ ។

ការណ៍ដែលពុំមានទីតាំងត្រង់ណាមួយឱ្យពិតប្រាកដ រឺប្រកបការងារណាឱ្យស្ថិតស្ថេរបែបនេះ លោកហៅថា **មនុស្សលើកកញ្ជើដើរ** ទាំងអស់ ៕

*ថ្ងៃទី ០៨-០២-០៧*

✿✿✿✿

# ៣៣៣. លេងក្មេងអាប់យស លេងពស់ខាំដៃ

**និយមន័យ**

ការលេងសើចខុសទំនង

## អត្ថាធិប្បាយ

" **យស** " មានន័យថា អានុភាព, តេជះ, កេរ្តិ៍ឈ្មោះល្អ, សេចក្តីប្រសើរថ្កុំថ្កើង, សេចក្តីស្រលាញ់រាប់អាន, សេចក្តីថ្លៃថ្នូរ ។

បើតាមខ្លឹមសារខាងលើនេះ អ្នកខ្លះមានសក្តិធំមែន តែពុំសូវមានយសប៉ុន្មានទេ, អ្នកខ្លះពុំមានសក្តិទេ តែមានយសច្រើនដែលគេហៅថា យសបរិវា គឺមានអ្នកស្រលាញ់រាប់អានច្រើន ។

ដូច្នេះ " យស " នេះពុំមែនមានតែលើអ្នកមានលុយច្រើន រឺមានបុណ្យសក្តិនោះទេ។ សូម្បីប្រជារាស្ត្រ សាមញ្ញក៏មានដែរ ។

ហេតុនេះហើយបានជាលោកប្រាប់ថា កុំលេងជាមួយក្មេង ព្រោះក្មេងគ្មានស្គាល់លោកណាមានសក្តិ រឺអត់សក្តិទេ តែកាលណាគេលេងធ្វើឱ្យវាឈឺវាខឹងហើយរួចវានិយាយគ្មានសីលធម៌ទេ ជួនកាលវាជេរក៏មាន ដែលជាហេតុនាំឱ្យអាប់ឱនដល់កិត្តិយស ។ ហ្នឹងហើយ ដែលគេហៅថា **ក្មេង** នោះ ។

ឯពាក្យថា **លេងពស់ខាំដៃ** គឺលោកលើកមកគ្រាន់ជាការបញ្ជាក់ និងប្រៀបធៀបនូវន័យខាងលើប៉ុណ្ណោះ ។ ព្រោះពស់កាលណាមនុស្សលេងវាៗនឹងចឹកមិនខាន គឺមិនខុសពីកូនក្មេងដូច្នោះឯង ។

*ថ្ងៃទី ០៩-០២-០៧*

# ៣៣៤. លិចកញ្ចង់ លង់កញ្ចើ

## និយមន័យ

ការលិចលង់វិនាសអន្តរាយទ្រព្យសម្បត្តិ

## អត្ថាធិប្បាយ

" **កញ្ចង់** " ពាក្យនេះដាក់មកសំរាប់បន្ថែមធ្វើឱ្យពាក្យ **លិច** រឹតតែមានន័យជ្រៅខ្លាំងឡើង, ធំឡើង គឺលិចខ្លាំងមែនទែន ។

" **កញ្ចើ** " ក្នុងទីនេះ ក៏មានន័យប្រហាក់ប្រហែលគ្នានឹងន័យខាងលើដែរ គឺលង់ខ្លាំងក្រៃលែង ។ ម្យ៉ាងទៀតពាក្យថា **កញ្ចើ** ដាក់មកជួយលំអ និងឱ្យមានសូរសៀងរណ្ដំលំហែងណងតាមសូរសិល្ប៍ធ្វើឱ្យរឹតតែចាប់អារម្មណ៍ខ្លាំងឡើងទៀត ។

" **លិចកញ្ចង់ លង់កញ្ចើ** " គឺធ្វើឱ្យវិនាសអន្តរាយទ្រព្យសម្បត្តិ ដោយសារតែកិរិយាមារយាទឥតសណ្ដាប់ធ្នាប់, ធ្វើអ្វីៗកញ្ចះកញ្ចោយគ្មានចេះគិតគូប្រយ័ត្នប្រយែង, ឥតគិតមុខគិតក្រោយឱ្យគ្រប់ជ្រុងជ្រោយ ។ ដូចជា :

- បុរសម្នាក់ចេញទៅរកស៊ីរត់ពន្ធដោយគ្មានចេះរកមធ្យោបាយគ្រប់គ្រាន់ឱ្យបានល្អ ក៏ត្រូវសមត្ថកិច្ចចាប់ពិន័យខាតដើមខាតចុង ។ នៅសល់របស់ខ្លះ ថែមត្រូវលក់ខាតអស់ទៀត ។

- យុវសិស្សម្នាក់ត្រូវប្រឡងធ្លាក់ហើយថែមត្រូវចោរលួចម៉ូតូបាត់ទៅទៀត ។ អ្វីដែលនាំឱ្យអន្តរាយ ហើយថែមហិនហោចទៀត លោកថា **លិចកញ្ចង់ លង់កញ្ចើ** ទាំងអស់ ៕

*ថ្ងៃទី ១៥-០៣-០៧*

# ៣៣៥. លូកប្រហុក លូកឱ្យកប់ក្លៀក

**និយមន័យ**

បើជ្រុលលូកដៃធ្វើ គប្បីធ្វើទាល់តែសំរេច

**អត្ថាធិប្បាយ**

អ្នកណាក៏ដឹងដែរថា ប្រហុកមានក្លិនមិនសូវល្អបន្តិច ។ ប៉ុន្តែ ប្រហុកក្នុងពេលនេះ ពុំមែនតំនាងឱ្យភាវៈអាក្រក់ទាំងអស់ទេ គឺតំនាងឱ្យការងារណាដែលពិបាកផងដែរ ។

📖 **អត្ថានុរូប**

ប្រហុកបើគេលូកត្រឹមតែបន្តិច ក៏ប្រលាក់ស្អុយជាប់ដៃ ។ ដូច្នេះ លោកប្រាប់ថា បើបានជាជ្រុលស្អុយជាប់ដៃទៅហើយត្រូវលូកខ្វារឱ្យកប់ដៃតែម្តងទៅ ។

📖 **អត្ថប្បដិរូប**

អត្ថន័យនៃពាក្យទំនឹមទំនៀមខាងលើនេះ លោកប្រៀបធៀបទៅនឹងការងារពិបាកដែលគេបានលូកដៃចូលធ្វើហើយ ។ គេត្រូវតាំងចិត្តដាច់ខាតថា គេត្រូវតែតស៊ូធ្វើការងារនោះទាល់តែបានសំរេចជាស្ថាពរសឹមឈប់ ។

ម្យ៉ាងទៀតក្នុងន័យនេះ លោកច្រើនប្រៀបធៀបទៅនឹងការងារណាដែលខុសច្បាប់ គឺធ្វើបន្តិចក៏ខុស ធ្វើច្រើនក៏ខុស ដូច្នេះត្រូវធ្វើច្រើនតែម្តងទៅ ។

ឧទាហរណ៍ :

- អ្នករកស៊ីរត់ពន្ធជ្រូក ១០ក្បាលទៅបរទេស គឺខុសនឹងច្បាប់ហាមឃាត់ហើយ ។ ដូច្នេះ បំនាច់ខុសនឹងច្បាប់ គេត្រូវដាក់ ១០០ក្បាលតែម្តងទៅ ។ ព្រោះ បើហោង គេគ្រាន់នឹងចាយដែរ តែបើស៊យ រត់ចោលស្រុកតែម្តងទៅ ៕

*ថ្ងៃទី ០៧-០៩-០៧*

❀❀❀❀



# ៣៣៦. លួចស្រលាញ់លួចកើតទុក្ខ

**និយមន័យ**

អ្វីដែលលួច សុទ្ធតែមានផលវិបាក

**អត្ថាធិប្បាយ**

វាជាការធម្មតាទៅហើយ កាលណាគេឮពាក្យថា "**លួច**" គេតែងនឹកឃើញដល់ក្រមរដ្ឋប្បវេណីដែលចែង ពីមាត្រាច្បាប់គំរូឱ្យជនលួច ត្រូវទទួលទោសទណ្ឌមានកំរិតធ្ងន់ស្រាលទៅតាមទំហំនៃការប្រព្រឹត្តរបស់ជនល្មើស ។

ប៉ុន្តែ ការលួចក្នុងនិយមន័យខាងលើនេះ ពុំមានច្បាប់ឯណាចែងពីការត្រូវទទួលទោសទណ្ឌតាមផ្លូវតុលាការទេ ព្រោះពុំមានអ្នកប្ដឹង ។ ដូច្នេះ គេត្រូវទទួលទោសទណ្ឌតាមផ្លូវសត្យានុម័តវិញ ។ ព្រោះថាអ្វីក៏ដោយឱ្យតែមានពាក្យថា **លួច** គេតែងទទួលផលមិនល្អទាំងអស់ ទោះបីគ្មានអ្នកណាដឹងក៏ដោយ ។ បើតាមទ្រឹស្ដីព្រះពុទ្ធសាសនាថា ការលួចសុទ្ធតែមានមនុស្សដឹងទាំងអស់ បើអ្នកដទៃមិនដឹង ក៏ខ្លួនឯងអ្នកលួចដឹងដែរ ។ ដូច្នេះត្រូវតែទទួលអកុសលកម្មចៀសមិនផុត ។ ក្នុងន័យខាងលើនេះទៀត លោកចង់ពោលថា បើអ្នកឯងលួចស្រលាញ់គេ អ្នកឯងក៏ត្រូវលួចកើតទុក្ខរីងរៃម្នាក់ឯងអស់កាលឆាប់ រឺយូរ ទៅតាមទំហំចិត្តដែលលួចស្រលាញ់គេនោះឯង ។ ព្រោះថាអ្នកឯងលួចស្រលាញ់គេមិនឱ្យគេដឹងក៏ត្រូវតែលួចកើតទុក្ខរីងរៃម្នាក់ឯងមិនឱ្យគេដឹងដូចគ្នា ។ ជួនកាលការលួចកើតទុក្ខនេះមានទំហំធំអាចឈានទៅដល់ទំរើអត្តឃាត ក៏មានដូចជា : លេបថ្នាំ, ចង-ក, លោតទឹក ។ល ។ ផងដែរ ។

នេះហើយ គឺជាផលកម្មដែលលួចនោះ ។ សមដូចពាក្យស្លោកមួយចែងថា : "សេចក្ដីស្នេហា ធំជាងសេចក្ដីស្លាប់" គឺបើគេកាន់តែបិទបាំង គេក៏កាន់តែ "អន្ទះសា" ខ្លាំងដែរ ។ គេនឹងបែកទ្រូងស្លាប់ ព្រោះមិនបានទំលាយចេញ ៕

*ថ្ងៃទី ០១-០៨-០៩*

# ៣៣៧. លើកក្ដោង ទាន់មានខ្យល់

**និយមន័យ**

ធ្វើអ្វីៗទាន់ឱកាសហុចឱ្យ

## អត្ថាធិប្បាយ

សុភាសិតនេះ លោកអប់រំថា ធ្វើអ្វីៗក៏ដោយឱ្យសមស្រប និងជាពិសេសធ្វើឱ្យ ទាន់ឱកាសដែលកំពុងហុចឱ្យ ។

### 🕮 អត្ថានុរូប

" **ខ្យល់** " នៅពេលនេះ លោកសំដៅយកចរន្តខ្យល់ដែលបក់មកខ្លាំងខុស ពីធម្មតា ប៉ុន្តែមិនថ្នាក់ដល់រលំផ្ទះសំបែងនោះទេ គឺជាខ្យល់ដែលឱ្យមនុស្សអាចទាញ យកផលប្រយោជន៍ពីចរន្តខ្យល់នេះ ប្រើការបាន ។ ដូចជា : លើកក្ដោងទូកឱ្យមាន ចលនាលឿនទៅមុខ, រោយស្រូវ, រោយសណ្ដែក, រោយល្ងជាដើម ។

### 🕮 អត្ថប្បដិរូប

គោលបំណងរបស់លោកដែលលើកយកពំនោលនេះមក គឺចង់សង្កត់ធ្ងន់ និង ជាពិសេសទៅលើមុខរបរអ្វី ដែលកំពុងហុចឱកាសឱ្យភ្លាមៗនោះ ។ គេត្រូវតែស្ទុះ ស្ទារឆក់យកឱកាសដ៏កម្រ និងកំពុងហុច

ឱ្យភ្លាមៗនោះអោយបានទាន់ពេលវេលា ។ ប៉ុន្តែ នៅក្នុងឱកាសយ៉ាង អាសន្ននេះ ក៏គេត្រូវប្រយ័ត្នប្រយែងណាស់ដែរ ។ ព្រោះថា វាអាច *មួយចានទឹក មួយចានគោក* ។ ដូច្នេះ គេត្រូវប្រើប្រាជ្ញាត្រិះរិះពិចារណា ឱ្យបានវាងវៃបំផុត ទើបអាចចាប់យកផលប្រយោជន៏នោះបាន ។ ដូចជា:

- ដីកំពុងឡើងថ្លៃ គេត្រូវប្រើគំនិតឱ្យបានខ្ពស់ឈ្លាសវៃបំផុត បើត្រូវលក់ គឺលក់ភ្លាម ។

- គេកំពុងសក់កម្មទិញនូវរបស់អ្វី យើងត្រូវសកម្មរករបស់នោះយក មកលក់ឱ្យ ទាន់សេចក្តីត្រូវការរបស់គេ ។

- ត្រូវប្រឹងយ៉ាងសកម្ម រកស៊ីនូវរបរអ្វី ដែលច្បាប់មិនទាន់ហាមឃាត់ ។

ការឆក់ឱកាស ឬឆ្លៀតឱកាសរកស៊ីនៅពេលដែលច្បាប់មិនទាន់ តឹងតែង ឬ នៅពេលមានហាងឆេង លោកថា *លើកក្តោង ទាន់មានខ្យល់* ។ ប៉ុន្តែន័យនេះមិនយោង ទៅដល់មុខរបរណាដែលខុសច្បាប់ផងទេ ៕

*ថ្ងៃទី ១៣-០៨-០៩*

✿✿✿✿

# ៣៣៨. លោកថាឆ្កួតបី

**និយមន័យ**

អបាយមុខទាំងបី រមែងនាំមកនូវសេចក្ដីវិនាស

## អត្ថាធិប្បាយ

ព្រះអនាវរណញ្ញាណ ទ្រង់ត្រាស់ថា អ្នកដែលប្រព្រឹត្តនូវល្បែងតែងនាំមកនូវសេចក្ដីវិនាសហិនហោចទាំងអស់ ទោះជាល្បែងប្រភេទណាក៏ដោយ ។ ល្បែងដែលព្រះអង្គ ទ្រង់ត្រាស់សំដែងទុកមកមានបី គឺល្បែងស្រី ឬល្បែងភេទ, ល្បែងស្រា និងល្បែង ស៊ីសងនានា ។

**ក. ល្បែងស្រី ឬល្បែងភេទ**

ល្បែងភេទនេះ សំដៅយកបុរស-ស្ត្រីណាដែលមានចិត្តលំអោនទៅរក "**កាមារម្មណ៍**" គឺជាអ្នកត្រេកត្រអាលភ្លើតភ្លើនក្នុងផ្លូវភេទ ។ បើជាបុរសតែងគាប់ចិត្តនឹងភេទស្ត្រី, បើជាស្ត្រីតែងគាប់ចិត្តនឹងភេទបុរស ពុំចេះឆ្អែតឆ្អន់ ។ ដូចជា :

- បុរសខ្លះចូលចិត្តដើរស្វែងរកគូដៃស្រីតាមហាង, តាមខារ៉ាអូខេ, តាមបារ, តាមសួន ច្បាររកក្រូចច្របាច់ជញ្ជក់ រឺ ក៏ដើរប្រមាញ់តាមផ្លូវ ។ល ។

- ស្ត្រីខ្លះងុបងល់នឹងប្រុសក្មេងខ្លាំងពេកទៅហ៊ានលួចលុយប្ដី ដើម្បីចិញ្ចឹមប្រុសក្មេង ។ ស្រីខ្លះចើកមែនទែនទៅ ហ៊ានរហូតយកប្រុសសហាយមកដេកលើផ្ទះទៀតផង ។ ខ្លះទៀតហ៊ានផិតក្បត់រត់ចោលប្ដី និងកូនទៅតាមប្រុសក៏មាន ។ល ។

## ខ. ល្បែងស្រា និងមេរ័យ

ល្បែងស្រា និងមេរ័យ (ទឹកបំបៅមេ) អ្នកដែលចូលចិត្តវារហូតដល់ថ្នាក់ញៀនញ៉ាំមដាមដិត ជាប់ដកខ្លួនមិនរួច ខានមិនបាន ដែលគេហៅថា "ដុះមេ " ។ កាលបើដុះមេក្នុងខ្លួនហើយ គេមិនអាចខានផឹកបានទេ ។ ព្រោះបើខានផឹក វានាំឱ្យក្ដួចង្អោរ ។ បុរាណាចារ្យលោកថា បើផឹកដល់ ១៤កែវ វានឹងអសោចិ៍ក្ដៅរិមិនខាន គឺដើរបូតក្រមា, សារុង, សំពត់ពីខ្លួន មិនខ្វីខ្មាសអ្នកណា ចង់លេចអីលេចទៅ ។

ម្យ៉ាងទៀត ការស៊ីផឹកនេះ បើផឹកម្នាក់ឯងក៏មិនឆ្ងាញ់ដែរទាល់តែមានគ្នា, មានពួកម៉ាកពួកភឿនដែលចេះផឹកស៊ីដូចគ្នា ។ លុះផឹកយូរៗទៅនាំឱ្យហិនហោចលុយកាក់ហ៊ានដល់យករបស់ក្នុងផ្ទះទៅលក់ រឺបញ្ចាំ រឺក៏ដោះខ្សែ-ក ខ្សែដៃ ប្រពន្ធយកទៅលក់ទៀត ដើម្បីបំពេញការញៀនរបស់គេ ។ ជួនកាលផឹកស៊ីស្រវឹងពីណាពីណីក្រៅផ្ទះ លុះចូលមកដល់ក្នុងផ្ទះក៏រករឿងវាយដំច្រំធាក់ប្រពន្ធកូនឥតត្រាប្រណីរហូតដល់ មានទោសទណ្ឌតាមផ្លូវតុលាការ ព្រោះតែអំពើហិង្សាក្នុងគ្រួសារក៏មាន ។

## គ. ល្បែងភ្នាល់

ភាសាអ្នកលេងល្បែងភ្នាល់គ្រប់ប្រភេទ តែងពោលថា " *ល្បែងតែងវេ ម្ដងយើង ម្ដងគេ* " ពាក្យសំលោកនេះហើយដែលលើកទឹកចិត្តឱ្យគេមានកំលាំងលេងមិនខ្លាចនឿយហត់ ។ ទោះបីជាគេចាញ់អស់លុយពីខ្លួន ក៏ចិត្តគេនៅតែមិនចាញ់ដែរ ។ ព្រោះគេសង្ឃឹមថា បន្តិចទៀតនឹងរឈ្នះមកវិញមិនខាន ។ ប៉ុន្តែ គេភ្លេចគិតពាក្យ

ស្លោកមួយថា" *មេមិនដែលនៅក្រោមពង*" ។ ល្បែងតែងវេពិតប្រាកដមែន គឺវាវេចុះវេឡើង វេទាល់តែដោះនាឡិកាដៃ, ខ្សែ-ក, ម៉ូតូ, ឡាន បញ្ចាំក្នុងវង់ល្បែង ។ បើអ្នកចាញ់ជាស្រីរូបស្រស់វិញ ច្បាស់ជាសុខចិត្តលក់សម្រស់ដោះកិត្តិយសចោលមួយភ្លែតសិនចុះ បើមានប្រុសត្រូវការ ។

ហ្នឹងហើយល្បែង ទោះជាល្បែងអ្វីក៏ដោយសុទ្ធតែនាំមកនូវសេចក្ដីវិនាសទាំងអស់ គឺវិនាសបុណ្យសក្តិ, វិនាសទ្រព្យធន, វិនាសកិត្តិយស ។

ល្បែងទាំងបីខាងលើនេះហើយដែលព្រះបរមសាស្ត្រាចារ្យទ្រង់ត្រាស់ថា :

**"ឥត្ថីធុត្តោ សុរាធុត្តោ អក្ខធុត្តោ ច យោ នរោ លទ្ធំ លទ្ធំ វិនាសេតិ តំ បរាភវតោ មុខំ "**
មានន័យថា ការញៀននឹងល្បែងស្នេហាក្ដី, ការញៀននឹងល្បែងស្រាក្ដី, ការញៀននឹងល្បែងភ្នាល់ក្ដី សុទ្ធតែនាំមកនូវសេចក្ដីវិនាស ទាំងអស់ ៕

*ថ្ងៃទី ២៧-០៩-០៩*

❀❀❀❀

# ៣៣៩. លក្ខណៈមនុស្ស៤ពួក កម្លោះឱ្យមើលជ្រុង ក្រមុំឱ្យមើលដាយ មេម៉ាយឱ្យមើលសក់ ជិតខាងឱ្យមើលព្រាំ

**និយមន័យ**

លក្ខណៈមនុស្ស ៤ប្រភេទ

**អត្ថាធិប្បាយ**

ពាក្យស្លោកនេះ ស្ទើរតែហួសសម័យកាលទៅហើយ តែយើងលើកយកមកធ្វើអត្ថាធិប្បាយ ដើម្បីរក្សាទុកកុំឱ្យបាត់បង់ ។

**ក. កម្លោះឱ្យមើលជ្រុង**

កាលសម័យពីដើម បុរាណាចារ្យ លោកឱ្យសំគាល់មើលមនុស្សកំលោះថា មានគំនិត រឺអត់ ។ លោកឱ្យមើលជ្រុងស្រែដែល កំលោះនោះភ្ជួរ ។ ដើម្បីទុកដាក់ កូនចៅជាគូវាសនាកុំឱ្យខុស ។

ព្រោះធម្មតាការភ្ជួរតែងតែសល់ត្រង់ជ្រុងទាំង៤។ បើ កំលោះនោះ មានគំនិតគេយកចបមកកាប់គ្រប់ជ្រុង បើចោលម្សៀតគេទុកចោលទាំងអស់ ដោយអាង លេសថា នង្គ័លចូលមិនដល់ ។

## ខ. ក្រមុំឱ្យមើលជាយ

តាំងពីបុរាណកាលរៀងមក ក្រមុំខ្មែរ ពេលទៅណាមកណាម្តងៗ តែងតែ បង់-ក ក្រមាជាប់ជានិច្ច ។ ហេតុនេះហើយបានជាលោកថា : បើគេ ចង់ដឹងថាក្រមុំនោះ ឧស្សាហ៍ ឬខ្ជិលច្រអូស ។ លោកឱ្យសង្កេតមើលតែ ជាយក្រមា គឺជាការគ្រប់គ្រាន់ ។ ព្រោះបើជាយក្រមានោះពុំត្រូវដេរលិនទេ ។ ចាស់ៗតែងមានដំនៀលថា : ក្រមុំ ចោលម្សៀតកណ្តៀតស្អុគ មិនគប្បីយក ធ្វើជាកូនប្រសារឡើយ ។ ព្រោះសព្វបើគ្រាន់តែជាយក្រមាបង់-កខ្លួនឯង ក៏ មិនលិនទៅហើយ ចុះទំរាំបើកិច្ចការផ្សេងៗ ដឹងជាយ៉ាប់យ៉ាងណាទៅទៀត ។

## គ. មេម៉ាយឱ្យមើលសក់

ជំនាន់ដើម ស្ត្រីខ្មែរដែលមានប្តីហើយ ច្រើនរាយមាយសក់ក្បាលគឺ តាមតែ វាក្រញេសក្រញាសយ៉ាងណាតាមដំនើរវាចុះ ។ ព្រោះគេគិតថា គេមានប្តីហើយតែង ខ្លួនឱ្យអ្នកណាស្រលាញ់ទៀត ។

ប៉ុន្តែក្នុងន័យខាងលើនេះ លោកឱ្យសំគាល់មើលនារីណាដែលនៅលេងសក់ ដូចជា : សិតយ៉ាងស្អាត, ចងជីបដោយបូ ជួនកាលលំអទៅដោយផ្កាទៀតផងនោះ គឺជាស្ត្រីមេម៉ាយហើយ ។ ព្រោះអីគេតែងខ្លួន

ដើម្បីបង្អួត ប្រុស១ ជូនជាវាសនាមាន អាចទាក់បានកំលោះអូរីហ្សិន ទៀតផង ។

ប៉ុន្តែកំនត់សំគាល់នេះ ហាក់ដូចជាហួសសម័យកាលទៅហើយ ។ ព្រោះ សម័យឥលូវនេះ នារី១ ទោះបីក្រមុំ, មេម៉ាយរឺមានប្តីក៏ដោយ គេលេងសក់សំបើមណាស់ ។ អ្នកខ្លះហាយឡាយសក់ សឹងតែបាត់អត្តសញ្ញាណខ្លួនឯងជាខ្មែរអស់ទៅហើយ ។

### ឃ. ជិតខាងឱ្យមើលព្រំ

ដើម្បីសំគាល់ឱ្យដឹងថា

អ្នកជិតខាងគឺអ្នកដែលមានព្រំដីជាប់គ្នាថាជាមនុស្សល្អ រឺមិនល្អលោកឱ្យសំគាល់ ដូចនេះ :

- ប្រសិនណាបើ អ្នកនៅជាប់ព្រំដីគ្នាជាមនុស្សអាក្រក់ គេតែងលួចអង្កីលបង្គោលព្រំបន្តិចម្តងបន្តិចម្តង ។

- អ្នកខ្លះយកដើមឫស្សីដាំ ដោតត្រង់ព្រំ ។ បន្ទាប់មកឫស្សី ចេះតែដុះទំពាំងកើនឡើងកើនឡើង ធ្វើឱ្យបាត់ខ្សែបន្ទាត់ព្រំ ហាក់ដូចជាអង្កីលផ្ទៃដីចូលមក ។

- អ្នកខ្លះ យកកូនចេកមកដាំត្រង់ខ្សែបន្ទាត់ព្រំ ។ ទំរើនេះក៏មានន័យដូចដើមឫស្សីដែរ ។

ពំនោលខាងលើនេះ ក៏មានន័យយោងទៅដល់ ខ្សែបន្ទាត់ព្រំសីមារដ្ឋរវាងរដ្ឋដែរ ៕

*ថ្ងៃទី ២៩-០៥-១០*

❁❁❁❁



# ៣៥០. វាយឆ្កែឱ្យមើលម្ចាស់

**និយមន័យ**

មុននឹងធ្វើទណ្ឌកម្មលើជនណាម្នាក់ ត្រូវគិតដល់អាណាព្យាបាល

## អត្ថាធិប្បាយ

### 🕮 អត្ថានុរូប

"**ឆ្កែ**" ជាសត្វតិរច្ឆាន ពុំមានចម្ងសញ្ញាចេះគិតពិចារណាខុសត្រូវអ្វីទេ ។ ប៉ុន្តែវាមានម្ចាស់ថែរក្សាវា ។ ដូច្នេះ បើកាលណាវាខាំ គេមិនត្រូវវាយវាភ្លាមតាមចិត្តខឹងនោះទេ គឺគេត្រូវគិតទៅដល់ម្ចាស់វាសិន ។ បើឆ្កែនោះជា ឆ្កែអនាថាគ្មានម្ចាស់ គេចង់វាយវា រឺធ្វើយ៉ាងណាក៏គ្មានបញ្ហាដែរ ។ ប៉ុន្តែបើឆ្កែនោះមានម្ចាស់ ជាអ្នកមានសម្បត្តិទ្រព្យ រឺអ្នកមានអំនាចវិញ ប្រាកដជាមានបញ្ហាហើយ ។

ដូច្នេះ គេត្រូវគិតគូទៅតាមផ្លូវច្បាប់វិញទើបត្រឹមត្រូវ ។

### 🕮 អត្ថប្បដិរូប

ប្រធានអង្គភាពម្នាក់ មានកំហឹងក្រេវក្រោធនឹងបុគ្គលិកក្រោមឱវាទម្នាក់ ដែលចេះតែប្រព្រឹត្តកំហុសឆ្គាំឆ្គងជាញយដង ទោះបីអប់រំយ៉ាងណាក៏មិនបានលទ្ធផលល្អសោះ ។ ប្រធានចង់ធ្វើទណ្ឌកម្ម រឺផ្លាស់ចេញ ។ ពេលនេះគាត់ត្រូវគិតទៅដល់អ្នក

អាណាព្យាបាលរបស់មនុស្សនេះសិនថាតើជាអ្នកមានបណ្ដាសក្ដិធំ រឺជាអ្នកមានទ្រព្យសម្បត្តិច្រើន រឺក៏អ្នកមានអំនាច ។ បើអ្នកអាណាព្យាបាលស្ថិតនៅក្នុងមនុស្សប្រភេទនេះ គេត្រូវស៊ូទ្រាំអត់ធ្មត់សិន ។ ព្រោះបើធ្វើតាមកំហឹងចិត្តអាចមានប្រតិកម្មមិនខាន ។ ប៉ុន្តែបើករណីធ្ងន់ធ្ងរ គេគួរដោះស្រាយជាមួយអ្នកអាណាព្យាបាល ទើបជាការគួរ ៕

*ថ្ងៃទី ១៥-០៣-០៧*



# ៣៤១. វត្តមួយសង្ក្រាជពីរ ទីមិនស្អាត

**និយមន័យ**

ការមើលបំនាំគ្នា

## អត្ថាធិប្បាយ

ធម្មតាវត្តអារាមនីមួយៗ តែងមានលោកគ្រូសង្ក្រាជ (ចៅអធិការ)ជាចៅអាវាសតែមួយអង្គទេ ។ ប៉ុន្តែនៅវត្តខ្លះដែលមានអធិករណ៍កើតឡើងដោយសារមហិច្ឆតាលោភលន់ដណ្តើមអំនាចគ្នាគ្រប់គ្រង ក៏នាំឱ្យវត្តនោះមានសង្ក្រាជពីរ ។

ដូច្នេះ វត្តដែលមានលោកគ្រូចៅអធិការពីរអង្គ វត្តនោះពុំសូវមានការលូតលាស់និងរីកចំរើនទេ ឯទីវត្តក៏គ្មានសណ្តាប់ធ្នាប់ និងស្អាតបាតដែរដោយសារតែការប្រចាំគ្នា. មើលបំនាំគ្នា ។

នៅក្នុងអង្គភាពមួយដែលមានសហប្រធានពីរនាក់ជាអ្នកគ្រប់គ្រង ។ គេតែងសង្កេតឃើញអង្គភាពនោះ ពុំសូវមានការជឿនលឿនទេ ។ ព្រោះទីណាក៏ដោយឱ្យតែមានអ្នកដឹកនាំពីរនាក់ មតិយោបល់ក៏មានពីរដែរ ។ ម្ល៉ោះហើយតែងតែប្រទាញប្រទង់គ្នាយកអាទិភាពតែរៀងៗខ្លួន ។

ម្យ៉ាងទៀត សូម្បីតែនៅក្នុងគ្រួសារប្តី-ប្រពន្ធដែលពីរនាក់នេះមានចិត្តមានះមិនព្រមរណបគ្នា ដណ្តើមអំនាចគ្នាគ្រប់គ្រងគ្រួសារតែរៀងៗខ្លួន ក៏ពុំមានសុវត្ថិភាពនិង រីកចំរុងចំរើនដែរ ៕

*ថ្ងៃទី ១៩-០៣-០៧*

# ៣៤២. វះពោះបង្ហាញក្អែក

## និយមន័យ

បើក-កកាយរឿងអាស្រូវភាសខ្លួនឯង រឺក្នុងគ្រួសារប្រាប់គេ

## អត្ថាធិប្បាយ

### 🕮 អត្ថានុរូប

បើគេវះពោះខ្លួនឯង គេនឹងឃើញពោះវៀនធ្លាយចេញមកក្រៅ ។ ពេលនោះសត្វក្អែកដែលជាសត្វចូលចិត្តស៊ីគ្រឿងក្នុង វានឹងមកប្រញាយនាំគ្នាចឹកស៊ីយ៉ាងខ្សៀវខ្សារ ។

### 🕮 អត្ថប្បដិរូប

អត្ថន័យខាងលើនេះ លោកពោលចំពោះមនុស្សដែលនិយាយស្តីអ្វីៗគ្មានគិតនាំឱ្យប៉ះពាល់ដល់កិត្តិយសខ្លួន រឺគ្រួសារខ្លួនឯង ។ គេជាមនុស្សមាត់អត់គំរបចូលចិត្តនិយាយចំនុចខ្សោយក្នុងគ្រួសារខ្លួន រឺក្នុងអង្គភាព ប្រាប់អ្នកក្រៅឱ្យគេដឹង ដែលជាហេតុនាំឱ្យគេមើលងាយ ជួនកាលអាចឈានទៅដល់ហេតុបច្ច័យដែលនាំឱ្យមានទោសទណ្ឌទៀតផង ។

ឧទាហរណ៍ :

- ប្រពន្ធម្នាក់និយាយពីការផិតក្បត់របស់ខ្លួនប្រាប់មិត្តភក្តិ ។

- ឪពុកម្នាក់ និយាយពីអត្តចរិតខិលខូចរបស់កូនប្រាប់គេ ។

- ម្តាយម្នាក់ និយាយពីកិរិយាមារយាទកូនស្រីដែលខុសគន្លងប្រពៃណីប្រាប់គេ។

- ប្រពន្ធម្នាក់ និយាយអំពីអំពើពុករលួយរបស់ប្តីអួតប្រាប់គេថា ប្តីខ្លួនចេះរកលុយគ្រាន់នឹងរស់ដែរ ។

ទំរើដែលបើក កកាយរឿងពីក្នុងគ្រួសារខ្លួនឯងប្រាប់អ្នកក្រៅឱ្យដឹងបែបនេះ លោកថា ដូចគេវះពោះខ្លួនឯង បង្ហាញឱ្យក្អែកឃើញ ៕

*ថ្ងៃទី ១៩-០៣-០៧*

✿✿✿✿



# ៣៤៣. វែងលែងដឹង ខ្លីក្រញឹងលីដឹងចូលព្រៃ

**និយមន័យ**

របស់ច្រើនប្រើសល់ គ្មានបញ្ហា របស់ខ្វះខាតនាំព្រួយរិះគិត

**អត្ថាធិប្បាយ**

📖 **អត្ថានុរូប**

" **ដឹង** " គឺជាឧបករណ៍សំរាប់ចាំងឈើពីធំមកតូច វាមានរាងតូចសំប៉ែតដូចពូថៅ តែផ្លែវានៅទទឹងដង ។

តាមអត្ថន័យខាងលើនេះ លោកចង់ពោលថា បើបានឈើវែងគ្រប់គ្រាន់ប្រើការ គេគ្មានកង្វល់អ្វីទេ គឺគេលែងនឹកនាដល់ "**ដឹង**" ហើយ គេលែង"ដឹង"ចោល ។ ប៉ុន្តែបើឈើខ្វះខាត គឺខ្លីកំបុតវិញ គេមិនអាចធ្វើអ្វីកើតឡើយ គេត្រូវតែលី**ដឹង** ចូលព្រៃ ដើម្បីកាប់, ចាំង, ឈើយកមកប្រើការទៀត ។

📖 **អត្ថប្បដិរូប**

មាសប្រាក់ ទ្រព្យធននានា ជាវត្ថុដែលជាទីប្រាថ្នារបស់ជនគ្រប់រូប ។ ដើម្បីនឹងបានរបស់អស់ទាំងនេះមក មនុស្សម្នាក់ៗ ខំប្រឹងស្វះស្វែងរកស៊ីគ្មានគិតពីក្តីលំបាកនឿយហត់អ្វីទេ ។ ព្រោះកាលណា បើគេមានប្រាក់ច្រើន ធនធានច្រើន គេពុំមានកង្វល់ចិត្តអ្វីឡើយ ។ ដូច្នេះ គឺគេលែងដឹងពី "***ក្តីក្រ***" ទៀតហើយ, ប្រៀបដូចជា

គេលែងឧបករណ៍ "***ដឹង***" ចោល ដោយសារគេបាន "***ឈើវែង***" ដូច្នេះឯង ។ ប៉ុន្តែ បើគេខ្វះខាតទ្រព្យធនធាន គឺដូចមានឈើ "***ខ្លីក្រញឹង***" នោះ គេត្រូវតែមូរជើងខោចូលព្រៃ មានន័យថា " ប្រយុទ្ធក្នុងការរកស៊ីអោយខ្លាំងក្លាតទៅទៀត " ៕

*ថ្ងៃទី ២១-០៣-០៧*

❀❀❀❀




# ព្រះវិហារ

# ៣៤៤. ទាស់ជំរៅទឹកសមុទ្របាន ទាស់ទឹកចិត្តមនុស្សមិនបាន

**និយមន័យ**

ចិត្តមនុស្សប្រែប្រួលឥតព្រំដែន

## អត្ថាធិប្បាយ

"**ទឹកសមុទ្ទ**" ទោះបីមានវិសាលភាពធំធេងយ៉ាងណាក៏ដោយ ក៏អ្នកប្រាជ្ញវិទ្យាសាស្ត្រអាចដឹងពីទំហំផ្ទៃក្រឡាបាន និងដឹងអំពីជំរៅទឹកតាមទីកន្លែងបានទៀតផង ។

ប៉ុន្តែ លោកថា បើគេចង់វាស់ស្ទាបអំពីជំរៅទឹកចិត្តមនុស្សវិញ គឺពិតជាមិនត្រូវទាល់តែសោះ។ ពីព្រោះ ចិត្តមនុស្សលោកពោរពេញទៅដោយតណ្ហា និងមហិច្ឆតាឥតព្រំដែន ។

ការលោភលន់, ការល្មោភចង់បាន, ការល្មោភអំនាចរបស់មនុស្សឥតមានសណ្ដាប់ធ្នាប់បែបនេះហើយ បានជាគេឃើញមនុស្សខ្លះដែលអ្នកផងកត់សំគាល់ថាជាមនុស្សល្អប្រសើរខ្ពង់ខ្ពស់គួរគោរព បែរជាហ៊ានប្រព្រឹត្តិអំពើពាលាថោកទាបដោយឥតអៀនខ្មាស ។ អ្នកខ្លះទៀត កាលណាមានគេមកសង្កត់ត្រង់ចំនុចខ្សោយក៏ស្រាប់តែប្ដូរចិត្តប្ដូរគំនិតប្រព្រឹត្តអំពើលាមកដោយឥតអៀនខ្មាសដែរ ។ ដូចជា :

- ឧកញ៉ាម្នាក់ប្រព្រឹត្តតែកុសលធម៌ ដើរចែកអំនោយ អ្នកផងស្រលាញ់គោរពគ្រប់គ្នា ស្រាប់តែមកកេងកីបប្រវ័ញ្ចយកដីប្រជារាស្ត្រទាំងមុខក្រាស់ងងើល ។

- នារីម្នាក់ដើររកស៊ីនៅមាត់សមុទ្ទ មានអត្តចរិតជាស្ត្រីមេផ្ទះគំរូ ។ ប៉ុន្តែមិនយូរប៉ុន្មាន ស្រីល្អនោះក៏រវេចបង្វេចរត់តាមប្រុសបាត់ទៅ ។

ហេតុនេះហើយបានជាលោកពោលថា គេអាចវាស់ជំរៅទឹកសមុទ្ទបាន ប៉ុន្តែគេមិនអាចវាស់ជំរៅទឹកចិត្តមនុស្សដែលនៅលើគោកបានឡើយ ៕

ផ្សារមាន់ *ថ្ងៃទី ២១-០៤-០៧*

| មោហ៍បាំង ជញ្ជាំងបិទ ក្ដិតបើក កក្រើកព្រះធរណី ។ |
|---|

❀❀❀❀



# ៣៤៥. វាយក្បាល បកចេកបញ្ចុក

**និយមន័យ**

សិល្បវិធី នៃចិត្តសាស្ត្រ

**អត្ថាធិប្បាយ**

ការស្ដីបន្ទោសទៅលើជនណាម្នាក់ ជាហេតុធ្វើឱ្យគេចុកចាប់ ។ ព្រោះធម្មតាអ្នករងទទួលនូវការស្ដីបន្ទោស រមែងមានអារម្មណ៍ពុះពោរខឹងតបវិញជាខ្លាំងដែរ ។ ព្រោះការស្ដីបន្ទោសនាំឱ្យខ្មាសគេផង, នាំឱ្យអាប់មុខមាត់ផង ។ ប៉ុន្តែ គេមិនហ៊ានតបវិញទេ ។ ព្រោះអ្នកដែលស្ដីបន្ទោសឱ្យនោះជាអ្នកមានឋានៈខ្ពស់ជាង ។ ដូចជា : ឪពុក,ម្ដាយ, គ្រូ, អាណាព្យាបាល និងជាមេកោយ ។ ប៉ុន្តែ ទោះបីជាមានឋានៈជាអ្វីក៏ដោយ ក៏គេនៅតែខឹងដដែល ទុកណាជាគេទទួលស្គាល់នូវកំហុសរបស់គេក៏ដោយ ។ បើការស្ដីបន្ទោសជាពាក្យធ្ងន់ៗ លោកថាឈើ ដូចគេវាយក្បាលអីចឹង ។

ប៉ុន្តែ អ្នកដែលស្ដីបន្ទោសគេខ្លះចេះប្រើវិធីចិត្តសាស្ត្រ ពេលដែលស្ដីបន្ទោសគេរួចហើយ គេហៅជននោះមកឱ្យលុយចាយ រឺឱ្យរបស់ស៊ីចុក រឺក៏ឱ្យរបស់អ្វីដែលល្មមពេញចិត្ត ។

សិល្បវិធី វាយប្រហារដោយពាក្យសម្ដីហើយ ហើយចេះប្រើចិត្តសាស្ត្រឱ្យគេត្រជាក់ចិត្តវិញបែបនេះ លោកហៅថា " **វាយក្បាល បកចេកបញ្ចុក** " ៕

*ថ្ងៃទី ២៣-០៣-០៧*

❀❀❀❀

# ៣៤៦. វរវីក ទទឹកស្ងួត

**និយមន័យ**

ភាពច្របូកច្របល់, ត្រលប់ធាតុ រលែងប្រាកដប្រជា

**អត្ថាធិប្បាយ**

" ***វរវីក រឺ វីកវរ*** " លោកសំដៅយកសភាពភ្ញាក់ផ្អើលជ្រួលជ្រើម, ជ្រួលច្របល់, កោលាហល, រញ៉ីករញ៉ុ ។

" **ទទឹកស្ងួត** " ក៏មានន័យប្រហាក់ប្រហែលគ្នា គឺម្ដងទទឹកម្ដងស្ងួត ។ ពេលណាទទឹក ក៏មិនល្អ ព្រោះពេលដែលគេមិនត្រូវឱ្យទទឹក ស្រាប់តែទទឹកអស់ ក៏ជាហេតុនាំឱ្យអន្តរាយហិនហោចអស់ដែរ ដូចជា ស្រូវអង្ករ កាលណាទទឹកហើយ គឺខូចការទាំងអស់ ។ ឯពាក្យថា **ស្ងួត** ក៏ដូចគ្នាដែរ គឺស្ងួតហួតហែងរាំងរីសដាំដំណាំអ្វីក៏មិនបានផលដែរ ។

ដូច្នេះ ពាក្យថា ***វរវីកទទឹកស្ងួត*** នេះ លោកសំដៅនៅពេលមានសប្បដិភ័យ គឺស្រុកមានសង្គ្រាម, ឬភ័យអាសន្នអន់ក្រដោយឧប្បត្តិហេតុអ្វីមួយ ។ ដូចជា :

- ស្រុកមានសង្គ្រាមរវាងជាតិ និងជាតិ, ប្រជារាស្ត្រធ្លាប់តែសុខសាន្ត បែរជារលែងសុខសាន្ត, ស្រុកធ្លាប់តែសំបូរសប្បាយ បែរជាទុរ្ភិក្ស ។
- ពេលមានរដ្ឋប្រហារបង្ហូរឈាមគ្នា ដើម្បីដណ្ដើមអំនាចគ្នាគ្រប់គ្រង ។

ពេលនេះទាំងមន្ត្រីរាជការ ទាំងអាណាប្រជានុរាស្ត្រ ជ្រួលច្របល់មិនដឹងជាបក្សខាងណាឈ្នះ ខាងណាចាញ់ បើបក្សខាងអញឈ្នះជាការប្រសើរ តែបើចាញ់វិញត្រូវស្លាប់ រឺរត់ចោលស្រុក ។

- ស្រុកមានបដិវត្តន៍ ដ៏ឆ្កួតលីលារបស់ពួកខ្មែរក្រហមក៏ធ្វើឱ្យស្ថានការណ៍ប្រែប្រួលពី ស ទៅ ខ្មៅ, ពីល្អ ទៅ អាក្រក់, ពីចំរើនទៅវិនាសអន្តរាយ ដូចជា អ្នកបញ្ញវន្តត្រូវសំលាប់ចោល, ពួកអវិជ្ជាចំកួតត្រូវឡើងធ្វើអ្នកដឹកនាំ ។

ស្ថានការណ៍ ក្រលាប់ចាក់ ច្របូកច្របល់បែបនេះហើយ គឺជាន័យរបស់ពាក្យ **វរវីក ទទឹកស្ងួត** ៕

*ថ្ងៃទី ២៤-០៣-០៧*

❀❀❀❀

| |
|---|
| **និព្វានំ បរមំ សុខំ** ៖ ព្រះនិព្វាន ជាឋានក្សេម<br>*ព្រះពុទ្ធ* |

# ៣៤៧. វិទ្យាសាស្ត្រ ដាវអាវុធមុខពីរ

**និយមន័យ**

ចំនេះដឹង និងបច្ចេកទេស អាចសំលាប់គេក៏បាន សំលាប់ខ្លួនឯងក៏បាន

**អត្ថាធិប្បាយ**

"**វិទ្យាសាស្ត្រ**" គឺជាគម្ពីរ រឺក្បួនច្បាប់ប្រាប់នូវចំនេះដឹងអ្វីមួយ. គឺអ្វីដែលគេអាចពន្យល់ប្រាប់ហេតុ ផល និងបច្ច័យអោយយល់បាន ។ល ។

ប៉ុន្តែពាក្យថា វិទ្យាសាស្ត្រនៅពេលនេះ លោកសំដៅយកបច្ចេកវិធី និងសិល្បវិធីកែច្នៃ ដែលអ្នកប្រាជ្ញយ៉ាងឆ្នើម១សម័យថ្មីបានស្រាវជ្រាវរាវរក និងពិសោធន៍យកមកប្រើប្រាស់ឱ្យទាន់តម្រូវការរបស់មនុស្សសម័យទំនើបដូចជា :

- សព្វាវុធ អាចសំលាប់គេក៏បាន អាចសំលាប់ខ្លួនឯងក៏បាន ។
- ថ្នាំពេទ្យ អាចលេប រឺចាក់ឱ្យជាសះស្បើយរោគក៏បាន អាចលេប រឺចាក់សំលាប់ក៏បាន ។
- គ្រឿងយន្ត អាចធ្វើឱ្យគ្រោះថ្នាក់ដល់ជីវិតគេក៏បានដល់ជីវិតម្ចាស់ខ្លួនឯងក៏បាន ។

ការលើកយកតួយ៉ាងមកបញ្ជាក់ប៉ុណ្ណេះ ក៏សមល្មមនឹងយល់ចូលចិត្តបានហើយ ៕

*ថ្ងៃទី ១១-០៩-០៧*

វិជ្ជាចោរលួចមិនបាន តែបើឱ្យបាន ។

**គេង វ៉ាន់សាក់**

# ៣៤៨. សាបមួយដៃ ប្រៃមួយចឹប

**និយមន័យ**

ពាក្យដោះសារឱ្យរួចផុតពីការស្តីបន្ទោស

## អត្ថាធិប្បាយ

### 🕮 អត្ថានុរូប

ពាក្យទំនឹមទំនៀមនេះ គ្រាន់តែជាពាក្យសំរាប់ដោះខ្លួនឱ្យរួចផុតពីការស្តីបន្ទោសប៉ុណ្ណោះ ។ ដូចជា :

ស្វាមីម្នាក់បន្ទោសប្រពន្ធថា ស្លអីក៏សាបម្ល៉េះ? អំបិលឡើងថ្លៃ រឺម៉ាក់វា ប្រពន្ធក៏ឆ្លើយថា មិនដឹងធ្វើ យ៉ាងម៉េចទៀតទេ ខ្ញុំបង់អំបិលមួយទូកដៃទៅហើយ នៅថាមិនប្រៃទៀត ។

ប៉ុន្តែ បើប្តីបន្ទោសថា សម្លអីក៏ប្រៃខ្លាំងម្ល៉េះ? ប្រពន្ធឆ្លើយថា ខ្ញុំបង់អំបិលតែមួយចឹបសោះ ចេះស្រែកថាប្រៃទៅកើត ដូចជាឆ្ងល់ដែរខ្ញុំ !

### 🕮 អត្ថប្បដិរូប

ពាក្យទំនឹមទំនៀមនេះ មានន័យថា ជាពាក្យសំរាប់ដោយសារយករួចខ្លួនមួយគ្រា-មួយគ្រា ភ្លាមៗ ដូចជា :

-ជាងកាត់ដេរម្នាក់ កាត់អាវរាងចង្អៀតបន្តិច ។ ម្ចាស់អាវមិនសូវពេញចិត្ត។ ជាងថា : ខ្ញុំក៏ដឹងដែរ ប៉ុន្តែរាងក្លួយឯងពាក់អាវរាងចង្អៀតបន្តិចបែបនេះ វាសមនឹងរាងក្លួយស្រីឯងណាស់ មើលទៅសិចស៊ីគួរអោយទាក់ទាញ ។

-ជាងកាត់ដេរម្នាក់ទៀត កាត់ខោរាងរលុងបន្តិច។ ម្ចាស់ខោមិនសូវពេញចិត្ត។ ជាងថា : ខ្ញុំក៏ដឹងដែរ ។ ប៉ុន្តែ បើខ្ញុំកាត់ឱ្យចង្អៀតបន្តិច ក្លួយឯងពិបាកអង្គុយ ព្រោះវាតឹងមុខ តឹងក្រោយ ។ម្យ៉ាងទៀត ក្រណាត់នេះ បោកទឹកម្តងទៅ វារួញបន្តិច ត្រូវនឹងក្លួយឯងចង់បានល្មម ៕

*ថ្ងៃទី ២៤-០៣-០៧*

❀❀❀❀

**គួរពិចារណា** ប្រើពាក្យខ្មែរវិញ

បាញ់ផៅ(យួន) នំចាក់អម្បែង(ខ្មែរ)

ដងកើ(យួន) ដងទង់ (ខ្មែរ)

# ៣៤៩. ស្លឱ្យសាប អង្គុយឱ្យទាប ប្រាជ្ញាឱ្យវៃ

**និយមន័យ**

ធ្វើអ្វីពីដំបូងឱ្យខ្សោយសិន សឹមខ្លាំងជាក្រោយ តែស្មារតីវាងវៃ

**អត្ថាធិប្បាយ**

**✳ស្លឱ្យសាប**

លោកប្រាប់ថា បើស្លសំលអ្វីក៏ដោយ ត្រូវស្លសាបជាមុនសិន បើមិនល្មមចិត្តសឹមថែមអំបិលជាក្រោយទៅតាមចំនង់ចំនូលចិត្ត ។ ព្រោះបើស្លប្រៃរួចទៅហើយ មិនងាយកែមកឱ្យសាប រឺឱ្យល្មមវិញបានស្រួលឡើយ បើបានក៏មិនសូវឆ្ងាញ់ដែរ ។

**✳អង្គុយឱ្យទាប ប្រាជ្ញាឱ្យវៃ**

ក្នុងន័យនេះ លោកចង់បញ្ជាក់ប្រាប់ថា ទោះទៅទីណាក៏ដោយក៏ត្រូវប្រុងប្រយ័ត្នក្នុងឥរិយាបថអង្គុយរបស់ខ្លួន ជាពិសេសក្នុងពិធីអ្វីមួយ ។ ដូចជានៅក្នុងអង្គសន្និបាត, អង្គប្រជុំនានា ។ល ។ គេមានរៀបកៅអីជា ច្រើនសំរាប់ទទួលភ្ញៀវ ។ លោកថាបើឃើញគេរៀបកៅអីដូច្នេះ ។ គេមិនគួរគប្បីចូលទៅអង្គុយកៅអីជួរមុខទេ ។ ព្រោះជួរនេះគេទុកសំរាប់ភ្ញៀវសំខាន់ដូចជា លោកអ្នកធំ, អ្នកមុខអ្នកការ រឺមន្ត្រីមានបណ្ដាសក្ដិធំជាងយើងជាដើម ។

ដូច្នេះ លោកប្រាប់ថា គេត្រូវទៅអង្គុយកៅអីថ្នាក់ទាប គឺជួរខាងក្រោយសិន ។

បើពេលនោះ អ្នករៀបចំកម្មវិធីស្គាល់, គេអញ្ជើញឱ្យទៅខាងមុខ ទើបសមរម្យនឹងទៅ ហើយពេញទៅដោយកិត្តិយសទៀតផង ។ បើពុំមានគេអញ្ជើញឱ្យទៅទេ គេសុខចិត្តអង្គុយកៅអីក្រោយចុះ ប៉ុន្តែត្រូវឱ្យមានប្រាជ្ញាវាងវៃ គឺកាលណាបើអង្គប្រជុំមានសំនួរចោទសួរ ។ គេត្រូវចេះឆ្លងឆ្លើយធ្វើឱ្យគេចាប់អារម្មណ៍ និងកោតក្រែងតាមក្រោយ ជាការប្រសើរណាស់ ។

ប្រសិនបើមិនធ្វើដូច្នេះទេ គឺភ្លែតភ្លាមរកកៅអីកិត្តិយសជួរមុខ ។ ស្រាប់តែពិធីករគេថា សូមទោស កៅអីនេះសំរាប់លោកឧកញ៉ាទេ សូមទៅខាងក្រោយ ។ ពេលនោះ តើគេត្រូវធ្វើមុខយ៉ាងម៉េចទេបានសម ព្រោះគេបាត់បង់កិត្តិយស, ទទួលមកវិញនូវកិត្តិយ៉ាប់ប៉ុណ្ណោះ ៕

*ថ្ងៃទី ២៥-០៣-០៧*

❀❀❀❀



# ៣៥០. សាច់មិនបានស៊ី យកឆ្អឹងព្យួរ.ក

**និយមន័យ**

គ្មានប្រយោជន៍ដល់ខ្លួនសោះ យកទុក្ខអំពល់មកដាក់ខ្លួន

**អត្ថាធិប្បាយ**

ពាក្យទំនឹមទំនៀម នេះលោកចង់និយាយពីមនុស្សខ្លះដែលនៅស្ងៀមៗស្រាប់តែមានព្រួយកង្វល់ដោយសារគេ ជួនកាលដឹងខ្លួន ជួនកាលទៀតមិនទាំងដឹងខ្លួនផង ។ ដូចជា:

- នៅស្ងៀមមិននៅ ដើរទៅមើលគេឈ្លោះគ្នា ។ គេចាប់ឱ្យធ្វើសាក្សីដឹងឮហើយក៏សុខចិត្តធ្វើសាក្សីឱ្យគេទៅ ។ បន្ទាប់មកឡើងចុះសាលាក្ដីជាញឹកញាប់ នាំព្រួយកង្វល់ឥតប្រយោជន៍ ។

- បុរសម្នាក់ ថ្ងៃមួយមានមិត្តភក្ត្រយកម៉ូតូមកផ្ញើ ។ ពេលគេចេញបាត់យូរពេកក៏អូសម៉ូតូនោះចូលក្រោមផ្ទះ ។ ស្រាប់តែពេលនោះដែរសមត្ថកិច្ចក៏មកចាប់ជាបន្ទាន់ភ្លាម ព្រោះម៉ូតូនោះចោរលួចយកមក ។

- ថ្ងៃមួយ បុរសម្នាក់បានឱ្យនារីដែលធ្លាប់ស្គាល់តាំងពីនៅរៀន ដោយសារម៉ូតូជាមួយ ។ លុះប្រពន្ធឃើញ ក៏ចោទផ្ដេសផ្ដាស បង្កើតជាបញ្ហាឡើង ៕

*ថ្ងៃទី ២៧-០៣-០៧*

❀❀❀❀

# ៣៥១. សុខចិត្តហូបស្មៀង គ្រាន់បើជាងយល់សប្តិហូបសាច់គោ

**និយមន័យ**

សូវយករបស់ជាក់ស្តែងតិចតួច ប្រសើរជាងយករបស់ស្រមើស្រមៃច្រើនឬធំ

**អត្ថាធិប្បាយ**

📖 **អត្ថានុរូប**

ការដែលគេរកម្ហូបឆ្ងាញ់មិនបានគេសុខចិត្តអត់ហូបសោះគឺជាការល្ងង់ខ្លៅ ។ ប៉ុន្តែបើគេមានស្មៀងហូបក៏គ្រាន់បើដែរ ។ ព្រោះស្មៀងដែលមានក្នុងកែវ គឺជាការណ៍មានពិតប្រាកដមែនគេអាចហូបបានទោះឆ្ងាញ់មិនឆ្ងាញ់ក៏ដោយ ។ ព្រោះយ៉ាងណាក៏វាគ្រាន់បើជាងការយល់សប្តិថាបានហូបសាច់គោទាំងគីឡូដែរ ។ ព្រោះសាច់គោក្នុងការយល់សប្តិគឺជាការកុហកមិនមានអ្វីពិតប្រាកដបន្តិចបន្តួចសោះឡើយ ។

📖 **អត្ថប្បដិរូប**

កិច្ចការដែលកំពុងធ្វើក្នុងដៃទោះបីតូចតាច រឺស្តួចស្តើងក៏ដោយ ក៏វាជាការណ៍ពិត ការប្រសើរជាងតំនែងនាយករដ្ឋមន្ត្រីដែលគ្រាន់តែជាការស្រមៃក្នុងការយល់សប្តិ។ តួយ៉ាងដូចជា ប្រាក់១រៀល ឬ១រយដែលមានក្នុងហោប៉ៅរបស់ខ្លួន វាប្រសើរជាងលុយរាប់លានក្នុងហោប៉ៅអ្នកដទៃ ។ ព្រោះលុយក្នុងហោប៉ៅខ្លួនៗអាច

ចាយវាយទៅតាមចិត្តចង់ ។ ឯលុយក្នុងហោប៉ៅគេគឺជាស្រមោល រឺជាការកុហក សំរាប់ខ្លួន ព្រោះខ្លួនមិនអាចយកចាយបានឡើយ ។

- កង់កញ្ចាស់ដែលមានក្នុងដៃប្រសើរជាងរថយន្តដ៏ទំនើបជារបស់គេ ។

- ឈើចាក់ធ្មេញមួយសរសៃប្រសើរជាងឈើហ៊ុបរាប់គីបជារបស់គេ ។

- ព្រានអណ្តាតប្រាក់ម្នាក់ប្រាប់ស្រីចើកថា បើនាងឯងសុខចិត្តលែងប្តីអោយដាច់ស្រេចរួចមកនៅជាមួយខ្ញុំៗនឹងទិញឡានទំនើបមួយគ្រឿងអោយ និងផ្ទះថ្មីមួយឈុតអោយ តើពេលនេះនាងសុខចិត្តរស់នៅក្នុងផ្ទះឈើ និង ជិះឡានកញ្ចាស់របស់ប្តីនាង?

- បេក្ខជនតំនាងរាស្ត្រម្នាក់ប្រាប់ឃោសនិកខ្លួនថា អ្នកឯងជួយឃោសនារកសំលេងឆ្នោតគាំទ្រយើងៗនឹងអោយម៉ូតូជិនំមួយគ្រឿងប្រើ រឺក៏ចាំយកអាថ្មីមួយគ្រឿងវិញនៅពេលយើងជាប់ឆ្នោត?

- ក្នុងន័យខាងលើនេះ លោកអោយនៅផ្ទះឈើ និងជិះឡានកញ្ចាស់ជាមួយប្តីចុះ ព្រោះជារបស់ជាក់ស្តែងមានរួចទៅហើយ ចាំទៅនៅជាមួយគេដឹងគេទិញអោយឬអត់ បើទៅនៅក្នុងកណ្តាប់ដៃគេទៅហើយ ។

ម៉្យាងទៀតលោកអោយយកម៉ូតូជិនំជិះទៅ ព្រោះមិនដឹងថាបេក្ខជននោះជាប់ឆ្នោតឬមិនជាប់ផង ៕

*ថ្ងៃទី ២៧-០៣-០៧*

# ៣៥២. ស៊ីព្រោះលោះកំលាំង

**និយមន័យ**

រស់ដោយសារគេដោយគ្មានមុខរបរ

## អត្ថាធិប្បាយ

ពាក្យទំនឹមទំនៀមនេះមានន័យថា ការរស់នៅដោយសារពឹងពាក់ស្នាក់អាស្រ័យនៅជាមួយគេដោយខ្លួនពុំមានសមត្ថភាពនឹងរកស៊ីចិញ្ចឹមជីវិតដោយខ្លួនឯងបាន ។ ព្រោះហេតុចាស់ជរាក៏មានអត់លទ្ធភាពនឹងប្រកបមុខរបរអ្វីមួយក៏មាន ។ ដូចជា :

- ឪពុកម្តាយ ជីដូនជីតា លោកចាស់ជរាទៅត្រូវបានកូនៗ ឬចៅៗជួយចិញ្ចឹមជួយទំនុកបំរុង ។
- យុវជនម្នាក់ នៅកំពុងសិក្សាបានមកស្នាក់អាស្រ័យនៅជាមួយឪពុកមា ។
- ក្មេងស្រីកំព្រាឪពុកម្តាយម្នាក់ ត្រូវម្តាយមីងយកមកចិញ្ចឹមគ្រាន់ជួយធ្វើការផ្ទះខ្លះៗ ។
- អ្នកខ្លះ ទៅជ្រកកោនក្នុងវត្ត ក្រោមការទំនុកបំរុងរបស់ព្រះសង្ឃ ។

អ្នកទាំងអស់ខាងលើនេះ សុទ្ធតែពពួកជន*ស៊ីព្រោះលោះកំលាំងដោយសារគេទាំងអស់* ៕

*ថ្ងៃទី ០៣-០៦-០៩*

# ៣៥៣. សង្សារបានខ្លួនមិនសូវអានិត សង្សារបានចិត្តអានិតហើយស្រលាញ់ផង

**និយមន័យ**

អ្វីដែលមិនទាន់ដឹង តែងចង់ដឹងជាងរបស់ដែលដឹងរួចហើយ

**អត្ថាធិប្បាយ**

ពាក្យទំនីមទំនៀមបុរាណមួយនេះ លោកពោលសំដៅចំពោះតែសេចក្ដីស្នេហារវាង ភេទមួយប៉ុណ្ណោះ ។ ក្នុងន័យនេះ លោកលើកយកតួអង្គពីរគូមកធ្វើបំរៀបធៀប គឺគូសង្សារភាគីមួយដែលតួអង្គស្រីបានប្រគល់ខ្លួនអោយតួអង្គប្រុស ។ មួយគូទៀតមិនទាន់ប្រគល់ខ្លួនអោយទេ ។ ប៉ុន្តែ គេចេះថ្នក់ថ្នមចិត្តគ្នាទៅវិញទៅមក គឺចេះស្រលាញ់គ្នាល្អូកល្អឺន មិនមានមោះមៃ រឺឃ្នើសចិត្ត ថ្នាំងថ្នាក់អ្វីសោះឡើយ ។

បើតាមន័យនេះ លោកពោលថា សង្សារដែលបានខ្លួនភាគីប្រុសកាត់បន្ថយសេចក្ដីស្រលាញ់ សេចក្ដីអានិតខ្លះហើយ ។ ព្រោះហេតុតែអ្វីៗដែលគេចង់ដឹង ចង់ស្គាល់រសជាតិ គឺគេបានដឹងបានស្គាល់រួចអស់ហើយ ។ នេះគឺជាបំនងធំរបស់បុរស ។ ឯសង្សារដែលបានចិត្ត រឺចិត្តបាន គឺចេះប្រណិប្រណាក់ ប្រចឹបប្រចុប កំប៉ិកកំប៉ុក ញិកញ៉ក់ ខ្ទិកខ្ទក់ គួរអោយខ្នាញ់ ។ ប៉ុន្តែនាងមិនបានបណ្ដោយខ្លួនទេ ។ ត្រង់នេះ ហើយ ដែលធ្វើអោយតួអង្គប្រុសរីងរឹតតែជ្រួលច្របល់ក្នុងកាមារម្មណ៍ ប្រកាច់ចាប់ មិនឈ្នះ ។ ដូច្នេះគេក៏មិនអាចបំភ្លេចបានភ្លាមៗឡើយ ។ ជាពិសេស តួអង្គប្រុស មិនទាន់បានស្គាល់រសជាតិ ៕

ថ្ងៃទី ២២-១០-០៩

# ៣៥៤. ស្នេហ៍មិនស្មើស្និទ្ធ

## និយមន័យ

មន្តអាគមសិល្បវិជ្ជាការ មិនមានប្រសិទ្ធិភាពជាងការជិតដិតស្និទ្ធស្នាល

## អត្ថាធិប្បាយ

" **ស្នេហ៍** " គឺជាមន្តអាគមអូមអាមដែលពីសម័យបុរាណកាល គេជឿថាជាមន្តអាគមសំរាប់ដាក់លើជនណាម្នាក់ធ្វើឱ្យគេទន់ចិត្តអានិតខ្លួន ។ ជាពិសេសគេដាក់លើនារីៗដើម្បីឱ្យគេអានិត និងស្រលាញ់ខ្លួន ។ គេជឿទៀតថា ទោះនាងនោះរឹងត្អឹងយ៉ាងណាក៏ដោយ កាលបើត្រូវស្នេហ៍គេហើយ នាងនោះនឹងអានិតស្រលាញ់គេភ្លាម ។

ប៉ុន្តែលុះដល់សម័យក្រោយៗតមក មានអ្នកក្លាហានខ្លះពោលថា ការដាក់ស្នេហ៍វាយូរណាស់ ។ ជួនកាលបើនាងនោះមានឋានៈខ្ពស់ រឺមានធនធានច្រើនជាងខ្លួនទៀតនោះដាក់មិនត្រូវឡើយ ។ ដូច្នេះ មានតែវិធីម៉្យាងទេ គឺចូលទៅជិតស្និទ្ធស្នាលនឹងនាងដោយល្បិចផ្សេងៗ ។ គេជឿប្រាកដថា ការស្និទ្ធស្នាលធ្វើឱ្យនាងទន់ចិត្តអានិតខ្លួនគេជាមិនខាន ។ ដូច្នេះ លទ្ធផលដែលត្រូវទទួលបាន គឺសមដូចបំនង ។

ការណ៍នេះហើយដែលធ្វើឱ្យគេហ៊ាន ពោលអួតអាងថា *ស្នេហ៍មិនស្មើស្និទ្ធទេ* ៕

*ថ្ងៃទី ២៨-០៣-០៧*

❀❀❀❀

# ៣៥៥. សន្សឹមកុំបំបោល ក្រែងពុំដល់ដូចប្រាថ្នា

**និយមន័យ**

ការងារធ្វើតាមសំរួល ទទួលលទ្ធផលល្អជាងតួងតាង

**អត្ថាធិប្បាយ**

## 🕮 អត្ថានុរូប

សាស្ត្រាច្បាប់កេរ្តិ៍កាលបានចែងក្នុងន័យខាងលើនេះ ដោយចង់បញ្ជាក់ថា បើគេធ្វើដំនើរតាមរទេះគោទៅតាមសំរួលគេនឹងទៅដល់ទីដៅដូចបំនង ។ ប៉ុន្តែបើគេបំបោលចង់ដល់ឆាប់ជួនក៏បានទៅដល់ទីដៅ ជួនកាលក៏ពុំបានទៅដល់គោលដៅឡើយ ។ ព្រោះអាចមានបញ្ហាតាមផ្លូវដូចជា គោខ្ទុកជើងទៅមុខពុំរួច ជួនរទេះត្រូវរង្គោះរង្គើ ខូចនេះខូចនោះនាំឱ្យស្ទុនដំនើរ ។ សមដូចពាក្យគេថា **តួងតាងដេកផ្លូវ** ។

## 🕮 អត្ថប្បដិរូប

កិច្ចការអ្វីក៏ដោយ គេត្រូវធ្វើសន្សឹមៗទៅតាមសំរួល កុំបង្ខំប្រូតកាត់ខ្លាំងពេក ។ ព្រោះទំរើដោយបង្ខំរមែង ពុំសូវបានសំរេចលទ្ធផលសមតាមបំនងឡើយ ។ ដូចជា :

- យុវសិស្សម្នាក់ ខំប្រឹងរៀនយ៉ាងខ្លាំង គេប្រូតកាត់ផ្លោះមួយឆ្នាំពីរថ្នាក់ ។ ព្រោះគេប្រញាប់ចាប់យកសញ្ញាប័ត្របណ្ឌិតច្បាប់ ។ ប៉ុន្តែ ដោយកាយសម្បទា គេផ្ទុកខ្លាំងពេក ធ្វើឱ្យគេបាក់កំលាំងរៀនទៅមុខទៀតលែងកើត ។

- ជាងតុ-ទូម្នាក់ ចង់ធ្វើទូមួយឱ្យហើយក្នុងរយៈកាលតែពីរថ្ងៃ។ គេខំប្រឹងអារកាត់ វាយដំប៉ូងប៉ុង។ ទូធ្វើជិតហើយទៅហើយ ស្រាប់តែត្រង់ត្រចៀកទ្វារ ត្រូវប្រេះ។ គេគាស់ឡើងធ្វើសារជាថ្មី ។ ម៉្លោះហើយត្រូវយឺតពេលជាងធ្វើតាមសំរួល ទៅទៀត ។ ទំរើសន្សឹមៗ និងតាមសំរួល គេគង់នឹងបានសំរេចផលសមតាមប្រាថ្នា៕

*ថ្ងៃទី ៣០-០៣-០៧*



# ៣៥៦. ស្រលាញ់កុំទៅញឹក រលឹកសឹមទៅម្ដង

**និយមន័យ**

អ្វីដែលឃើញដដែលៗនាំឱ្យធុញទ្រាន់ យូៗឃើញម្ដងនាំឱ្យចាប់អារម្មណ៍

**អត្ថាធិប្បាយ**

មិត្តភក្តិដែលស្រលាញ់គ្នាជិតដិតស្និទ្ធស្នាលយ៉ាងណាក៏ដោយ កាលបើទៅជួបគ្នាញឹកញាប់ពេកនឹងទៅជាធម្មតា ។ ជួនកាលនាំឱ្យគេធុញទ្រាន់មិនសូវចង់រវីរវល់ នឹងយកចិត្តទុកដាក់ជាហេតុនាំឱ្យអស់តំលៃ ។ ជាពិសេសគេមិនទាំងចង់និយាយរកទៀតផង។

ប៉ុន្តែ បើយូរៗទៅម្ដង គេទទួលស្វាគមន៍រាក់ទាក់ទាញកៅអីដាក់ឱ្យអង្គុយ និងរកអ្វីមកឱ្យទទួលទានទៀតផង ។ ជួនកាលគេឃាត់ឱ្យនៅអាស្រ័យបាយក៏មាន ។

- ការដែលទៅញឹកញាប់នេះ កុំថាឡើយត្រឹមមិត្តភក្តិសំលាញ់ សូម្បីតែបងប្អូន, គូសង្សារ រឺកូនឃ្មេិតក៏ដោយក៏គេជិនណាយនឹងធុញទ្រាន់ដែរ ព្រោះវាដដែលៗពេក ។

- ហេតុនេះហើយបានជាលោកប្រាប់ថា ទោះបីស្រលាញ់ បាត់មុខមិនបានក៏ដោយ គេមិនត្រូវទៅញឹកពេកទេ បើរលឹកខ្លាំងណាស់សឹមទៅម្ដងចុះ ៕

*ថ្ងៃទី ៣១-០៣-០៧*

# ៣៥៧. សំដីជាឯក លេខជាទោ

**និយមន័យ**

លំដាប់អត្ថសញ្ញាណជាតិសាសន៍និមួយៗ

## អត្ថាធិប្បាយ

✳"**សំដីជាឯក**"គ្រប់ជាតិសាសន៍និមួយៗ ទោះឯករាជ្យក្ដី មិនឯករាជ្យក្ដី ទោះមាន អរិយធម៌ ជឿនលឿនក្ដី អន់ថយក្ដី រមែងមានភាសានិយាយប្រចាំជាតិសាសន៍ ប្រចាំកុលសម្ព័ន្ធ របស់ខ្លួនជានិច្ច ។ ព្រោះថាមិនដែលមានជាតិសាសន៍ណាមួយដែលគ្មានភាសា និយាយគ្នានោះទេ សូម្បីតែសត្វតិរច្ឆានគ្រប់ប្រភេទ ក៏មានភាសាប្រចាំត្រកូល របស់វាដែរ ។ ទោះណាជាសត្វស្លាប រឺសត្វមានជើងប៉ុន្មានក៏ដោយ ។

ហេតុនេះហើយ បានជាលោកទុកភាសានិមួយៗជាអទិភាពមុនគេបង្អស់ គឺសំដីជាឯក។

✳"***លេខជាទោ***" ពាក្យថា "**លេខ**"មានន័យថា ការគូសវាស ស្នាមកំនត់ចំណាំ គ្រឿងសំគាល់អក្សរ សំបុត្រ...។

តាមន័យខាងលើនេះ ជាតិសាសន៍ណាក៏ដោយ ទោះបីមានវប្បធម៌ អរិយធម៌ ជឿនលឿនក្ដី មិនជឿនលឿនក្ដី សុទ្ធសឹងតែមាន "**លេខ**" ឬ អក្សរទាំងអស់គ្នា វៀរលែងតែសត្វតិរច្ឆានចេញ ។

ហេតុនេះហើយបានជាលោកចាត់ទុក "**លេខ**" ជាលំដាប់ថ្នាក់ទីពីរ គ្រាន់តែលោកញែក "**លេខ**"ជាពីរប្រភេទ គឺប្រភេទលេខ សំខ្យា និងលេខប្រភេទព្យញ្ជនៈ រឺ អក្សរ។

- ការណ៍ដែលលោករៀបលំដាប់សំដី រីភាសានិងលេខដូច្នេះ ព្រោះធម្មតាមនុស្សជួបប្រស្រ័យគ្នា, ទាក់ទងសន្ទនាគ្នាសុទ្ធតែយកភាសានិយាយចរចាគ្នា សុទ្ធតែយកភាសាជាត្រីមុខទាំងអស់ ទើបគេសរសេរជាលេខ ឬអក្សរទៅតាមក្រោយ ។ គ្រាន់តែ លេខ ឬអក្សរនោះមានលក្ខណៈសំគាល់និងកំនត់ចំនាំទៅតាមការសន្មត់របស់ជាតិសាសន៍ ឬកុលសម្ពន្ធនិមួយៗប៉ុណ្ណោះ ។ ដូចជា :

- ពួកកុលសម្ព័ន្ធ(ជនជាតិភាគតិច)ក៏មានអក្សរប្រចាំត្រកូលរបស់គេដែរ ។ ឧបមាថា: បើគេត្រូវទារអ្វីដែលម្នាក់ទៀតជំពាក់ ។ គេផ្ញើមែកឈើប៉ុនម្រាមដៃទៅ ។ បើមិនយកមកសង គេផ្ញើមែកឈើផ្សេងម្តងទៀត តែគេរោលភ្លើងបន្តិច ដើម្បីឱ្យដឹងថា គេខឹងតិចៗហើយ ។ បើមិនយកមកសងទៀត គេដុតមែកឈើនេះឱ្យឆេះខ្លាំងដើម្បីឱ្យដឹងថាគេខឹងខ្លាំងហើយ ។ល ។

- ជាតិសាសន៍ដែលមានវប្បធម៌ និងអរិយធម៌ជឿនលឿន គេយកស្នាមគំនូសគូសលើស្លឹកឈើ ឬស្បែកសត្វ ឬក៏លើក្រដាស ។

ហេតុនេះហើយ បានជាលោកទុក*លេខ រី អក្សរ ជាលំដាប់ទីពីរ (លេខជាទោ)* ៕

---

❧ *សំគាល់* ***ត្រីមុខ*** *ត្រីជាប្រធានជាអ្នកនាំមុខក្នុងល្បែងអុក មិនបាច់ថែមអក្សរជាត្រីទៀតទេ ។*

*ថ្ងៃទី ៣១-០៣-០៧*

# ៣៥៨. សំនាបយោងដី ស្រីយោងប្រុស

**និយមន័យ**

គំហើញនូវរូបភាពមួយ រួចយោងទៅដល់រូបភាពមួយទៀត

**អត្ថាធិប្បាយ**

* **សំនាបយោងដី** ផ្ទៃដីដែលពុំទាន់មានសំនាប រឺស្មៅដុះ គេមិនអាចដឹងថា ដីត្រង់នោះមានជីជាតិ ឬអត់ទេ ។ គឺទាល់តែគេបានឃើញសំនាប ឬស្មៅត្រង់កន្លែងនោះល្អ ឬមិនល្អទើបគេដឹងថា ដីត្រង់កន្លែងនោះមានជីជាតិ ឬក៏ខ្សោះ។ តួយ៉ាងដូចជា: គេសាបសំនាបក្នុងថ្នាលមួយ មានកន្លែងខ្លះសំនាបដុះលូតលាស់ល្អ ធ្វើឱ្យគេដឹងថា ដីត្រង់នោះមានជីរជាតិល្អ ។ បើសំនាបដុះរេញៗ គេដឹងថាដីត្រង់នោះខ្សោះ ។

* **ស្រីយោងប្រុស** ក្នុងន័យនេះលោកសំដៅយកប្ដី-ប្រពន្ធក្នុងគ្រួសារមួយដែលមានប្រពន្ធចេះយោងមុខមាត់ប្ដី ។ ដូចជា :

- ប្រពន្ធម្នាក់មានប្ដីជាចៅកែសិប្បកម្មផ្ទាំងដែលមិនចេះអក្សរសោះ ។ ថ្ងៃមួយមានភ្ញៀវកាន់លិខិតបញ្ជាទិញផ្ទាំងមួយចំនួនមកហុចឱ្យប្ដីហើយពោលថា សុំចៅ-កែមើលហើយឆ្លើយតបទៅចៅកែខ្ញុំវិញផង ។ ពេលនោះ ប្រពន្ធស្ទុះមកយកលិខិតពីដៃប្ដីរួចនិយាយថាបងឯងនៅប្រស្រ័យលេងជាមួយភ្ញៀវចុះ ចាំខ្ញុំយកលិខិតនេះទៅមើលជំនួស ។ រួចហើយប្រពន្ធយកលិខិតឆ្លើយតបមកហុចឱ្យភ្ញៀវ ព្រមទាំងនិយាយប្រាប់

ប្តីពីន័យលិខិតផ្ញើមក និងផ្ញើតបទៅវិញ ។ ភ្ញៀវត្រលប់ទៅវិញដោយ ឥតដឹងថាប្តីអត់ចេះអក្សរ១តួសោះ ។ ម៉្យាងទៀត ពេលមានភ្ញៀវឡើងផ្ទះ ប្រពន្ធស៊ុះស្មារមកអញ្ជើញភ្ញៀវព្រមទាំងលើកកៅអីអោយភ្ញៀវអង្គុយនិងចាក់ទឹកតែជូនភ្ញៀវពិសារ ។

ពេលភ្ញៀវត្រលប់ទៅវិញនាងជូនភ្ញៀវដល់មាត់ទ្វាររបង ។

ហ្នឹងហើយដែលលោកថាស្រីឃោងប្រុស ៕

*ថ្ងៃទី ០១-០៤-០៧, ថ្ងៃបោះឆ្នោតរើស ឃុំ-សង្កាត់*

❀❀❀❀



# ៣៥៩. សត្វបរោក្ខា ទុំមែកពោធិ ស៊ីផ្លែជ្រៃ

## និយមន័យ

ជនដែលរមិលគុណអ្នកដែលជួយខ្លួន

### 🕮 អត្ថានុរូប

✳ **សត្វបរោក្ខា :** ពពួកសត្វរាត្រីចរ, សន្តានសត្វជ្រឹង ។ វាមានជើងសំរាប់ថ្ពក់ និងមានស្លាបស្តើង ។

✳ **ទុំមែកពោធិ :** ការណ៍ពិត ជើងវាទុំមិនបានទេ គឺគ្រាន់តែសំរាប់ថ្ពក់ប៉ុណ្ណោះ ។ វាចូលចិត្តមករកចំនីលើដើមពោធិ ។ ព្រោះ បើពោធិមានផ្លែ វាស៊ីផ្លែពោធិ ។ បើពោធិមានជ្រៃព័ទ្ធព័ន្ធ ហើយមានផ្លែទៀត វាស៊ីផ្លែជ្រៃ ។

### 🕮 អត្ថប្បដិរូប

"**ស៊ី**" នៅពេលនេះ សំគាល់ន័យថា : ស្ម័គ្រស្មាគម, នៃបនិត្យ ស្និទ្ធមេត្រី ។

អត្ថរសក្នុងន័យខាងលើនេះ លោកចង់ពោលសំដៅទៅជនគ្មេរគុណដែលមាននិស្ស័យបំភ្លេចនូវឧបការគុណរបស់អ្នកដែលធ្លាប់ជួយទំនុកបំរុងខ្លួន ឱ្យបានសុខស្រួលនោះ រួចបែរជាទៅបំរើផលប្រយោជន៍ឱ្យអ្នកផ្សេងដទៃទេទៅវិញ ។ ដូចជា :

-យុវជនម្នាក់ ស្នាក់អាស្រ័យជាមួយឳពុកមា ។ ឳពុកមា ខំជួយផ្គត់ផ្គង់ឱ្យរៀនសូត្រ ។ លុះបាន ការងារធ្វើ ជននេះបែរជាទៅជួយរកផលប្រយោជន៍ឱ្យអ្នក ផ្សេងទៅវិញ ។

-យុវជនម្នាក់ទៀត បានមកជ្រកកោនក្នុងវត្តព្រះពុទ្ធសាសនា គេស៊ីព្រោះលោះកំលាំងនឹងព្រះសង្ឃ ដើម្បីរៀនសូត្រ ។ ប៉ុន្តែជននេះ បែរជាលបទៅបំរើផលប្រយោជន៍ឱ្យពាហិរសាសនាទៅវិញ ។

ដូច្នេះ មនុស្ស "ក្បាលចេញ កន្ទុយចូល រឺ មនុស្សក្បាលពីរ" ដូច្នេះលោកហៅថា : "*សត្វបរោក្ខា*" ទាំងអស់ ៕

ថ្ងៃបោះឆ្នោត-ឃុំ-សង្កាត់ *០១-០៤-០៧*

❀❀❀❀



# ៣៦០. ស្ងួចអោយសាច់ កុំបង្ហាញព្រៃ

**និយមន័យ**

សុខចិត្តអោយសាច់ស៊ី កុំប្រាប់កន្លែងរក

**អត្ថាធិប្បាយ**

ខ្លឹមសារក្នុងន័យខាងលើនេះ លោកប្រាប់ថា បើអ្នកទៅប្រមាញ់ រឺទៅនេសាទបានសាច់យួរមកហើយមានគេសួររកកន្លែងប្រមាញ់ លោកហាមមិនឱ្យប្រាប់ទីកន្លែងគេទេ ។ ដ្បិតអីអ្នកដែលសួររកប្រភពប្រមាញ់ សុទ្ធតែចង់ទៅរកផងដែរ ។ ដូច្នេះគេត្រូវតែលាក់ទីកន្លែងរកស៊ីដោយសុខចិត្តចំនាយសាច់ដែលរកបានមកឱ្យជាទានដល់គេខ្លះចុះទោះបីខាតផលខ្លះក៏ដោយ ។

ព្រោះបើប្រាប់គេទៅនឹងនាំឱ្យខូចលាភ គឺត្រូវបាត់បង់ផលប្រយោជន៍ច្រើន ។ ម៉្យាងទៀតការរកស៊ី គេមិនត្រូវចិត្តល្អពេកទេ និងមិនត្រូវគិតពីសីលធម៌ខ្លាំងពេកដែរ ។ សមដូចច្បាប់កេរ្តិ៍កាលពោលថា **ផ្លូវវៀចកុំបោះបង់ ផ្លូវណាត្រង់កុំដើរហោង** ៕

*ថ្ងៃទី ០១-០៤-០៧,* ផ្ទះបាះឆ្នោត -ឃុំ-សង្កាត់

❁❁❁❁

# ៣៦១. ស្រីខ្មៅដូចក្អិតអម្បែង ចេះតុបចេះតែងប្ដីលែងមិនរួច

**និយមន័យ**

ការពោលអួតសរសើរពីគុណសម្បត្តិស្រីសំបុរខ្មៅ

**អត្ថាធិប្បាយ**

ពាក្យទំនឹមទំនៀមនេះ លោកពោលត្រង់ៗមិនពិបាកយល់ទេ ។

" **ក្អិតអម្បែង**" តែងពោលដោយផ្សែងភ្លើងជាខ្លាំង ។ ក្នុងន័យនេះបញ្ជាក់ឱ្យឃើញថានារីដែលមានសំបុរកាយខ្មៅមិនសូវបានជាទីនិយមប៉ុន្មានទេ ។ ប៉ុន្តែបើនារីនោះមានចរិយាសម្បត្តិល្អប្រសើរ ជាពិសេសចេះតុបតែងសំអាងរាងកាយ ឱ្យស្អាតបាតទៅតាមទំនង គឺចេះជ្រើសយកគ្រឿងសំអាងឱ្យស៊ីនឹងសំបុរខ្លួនវិញនោះ ។ បុរសទាំងឡាយប្រាកដជាពិតពិលរមិលមើលមិនដាក់ភ្នែក និងមានចំនាប់អារម្មណ៍យ៉ាងខ្លាំងជាមិនខាន ។ ជាពិសេសអ្នកជាប្ដីតែម្ដងគឺគេមិនអាចបោះបង់នាងចោលបានងាយៗឡើយ សមដូចពាក្យចំអែចំអន់គេពោលថា" *ខ្មៅមានជាតិ រីខ្មៅតែរូបតែម្ហូបឆ្ងាញ់*" ។ ម្ហូប សំដៅយក កិរិយាមារយាទល្អ ម្យ៉ាងទៀត ន័យតុបតែងនេះ ក៏យោងទៅដល់ការចេះតុបតែងរៀបចំទុកដាក់ទ្រព្យសម្បត្តិ ដែលប្ដីរកបានមកផងដែរ ៕

*ថ្ងៃទី ០១-០៤-០៧*, ថ្ងៃបោះឆ្នោតរើស-ឃុំ-សង្កាត់

# ៣៦២. សូវយកស្រីខូចធ្វើប្រពន្ធ កុំយកប្រពន្ធធ្វើស្រីខូច

**និយមន័យ**

យករបស់ខូចកែច្នៃអោយល្អបាន ប្រសើរជាងយករបស់ល្អទៅធ្វើឱ្យខូច

**អត្ថាធិប្បាយ**

" **ស្រីខូច** " នៅពលនេះលោកសំដៅយកស្រីដែលបាត់បង់កិត្តិយស, បាត់បង់ប្រពៃណី និងទំនៀមទំលាប់ដ៏ល្អរបស់ជាតិ គឺស្ត្រីនគរសោភិនី ។ ស្ត្រីប្រភេទនេះតែងទទួលការរើសអើងពីសហគមន៍ជាតិ ។

ប៉ុន្តែក្នុងន័យខាងលើនេះ លោកចង់និយាយថា បើគេយកប្រពន្ធស្ត្រីប្រភេទនេះក្រោយពីបានអប់រំឱ្យលះបង់និងកែប្រែនូវអត្តចរិតថោកទាបជាទីស្អប់ខ្ពើមរបស់សង្គមជាតិបាននោះ វាជាការប្រសើរជាងយកប្រពន្ធដែលសង្គមជាតិទទួលស្គាល់ថា ជានារីល្អប្រសើរទៅធ្វើជាស្រីខូច ដើម្បីរកកំរៃចិញ្ចឹមជីវិតនោះ គឺជាការថោកទាបបំផុត ។

ហេតុនេះហើយបានជាលោកប្រាប់ថា សុខចិត្តយកអ្វីដែលអស់តំលៃមកច្នៃឱ្យមានតំលៃវាប្រសើរជាងយករបស់ដែលមានតំលៃរួចហើយ ទៅធ្វើឱ្យខូចតំលៃវិញនោះ ៕

*ថ្ងៃទី ០៨-០៤-០៧*

# ៣៦៣. សម្បត្តិកំចាត់ព្រួយ មានគេជួយមិនបាច់ហៅរក

## និយមន័យ

មានធនធានច្រើន មនុស្សផងស្គាល់គោរពស្រលាញ់

## អត្ថាធិប្បាយ

បុរាណសុភាសិត បានកម្រិតតម្លៃលើទ្រព្យសម្បត្តិថាជារបស់ឧដុង្គឧត្តមវិសេសវិសាលអស្ចារ្យខ្លាំងក្រៃ ។ ដោយលោកយល់ថា បើគេមានទ្រព្យសម្បត្តិស្ដុកស្ដម្ភ គេពុំមានព្រួយកង្វល់អំពីអ្វីទាំងអស់ ។ បើគេមានទុក្ខព្រួយពីរឿងអ្វីមួយក៏គេពុំមានកង្វល់អ្វីដែរ ។ ព្រោះគេមានសំអាងលើទ្រព្យសម្បត្តិថា អាចជួយគេឱ្យចាកផុតទុក្ខព្រួយកង្វល់គ្រប់បែបយ៉ាងទាំងអស់ ។

ម្យ៉ាងទៀតបើគេជាអ្នកមានស្ដុកស្ដម្ភដូច្នេះ រមែងមានមនុស្សគោរពស្រលាញ់ចេញចូលមិនពិបាកហៅរកឡើយ ។ បើគេចង់បើកសិប្បកម្ម រឺប្រកបមុខរបរអ្វីមួយគេគ្មានព្រួយកង្វល់អ្វីទេ ។

បើគេមានរឿងទោសទណ្ឌប្រការណាមួយ គេជឿថាទ្រព្យសម្បត្តិប្រាក់កាសអាចជួយសង្គ្រោះគេឱ្យផុតទុក្ខទោស ទុក្ខព្រួយកង្វល់គ្រប់បែបយ៉ាង ។

បើមានរវល់ធ្វើពិធីអ្វីមួយ តែងមានមនុស្សចូលមកជួយធ្វើសស្រាក់សស្រាំដោយមិនពិបាកហៅរកផង ។

ហ្នឹងហើយ សម្បត្តិអាចកំចាត់ទុក្ខព្រួយកង្វល់បានទាំងអស់ ៕

*ថ្ងៃទី ២៤-០៦-០៩*

# ៣៦៤. សម្បត្តិច្រើន ចំរើនបុណ្យ, ប្រពន្ធល្អសម្បូរមិត្រ

**និយមន័យ**

ឥទ្ធិពលទ្រព្យសម្បត្តិ និង ប្រពន្ធកបកល្យាណី

**អត្ថាធិប្បាយ**

ប្រពន្ធល្អនៅពេលនេះសំដៅយកស្ត្រីដែលមានគុណសម្ប័ទខ្ពស់, មានសីលធមិខ្ពស់, មានចរិយាសម្ប័ទខ្ពស់ ។ល ។ ស្ត្រីប្រភេទនេះប្រព្រឹត្តតែអំពើជាកុសលដែលលោកហៅថា " **កល្យាណភរិយា** " ។

សុភាសិតនេះមិនមែនជាបុរាណសុភាសិតទេ គឺជានវសុភាសិត (សុភាសិតថ្មី) ដែលគេទើបតែនឹងបង្កើតឡើងនៅក្នុងសម័យសំភារៈនិយម គឺប្រហែលឆ្នាំ ១៩៥៣ នេះឯង ។

ព្រោះគេយល់ថា កាលណាមានសម្បត្តិប្រាក់កាសច្រើននឹងកើនបុណ្យសក្តិមួយកម្រិតទៀត ដោយគេយកសម្បត្តិ ឬប្រាក់ធ្វើជាស្ពានចម្លងឱ្យគេមានតួនាទី, មានឋានៈបាន ។

រីឯប្រពន្ធល្អ បរិបូរណ៍មិត្រ គឺជាប្រពៃណីរបស់ខ្មែរទៅហើយ ។ ព្រោះបើមានឧត្តមភរិយាចេះគួរសមរាក់ទាក់នឹងញាតិព្រៀងលាន ។ គេរមែងមានអ្នកផងស្រលាញ់រាប់អានជាច្រើន រាប់តាំងពីក្មេងៗរហូតដល់ចាស់ព្រឹទ្ធាចារ្យ ៕

*ថ្ងៃទី ២៤-០៦-០៩*

# ៣៦៥. ស្អាតតែរូប តែម្ហូបមិនឆ្ងាញ់

**និយមន័យ**

រូបសម្ប័ទស្រស់ប្រិមប្រិយ តែគុណសម្ប័ទគ្មាន

**អត្ថាធិប្បាយ**

ពាក្យពំនោលនេះ លោកពោលចំពោះតែស្ត្រីភេទទេ ។ គឺជាពាក្យពោលចំអកឱ្យស្ត្រីដែលមានរូបស្អាតស្រស់តាំងពីដំនើរ រាងរៅសមសួនគួរឱ្យពិសម័យ ។ តែកិរិយាមារយាទគ្មានសមរម្យខ្លួនជាស្រី និងគ្មានចរិយាសម្ប័ទ ដូចជា :

- ស្ត្រីខ្លះ កើតក្នុងត្រកូលអភិជន តែមិនមានចំនេះដឹងអ្វីក្នុងខ្លួនទេ គឺមិនបានសិក្សាវិជ្ជាផ្លូវលោកផ្លូវធម៌ ជាពិសេស គេគ្មានវិជ្ជាជីវៈដូចជា ការត្បាញ រវៃ ឬបច្ចេកវិទ្យាអ្វីមួយឡើយ ។

- ស្ត្រីខ្លះ មួយថ្ងៃៗគិតតែពីតុបតែងខ្លួន, ស្លៀកពាក់គ្រប់ម៉ូដគ្រប់ម៉ាក, លាបលន, លាបឡេតីយ៉ាងរលោង តែគ្មានចិត្តគំនិតចង់ចេះចង់ដឹងពីវិជ្ជាមេផ្ទះ គ្មានសីលធម៌ គ្មានគុណសម្ប័ទឡើយ ។ល ។

- ស្ត្រីខ្លះ មានរូបសម្ប័ទស្រស់ត្រកាលពីធម្មជាតិ តែមារយាទមិនថ្លៃថ្នូរ គឺមិនលុះដោយដំបូន្មានឪពុកម្តាយ និងចាស់ទុំឡើយ ។ គេចូលចិត្តសេពគប់នឹងពួកប្រុសពាល និងប្រព្រឹត្តអនាចារមានសេពគ្រឿងញៀនជាដើម ៕

*ថ្ងៃទី ២៤-០៤-០៧*

# ៣៦៦. ស៊ូស្លាប់ក្នុងកិត្តិយស កុំឱ្យដុះពោះក្នុងការបំផ្លាញជាតិ

**និយមន័យ**

សុខចិត្តធ្វើអ្នកក្រស្អាតស្អំ មិនធ្វើអ្នកមានពុករលួយ

**អត្ថាធិប្បាយ**

ឧត្តមគតិ របស់មនុស្សម្នាក់ៗ រមែងមានគំនិតផ្សេងៗគ្នា ។ អ្នកខ្លះយល់ថា សុខចិត្តក្រីក្ររស់នៅតាមសម្មាជីវោ គឺមិនហ៊ានប្រព្រឹត្តនូវអ្វីដែលនាំឱ្យបាត់បង់ កេរ្តិ៍ឈ្មោះ, បាត់បង់សេចក្តីថ្លៃថ្នូរ, បាត់បង់កិត្តិយស ។ល ។ បើទុកណាជាគេ ធ្លាក់ក្នុងក្តីទីទ័លក្រ លំបាកលំបិន ខ្វះមុខខ្វះក្រោយយ៉ាងណាក៏ដោយចុះ ឱ្យតែមាន ឈ្មោះថាជាអ្នកស្នេហាជាតិមាតុភូមិ ។

ប៉ុន្តែ នៅមានជនមួយពួកទៀតតែងពោលថា ទ្បេងមិនឈ្នះទ័ល ។ តែកាលណាទីទ័លក្រហើយ សុខចិត្តធ្មេចភ្នែកបូម ឬពុករលួយមួយគ្រាសិនចុះ ចាំរាងចូរធារបន្តិចសឹមធ្វើជាអ្នកស្អាតស្អំម្តង ។ ប៉ុន្តែ តណ្ហាមនុស្សធ្វើម្តេចនឹងស្កប់ស្កល់ទៅបាន ។ លុះប្រព្រឹត្តអំពើពុករលួយយូរៗទៅក៏ក្លាយទៅជាទម្លាប់ និងជារឿងធម្មតា ។ ព្រោះប្រព្រឹត្តដូច្នេះបែបរាងស្រួលខ្លួនគ្រាន់បើដែរ ។ ទីបំផុតគេមានលុយទិញឋានន្តរសក្តិ ទីឧកញ៉ា មានឈ្មោះថា អ្នកស្នេហាជាតិដូចគ្នា ។

ដូច្នេះ គេក៏ប្រព្រឹត្តអំពើពុករលួយទាល់តែដុះពោះ ចង់អ្នកណាជេរម្រ៉ាយថា អាបំផ្លាញជាតិយ៉ាងណាក៏ដោយចុះ ស្រេចតែអញមិនខ្ចីលឺ ៕

*ថ្ងៃទី ១០-០៤-០៧*

# ៣៦៧. ស្រុកសង្គ្រាមត្រូវការអ្នកក្លាហាន ស្រុកសាន្តត្រាណត្រូវការអ្នកចេះដឹង

## និយមន័យ

តំរូវការគុណសម្បទមនុស្សតាមកាលៈទេសៈ

### អត្ថាធិប្បាយ

**✳ ស្រុកសង្គ្រាមត្រូវការអ្នកក្លាហាន**

នៅពេលស្រុកមានចំបាំងរាំងជលរវាងភាគីពីរ ។ ដូច្នេះ ភាគីខាងណាក៏ត្រូវការកម្លាំងទ័ពដូចគ្នា ដើម្បីធ្វើការវាយប្រយុទ្ធដណ្តើមអំនាចគ្នា ។ អ្នកដឹកនាំភាគីម្ខាង១សុទ្ធតែខំប្រឹងអំពាវនាវរកអ្នកក្លាហានដើម្បីធ្វើពលសេនាយោធា ។ ដូច្នេះនៅពេលអាសន្នវរវឹកទទឹកស្ងួតបែបនេះ គេឥតគិតអ្វីក្រៅពីសេចក្តីក្លាហានទេ ។ គឺគេមមាញឹកក្នុងការប្រមូលយកអ្នកក្លាហានជាងអ្នកមានចំនេះ ។ ព្រោះស្រុកមានវិប្បរិតមិនទាន់មានសន្តិភាពរៀបរយបែបនេះ យកអ្នកមានចំនេះមកធ្វើការនៅកន្លែងឯណាបាន ។

**✳ ស្រុកសាន្តត្រាណត្រូវការអ្នកចេះដឹង**

កាលណាស្រុកមានសន្តិភាពរៀបរយល្អហើយ អ្នកដឹកនាំតែងប្រមូលយកអ្នកដែលមានចំនេះដឹង ដើម្បីធ្វើការតាមផ្នែកតាមស្ថាប័នតាមមុខជំនាញ តាមមុខក្រសួងនានា ។ ព្រោះការងារក្នុងការិយាល័យ តែងទាមទារអ្នកមានសមត្ថភាព មាន

ចំនេះដឹង ទើបធ្វើការកើត ។

ដូច្នេះ គេត្រូវការអ្នកមានចំនេះដឹងតាំងពីថ្នាក់ទាបរហូតដល់ថ្នាក់ខ្ពស់ មានពួកបញ្ញវន្តដូចជា វិស្វករ បណ្ឌិត ស្ថាបត្យករជាដើម ៕

*ថ្ងៃទី ១១-០៤-០៧*



# ៣៦៨. ស្រីៗបង្វិលចង្ក្រានមិនជុំ

**និយមន័យ**

ទំរើងដែលៗ ហាក់ដូចមិនចប់ ឬមិនជុំ

**អត្ថាធិប្បាយ**

ពាក្យទំនឹមទំនៀមនេះ ក្លាយទៅជាពាក្យស្លោកប្រចាំសម័យកាលទៅហើយ ។ ព្រោះកាលពីសម័យដើមកូនស្រី សឹងតែទាំងអស់ចាស់ទុំម៉ែឪមិនឱ្យទៅរៀនអក្សរទេ ដោយគាត់ខ្លាចចេះសរសេរសំបុត្រផ្ញើទៅសង្សារ ។

ម្យ៉ាងទៀត ការរៀនអក្សរនៅសម័យកាលនោះ សាលាតាំងនៅតែក្នុងវត្ត រឺរៀនតាមកុដិព្រះសង្ឃ ហើយដែលមានព្រះសង្ឃជាអ្នកបង្រៀនទៀតផង ។

ម្លោះហើយ កូនស្រីមិនហ៊ានទៅរៀនទេ ។ ដូច្នេះ នាងត្រូវតែធ្វើការនៅផ្ទះ ដូចជា រៀបចំទុកដាក់ផ្ទះសម្បែង និងរៀនត្បាញ រវៃ ត្បាញសំពត់ ហូល ក្រមា កន្ទេល ។ ជាពិសេសរៀនដណ្តាំស្ល គឺធ្វើខ្លួនឱ្យទៅជាមេផ្ទះដ៏ល្អប្រចាំគ្រួសារ បន្តគ្នាតាំងពីជីដូនរហូតដល់ចៅ ។

ហេតុការណ៍នេះហើយ ដែលនាំឱ្យលោក លើកជាពាក្យទំនឹមទំនៀមថា *កូនស្រីបង្វិល ចង្ក្រានមិនជុំទេ* ។

ប៉ុន្តែកាលសម័យឥលូវនេះ ប្រទេសជាតិកាន់តែរីវឌ្ឍន៍ រីកចម្រើនឡើង កូនស្រីក្តី កូនប្រុសក្តីមានកាតព្វកិច្ចត្រូវចូលរៀនសូត្រដូចៗគ្នា ៕

*ថ្ងៃទី ១៣-០៤-០៧*

# ៣៦៩. ស្លូតស្លាប់ ទៀចទេរមានភព្វអាយុយឺនយូរ

**និយមន័យ**

ស្លូតហួសគ្មានបានការ ចេះល្បិចកិច្ចកលខ្លះរស់បានយូរ

**អត្ថាធិប្បាយ**

" **ស្លូតស្លាប់** " លោកសំដៅយកមនុស្សដែលស្លូតហួស សោកៀហួស អន់ហួស គំរក់ហួស ។ មនុស្សប្រភេទនេះស្លូតផង ត្រង់ផង គ្មានចេះមាត់-កតវ៉ានឹងអ្នកណាឡើយ គឺគេសុខចិត្តតែនៅស្ងៀមៗ ទោះបីគេស្តីឱ្យខុសក៏ដោយ ត្រូវក៏ដោយ ខ្លាំងណាស់បានត្រឹមតែញ៉ឹមៗ គេស្លូតស៊ូស្លាប់ទៅចុះ ។

មនុស្សប្រភេទនេះ ប្រៀបដូចស្មៅជើងក្រាស់ចង់អ្នកណាដើរជាន់យ៉ាងណាក៏បានដែរ ។

" **ទៀចទេរមានភព្វអាយុយឺនយូរ** " ជនប្រភេទនេះលោកសំដៅយកមនុស្សណាដែលចេះមានល្បិចកិច្ចកលខ្លះ មានមធ្យោបាយចេះគេចកែនាយអាយសម្រាប់ដោះខ្លួននៅពេលមានបញ្ហាចោទឡើងម្តងៗ ដែលកើតមានឡើងជាយថាហេតុ ។

ក្នុងន័យនេះដដែល មានមនុស្សខ្លះប្រព្រឹត្តតែអំពើល្អគ្រប់ជំហាន សូម្បីតែសហគមន៍ក៏ទទួលស្គាល់ថា ជាមនុស្សល្អគ្រប់គ្នាដែរ ។ ប៉ុន្តែនៅពេលមួយជននេះបានប្រព្រឹត្តអំពើជាកំហុសដោយស្ទាត់កំបាំង និងដោយមនុស្សគ្រប់គ្នា ជឿជាក់ថាល្អរួចទៅហើយនោះ គេក៏គ្មានអ្នកណាម្នាក់សង្ស័យឡើយ ។

ដូច្នេះ អំពើល្អហាក់ដូចជាជួយបិទបាំងឱ្យគេបានរួចខ្លួនយ៉ាងស្រួល ។

មនុស្សប្រភេទនេះ លោកប្រៀបដូចផ្ទីរអាចម៍មាន់ ។ ធម្មតាផ្ទីរអាចម៍មាន់តែងមានបន្លាស្រួចមុតស្អេកស្កះ ។ ម្ល៉ោះហើយមនុស្សផងទាំងពួងមិនហ៊ានដើរជាន់ទេ ៕

*ថ្ងៃទី ១៣-០៤-០៧*

✿✿✿✿

ព្រះវិហារ



# ៣៧០. សម្តីសរជាតិ មារយាទសរត្រកូល

**និយមន័យ**

ភាសា និង ចរិយានាំឱ្យគេដឹងទៅដល់ជាតិសាសន៍ និងពូជអំបូរ

**អត្ថាធិប្បាយ**

" **សម្តីសរជាតិ** " សម្តី ឬភាសានៃជាតិសាសន៍និមួយៗ កាលណានិយាយឡើង ធ្វើឱ្យគេរលឹកនឹកឃើញទៅដល់ជាតិសាសន៍របសសាមីខ្លួន ។ ព្រោះសម្តី ឬភាសានេះហើយ ដែលជាមូលដ្ឋាននៃវប្បធម៌ជាតិរបស់គេ ។ ដូច្នេះ គេអាចស្គាល់ថាជាជាតិសាសន៍ណាមួយ គឺតាមរយៈភាសានេះឯង ។

" **មារយាទសរត្រកូល** " មារយាទគឺជាបុគ្គលិកលក្ខណៈ ឬជាអត្តចរិតរបស់មនុស្សម្នាក់ៗ ។ ដូច្នេះ កាលណាជនណាម្នាក់ប្រព្រឹត្តនូវកម្មអ្វីមួយ គឺជាហេតុសរបញ្ជាក់ឱ្យឃើញថាជននោះកើតក្នុងត្រកូលល្អ ឬអាក្រក់បាន ដូចជា ៖

- ក្មេងពាលម្នាក់ ដើរប្រព្រឹត្តតែអំពើអសីលធម៌, អនាចារ ប្រាសចាកប្រពៃណីជាតិ ។ គេដឹងថា ក្មេងពាលនោះ រស់ក្នុងត្រកូលមានការអប់រំតិច ឬខ្សោយ ។ ទោះបីត្រកូលនោះជាអភិជនក៏ដោយ ។

- តាចាស់អភិជនម្នាក់ ដើរទិញតែព្រហ្មចារីយក្មេងស្រី ដើម្បីបំពេញតណ្ហាខ្លួន ។ គេដឹងថា តាចាស់អភិជននោះ រស់ក្នុងត្រកូលទុឃិស, អសីលធម៌ ប្រាសចាកគន្លងព្រឹទ្ធាចារ្យ ៕

ចូលឆ្នាំកុរ នព្វស័ក ថ្ងៃទី *១៤-០៤-០៧*

# ៣៧១. ស្រលាញ់មេ បំពេកូន

**និយមន័យ**

ស្រលាញ់ម្ដាយ ត្រូវថ្នាក់ថ្នមកូន រឺយកកូនធ្វើជាធ្នាក់

**អត្ថាធិប្បាយ**

ពាក្យថា " **មេ និង កូន** " នៅពេលនេះ បញ្ជាក់ឱ្យដឹងថា ជាស្រ្ដីមេម៉ាយមានកូនតូច ជួនកាលអាចឈានទៅដល់ប្រពន្ធគេទៀតផង ។

ន័យក្នុងទំនឹមទំនៀមនេះ លោកនិយាយពីអ្នកដែលចាប់ចិត្តស្រលាញ់ស្រ្ដីដែលមានកូន ជាពិសេសគឺមានកូនតូច ។ ដើម្បីឈានទៅដល់ម៉ែ គេត្រូវយកកូនធ្វើជាធ្នាក់ ។

ដំបូងគេត្រូវយកនំចំណី រឺបាយឡុកបាយឡ ដែលជារបស់កូនក្មេងចូលចិត្តទៅផ្ញើកូនតូចជាញយៗ ។ ជាពិសេស បើអាចធ្វើបាន គេត្រូវចេះបីបមថ្នមថ្នាក់លើក-៣ រឺបញ្ជិះ-ក ។ ចំណែកម៉ែ គេមិនបាច់ចែចរ៉ប្រែពេកទេ ។ ព្រោះការថ្នាក់ថ្នមកូន ការជិតដិតស្និទ្ធស្នាលនឹងកូន វាមានឥទ្ធិពល ជាងការស្និទ្ធស្នាលជាមួយម៉ែទ្វេដងទៅទៀត ។ ម្យ៉ាងទៀតនៅក្នុងពេលនេះដែរ បើមានអ្នកក្រៅណាម្នាក់បញ្ចេះកូនឱ្យហៅគេថា ប៉ា ប៉ា ក្មេងនោះនឹង ហៅគេថា ប៉ា ភ្លាម ។ ព្រោះវាកំពុងអត់ប៉ាហៅផង ។ ពេលនេះហើយដែល ម៉ែមានអារម្មណ៍ចំលែកក្នុងចិត្ត ចំលែកចុះ ចំលែកឡើង ម៉ែ

ស្រលាញ់គេដោយមិនដឹងខ្លួន ។

ក្នុងន័យខាងលើនេះដែរ ក៏មានពំនោលមួយគេពោលបញ្ច្រាសមកវិញថា បើស្រលាញ់កូន ឱ្យជូននំចំណីម៉ែ គឺយកម៉ែធ្វើជាធ្នាក់ម្ដងវិញ ។

ពំនោលនេះ គេចង់និយាយថា បើម៉ែចាស់មានកូនក្រមុំ គេត្រូវអោនលំទោនជូននំចំណីម៉ែវិញម្ដង ។ ការជូនញឹកញយទៅ សភាពជិតដិតស្និទ្ធស្នាលក៏កើតមានឡើង ។ បើមានភាពស្និទ្ធស្នាលកើតមានហើយ តើមានស្នេហ៍ស្អកឯណាគ្រាន់បើជាង ។

✳ **កំណត់សម្គាល់**

វិធីសាស្ត្រខាងលើនេះ តាមការសង្កេតឃើញថា វាមានលក្ខណៈជាសាកលទៅហើយ ។ ទោះជាតិសាសន៍ណាក៏ឃើញគេប្រើវិធីនេះដែរ ហើយមានប្រសិទ្ធិភាពដូចគ្នាទាំងអស់ ៕

*ថ្ងៃទី ១៦-០៤-០៧*

❀❀❀❀

# ៣៧២. ស្រលាញ់ខ្លួនឱ្យស្ងួនចំណី ស្រលាញ់ស្រីឱ្យស្ងួនចិត្ត

**និយមន័យ**

បើស្រលាញ់ជីវិត និងស្រលាញ់ស្រីត្រូវចេះតមចំនី និងថ្នាក់ថ្នមចិត្ត

**អត្ថាធិប្បាយ**

❖ **ស្រលាញ់ខ្លួនឱ្យស្ងួនចំណី**

លោកថា បើអ្នកស្រលាញ់ខ្លួន ចូរប្រយ័ត្ននូវចំនីអាហារណាដែលជាទោសដល់សុខភាពរបស់ខ្លួនកុំទទួលទាន។ ព្រោះបើទទួលទានទៅនឹងធ្វើឱ្យខ្លួនទទួលរងនូវជម្ងឺផ្សេងៗដូចជា ភាគរូស ឈឺពោះ រឺបង្កជាបញ្ហាផ្សេងៗ ។ ម្យ៉ាងទៀតបើមានជម្ងឺប្រចាំកាយដូចជា ជម្ងឺទឹកនោមផ្អែម, ថ្លើម, ក្រពះ។ល ។ គេត្រូវតែតមចំនីអាហារដែលប្រឆាំងនឹងជម្ងឺអស់ទាំងនេះ ព្រោះវាឈានទៅដល់សេចក្តីស្លាប់បាន ។

❖ **ស្រលាញ់ស្រីឱ្យស្ងួនចិត្ត**

ការស្ងួនចិត្ត គឺជាការចេះថ្នាក់ថ្នម ថែរក្សាចិត្តស្រីឱ្យបានល្អប្រសើរ ត្រូវឱ្យដឹងពីចំនង់ចំនូលចិត្តគេ ។ ជាពិសេស ត្រូវដឹងពីចំណុចខ្សោយរបស់គេ ។ កាលបើអ្នកគ្រប់គ្រងចិត្តគេបានហើយ អ្វីៗគេនឹងប្រគល់ជូនត្រលប់មកឱ្យអ្នកវិញគ្រប់បែបយ៉ាងជាមិនខាន ៕

*ថ្ងៃទី ២២-០៤-០៧*

# ៣៧៣. សូវស្អុច កុំឱ្យដាច់

**និយមន័យ**

មានអ្វីបន្តិចបន្តួច ប្រសើរជាងគ្មាន

**អត្ថាធិប្បាយ**

របស់អ្វីក៏ដោយ បើគេមានចិត្តបន្តិចបន្តួចក៏ប្រសើរជាងគ្មានសោះដែរ ។ និយាយដោយហោចទៅ បើគេមានអំបិលមួយគ្រាប់ទទួលទាននឹងបាយ ក៏គ្រាន់បើជាងទទួលទានបាយទទេរដែរ ។ ព្រោះថា អ្វីដែលគ្រាន់តែរៀវស្អុច មានន័យថាមិនទាន់ដាច់ឬរលត់បាត់សូន្យទៅឡើយទេ ។ គេអាចអបស្មបប្រើការបានតទៅទៀត ។

ម្យ៉ាងទៀត សោហ៊ុយលុយកាក់ក៏ដូចគ្នាដែរ បើមាននៅសល់ខ្លះក្នុងហោប៉ៅសូម្បីតែមួយរៀល ក៏វាប្រសើរជាងគ្មានសោះដែរ ។

ការណ៍នេះហើយ ដែលលោកទូន្មានថា បើយ៉ាងណា។ឱ្យត្រឹមតែស្អុចបានហើយ កុំឱ្យតែដាច់ត្អិលតែម្តង នោះគឺជាការពិបាកច្រៃហើយ ។

នេះជាខ្លឹមសារក្នុងនិយមន័យខាងលើនេះ *គឺសុខចិត្តស្អុច កុំឱ្យដាច់ សុខចិត្តប្រកាច់កុំឱ្យស្លាប់* ៕

*ថ្ងៃទី ២៣-០៤-០៧*

❀❀❀❀

# ៣៧៤. សេះដាច់យកសេះតាម

**និយមន័យ**

បាត់បង់របស់ធំ ត្រូវយករបស់ធំទៅតាម

## អត្ថាធិប្បាយ

### ❖ អត្ថានុរូប

សេះជាសត្វដើរលឿន លុនលឿន ផាយលឿន ។ ដូច្នេះ កាលណាបើវាដាច់បាត់ គេត្រូវយកសេះដូចគ្នា ជិះដេញតាមទៅចាប់យកវាមកវិញ ។ ព្រោះបើគេយកគោ ឬក្របីជិះ ដេញតាមនោះ ប្រាកដជាតាមមិនទាន់ទេ ។

### ❖ អត្ថប្បដិរូប

ក្នុងន័យនេះ លោកធ្វើការប្រៀបធៀបថា បើគេបាត់បង់លុយកាក់ រឺខាតទុនធំនោះ ដើម្បីនឹងស្ទូចយករបស់ដែលបាត់បង់នោះមកវិញ ។ គេត្រូវយកលុយកាក់ច្រើន ឬទុនធំប្រហាក់ប្រហែលគ្នាមករកស៊ីទៀត ទើបតាមប្រាក់កាសដែលខាតនោះមកវិញបានដូចជា :

- គេរកស៊ីខាតអស់មួយលានរៀន គេត្រូវយកមួយលានរៀល រឺពីរលានរៀលទៅរកស៊ីទៀត ទើបដេញតាម រឺស្ទូចយកប្រាក់ដែលបង់ខាតនោះមកវិញបាន ។
- សិស្សម្នាក់ប្រលងធ្លាក់សញ្ញាប័ត្រ ដោយសារចំនេះវិជ្ជាមិនគ្រប់គ្រាន់ ។

ដូច្នេះគេត្រូវខំរៀនឱ្យខ្លាំង ជាងមុនដើម្បីតាមទៅយកសញ្ញាប័ត្រនោះឱ្យបានមក ។

ក្នុងន័យខាងលើនេះ មិនស៊ីជម្រៅទៅដល់ការចាញ់ល្បែង រួចទៅយកលុយពីផ្ទះថែមទៀត ដើម្បីដេញតាមប្រាក់ដែលចាញ់នោះទេ ៕

*ថ្ងៃទី ២៣-០៤-០៧*

❀❀❀❀



# ៣៧៥. ស្រមោចនៅជិតស្ករ

**និយមន័យ**

នៅជិតរបស់ដែលកំពុងត្រូវការ

## អត្ថាធិប្បាយ

### ❖ អត្ថានុរូប

ធម្មតាសត្វស្រមោចតែងចូលចិត្តរបស់ណាដែលផ្អែមមានស្ករជាដើម ។ បើគេដាក់ស្ករបិទមិនសូវជិតស្និទ្ធ សត្វស្រមោចស្រង់ក្លិនដឹងទាំងអស់ ។ កាលណាវាស្រង់ក្លិនបានហើយ វាតែងមករោម បើវាអាចចូលពាំបានវានឹងចូលពាំជញ្ជូនគ្រាប់ស្ករនោះទៅទុកនៅសំបុកវា ។

### ❖ អត្ថប្បដិរូប

តាមន័យខ្លឹមសារខាងលើនេះ លោកច្រើនពោលប្រៀបទៅនឹងកម្លោះ-ក្រមុំ ។ អ្នកទាំងពីរប្រភេទនេះ ពិតមែនតែរូបរាងកាយខាងក្រៅផ្ទុយគ្នាមែន តែផ្លូវចិត្តខាងក្នុងច្រើនតែរត់រកគ្នា ។ បើមិនរត់រកគ្នាទៅវិញទៅមកទេ ក៏កម្លោះរត់រកក្រមុំមុនដែរ ។ កាលបើកម្លោះចេះតែរត់រកគេជាញឹកញយដង និងជាយូរៗទៅលែងអីនឹងទោរទន់រកគ្នា ។ កាលបើគេទោរទន់រកគ្នាហើយ ប្រាកដជាមានបញ្ហាកើតឡើងជាមិនខាន ។

ហេតុនេះហើយបានជាលោកតែងពោលប្រាប់ថា *កុំយកស្ករដាក់ជិតស្រមោច រឺកុំយកសុរាដាក់ជិតអ្នកប្រមឹក* ៕

*ថ្ងៃទី ២៣-០៤-០៧*

# ៣៧៦. ស្អប់អាចម៍ជិះដីរ ស្អប់ក្ដីឡើងចុងត្នោត

**និយមន័យ**

គេចពីអ្វីដែលស្អប់ ត្រលប់មកជួបដោយចៃដន្យ

**អត្ថាធិប្បាយ**

៱ **ស្អប់អាចម៍ជិះដីរ**

" **អាចម៍** " គឺជាកាកសំនល់ដែលគួរខ្ពើមរអើម និងដែលនរណា១ក៏ចៀសវាងមិនចង់ប៉ះពាល់ រឺចង់ឃើញដែរ សូម្បីតែអាចម៍លេចចេញពីគូទខ្លួនឯងក៏ដោយ ។ ដូចគេនិទានមានបុរសម្នាក់ស្អប់អាចម៍ឡើងជិះដីរ ព្រោះខ្លាចដើរទៅជាន់អាចម៍ ។

៱ **ស្អប់ក្ដីឡើងចុងត្នោត**

ពាក្យថា " **ក្ដី** " នៅពេលនេះលោកសំដៅយកការឈ្លោះប្រកែកគ្នាធម្មតា គឺមិនសុីជម្រៅដល់ការឡើងសាលាក្ដីក្ដាំនោះទេ ។ ជាការទូទៅអ្នកណាក៏ចង់ចៀសវាងជម្លោះនេះណាស់ ។ ប៉ុន្តែអ្នកខ្លះចេះតែចៃដន្យជួបនឹងសំអប់នេះទៅវិញ ។ ទាក់ទងក្នុងន័យខាងលើនេះ លោកបានលើករឿងល្បើកមួយដូចតទៅ :

មានបុរសម្នាក់ មានការធុញទ្រាន់នឹងជម្លោះ ក៏ប្រឹងគេចវេះរួចឡើងទៅពួននៅលើចុងត្នោត ។ ដើម្បីកែអផ្សុក បុរសនោះក៏កាត់ស្លឹកត្នោតចាក់ជាស្មុគ ។ លុះចាក់បានច្រើនក៏បែកប្រាជ្ញាថាយកទៅលក់បានចំនេញទិញមេមាន់ រួចទិញមេគោ...រួចរៀបការ

ប្រពន្ធមួយ រួចមានកូនតូចមួយ ។ រួចថ្ងៃមួយកូនតូចនោះវារមករំខានអញកំពុង អានកាសែត ។ អញស្រែកហៅប្រពន្ធឱ្យមកចាប់កូន ។ តែគេហ៏មមាញឹកក្នុងផ្ទះបាយមិនបានមកចាប់ទេ ។ អញខឹងខ្លាំង អញស្ទុះទៅទាត់មួយជើង ។

បុរសនោះគិតហើយក៏ក្រោកឡើងមែនទែន ទាត់ចាងត្នោតមួយជើងភឹង រួចក៏របូតជើងធ្លាក់ចុះមក ។ តែបានស្រវាចាប់ស្លឹកត្នោតជាប់ ។ គាប់ជួនពេលនោះដែរបុរសស្អប់ខ្ពើមអាចម៍ជិះដំរីមកទាន់ពេលល្មម ។ បុរសចាក់ស្មុគក៏អង្វរឱ្យជួយយកអាសារផង ដោយសន្យាថានឹងទៅនៅបម្រើអស់មួយជីវិត ។ បុរសស្អប់អាចម៍ក៏ក្រោកឈរលើខ្នងដំរីចាប់ជើងទាំងពីរ ។ ដោយជំហរលើខ្នងដំរីញ័រៗ ដំរីស្មានថាម្ចាស់ឱ្យសញ្ញាដើរទៅមុខ ក៏ដើរចេញទៅ ទុកឱ្យបុរសទាំងពីរនៅប្រតោងគ្នា ។ ពេលនោះបុរសស្អប់ក្ដីភិតភ័យពេក ព្រោះតែត្រូវទម្ងន់គេតោងជើង ក៏លេចអាចម៍ដាក់បុរសស្អប់អាចម៍ ។ បុរសស្អប់អាចម៍ ក៏អង្វរបុរសស្អប់ក្ដីថា ៖ សូមបងតោងឱ្យជាប់ ពេលរួចជីវិត ខ្ញុំសុខចិត្តទៅនៅបម្រើបងឯងមួយជីវិតវិញ ។ បុរសស្អប់ក្ដីក៏ជេរគ្នារួចបង្កើតជាជម្លោះមួយទៅ ៕

*ថ្ងៃទី ២៤-០៤-០៧*

✿✿✿✿

# ៣៧៧. សូវចង្អៀតផ្ទះ កុំឱ្យចង្អៀតចិត្ត

**និយមន័យ**

ការចង្អៀតចង្អល់ រឺធូរទូលាយស្ថិតនៅក្នុងចិត្តទាំងអស់

**អត្ថាធិប្បាយ**

ព្រះពុទ្ធជាអម្ចាស់ទ្រង់ត្រាស់ថា **មនោ បុព្វង្គមា ធម្មា** = អ្វីក៏ដោយទោះបីល្អ អាក្រក់ បុណ្យបាប គុណទោស សុទ្ធតែកើតឡើងអំពីចិត្តទាំងអស់ ។ ព្រោះចិត្តហ្នឹងឯងជាប្រធាន ជាអ្នកសម្រេចអ្វីៗគ្រប់យ៉ាង ។ ដូច្នេះបើផ្ទះចង្អៀតក៏ដោយតែចិត្តមិនចង្អៀតចង្អល់ចិត្តសប្បាយរីករាយ ចិត្តជាកុសល ផ្ទះតូចរឺខ្ទមនោះមើលទៅឃើញហាក់ដូចជាធំទូលាយ ។ ផ្ទុយមកវិញ បើផ្ទះធំស្កឹមស្កៃ ប៉ុន្តែចិត្តមិនសប្បាយ មិនរីករាយ ចិត្តជាអកុសល ផ្ទះធំនោះមើលទៅឃើញហាក់ដូចជា ចង្អៀតទើសមុខទើសក្រោយ នៅពុំសុខសាន្តឡើយ ។

ឧទាហរណ៍ :

- ស្វាមីម្នាក់រស់នៅក្នុងផ្ទះធំស្កឹមស្កៃជាមួយប្រពន្ធដែលរអ៊ូរទាំរញ៉ាំរញ៉ៃ ។ គេធុញថប់ចង្អៀតចង្អល់ក្នុងចិត្តខ្លាំងណាស់ ។ គេសុខចិត្តចុះចេញទៅនៅខ្ទមតូចមួយដែលមានអ្នកចេះថ្នាក់ថ្នមចិត្តឱ្យសប្បាយរីករាយ ។ គេយល់ថាខ្ទមនេះ គឺជាវិមានសុភមង្គលសម្រាប់គេទៅវិញ ។

- ស្វាមីម្នាក់ទៀតរស់ក្នុងគ្រួសារដែលហូបសុទ្ធតែម្ហូបឆ្ងាញ់ៗរាល់ថ្ងៃ តែសម្ដីប្រពន្ធមិនឆ្ងាញ់សោះ ។ គេហូបម្ហូបទាំងនេះទាំងជូរ, ចត់, ល្វីង, ប្រៃ គ្មានឱជារសបន្តិចឡើយ ។ ពេលមួយ គេមានស្រីស្នេហ៍ នាងនោះដាក់ឱ្យហូបតែត្រីងៀតគំរាំងមួយចំរៀក ជូនកាលអត់ទាំងត្រីទៅទៀត មានតែទឹកជ្រក់ ឬទឹកម្ជូរ ។ ប៉ុន្តែពាក្យពេចន៍ នាងពោរពេញទៅដោយទឹកដមគួរភិសម័យ ម្ល៉ោះហើយត្រីងៀតក្ដី ទឹកជ្រក់ក្ដី ទឹកម្ជូរក្ដី ក្លាយទៅជាសំលម្ជូរគ្រឿង ជាឡុកឡាក់ ពិសេសមានឱជារសអីម្ល៉េះទេ ។

ត្រង់នេះហើយ ដែលលោកថា *ចង្អៀតអីចង្អៀតទៅ កុំឱ្យតែចង្អៀតចិត្ត* ៕

*ថ្ងៃទី ២៦.០៤.០៧*

❀❀❀❀



# ៣៧៨. ស៊ីពងរងសំបុក

**និយមន័យ**

ហ៊ានស៊ី ត្រូវតែហ៊ានគ្រប់គ្រង

**អត្ថាធិប្បាយ**

ពាក្យទំនីមទំនៀមនេះ លោកពោលសំដៅយកអ្នកថ្មីដែលចូលមកជំនួសអ្នកមុនដែលត្រូវឃ្លាតចេញ ។ ប៉ុន្តែពំនោលនេះ លោកមិនពោលជាសកល ឬជាលក្ខណៈទូទៅទេ គឺលោកចង់និយាយចំពោះតែទៅលើអ្នកដែលស្ម័គ្រចិត្តដោយខ្លួនឯង ឥតមានគេមកបង្ខំដូចជា :

បុរសម្នាក់ មានទំនាក់ទំនងស្នេហ៍ជាមួយអ្នកមេម៉ាយកូនបី ។ ពេលដែលបានក្លាយខ្លួនជាប្ដីស្របច្បាប់ហើយ គេក៏ត្រូវមានភារកិច្ចគ្រប់គ្រងគ្រួសារនេះឡើង ។ ពេល នោះ គេត្រូវមានកាតព្វកិច្ចរកស៊ីចិញ្ចឹមម្ដាយគេផង ចិញ្ចឹមកូនរបស់គេផង ។

ហេតុនេះហើយ បានជាលោកពោលថា បើហ៊ានស៊ីពង គឺស៊ីម៉ែគេហើយ ត្រូវតែហ៊ានរងសំបុកទៀត គឺត្រូវគ្រប់គ្រងគ្រួសារនេះដោយហ៊ានចិញ្ចឹមកូនគេ ទោះចង់ឬមិនចង់ក៏ដោយក៏ត្រូវតែទទួលរងដែរ ៕

*ថ្ងៃទី ២៧.០៤.០៧*

# ៣៧៩. ស្លៀកស្បង់មិនកោរសក់ ឆ្លុះកញ្ចក់ធ្មេចនេត្រា

## និយមន័យ

ទ្រទ្រង់ផ្នួស តែមិនប្រតិបត្តិតាមធម៌វិន័យ

## អត្ថាធិប្បាយ

### ៱ ស្លៀកស្បង់មិនកោរសក់

" **ស្បង់** " គឺជាសំពត់សម្រាប់ស្លៀករបស់អ្នកបួសក្នុងព្រះពុទ្ធសាសនា ។

ក្នុងខ្លឹមសារខាងលើនេះ លោកពោលសំដៅទៅលើអ្នកបួសក្នុងព្រះពុទ្ធសាសនាដែលគ្មានវិន័យ មិនប្រតិបត្តិតាមព្រហ្មចរិយធម៌ ប្រព្រឹត្តតែអំពើមិនសមស្របក្នុងពុទ្ធប្បញ្ញត្តិ ដូចជាសង្ឃខ្លះដើរថតបទចម្រៀងខារ៉ាអូខេ ដោយឥតអៀនខ្មាស់ ដែលគេហៅថា **អាលជ្ជីសង្ឃ** ។ ម្យ៉ាងទៀតមានសីលវន្ត-សីលវន្តីខ្លះកាន់សីល១០ ទៅហើយ តែចិត្តនៅព្រើល ភ្ញាក់ផ្អើលតែនឹងលាភសក្ការៈដោយឥតអៀនខ្មាស់ ។ បើឮថាមានគេចែកអំនោយសំពត់-សមួយដុំ ឬក្រមាមួយវិញ ស្ទុះរកកន្លែងចុះឈ្មោះ ខ្សឹបខ្សៀវគ្នាចុះឡើង ។ តែបើមិនបានវិញ ចាំស្ដាប់ចុះឮសូរតែរអ៊ូរទាំភ្លេចសីល ភ្លេចទានអស់ហើយ ។

## ៱ ឆ្លុះភពាក់ឆ្មេចនេត្រា

ខ្លឹមសារនេះ លោកសំដៅយកអ្នកដែលបានសិក្សា បានរៀន បានសូត្រនូវគម្ពីរ ដីកា ក្បួនច្បាប់ផ្សេងៗដែលព្រះបរមគ្រូទ្រង់ត្រាស់សំដែងទុកមក ។ ប៉ុន្តែមិនបាន គោរពប្រតិបត្តិតាមទេ គឺគេរៀន, គេមើល, គេអាន, គេសូត្រឱ្យតែគេកោត គេឮ ប៉ុណ្ណោះ ។ គេឥតខំប្រឹងយល់ឱ្យបានស៊ីជម្រៅ ពិចារណាឱ្យបានធ្លុះធ្លាយនូវពុទ្ធវចនៈ ទាំងនោះឡើយ ។ ការដែលបានរៀនសូត្រនូវក្បួនច្បាប់គម្ពីរដីកា ធម៌វិន័យដែលជា ពុទ្ធប្បញ្ញត្តិ ឬ ពុទ្ធានុញ្ញាត លោកទុកដូចបានឆ្លុះកញ្ចក់ឱ្យបានដឹងបានយល់អំពីឱវាទ របស់ព្រះអង្គ ។ តែកង្វះខាតការគោរពប្រតិបត្តិ លោកទុកដូចឆ្មេចនេត្រា ព្រោះគ្មាន បានផល ឬគំហើញ អ្វីបន្តិចសោះ ៕

*ថ្ងៃទី ២៦-០៤-០៧*

✿✿✿✿

| ស្រែកយំ ស្រែកឃ្លាន នៅលើគំនរស្រូវ |
|---|

# ៣៨០. សីលជាស្ពាន ទានជាស្បៀង

**និយមន័យ**

ការប្រព្រឹត្តិអំពើល្អ ជាស្ពានចម្លងទៅកាន់សុគតិ និងអំនោយជាអាហារូបត្ថម្ភ

**អត្ថាធិប្បាយ**

### ▲ សីលជាស្ពាន

" **សីល** " មានន័យថា ការវៀរចាកនូវអំពើអាក្រក់ ។

តាមន័យខាងលើនេះ លោកចង់បញ្ជាក់ប្រាប់ថា បើកាលណាគេមានសីលនៅក្នុងខ្លួន ឈ្មោះថា គេមានស្ពានចម្លងហើយ ។ គឺជាស្ពានចម្លងពីឥធលោកនេះ ទៅកាន់សុគតិលោក ។ សមដូចព្រះពុទ្ធដីកាថា **សីលេន សុគតី យន្តិ** សត្វទាំងឡាយទៅកាន់សុគតិភពក៏ដោយសារសីល ។ តាមន័យនេះដដែលស្ពាននេះមានប្រវែងផ្លូវវែងឆ្ងាយណាស់ដែលគេមិនអាចប្រមាណបាន ។ ដូច្នេះ អ្នកដែលមានដំនើរទៅតាមស្ពាននេះ ត្រូវមានអាហារូបត្ថម្ភបន្ថែមទៀត ទើបមានកំលាំងគ្រប់គ្រាន់នឹងទៅដល់បាន ។

### ▲ ទានជាស្បៀង

ស្បៀងនៅពេលនេះ កើតឡើងដោយសារផលនៃការឱ្យទាន ដូចជាធ្វើទានថ្វាយដល់ព្រះសង្ឃ ហៅថា សង្ឃទាន ។ ការទេសនា ការពន្យល់ធម៌អាថ៌ ការបោះពុម្ពផ្សាយ ពីធម៌វិន័យក្បួនច្បាប់ចែកចាយដល់បរិស័ទ ដល់សិក្ខាកាម ឱ្យបានយល់ដឹងនូវ ព្រះធម្មត្ថរស នៃព្រះសម្មាសម្ពុទ្ធ ហៅថា "ធម្មទាន" ។ ការធ្វើអំនោយជាគ្រឿង ប្រើប្រាស់ ជាអាហារូបត្ថម្ភ ហៅថា "អាមិសទាន" ។ល ។

ផលានិសង្សដែលកើតឡើងអំពីការធ្វើទានទាំងអស់នេះ បានប្រែក្លាយជាស្បៀងសម្រាប់អ្នកដែលមាន ចិត្តប្រាថ្នាទៅកាន់សុគតិភពទាំងអស់ ៕

*ថ្ងៃទី ២៦-០៤-០៧*

# ២៤៣. ប្រពន្ធរកបានឆាប់ ឆាប់មានសហាយ ប្រាក់រកបានងាយ ងាយចាយឆាប់អស់

**និយមន័យ**

អ្វីដែលចូលមកដោយធូរ ចេញទៅវិញក៏ធូរដែរ

**អត្ថាធិប្បាយ**

**ក. ប្រពន្ធរកបានឆាប់ៗមានសហាយ**

មនុស្សស្រីណា ដែលប្រុសទៅលួងលោមយកមកធ្វើជាប្រពន្ធបានដោយងាយពេក, ឆាប់ពេក និងរហ័សពេក ច្រើនតែជាស្ត្រីដែលពុំសូវមានគំនិតចេះគិតឱ្យបានម៉ត់ចត់ និងពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយទេ គឺឱ្យតែមានគេមកនិយាយផ្អែមល្ហែមលួងលោមតែបន្តិច ក៏ទោរទន់បាក់ចិត្តស្រលាញ់គេភ្លាម, វេចបង្វេចទៅតាមគេភ្លាម គ្មានសួរពិគ្រោះយោបល់នឹងញាតិមិត្តណាម្នាក់ឡើយ ។

ដូច្នេះស្រីប្រភេទងាយនេះ លោកថាដល់ពេលចេញទៅវិញក៏ឆាប់ដូចគ្នានឹងពេលចូលមកដែរ ។ លោកប្រៀបប្រដូចរឿងនេះទៅនឹងដើមឈើដែលដុះងាយដុះរហ័ស ដល់ពេលងាប់ក៏ឆាប់ ក៏រហ័សដូចគ្នា ដូចជា : ដើមជី, ម្ទេស, ប៉េងប៉ោះ ។ល ។

**ខ. ប្រាក់រកបានងាយៗចាយឆាប់អស់**

ខ្លឹមសារនេះ ក៏មានន័យដូចខាងលើដែរ ព្រោះប្រាក់ដែលរកបានមកងាយៗ

មនុស្សដល់ពេលចាស់ បានលះបង់ចិត្តចេញពីផ្ទះសម្បែង ចេញពីប្រពន្ធ រឺប្តី ចេញពីកូន(ឧបេក្ខាចិត្ត) ចេញពីមុខរបររកស៊ីទាំងអស់ ព្រោះខ្លួនចាស់ហើយ ។ ភារកិច្ចនេះត្រូវធ្លាក់ទៅលើកូនជាអ្នកបន្តវេនម្តង ។

ដោយសារលោកតា រឺលោកយាយ ពុំសូវមានចិត្តកង្វល់នឹងអ្វីៗទាំងអស់នេះ ហើយដែលនាំឱ្យចិត្តគាត់មូលផ្តុំតែជាមួយចៅមួយផ្នែកប៉ុណ្ណោះ ។

ហេតុនេះហើយ បានជាលោកថា ស្រលាញ់កូនមួយតៅស្រលាញ់ចៅមួយថាំង ។

ប៉ុន្តែ បើមានករណីពិសេស ដូចជាលោកតាមានប្រពន្ធក្មេង ហើយមានកូនទៀតនោះ ។ គេជឿថាលោកតា ប្រាកដជាបែរពីស្រលាញ់ចៅមកស្រលាញ់កូនខ្លួនឯងពីរថាំងមិនខាន ។

ម្យ៉ាងវិញទៀតមនុស្សវ័យចាស់ចូលចិត្តកូនក្មេងណាស់ ៕

*ថ្ងៃទី ២៧-០៤-០៧*

❀❀❀❀

# ៣៨២. ស្វា១ អំប្រែក២

**និយមន័យ**

ខ្លួនតែម្នាក់ទទួលបន្ទុកពីរ

**អត្ថាធិប្បាយ**

**អំប្រែក** នៅពេលនេះលោកសំដៅយកការងារ រឺភារកិច្ចដែលត្រូវផ្ទុកទៅលើបុគ្គលតែម្នាក់ ។

បុគ្គលតែម្នាក់នេះ ត្រូវមានករណីយកិច្ចដែលត្រូវបំពេញដល់ទៅពីរ ។ គឺគេត្រូវទទួលខុសត្រូវ និងធានាការពារផលប្រយោជន៍ពីរផ្នែកដូចជា :

- លោកសាស្ត្រាចារ្យ លី សាលី ត្រូវទទួលភារកិច្ចជានាយកសាលាផង ត្រូវបង្រៀនសិស្ស១ថ្នាក់ថែមទៀតផង ។

- រដ្ឋមន្ត្រីម្នាក់ ត្រូវទទួលបំពេញមុខងារនៅក្រសួងសន្តិសុខជាតិផង នៅក្រសួងប្រេងឥន្ធនៈផង ។

- អគ្គនាយកក្រុមហ៊ុនម្នាក់ ធ្វើការឱ្យក្រុមហ៊ុនឯកជន១ផង ធ្វើជំនួញខ្លួនឯងផង ។

- ឧត្តមស្វាមីម្នាក់ ត្រូវគ្រប់គ្រងគ្រួសារមុនផង គ្រួសារក្រោយផង (ចំពោះអ្នកមានគ្រួសារពីរ) ។

- ករណីខ្លួនតែម្នាក់ រ៉ែកអំប្រែកដល់ទៅពីរបែបនេះលោកថា *ស្វា១ អំប្រែក២* ៕

*ថ្ងៃទី ២០-០៨-០៧*

# ៣៨៣. សាមគ្គីជាកម្លាំង

**និយមន័យ**

ការប្រមូលផ្ដុំកម្លាំងតូចៗជាកម្លាំងធំមួយ

**អត្ថាធិប្បាយ**

" **សាមគ្គី** " គឺការរួបរួម ការប្រមូលផ្ដុំកម្លាំងតូចៗដែល នៅរាត់រាយមិនមូល ត្រកូលឱ្យមកផ្ដុំគ្នាធ្វើជាកម្លាំងរឹងមាំតែមួយ ។

កាលបើបានកម្លាំងធំហើយ គេអាចសម្រេចកិច្ចការអ្វីៗទៅតាមបំនងបាន ដូចជា :

- អំបោះមួយសរសៃមិនអាចធ្វើជាខ្សែចងអ្វីមួយបានទេ ព្រោះជំនាប់របស់វាតិចតួចពេក ។ ប៉ុន្តែ បើគេយកខ្សែអំបោះជាច្រើនសរសៃមកវេញបញ្ចូលគ្នាជាធ្លុងមួយទៅតាមទំហំដែលគេត្រូវការ គេនឹងបានជាខ្សែពួរមួយដែលអាចយកទៅទាក់ដំរីសារក៏បាន ។

- ប្រជាជនម្នាក់ទៅតវ៉ា ដោយសារឧកញ៉ាម្នាក់រំលោភយកដី ។ គេមិនអាចទទួលលទ្ធផលបានល្អទេ តែបើគេប្រមូលគ្នារាប់រយរាប់ពាន់នាក់ទៅតវ៉ាវិញ គេនឹងទទួលបាននូវលទ្ធផលយ៉ាងគាប់ចិត្ត ។ សមដូចពាក្យលោកថា*សម្លេងមហាជនគឺជាសម្លេងព្រះមហាក្សត្រ* ។

ដូច្នេះ កាលណាមានកម្លាំងធំ គេអាចរំលាយភ្នំមួយក៏បានដែរ ៕

*ថ្ងៃទី ២៧-០៤-០៧*

✿✿✿✿

# ៣៨៤. ស្តោះទឹកមាត់លើទ្រូងឯង

**និយមន័យ**

សម្តីនិយាយចេញទៅ តែផលវិបាកត្រូវសងមកលើខ្លួនឯងវិញ

**អត្ថាធិប្បាយ**

បើកាលណាគេដេកផ្ងា ហើយស្តោះទឹកមាត់ចេញទៅ ។ ទឹកមាត់នោះនឹងធ្លាក់មកលើដើមទ្រូងខ្លួនឯងវិញមិនខាន ។ ការប្រៀបធៀបឧបមានេះ លោកចង់និយាយយោងទៅដល់អ្នកដែលហាស្តីពុំបានគិតពីផលវិបាក ដែលត្រូវស្រោចមកលើខ្លួនឯងវិញដូចជា :

- ឪពុកខឹងនឹងកូនដែលចេះតែដើរលេងពុំគិតរៀនសូត្រ ក៏និយាយប្រាប់គេពីអត្តចរិតខិលខូចរបស់កូនថា យ៉ាងនេះមួយយ៉ាងនោះមួយ ។ អ្នកស្តាប់លឺហើយគេនិយាយបកត្រលប់មកវិញថា រឿងកូនខិលខូចនេះ គឺមកពីខ្វះការអប់រំរបស់ឪពុកម្តាយ ។ បើឪពុកម្តាយចេះអប់រំតាំងពីវានៅតូចៗមក ម្ល៉េះសមកូនមិនប្រព្រឹត្តអំពើពាលា ដើរអាវ៉ាសែដែលគេហៅថា " *ក្មេងទំនើង* " នោះទេ ។

- លោកគ្រូម្នាក់និយាយប្រាប់គេថា កូនសិស្សខ្ញុំរៀនខ្សោយណាស់ ។ អ្នកស្តាប់លឺហើយគេថា អារឿង ខ្សោយនេះមកពីគ្រូមិនចេះបង្រៀនវា ៕

*ថ្ងៃទី ២៩-០៤-០៧*

❀❀❀❀

# ៣៨៥. សំលមិនឆ្ងាញ់ ឱ្យតែនៅក្តៅ ប្រពន្ធខ្មៅ ឱ្យតែនៅក្មេង

**និយមន័យ**

ចំនុចខ្លាំងជួយយោងចំនុចខ្សោយ

**អត្ថាធិប្បាយ**

**៱ សំលមិនឆ្ងាញ់ឱ្យតែនៅក្តៅ**

**អណ្តាត** គឺជាឧបករណ៍នៃសរីរាង្គរបស់មនុស្ស ដែលមានមុខងារទទួលនូវរស-ជាតិអាហារគ្រប់យ៉ាង ។ តែបើសំលអន់ពេក អណ្តាតក៏ពុំសូវទទួលបាននូវរសជាតិដែរ ។ ដូច្នេះដើម្បីឱ្យអណ្តាតទទួលបាននូវរសជាតិ គេត្រូវពញោក់សរសៃទទួលរសជាតិ នៃអណ្តាតឱ្យភ្ញាក់ឡើង ដូចជាបើសំលត្រជាក់ពេក គេត្រូវញៀចម្ទេស ដើម្បីធ្វើឱ្យអណ្តាតកំរើកងើបឡើងទទួលនូវរសជាតិ ។ ប៉ុន្តែបើសំលនោះនៅក្តៅក៏អាចធ្វើឱ្យភ្ញោចសរសៃអណ្តាតហើយក៏ហាក់ដូចជាមានឱជារសគ្រាន់បើដែរ គឺគ្រាន់បើជាងសំលត្រជាក់ជាច្រើន ។

**៱ ប្រពន្ធខ្មៅឱ្យតែនៅក្មេង**

ក្នុងន័យនេះ ប្រពន្ធខ្មៅហាក់ដូចមិនជាទីនិយមរបស់ស្វាមីប៉ុន្មានឡើយ ។ ប៉ុន្តែបើស្រីម៉ៅនោះនៅកំពុងពេញវ័យ ក៏មិនជាអន់ថយប៉ុន្មានដែរទេ ។ ព្រោះថាស្ត្រីដែល

នៅកំពុងពេញវ័យ អ្វីៗក៏កំពុងពេញសោភណភាព និងមានទឹកដមទាំងអស់ ដូចជាពណិសម្បុរស្បែកឆវីវណ្ណមានសម្រស់គួរឱ្យគយគន់ ។

ម្យ៉ាងទៀត បើស្រីម៉ៅនោះចេះតែងខ្លួនសមតាមទំនង គឺចេះរើសពណ៌សម្លៀកបំពាក់វិញនោះ ប្រាកដជាព្រិលភ្នែកហើយ ។ សមដូចពាក្យចាស់លោកថា *ស្រីសល្អជាងស្រីខ្មៅ ត្រូវប្រេងត្រូវម្សៅ ស្រីម៉ៅស្អាតជាង* ។

ហេតុនេះហើយបានជាមានពាក្យគេថា *ប្រពន្ធខ្មៅក៏ខ្មៅចុះ ឱ្យតែនៅក្មេង* វាប្រាកដជាស្រស់ត្រកាលដូចតែគ្នាហ្នឹង បើមិនជឿ សាកមើលទៅ ៕

*ថ្ងៃទី ១៧-០៨-០៧*

❀❀❀❀

☞ **ជំងឺ** នាំមកនូវ **ចំហោត** គ្រប់យ៉ាង

*លី ថៃលី*

# ៣៨៦. ស្អប់កុំឱ្យចាញ់ ស្រលាញ់កុំឱ្យខ្ចី

**និយមន័យ**

ត្រូវការពារខ្លួន និងការពារមិត្តភាព

**អត្ថាធិប្បាយ**

▲ **ស្អប់កុំឱ្យចាញ់** ពាក្យទំនឹមទំនៀមនេះមានន័យថាត្រូវប្រុងប្រយ័ត្ន និងការពារខ្លួនកុំឱ្យគេចាប់ថ្នាក់ ដាក់ពិរុទ្ធកម្មមកលើខ្លួនបាន ។

ឧទាហរណ៍ : នាយ "ក" ជាសត្រូវស្លាប់-រស់និងនាយ"ខ" ដែលរស់នៅ ក្នុងភូមិជាមួយគ្នា ។ ដោយសំអប់នេះខ្លាំងពេកនាយ"ក" ក៏លបទៅប្រហារនាយ"ខ" ជាសំងាត់ រឺជួលគេឱ្យសំលាប់នាយ"ខ"បាត់ទៅ ។ លោកហាមមិនឱ្យធ្វើដូច្នេះទេ ព្រោះបើសមត្ថកិច្ចចុះស្រាវជ្រាវ ជាដំបូងគេត្រូវស៊ើបរកមនុស្សណាដែលជាគូសត្រូវនឹងនាយ "ខ"ជាមុនសិន ។ ដូច្នេះនាយ"ក" គឺជាមុខសញ្ញាដែលត្រូវគេយកចិត្តទុកដាក់មុនគេ ទើបធ្វើការស្រាវជ្រាវបន្ត ។ បើគ្មានពាក់ព័ន្ធទេទើបរួចខ្លួន ។

▲ **ស្រលាញ់កុំឱ្យខ្ចី** ពាក្យថាស្រលាញ់គឺលោក សំដៅយកមនុស្សជាមិត្តសម្លាញ់ រាប់អានគ្នាជិតដិតស្និទ្ធស្នាល ។ ធម្មតាអ្នកដែលស្រលាញ់រាប់អានគ្នា លោកមិនចង់ឱ្យបែកបាក់ប្រេះឆាអន់ចិត្តនឹងគ្នា ។ ហេតុនេះហើយបានជាលោកប្រាប់ថា បើមានរបស់អ្វីពុំគួរឱ្យខ្ចីទេ ដូចជា នាយសុខ ខ្ចីពូថៅនាយសៅ ។ នាយសុខ យក

មកប្រើយូរថ្ងៃនាំឱ្យនាយសៅអន់ចិត្ត ព្រោះគេរកពូថៅប្រើគ្មាន ។ បើគេរហ័សយកសងវិញតែពូថៅឆែបបន្តិច ។ បើពូថៅមិនឆែប និងមិនយូរថ្ងៃ ប៉ុន្តែខ្ចីញឹកញាប់ពេកក៏នាំឱ្យគេរំខានចិត្តដែរ ។

កត្តាទាំងអស់នេះហើយ ដែលនាំឱ្យអរិចិត្តគ្នាដែលលោកប្រាប់ថា"កុំឱ្យខ្ចី" ៕

*ថ្ងៃទី ២៩-០៤-០៧*

✿✿✿✿



# ៣៨៧. ស៊ីលៀសរអៀសខ្លួន

**និយមន័យ**

មនុស្សមានចំណុចខ្សោយ ចេះតែផ្អើលៗ និងរសើបគួទ

**អត្ថាធិប្បាយ**

**"ស៊ីលៀស"** ពាក្យនេះ លោកពោលសំដៅចំពោះមនុស្សខ្លះ ដែលប្រព្រឹត្តនូវអំពើខុសឆ្គងអ្វីមួយមិនសមរម្យដូចជាប្រាសចាកប្រពៃណី រឺខុសច្បាប់ទម្លាប់ដែលគេហៅថា មនុស្សមានចំណុចខ្សោយ ។ ដូចជា :

- នារីម្នាក់ បានប្រាសចាកប្រពៃណីជាសំងាត់ជាមួយសង្សារ ។ កាលណាបើឮគេនិយាយពីកូនកើតឥតខាន់ស្លា រឺនិយាយពីប្រពៃណីរវាងកម្លោះក្រមុំ ។ នារីនោះអង្គុយនៅមិនសុខទេ ចេះតែផ្អើលៗ និងរសើបគួទ ។

- ស្ត្រីម្នាក់មានប្តីច្រើនដង ។ កាលណាឮគេនិយាយពីស្រីចិត្តសាវ៉ា ។ ស្រីនោះចេះតែរអៀសខ្លួន ព្រោះអារម្មណ៍ចេះតែនឹកគិតថា ក្រែងគេនិយាយដៀមដាមឱ្យ ខ្លួន ។

- ជនទុច្ចរិតម្នាក់ ប្រព្រឹត្តតែអំពើលួច ឆក់ ប្លន់ ។ល ។ កាលបើឮ គេនិយាយពីសមត្ថកិច្ចប៉ូលិសចាប់ចោរ ជននោះចេះតែរសើបគួទអង្គុយមិនស្ងៀម បើត្រូវសើចក៏សើចមិនសមដែរ ។

ប៉ុន្តែការណ៍ពិត អ្នកនិយាយគ្មានចេតនាលើអ្នកណាទាំងអស់ គឺគេនិយាយដោយស្មោះត្រង់សុទ្ធសាធ ។ ព្រោះគ្នាគ្មានបានដឹងពីរឿងរ៉ាវអ្នកណាម្នាក់ឡើយ ។

មនុស្សភ្ញាក់ផ្អើល និងការរសើបគួទដូចខាងលើនេះហើយដែលលោកហៅថា *មនុស្សស៊ី លៀសរអៀសខ្លួន* ៕

*ថ្ងៃទី ២៩-០៤-០៧*

# ៣៨៨. ស្រលាញ់ពេញប្រាស, ស្អប់ជំពប់ជើ

**និយមន័យ**

ការតាំងទុកក្នុងចិត្តជិតជាប់ក្នុងអារម្មណ៍ថាស្រលាញ់ និង សំអប់

**អត្ថាធិប្បាយ**

ពំនោលក្នុងនិយមន័យខាងលើនេះ លោកសំដៅយកការស្រលាញ់ និងសំអប់រវាងភេទដែលបុគ្គលប្រុស ស្រីធ្វើទុកក្នុងចិត្តជានិច្ចកាល ។ ន័យនេះសមដូច ព្រះពុទ្ធវចនៈទ្រង់ត្រាស់ថា **យោ និសោ មនសិការៈ** គឺការតំកល់ ទុកយ៉ាងមុតមាំក្នុងចិត្ត ។

ដូច្នេះ អ្វីដែលផុយពីផ្លូវចិត្ត កាលបើគេបានជួបប្រទះរមែងប៉ះទង្គិចនឹងអារម្មណ៍នាំឱ្យគេចូលចិត្តយល់ខុសថា : អ្វីដែលស្អប់ចេះតែជួប និងអ្វីដែលស្រលាញ់ចេះតែព្រាត់ប្រាស ។

ប៉ុន្តែតាមការណ៍ពិតការជួប និងការព្រាត់ប្រាសវាជាដំណើរចៃដន្យទៅតាមនិស្ស័យកម្មរបស់សត្វលោកក្នុងវដ្តៈនេះឯង ។

បំរៀបធៀបម្យ៉ាងទៀតថា គេស្អប់អាចម៍ ពេលគេដើរជាន់អាចម៍ គេតែងពោល : បើថាឯងស្អប់អាចម៍ ចេះតែដើរជាន់អាចម៍ ចុះត្រង់ដើរមិនជាន់រាប់ម៉ឺនដងម៉េចក៏មិនថាផង ? ។ ហ្នឹងហើយដែលថា : អ្វីដែលផុយពីផ្លូវចិត្តចេះតែមានអារម្មណ៍យល់ខុសដូចពោលមកខាងលើនេះស្រាប់ ៕

*ថ្ងៃទី ១៣-០៧-១០*

# ៣៨៩. សំនាងពីអតីត គំនិតបច្ចុប្បន្ន

**និយមន័យ**

កុសលផលបុណ្យសាងពីជាតិមុន និង ការចេះគ្រប់គ្រងជាតិបច្ចុប្បន្ន

**អត្ថាធិប្បាយ**

"**សំនាងពីអតីតៈ** " គឺការកសាងពីជាតិមុនមក ។

យោលតាមទ្រឹស្តីពុទ្ធនិយមថា មានជាតិមុន ជាតិបច្ចុប្បន្ន និងជាតិអនាគត ។

ក្នុងន័យខាងលើនេះ លោកនិយាយពីការកសាងកម្មពីជាតិមុន ។ ផលកម្មនោះនឹងផ្តល់ជូនដល់ម្ចាស់ទំរើ ក្នុងជាតិនេះទាំងអស់ ទោះល្អក្តី អាក្រក់ក្តី ។ តែក្នុងន័យខាងលើនេះ លោកនិយាយតែពីកុសលកម្ម(អំពើល្អ) ដែលហៅថា សំនាង ឬការកសាង ។

ដូច្នេះក្នុងជាតិនេះ គឺជាជាតិដែលរង់ចាំទទួលនូវផលពីជាតិមុន រួចបង្កើតបានជាសំនាង ។

"**គំនិតបច្ចុប្បន្ន** " បើមានសំនាងកើតក្នុងត្រកូលអ្នកមាន ទ្រព្យសម្បត្តិមហាសាលក៏ដោយ បើគំនិតមិនកើតគ្រប់គ្រងទ្រព្យសម្បត្តិទាំងនោះពុំបាន គេក៏ត្រូវតែរលាយវិនាសហិនហោចទ្រព្យសម្បត្តិអស់ទៅវិញមិនខាន ដូចជា ចាយវាយខ្ជះខ្ជាយគ្មានគិតមុខក្រោយ ដើរលេងស៊ីផឹក និងលេងល្បែងភ្នាល់ផ្សេងៗជាដើម ។

ដូច្នេះពុំមែនមានសំនាងហើយ ចេះតែល្អប្រសើររហូតនោះទេ បើខ្វះគំនិតគ្រប់គ្រងផងនោះ ៕

*ថ្ងៃទី ៣០-០៤-០៧*

# ៣៩០. សងសឹកជាការកំឡៅ

**និយមន័យ**

ការចងគំនុំព្យាបាទគ្នាជាការល្ងង់ខ្លៅ

**អត្ថាធិប្បាយ**

តាមទ្រឹស្តីក្នុងព្រះពុទ្ធសាសនាបានចែងថា **អក្កោធេន ជិនេ កោធំ** = ពៀររំងាប់ដោយការមិនចងពៀរ ។

តាមន័យនេះ គឺលោកមិនចង់ឱ្យមនុស្សមានគំនិត ចេះតែរករឿងគុំគួនព្យាបាទគ្នាទេ ។ ព្រោះថាជម្លោះកើតមានហើយ ហើយរលត់សាបសូន្យទៅវិញបាន ក៏អាស្រ័យដោយការមិនសងសឹកតបទៅវិញទៅមក ។ ការសងសឹកគ្នាមានន័យថា គេចេះតែបន្តកម្មពៀរឱ្យវែងទៅមុខទៀត ។ អ្នកដែលចេះតែបន្តការសងសឹកគ្នា ទៅវិញទៅមកមិនចេះចប់ លោកចាត់ទុកថាជាមនុស្សអវិជ្ជា គឺមនុស្សល្ងង់ខ្លៅ ។ ធម្មតាមនុស្ស ល្ងង់ខ្លៅ មានកង្វះខាតការពិចារណា គឺគេចេះតែគិតថា បើមិនតបត ទៅវិញទេហាក់ដូច ជាអន់ពេកចាញ់ចិត្តគេពេក ដូច្នេះត្រូវតែសងសឹកទៅវិញកុំឱ្យខ្មាស់គេ ។

ការសងសឹកគ្នាចុះឡើង បែបនេះមានន័យថា ជីវិតគេទាំងសងខាងស្ថិតនៅមាត់ជ្រោះមរណៈទាំងអស់ ៕

*ថ្ងៃទី ០៣-០៥-០៧*

❀❀❀❀

# ៣៩១. ស៊ីបាយបោកឆ្នាំង

**និយមន័យ**

មនុស្សគ្មានគុណលើអ្នកមានគុណរបស់ខ្លួន

## អត្ថាធិប្បាយ

ពាក្យទំនឹមទំនៀមនេះ លោកពោលសំដៅដល់មនុស្សណាដែលរមិលគុណអ្នកដែលមានគុណមកលើខ្លួន ដោយប្រព្រឹត្តអំពើយង់ឃ្នង, អសីលធម៌ពុំគួរគប្បី ដូចជា :

- ពូសុខបានយកយុវជនកំព្រាម្នាក់មកចិញ្ចឹមឱ្យរៀនសូត្រ ។ លុះនៅយូរៗទៅក៏មានទំនាក់ទំនងនឹងកូនក្រមុំពូសុខ ។ ថ្ងៃមួយពូសុខបានដឹងហេតុការណ៍នេះ ក៏ជេរថា យើអាចោរស៊ីបាយបោកឆ្នាំង ។

- មិត្តភក្តិពូម៉ៅម្នាក់បានមកស្នាក់បក្សប៉ុនអាស្រ័យនៅជាមួយគាត់ជាយូរខែ ។ ស្រាប់តែថ្ងៃមួយមិត្តភក្តិនោះបានសមគំនិតឃុបឃិត រួចក៏ពង្រាត់យកប្រពន្ធគាត់ទៅបាត់ ។

អត្ថន័យខាងលើនេះ លោកច្រើនពោលសង្កត់ធ្ងន់ទៅលើអ្នកដែលប្រព្រឹត្តខុសក្នុងផ្លូវភេទ ដូចបានបរិយាយមកស្រាប់ ៕

*ថ្ងៃទី ៣០-០៤-០៧*

❀❀❀❀

# ៣៩២. សំពត់រហែក កុំហែកថែម

**និយមន័យ**

រឿងអាស្រូវភាសរបស់គេ កុំបរិហារបន្ថែម

**អត្ថាធិប្បាយ**

**សំពត់រហែក** លោកប្រៀបប្រដូចទៅនឹងរឿងអាស្រូវភាសទាំងឡាយណាដែលជារបស់កើតមានរួចទៅហើយ ។

លោកអប់រំថា គួរតែជួយបិទបាំងគ្នាផងទៅធ្វើម្ដេចបានជាកន្លងជ្រុលហួសអស់ទៅហើយ ។ លោកមិនចង់ឱ្យអ្នកដែលបានដឹងរឿងនេះហើយ យកទៅនិយាយបូរបាច់ប្រាប់គ្នីគ្នាឱ្យរីតតែឮសុះសាយវែងអន្លាយតទៅទៀត ។ លោកថាសំពត់រហែករួចទៅហើយ បើមិនបានជួយដេរភ្ជិតទេ ក៏ពុំគួរនឹងចាប់ហែកឱ្យរីតតែរហែកបន្ថែមទៀតឡើយ ។

ឧទាហរណ៍ :

- កូនចៅពូមៀម បានខូចកាចនឹងគ្នារួចទៅហើយ ។ បើអ្នកបានដឹងរឿងនេះ ចូរនៅឱ្យស្ងៀម ជួយលាក់ទុកក្នុងចិត្ត ឈ្មោះថាបានជួយដេរភ្ជិតសំពត់រហែក នោះបានហើយ ។

- ប្រពន្ធពូពាងបានលបលាក់មានសហាយ ។ រឿងនេះក៏មិនគួរនិយាយឱ្យឮ

ចេញពីមាត់មួយទៅមាត់មួយទៀតដែរ ។

ការណ៍អ្វីក៏ដោយ ដែលជារឿងអាស្រូវភាស គួរតែជួយបិទបាំងគ្នា ឈ្មោះថាបានកាន់យកនូវសីលធម៌ រឺបានបំពេញនូវអំពើជាកុសលមួយដែរហើយ ។

ករណីនេះលោកច្រើនពោលតែពីរឿងអាស្រូវភាសផ្លូវភេទជាងរឿងអាស្រូវឯទៀត ៕

*ថ្ងៃទី ០១-០៥-០៧*



# ៣៩៣. សុខស្លាប់បា កុំឱ្យស្លាប់មេ

## និយមន័យ

សុខចិត្តស្លាប់ប្រុស កុំឱ្យស្លាប់ស្រី

## អត្ថាធិប្បាយ

បំនកស្រាយតាមខ្លឹមសារក្នុងន័យខាងលើនេះ គឺលោកចង់ពោលថា បើរឿងនេះត្រូវស្លាប់ម្នាក់ លោកថាសុខចិត្តស្លាប់បាជាប្រុសទៅចុះ ពិតមែនមនុស្សប្រុសជាអ្នករកស៊ីចិញ្ចឹមគ្រួសារ គ្រប់គ្រងគ្រួសារក៏ដោយ ក៏លោកសុខចិត្តចំនាយចោលដែរ ។ លោកសុខចិត្តទុក"មេ"ជាស្រីវិញដោយលោកយោលទៅលើព្រហ្មវិហារធម៌ គ្របដណ្តប់មកលើកូនប្រុសស្រីក្នុងការថែទាំបីបមថ្នមថ្នាក់លើកដាក់ ផ្ទុតទឹកបញ្ចុកនំចំណីសព្វគ្រប់បែបយ៉ាងបានល្អជាងមនុស្សប្រុសជា "បា" ។ ពិតមែនតែ"មេ" ជាស្រីមិនសូវពូកែរកស៊ីឱ្យបានខ្លាំងក្លាដូចបាជាប្រុសក៏ដោយ ។

ម្យ៉ាងទៀតព្រះពុទ្ធដីកា ក៏តែងពោលថា ម្តាយគឺជាមិត្តដ៏ជិតស្និទ្ធរបស់កូនប្រុសស្រីគ្រប់ប្រាណ ។

ក្នុងន័យខាងលើនេះ លោកឱ្យតម្លៃខ្លាំងទៅលើការបីបមថ្នមថ្នាក់ ធ្វើឱ្យកូនមានកំនក់ក្តៅ និងមានមនោសញ្ចេតនារវាងកូននឹងម្តាយខ្លាំងជាងឪពុក ។

ហេតុនេះហើយបានជាគេឃើញកូនប្រុសស្រីស្រលាញ់ម្តាយខ្លាំងជាងឪពុក ៕

*ថ្ងៃទី ០១-០៥-០៧*

# ៣៩៤. ស្លាប់មិនដូរឈ្មោះ រស់មិនដូរត្រកូល

**និយមន័យ**

សម្ដីអំនួតរបស់អ្នកមានចិត្តមានះ

**អត្ថាធិប្បាយ**

ពាក្យពំនោលនេះ ពុំមែនមានមកពីបរមបុរាណមកទេ គឺគេទើបនឹងឮនៅទសវត្សរ៍ឆ្នាំ ១៩៩០នេះឯង ។

គោលបំនងនៃអ្នកដែលបង្កើតពាក្យនេះឡើង គឺដើម្បីសម្ដែងឱ្យអ្នកផងទាំងពួងឃើញ និងកោតស្ញប់ស្ញែងនៃកាយវិការរបស់គេថាជាអ្នកម៉ឺងម៉ាត់ និងអង់អាចក្លាហានជាប់ជានិច្ច ។

មួយ៉ាងទៀតគេចង់បញ្ជាក់ថា គេជាមនុស្សប្រាកដនិយមពិតប្រាកដណាស់ គឺគេមិននិយាយបាតដៃជាខ្នងដៃទេ គឺគេនៅតែរក្សាកេរ្តិ៍ឈ្មោះរបស់គេជាដរាប ទោះនៅរស់ក៏ដោយ ស្លាប់បាត់រូបក៏ដោយក៏មានៈចិត្តគេនៅតែជាអ្នកក្លាហានប្រាកដនិយមដដែល ដូចជា កាលនៅរស់គេមានឈ្មោះសុវណ្ណហង្ស លុះស្លាប់ទៅក៏គេនៅតែឈ្មោះសុវណ្ណហង្សដដែល មិនអាចប្រែជាសុវណ្ណព្រាបឡើយ ។

ឯពាក្យថា **រស់មិនដូរត្រកូល** ក៏មានខ្លឹមសារប្រហាក់ប្រហែលគ្នាដែរ គឺគេធ្វើអ្វីៗទោះបីល្អក៏ដោយ អាក្រក់ក៏ដោយ គេមានមានៈចិត្តមុតមាំដាច់ខាតដោយហ៊ានទទួលខុសត្រូវនូវរាល់ទំរើដែលគេបានធ្វើ ។ គេឥតមានចិត្តរុញរា រឺកំសាកកំសោយឡើយ មានន័យថាគេហ៊ានទទួលនូវផលវិបាកទាំងអស់ដោយឥតមានខ្លាចបុរសបុគ្គល រឺមារព្រហ្មយមយក្សណាម្នាក់សោះឡើយ ៕

*ថ្ងៃទី ២២-០៥-០៧*

# ៣៩៥. សុខលិចទូកកណ្ដាលទន្លេ កុំឱ្យតែភ្លើងឆេះផ្ទះ

## និយមន័យ

សុខចិត្តប្រឈមមុខនឹងមរណៈ ឱ្យតែនៅសល់ទ្រព្យសម្បត្តិ

## អត្ថាធិប្បាយ

ទ្រព្យសម្បត្តិប្រើប្រាស់គ្រប់បែបយ៉ាងបានមកពីការខិតខំសន្សំសំចៃបន្តិចម្ដង-បន្តិចម្ដង ទំរាំធ្វើបានជាផ្ទះសម្បែងសម្រាប់រស់នៅ ។ កាលណាបានផ្ទះជ្រកហើយ តោងខំសន្សំប្រាក់កាសដើម្បីទិញសម្ភារៈប្រើប្រាស់ទៀត ។ បើមុខរបររកស៊ីពុំសូវកាក់កប អ្នកខ្លះសឹងតែមួយជីវិតនៅតែសន្សំទិញម៉ូតូឬកង់កញ្ចាស់មួយប្រើមិនបាន ។ ដូច្នេះ ឃើញថាគេត្រូវប្រើពេលយូរណាស់ ។ បើជាអ្នករកស៊ីដោយកម្លាំងពលកម្មវិញ តោងបង្ហូរញើសរាប់ពាន់ម៉ឺនតំណក់ទំរាំសង់បានកូនជម្រកមួយ ។

ដោយសារពិបាកនឹងរកទ្រព្យយ៉ាងនេះហើយ ទើបលោកពោលថា សុខចិត្តប្រថុយនឹងគ្រោះថ្នាក់ដល់ជីវិតទៅចុះកាលបើចៀសមិនផុត ឱ្យតែនៅសល់ទ្រព្យសម្បត្តិទុកឱ្យអ្នកនៅរស់ប្រើប្រាស់ ។ ព្រោះថាបើកាលណា ភ្លើងឆេះផ្ទះវិញ គឺខ្ទេចម៉ដ្ឋអស់រលីងគ្មានសេសសល់អ្វីក្រៅពីផេះទេ ។ បន្ទាប់ពីភ្លើងឆេះផ្ទះរួចរកតែឆ្នាំងដាំបាយក៏ ពុំបានផង ។ ឯការលិចទូកកណ្ដាលទន្លេ ក៏ពុំប្រាកដជាស្លាប់ទាំងអស់ដែរ គឺអាចហេងស៊យ ។

ហេតុនេះហើយបានជាលោកថា *សុខចិត្តឱ្យលិចទូកចុះ កុំឱ្យភ្លើងឆេះផ្ទះ* ៕

*ថ្ងៃទី ២៧-០៥-០៧*

# ៣៩៦. សេចក្ដីព្យាយាមគង់បានសម្រេចដូចប្រាថ្នា

**និយមន័យ**

ការសន្សំបន្តិចម្ដងៗអាចសម្រេចបំណងបាន

**អត្ថាធិប្បាយ**

ការងារគ្រប់បែបយ៉ាង សុទ្ធសឹងតែកើតឡើងពីសេចក្ដីព្យាយាមទាំងអស់ ព្រោះថាបើមិនព្យាយាមធ្វើ ប្រាកដជាមិនបានទៅដល់គោលដៅទេ ។ ម្យ៉ាងទៀតសេចក្ដីព្យាយាមជាឫសគល់នៃសេចក្ដីសម្រេចគ្រប់យ៉ាង និងគ្រប់បំណងទាំងអស់ ។ សូម្បីតែការសិក្សាក៏យកសេចក្ដីព្យាយាមជាបច្ច័យដើម្បីឈោងទៅ ចាប់នូវសេចក្ដីសម្រេចសមតាមបំណងដែរ ។

ក្នុងន័យនេះទៀត លោកក៏គិតទៅដល់ការធ្វើបុណ្យសុន្ទរីទានក៏ត្រូវមានការព្យាយាមធ្វើបន្តិចម្ដង-បន្តិចម្ដង រហូតដល់បានសម្រេចមគ្គផលសមតាមប្រាថ្នាដូចគ្នា ។

ឧទាហរណ៍ :

- សត្វកណ្ដៀរតូចមួយ ព្យាយាមពាំយកធូលីដីទៅគរទុកត្រង់កន្លែងមួយយូរៗទៅក៏បង្កើតបានជាដំបូកមួយយ៉ាងធំ ។

- ជាងចម្លាក់ម្នាក់ព្យាយាមដាប់ផ្ទាំងថ្មដា បន្តិចម្ដង-បន្តិចម្ដង ទីបំផុតក៏លេចចេញជារូបភាពផ្សេងៗសមតាមបំណង ។

- អ្នកក្រកម្សត់ម្នាក់ខំប្រឹងសន្សំប្រាក់បន្តិចម្ដង-បន្តិចម្ដង យូរៗទៅក៏ក្លាយទៅជាពាណិជ្ជករយ៉ាងធំម្នាក់បាន ។

- យុវជនម្នាក់ ខំប្រឹងព្យាយាមសិក្សារហូតដល់បានជាបណ្ឌិតម្នាក់ ៕

*ថ្ងៃទី ១៥-០៨-០៧*

# ៣៩៧. សូវស្រក់ឈាម មិនឱ្យស្រក់ទឹកភ្នែក

**និយមន័យ**

វោហារអំនួតរបស់អ្នកក្លាហាន

## អត្ថាធិប្បាយ

ធម្មតាអ្នកក្លាហានតែងមានអត្តចរិតស្វាហាប់ អង់អាច, ម៉ឺងម៉ាត់គ្មានចេះខ្លាចរអែង និងកោតក្រែងបុគ្គលណាម្នាក់ឡើយ ។ គឺគេសម្ដែងឬកពាឱ្យឃើញថា គេមិនព្រមចុះញ៉ម ឱនលំទោនចំពោះគូសត្រូវណាម្នាក់ទេ ព្រោះគេយល់ថាទំរើដូច្នេះនាំមកនូវភាពអាម៉ាស់ និងអាប់ឱនកិត្តិយសយ៉ាងសំបើមណាស់សម្រាប់ជីវិតរបស់គេ ។

ហេតុនេះហើយ គេមិនដែលឃើញជនប្រភេទនេះលុតជង្គង់អង្វរ-កគូបដិបក្សដល់ម្ដងណាសោះឡើយ ។ ព្រោះគេយល់ថា ការមិនព្រមចុះញ៉មអ្នកណាម្នាក់ដូច្នេះ គឺជាសភាពអង់អាចក្លាហានរបស់គេ រឺថាជាកិត្តិយសរបស់គេ ។ ម្ល៉ោះហើយ ទោះបីគេដឹងថាត្រូវប្រឈមនឹងហេតុការណ៍យ៉ាងធ្ងន់ធ្ងររហូតដល់ស្រក់ឈាមក៏ដោយ ក៏គេមិនរុញរាដែរ ៕

*ថ្ងៃទី ១៥-០៨-០៧*

❀❀❀❀

# ៣៩៨. សុ_ចិ_បុ_លិ

**និយមន័យ**

រូបមន្តរឺគន្លឹះនៃការសិក្សា

**អត្ថាធិប្បាយ**

អង្គទាំង ៤នៃកាសិក្សានេះ គឺជាពុទ្ធវចនៈរបស់ព្រះបរមគ្រូជាម្ចាស់នៃយើងទ្រង់ត្រាស់សម្តែងទុកមក ។ ព្រោះរូបមន្តនេះគឺជាគន្លឹះ រឺជាបិតានៃការសិក្សានូវចំនេះវិជ្ជា សិល្ប៍សាស្ត្រគ្រប់បែបយ៉ាងទាំងអស់ ។

អ្នកសិក្សាសិល្ប៍វិជ្ជាអ្វីក៏ដោយ បើកាលណាខ្វះអង្គទាំងបួននេះហើយ គេមិនអាចរៀនឱ្យបានពូកែឡើយ ។

អត្ថន័យនៃអង្គទាំងបួនគឺ :

- **សុ** (សុត្តៈ) = ស្តាប់
- **ចិ** (ចិន្តៈ) = គិត, ពិចារណា
- **បុ** (បុច្ឆៈ) = សាកសួរ
- **លិ** (លិខិតៈ) = កត់ត្រាទុក

ដូច្នេះ មុននឹងសិក្សានូវចំនេះវិជ្ជាអ្វីមួយ ។ មុនដំបូងលោកឱ្យប្រឹងស្តាប់ (សុ) គេពន្យល់អធិប្បាយ ។ បើស្តាប់រួចហើយលោកឱ្យយកន័យ ឬខ្លឹមសារទាំងនោះ

មកត្រិះរិះគិតពិចារណា (ចិ) ឱ្យបានកាន់តែច្បាស់សេចក្តីល្អឡើង ។

ប៉ុន្តែបើគិតពិចារណាហើយ នៅតែមិនយល់ច្បាស់ល្អ រឺនៅមានសង្ស័យត្រង់ណានិមួយ លោកឱ្យសាកសួរ(បុ) ឱ្យគេជួយពន្យល់ម្តងទៀតទាល់តែចូលចិត្តស្តាប់បាន ។ កាលណាបើស្តាប់យល់ល្អហើយ លោកឱ្យកត់ត្រាទុកចំនាំ (លិ)ទៅថ្ងៃក្រោយទៀត ក្រែងលោភ្លេចភ្លាំងច្រលំន័យ ។

ប្រសិនបើអ្នកសិក្សាណាម្នាក់បានអនុវត្តតាមអង្គនៃរូបមន្តទាំងបួននេះបានល្អហើយ លោកហៅអ្នកនោះ ថាជាអ្នកសិក្សាពូកែឆ្នើមលើសគេ ៕

*ថ្ងៃទី ១៥-០៨-០៧*



# ៣៩៩. សេចក្តីស្រលាញ់ស្មើខ្លួនមិនមាន

**និយមន័យ**

ស្រលាញ់អ្វីក៏មិនស្មើនឹងស្រលាញ់ខ្លួនឯងដែរ

**អត្ថាធិប្បាយ**

ពាក្យថា"**ខ្លួន** " នៅពេលនេះលោកសំដៅយក "ជីវិត"ដែលជារបស់ខ្លួន ។

ព្រះពុទ្ធភាសិតទ្រង់សម្តែងថា **នត្ថិ អត្តសមំ បេមំ** មានន័យថា បុគ្គលស្រលាញ់អ្វីរាប់តាំងពីឪពុកម្តាយ បងប្អូន កូនចៅ...ឬសម្បតិទ្រព្យដ៏មានតម្លៃយ៉ាងណាក៏ដោយ ក៏សេចក្តីស្រលាញ់នោះមិនអាចប្រៀបស្មើនឹងសេចក្តីស្រលាញ់ជីវិតរបស់ខ្លួនដែរ ។

ព្រោះថា "**ជីវិត**" របស់បុគ្គលម្នាក់ៗមានតម្លៃពុំអាចកាត់ថ្លៃបាន វាគឺជាកម្មសិទ្ធផ្តាច់មុខរបស់បុគ្គលម្នាក់ៗដែលគេមិនអាចរំលែកឬផ្លាស់ប្តូរ ផ្ទេរពីម្នាក់ទៅម្នាក់ទៀត បានឡើយ ។

ម្យ៉ាងទៀត "**ជីវិត**" នេះក៏ពុំមានដាក់លក់ រឺទិញដូរបានដែរ ទោះបីមានប្រាក់ច្រើនដល់ម្លាក៏ដោយ ។

ឧទាហរណ៍ :

- គ្រួសារមួយជិះទូកកណ្តាលទន្លេ ពេលមានខ្យល់ព្យុះបោកលិចទូកនោះ ។ គេឃើញម្នាក់ៗខំប្រឹងហែលយកព្រះអាយុសតែរៀងៗខ្លួន ។

អាស្រ័យហេតុនេះហើយ បានជាលោកថាគ្មាននរណាម្នាក់ស្រលាញ់គេជាងស្រលាញ់ខ្លួនឡើយ បើមានឮថាក៏គ្រាន់តែជាអំនួត រឺបោកប្រាស់ប៉ុណ្ណោះ ៕

*ថ្ងៃទី ១៦-០៨-០៧*

# ៤០០. ស្វាងតឹង ស្រវឹងធូរ

**និយមន័យ**

ឥរិយាបថប្រែប្រួលនៃអ្នកផឹកស្រា

**អត្ថាធិប្បាយ**

អ្នកផងទាំងពួងតែងសម្គាល់ឃើញនូវឥរិយាបថអ្នកផឹកស្រាថា : អ្នកខ្លះផឹកកាច អ្នកខ្លះផឹកស្លូត ។

ពេលនេះលោកនិយាយពីអ្នកផឹកស្លូត គឺអ្នកស្រវឹងធូរ ។ មនុស្សប្រភេទនេះនៅធម្មតាធ្លាប់តែកាច បើមានអំនាចបន្តិចផង នរណាមើលមុខសឹងតែមិនបាន ។ តែលុះដល់បានទឹកអំនាចចូលពោះ បែរជាប្រែប្រួលឥរិយាបថអស់រលីង គឺទៅជាមនុស្សមានសភាពស្លូតបូត សុភាពរាបសារ ចង់អ្នកណាថាអ្វីក៏មិនតប.តវិញដែរ ។ ចំនែកប្រាក់កាសវិញក៏ហ៊ានប៉ាវគេស៊ីផឹកគគ្រឹកគគ្រេង ។ បើនៅក្នុងគ្រួសារវិញទោះបីប្រពន្ធ-កូនមាត់ឡូឡាក៏មិនខឹងឡើយ ។

ប៉ុន្តែគេសម្គាល់ឃើញម្យ៉ាងទៀតថា បើមនុស្សនេះរាងស្វាងស្រវឹងបន្តិចម្តង-បន្តិចម្តង កំនាចក៏ត្រឡប់មកវិញបន្តិចម្តង-បន្តិចម្តងដែរ ។ បើប្រពន្ធកូនចង់ពិភាក្សាការងារអ្វីក៏ពុំសូវចុះសម្រុងឡើយ ។ នេះគឺជាអត្តចរិតរបស់អ្នកផឹកខ្លះ ។

ហេតុនេះហើយទើបមានពាក្យថា: *ស្វាងតឹង ស្រវឹងធូរ ឬថា ខ្មោចចេញ ខ្មោចចូលក៏បាន* ៕

*ថ្ងៃទី ១៨-០៨-០៧*

# ៤០១. ស៊ីត្រង់ណា ជុះត្រង់នោះ

**និយមន័យ**

រស់នៅកន្លែងណាប្រព្រឹត្តអំពើលាមកកន្លែងនោះ

**អត្ថាធិប្បាយ**

នៅក្នុងសង្គមមនុស្ស តែងមានជនមួយចំនួនតូចដែលចូលចិត្តស៊ីត្រង់ណាជុះត្រង់នោះ ។ មនុស្សនេះបើ បានទៅស្នាក់អាស្រ័យស៊ីព្រោះលោះកម្លាំងនឹងសប្បុរសជនម្នាក់ណាហើយ ។ គេមិនដែលជួយយកអាសារអ្នកដែលមានឧបការគុណលើ ខ្លួន ឬធ្វើអំពើអ្វីដើម្បីតបស្នងសងគុណគេទេ ។ ផ្ទុយទៅវិញ គេប្រព្រឹត្តតែអំពើអសីលធម៌ អនាចារ នាំឱ្យអាប់ឱនកិត្តិយសអ្នកមានគុណទៅវិញ ។ គឺគេរស់នៅទីកន្លែងណា គេប្រព្រឹត្តអំពើលាមកកន្លែងនោះ ។ ដូចជា :

- នាយខ្វន បានទៅរស់នៅក្នុងភូមិមួយ ។ គេមិនដែលមានគំនិតជួយកសាង ឬវិភាគទានដើម្បីស្ថាបនា អ្វីដែលជាសម្បត្តិសារធារណៈទេ ។ ផ្ទុយទៅវិញ គេតែងលួចយកសម្ភារៈសាធារណៈទៅលក់យកកម្រៃផ្ទាល់ខ្លួន ។

- នាយខ្វិត បានទៅស្នាក់អាស្រ័យនឹងឪពុកមា ។ គេតែងព្យាយាមលួចសម្បត្តិទ្រព្យឪពុកមាទៅលក់ ជួនកាលប្លន់មាឯងទៀតផង ។ ជួនកាលទៀតហ៊ានលូកលាន់កូនក្រមុំមាឯងដែលត្រូវជាប្អូនជីដូនមួយថែមទៀតផង

មនុស្សដែលរស់នៅកន្លែងណាប្រព្រឹត្តអំពើលាមកកន្លែងនោះ *គឺជាមនុស្សស៊ីត្រង់ណាជុះត្រង់នោះ រឺជាមនុស្សស៊ីបាយបោកឆ្នាំង* ៕

*ថ្ងៃទី ១៨-០៨-០៧*

# ៤០២. ស្វាស៊ីបាយ លាបមាត់ពពែ

**និយមន័យ**

ជនកំហូចយកកំហុសខ្លួនឯងទំលាក់ឱ្យគេ

**អត្ថាធិប្បាយ**

ជនទុយិសខ្លះ ដើម្បីលុបលាងនូវទោសកំហុសរបស់ខ្លួនដែលបានប្រព្រឹត្តពុំសមរម្យ យកទៅទម្លាក់ដាក់ឱ្យអ្នកដទៃដែលគ្មានដឹងអ្វីបន្តិចសោះ ។ ដូចជាមានអ្នកនយោបាយខ្លះដែលមានកំហុសខ្លួនឯង ភ័យខ្លាចក្រែងមានទោសដល់ខ្លួន ក៏ក្លែងរកល្បិចកលយកកំហុសនេះទៅទម្លាក់ឱ្យគេ ។

សមប្រកបនឹងករណីនេះ មានអ្នកធំម្នាក់មានកញ្ចប់គ្រឿងញៀនដែលមិនអាចរំដោះចេញបាន ក៏ប្រើល្បិចឱ្យសហការីជំនិតម្នាក់ យកកញ្ចប់នេះទៅដាក់នៅកន្លែងធ្វើការរបស់អ្នកណាម្នាក់ដែលខ្លួនស្អប់ រួចក៏ក្លែងទៅធ្វើជាចាប់គេ ។

ទាក់ទងនឹងន័យខាងលើនេះ លោកបានលើកជារឿងល្បើកមួយដូចតទៅ :

ថ្ងៃមួយមានបុរសម្នាក់បានដឹកពពែមួយក្បាលទៅតាមខ្លួន។ លុះបានទៅដល់ទីវាលស្មៅ និងទឹកហើយ បុរសនោះក៏ដោះលែងពពែឱ្យស៊ីស្មៅ ។ ឯខ្លួនឯងក៏ប្រះខ្លួនដេកលក់ក្រោមដើមឈើធំទៅ ។ ពេលនោះ សត្វស្វាមួយដែលនៅលើដើមឈើនោះក៏បានចុះមកស្រាយបង្វិចបាយហើយស៊ីយ៉ាងឆ្អែត ។ ពេលស៊ីរួចស្វាក៏យកដៃដែលប្រលាក់ បាយទៅជូតមាត់ពពែដែលជាសត្វស្លូត រួចក៏ឡើងទៅលើដើមឈើបាត់ទៅ ។

ឯបុរសនោះពេលភ្ញាក់ឡើងក៏នឹកឃ្លានបាយ ស្រាប់តែឃើញបាយជ្រុះរាត់រាយ បាយក៏អស់ត្រីអាំងក៏ម៉ដ្ត ក៏នឹកខឹងជាខ្លាំង ។ លុះងាកទៅឃើញមាត់ពពែសុទ្ធតែបាយក៏សម្គាល់ថា សត្វពពែចង្រៃនេះហើយស៊ីបាយអញ ។ បុរសឆោតល្ងង់នោះក៏យកដំបងមកសំពងពពែស្លូតត្រង់យ៉ាងធ្ងន់ដៃ ។

ល្បើកនិទាននេះបញ្ជាក់ឱ្យឃើញថា មនុស្សស្លូតត្រង់តែងរងនូវអំពើមួលបង្កាច់ពីមនុស្សកំហូចដែលនាំឱ្យមានគ្រោះថ្នាក់ដោយឥតដឹងខ្លួន ។ ករណីនេះសមដូចពាក្យបុរាណមួយឃ្លាពោលថា : *ស្លូតស្លាប់ វៀចវេរមានភព្វអាយុយឺនយូរ* ៕

*ថ្ងៃទី ១៩-០៨-០៧*

✿✿✿✿



# ៤០៣. ស្លាប់ក្រោមកន្ទុយក្បិន

**និយមន័យ**

ប្រុសដែលឈានពីក្រោយគូទស្រ្តី

**អត្ថាធិប្បាយ**

ពាក្យថា "**កន្ទុយក្បិន**" លោកសំដៅយកផ្លូវភេទស្រ្តី ។

ពាក្យទំនឹមទំន្មៀមនេះ ជាពាក្យបន្តុះបង្អាប់មនុស្សប្រុសដែលមុជមិនជ្រៅ ទៅមិនឆ្ងាយពីប្រពន្ធ ។ គឺ ប្រុសដែលយល់ព្រមឱ្យប្រពន្ធធ្វើមេបញ្ជាការប្រចាំគ្រួសារ ។ ប្រុសប្រភេទនេះខ្លាចប្រពន្ធណាស់ បើប្រពន្ធប្រើឱ្យធ្វើអ្វី ទោះបីធ្ងន់យ៉ាងណាក៏ដោយ គឺតែធ្វើតាមបញ្ជាទាំងអស់ ។ ជួនកាលប្រពន្ធប្រើឱ្យទៅឈ្លោះនឹងគេៗក៏ទៅដែរ ដោយឥតមានគិតគូរអ្វីឡើយ ។ ឱ្យតែប្រពន្ធប្រើ គេហាក់ដូចជាគ្មានខ្លាចយក្សមារអ្វីសោះទេ ។ គេខ្លាចតែម្យ៉ាងគត់ គឺខ្លាចប្រពន្ធ "*កាត់របប*" តែមួយប៉ុណ្ណោះ ។

រួមសេចក្តីមកថា គេសុខចិត្តបូជាអ្វីៗទាំងអស់ដើម្បីបុព្វហេតុ "*របបប្រពន្ធ*" ។

*ថ្ងៃទី ២១-០៨-០៧*

❁❁❁❁

# ៤០៤. ស្រីមាយា១០០ជំពូក

**និយមន័យ**

កលល្បិចស្ត្រីមានច្រើនបែប, ច្រើនយ៉ាងណាស់

**អត្ថាធិប្បាយ**

ពាក្យពេចន៍នេះ ពុំមែនមានន័យថា ជាការបន្តុះបង្អាប់ រឺរើសអើងចំពោះស្ត្រីភេទទេ ។ គឺលោកចង់និយាយ យោងទៅតាមសត្យានុមតិ ដែលពិតជាក់ស្តែងក្នុងសង្គមប៉ុណ្ណោះ ។

ស្រីសម្បូរណ៍ល្បិចកិច្ចកលច្រើនលក្ខណៈណាស់ ហើយសុទ្ធតែសម១ និងមានទំនងល្អទៀតផង ។ ល្បិចកិច្ចកលអស់ទាំងនេះមានប្រសិទ្ធភាពជាទីបំផុត ពេលដែលស្ត្រីប្រើទៅលើបុរស ជួនគេសម្តែងចេញតាមមាយា ជួនតាមភាពម៉ឹងម៉ាត់ ជួនតាមភាពទន់ភ្លន់តំអែរតំអូញឱ្យស្លាប់ចិត្ត ។ល ។ បានសេចក្តីថា ល្បិចអ្វីក៏ដោយក្រែងតែស្ត្រីមិនចង់ធ្វើ ។ បើគេចង់ធ្វើវិញសុទ្ធសឹងមានប្រសិទ្ធិភាព និងសម្រេចបំណងទាំងអស់ ។ ដូចជា :

- ភរិយាម្នាក់ រកល្បិចកលទៅជួបសហាយ ប្រាប់ប្តីថាទៅទិញអាវពេលត្រលប់មកវិញយកអាវមួយមកបង្ហាញប្តី-ចប់ ។

- ប្រពន្ធម្នាក់ យកប្រុសកំណាន់ចិត្តមកនៅផ្ទះជាមួយ ។ គេប្រាប់ប្តីថាបងប្អូន

មកស្នាក់នៅមួយរយៈតូច ពេលឱកាសសមស្របនាំគ្នាចូលបន្ទប់យ៉ាងសុខសាន្ត ។ លុះមានផ្ទៃពោះឆ្លើយដាក់ប្ដី ។

- ប្រពន្ធខ្លះទៀតពេលប្ដីចេញទៅធ្វើការបាត់ គេក៏ចេញទៅតាមក្រោយ ។ មុនពេលប្ដីត្រលប់មកដល់ផ្ទះវិញ ។ គេមកដល់ផ្ទះចំអិនអាហារធ្វើមិនដឹង ។ លោកប្ដីសរសើរថា ប្រពន្ធអញមិនចេះដើរទៅណាផ្ដេសផ្ដាសទេ ឃើញនៅតែផ្ទះ ។

- ប្រពន្ធខ្លះពេលប្ដីនៅផ្ទះក៏ដោយ គេឃ្លូរកន្ត្រកទៅផ្សារ ។ ឆក់ឱកាសយ៉ាងរហ័នេះ គេជួបគូស្នេហ៍យ៉ាងសុវត្ថិភាព ។

- ប្រពន្ធម្នាក់មានប្ដីកាចចង់ដើរទៅណាក៏ពុំបាន តែប្រពន្ធមានឥរិយាបថស្រគត់ស្រគំណាស់ ទាល់តែប្ដីទុកចិត្តថា ប្រពន្ធអញជាស្ត្រីមេផ្ទះគំរូ ។ *ប៉ុន្តែដឹងអីនឹងលើរង្កើក្រោមសោះ* ។

- ប្រពន្ធម្នាក់ត្រូវស្មុនពេលដោយជួបគ្នាយូរពេក ។ ពេលត្រលប់មកដល់ផ្ទះ គេក៏លើកកញ្ចប់នំបង្ហាញប្ដីថា បងអើយថ្ងៃមុន អូនឮថាបងចង់ញ៉ាំនំគម ។ អូនទៅផ្សារខំដើររកទិញទំរាំបានយកមកផ្ញើបង អីចឹងហើយបានជារាងយឺតពេលបន្តិច ។ ឯលោកប្ដីវិញឆ្លើយថា មិនអីទេអូន ។ គេសប្បាយចិត្តណាស់ដោយឃើញប្រពន្ធយកចិត្តទុកដាក់នឹងខ្លួន ខំប្រឹងសរសើរប្រពន្ធថាចិត្តបាន រួចក៏ពមនំគមយ៉ាងស្អិត-ក ទោះជានំគមនោះរាងផ្អូមបន្តិចក៏ឆ្ងាញ់ដែរ ។

ម្យ៉ាងដែរ នំគមឯងឱ្យគេស៊ី នំគមផ្សារឱ្យប្ដីហូប ។

ការលើកមកប៉ុណ្ណេះគ្រាន់តែជាឧទាហរណ៍យ៉ាងតិចតួចបំផុត ៕

*ថ្ងៃទី ២២-០៨-០៧*

❀❀❀❀

# ៤០៥. ស្រីមាយាដកខ្ទី

**និយមន័យ**

ស្រីដែលមានពុតត្បុត និងមានកលល្បិចខ្ពស់

**អត្ថាធិប្បាយ**

ពាក្យទំនឹមទំនៀមនេះ សម្រាប់ដេរ ឬបន្ទុះបង្អាប់ស្រីណាដែលមានពុតត្បុត និងកលមាយាយ៉ាងប៉ិនប្រសប់ ។ ដោយសារស្រីនោះចេះរកមធ្យោបាយយ៉ាងសមស្រប មិនងាយចាប់ផ្ទាក់បាន ។

ទាក់ទងនឹងន័យខាងលើនេះ លោកបានលើកល្បើកមកនិទានដូចតទៅ :

ប្រពន្ធចើកម្នាក់ លួចសហាយនឹងអន្ទិតម្នាក់ ។ ពេលយប់ប្រុសនោះតែងមកពួនត្រង់គុម្ពខ្ទី រួចអង្រួនដើមខ្ទីជាសញ្ញា ។ ស្រីចើកនោះដឹងក៏ចុះទៅជួបគ្នាដោយយកលេសថា ទៅដកខ្ទី ។ ពេលឡើងមកលើផ្ទះវិញ ប្តីសួរថា ហេតុអ្វីក៏ខ្នងឯងប្រលាក់សុទ្ធតែដី ។ ស្រីចើកឆ្លើយថា អ្នកអើយ! បើអ្នកបានឃើញផងប្រហែលសើចរហែកមាត់មិនខានទេ ។ គឺខ្ញុំប្រឹងដកខ្ទីខ្លាំងពេក របើកទាំងឬស ដួលខ្ញុំដាច់ផ្ងារទៅក្រោយ បើអ្នកមិនជឿមើលខ្នងខ្ញុំប្រលាក់សុទ្ធតែដី ។ ប្តីជឿក៏នៅស្ងៀម ។

យប់មួយប្តីប្រាប់ថា ឯងកុំទៅណាចាំខ្ញុំផ្លុំបទអុំទូកឱ្យស្តាប់ ។ គាប់ជួនពេលនោះ ប្រុសសហាយក៏ទៅដល់ធ្វើសញ្ញាដូចមុន ។ ស្រីចើកដឹងក៏សួរទៅប្តីថា អ្នកផ្លុំខ្លុយ

រាល់ថ្ងៃមានមើលរន្ធទេ ។ ប្ដីថាអត់ទេ ។ ប្រពន្ធថា ដើម្បីឱ្យខ្ញុំជឿផង ខ្ញុំសូមបិទភ្នែកអ្នក ។ ប្រពន្ធក៏បិទភ្នែកប្ដីទាំងពីរ រួចក៏ដេកកើយភ្លៅប្ដីកន្ទេកជើងទាំងពីរប្រហែល ៩០ អង្សា ។ ប្រុសសហាយយល់សញ្ញាក៏ឡើងទៅរួមរ័ក ។ ប្ដីសួរថា ឯងញាក់អីក៏ខ្លាំងម្ល៉េះ? ។ ប្រពន្ធឆ្លើយថា ញាក់តាមសង្វាក់ភ្លេងអ្នកឯង ព្រោះយប់នេះអ្នកឯងផ្លុំបានពិរោះល្អណាស់ ។ ប្ដីថា អូហ៎មកពីឯងជួយបន្ទរផង...

ស្រីចេកនេះ ចេះរកលេសមកដោះស្រាយឱ្យសមស្របទៅនឹងអ្វីដែលមានជាក់ស្ដែងបែបនេះ លោកហៅថា *ស្រីមាយាដកខ្វី* ៕

*ថ្ងៃទី ២២-០៨-០៧*

❀❀❀❀



# ៤០៦. ស្រូវក្នុងជង្រុក ប្រហុកក្នុងពាង

**និយមន័យ**

ការត្រៀមរបបអាហារប្រចាំគ្រួសារ

## អត្ថាធិប្បាយ

បុព្វបុរសខ្មែរតាំងពីសម័យដើមមកតែងទូន្មានកូន-ចៅគ្រប់គ្នាឱ្យប្រុងប្រៀបទប់ទល់នឹងកង្វះខាតដែលកើតឡើងជាយថាហេតុ ។

ព្រោះសម័យកាលមុន ស្រុកទេសពុំសូវមានសន្តិភាពប៉ុន្មានទេ ព្រមទាំងជួបប្រទះនឹងគ្រោះមហន្តរាយ ធម្មជាតិមានទឹកជំនន់ជាដើម ។ កាលណាមានទឹកជំនន់ធំ ការងារកសិកម្មក៏ត្រូវវិនាសហិនហោចអស់ ម្ល៉ោះហើយភាពទុរភិក្សក៏កើតមានឡើង ។

អាស្រ័យហេតុនេះហើយ បានជាលោកទូន្មានឱ្យមានស្បៀងបម្រុងប្រចាំគ្រួសារ ។ ព្រោះថា បើគេធ្វើកសិកម្មមិនបានផលមួយរដូវក៏នៅតែមាន ស្បៀងសម្រាប់ផ្គត់ផ្គង់ក្រុមគ្រួសារបានដែរ ។ គឺគេត្រូវឱ្យមានស្រូវក្នុងជង្រុកជាប់ជាប្រចាំ ។ ប៉ុន្តែបើមានតែបាយ អត់ម្ហូបក៏ទៅមិនរួចដែរ ។ ដូច្នេះ លោកឱ្យត្រៀមម្ហូបទៀត ។ ឯម្ហូបដែលទុកបានយូរហើយថោកទៀតនោះ គឺប្រហុក ។ លោកចង់និយាយថា បើអត់មានអ្វីសោះក៏ចាំបាច់ត្រូវតែមានប្រហុក ត្រៀមទុកជាប្រចាំដែរ ។ ព្រោះកាលគេរកត្រីពុំបានច្បាស់ជាគ្មានអ្វីវិសេសវិសាលជាងប្រហ៊ីងក្នុងប៉ុក ប្រហុកក្នុងពាងទេ ។ ព្រោះគេអាចចិញ្ច្រាំផ្សំគ្រឿងនាយអាយដាក់ចំហុយទៅ ។ ឯអន្លក់មានត្រកួន ព្រលិតក៏មិនខ្វះដែរ តែប្រសិនបើខ្វះត្រយ៉ូងចេកចេញផ្លែមិនទាន់អស់ កាច់សិនក៏បាន ៕

*ថ្ងៃទី ២២-០៨-០៧*

# ៤០៧. ស្លាប់ទៅបិទភ្នែកមិនជិត

**និយមន័យ**

មនុស្សស្លាប់ទៅ តែនៅមានកង្វល់

**អត្ថាធិប្បាយ**

ពាក្យទំនឹមទំនៀម ជាពំនោលរបស់ចាស់តាំងពីបុរាណកាលយូរយារមកហើយ គឺលោកចង់ពោលសំដៅទៅដល់មនុស្សណាដែលដល់ពេលជិតស្លាប់ ។ ប៉ុន្តែនៅមានកង្វល់រឿងអ្វីមួយដែលពុំទាន់បានដោះស្រាយរួចនៅឡើយ ដូចជា :

- អ្នកខ្លះមានគេជំពាក់លុយច្រើន តែគេនៅមិនទាន់បានសងអស់ ។
- អ្នកខ្លះធ្វើផ្ទះសំបែងទុកឱ្យកូនចៅនៅមិនទាន់រួចរាល់ ។
- អ្នកខ្លះ នៅមិនទាន់បានរៀបចំទុកដាក់កូនឱ្យមានគ្រួសារ ជាពិសេសគឺកូនស្រីពៅ ។
- អ្នកខ្លះ មានកូនកំពុងឈ្លោះប្រកែកគ្នាដណ្តើមកេរមតិកមានដីធ្លី និងស្រែចំការជាដើម ។
- អ្នកខ្លះ នៅនឹកស្តាយប្រពន្ធកំពុងពេញស្រលាញ់.... ។ល ។......

អ្នកដែលមានវិបត្តិផ្លូវចិត្ត ដូចបានពោល មកខាងលើនេះ នៅពេលឈឺ ដែលពុំមានសង្ឃឹមថា "*រស់*" តែងត្អូញត្អែរប្រាប់គេថា : "ខ្ញុំស្លាប់ទៅបិទភ្នែកមិនជិតទេ ព្រោះនៅមិនទាន់បានដោះស្រាយបញ្ហាក្នុងគ្រួសាររួចរាល់.."

ប៉ុន្តែតាមការណ៍ពិត ពុំប្រាកដជាបិទជិត ឬមិនជិតនោះទេ ។ ព្រោះគេសង្កេតឃើញមានអ្នកខ្លះគ្មានរឿងរ៉ាវគួរឱ្យព្រួយកង្វល់អ្វីផង ស្រាប់តែពេលស្លាប់គេឃើញបើកភ្នែកក្រលោតហាក់ដូចជាខំប្រឹងមើលគេ តើអ្នកណាមកខ្លះ? ។ កាលបើជួបរិការដ្ឋានបែបនេះ មានអ្នកខ្លះបកស្រាយថា : បានជាដូច្នេះ មកពីគាត់នៅនឹកស្ដាយទ្រព្យសម្បត្តិ មាសប្រាក់ជាច្រើនដែលគាត់ខំសន្សំមិនហ៊ានស៊ីចាយ មិនហ៊ានធ្វើបុណ្យ ។ល ។ ម្យ៉ាងទៀតគាត់នៅមានវិប្បដិសារី ព្រោះទ្រព្យធនទាំងអស់នេះសុទ្ធ តែបានមកពីអំពើទុច្ចរិតមានលួចជាតិ និងស៊ីសំនូកជាដើម ។

មានអ្នកខ្លះទៀត គ្រួសារមានវិបត្តិចំរូងចំរាស់ពេញផ្ទះតែពេលស្លាប់គេឃើញបិទភ្នែកស្លាប់យ៉ាងជិតធ្វើព្រងើយ ។

ឯអ្នកបកស្រាយ ក៏បកថា : ខ្មោចនេះគ្មានគិតកូនចៅណាទាំងអស់ គឺគេស្លាប់ទៅបិទភ្នែកយ៉ាងជិតសម្ងំយកសុខម្នាក់ឯងគ្មានជំពាក់អ្នកណាមួយរៀល ។

រីឯការណ៍ពិតប្រាកដមែនទែនថាជាយ៉ាងណានោះ ស្រេចលើការវិនិច្ឆ័យយល់ចូលចិត្តរបស់អ្នកសិក្សាទៅចុះ ។

យើងគ្រាន់តែបកស្រាយន័យទៅតាមពំនោលរបស់អ្នកចាស់បុរាណប៉ុណ្ណោះ ៕

*ថ្ងៃទី ១៦-០៧-១០*

❀❀❀❀

# ៤០៨. ស្រីក្ងោកមាស

**និយមន័យ**

ស្រីដែលមានកាមារម្មណ៍ឥតល្ហែ

**អត្ថាធិប្បាយ**

ពាក្យទំនឹមទំនៀមនេះ លោកធ្វើបំរៀបធៀបស្រីអាសទៅនឹងសត្វក្ងោកញី ។ សត្វក្ងោកញីមានស្លាបកន្ទុយវែង ប្រកបដោយក្រលាមូល១ៗរំលេចពណ៌ចំរុះដូចគំនូរ ។ ក្ងោកញីនេះ កាលណាឃើញឈ្មោលវាតែងលាតត្រដាងស្លាបកន្ទុយបង្អួតឈ្មោល ដើម្បីទាក់ទាញឈ្មោលឱ្យមកបន្តពូជ ។

ហេតុនេះហើយ បានជាលោកធ្វើបំរៀបធៀបចំពោះស្រីអាសដែលមានការភ្លើតភ្លើនក្នុងកាមតណ្ហា គឺត្រេកត្រអាលតែក្នុងរសផ្លូវភេទមិនស្កប់ស្កល់ ។

ស្រីប្រភេទនេះ មិនញញើត ហើយក៏មិនរុញរាក្នុងការផិតក្បត់ និងរត់ចោលប្ដីចោលកូនទេ ។ គេតែងបណ្ដោយខ្លួនឱ្យកាមទេព ឬកាមតណ្ហាដឹកមុខដោយសេរី គេពុំសូវបានគិតទៅដល់ប្រពៃណីទំនៀមទំលាប់អ្វីសោះ ។ គេពុំខ្វល់នឹងអ្នកណាសើចចំអករិះគន់ពីចរិតរបស់គេឡើយ ។

ដោយលក្ខណៈឥតអៀនខ្មាស និងស្រើបស្រាលបែបនេះហើយបានជាលោកយកពាក្យថាស្រីភ្ជាប់នឹងសត្វក្ងោកញី ។ ឯពាក្យថា **មាស** ក្នុងទីនេះលោកឱ្យន័យថា ស្រីដែលត្រេកត្រអាលនឹងប្រុស១ៗដូចពាក្យថា **ស្រីផ្កាមាស** ដូច្នោះដែរ ៕

*ថ្ងៃទី ០៣-១០-០៩*

# ៤០៩. ស្លាប់ទាំងរស់ ស្អុយទាំងស្រស់

**និយមន័យ**

មនុស្សបំពៃលោក និង មនុស្សប្រព្រឹត្តអំពើលាមកទុកដូចជា គម្រង់ ខ្មោច

**អត្ថាធិប្បាយ**

**□ ស្លាប់ទាំងរស់**

លោកអគ្គបណ្ឌិត **ម៉ុត សារឧទ្យ** បានបង្កើតពាក្យនេះឡើងក្នុងគោលបំនងថា : មនុស្សខ្លះពិតមែនតែរស់នៅជ្រងោ ។ ប៉ុន្តែគ្មានបានបំពេញអំពើជាកុសល ជាសារធារណៈអ្វីបន្តិចសោះឡើយ ។ គឺជាមនុស្សគ្មានប្រយោជន៍ដល់សង្គមជាតិ រឺសហគមន៍ផ្សេងៗសោះ ។ ពោលគឺមនុស្សប្រភេទនេះបើទោះបីគេរស់នៅក្នុងត្រកូលអភិជនបរិបូរដោយភោគទ្រព្យយ៉ាងណាក៏ដោយ ក៏គេគ្មានសទ្ធាជ្រះថ្លាបរិច្ចាគដើម្បីកសាងសមិទ្ធផលនានាមាន : ផ្លូវ, ស្ពាន, សាលារៀន, មណ្ឌលសុខភាព រឺបំពេញកុសលក្នុងសាសនា មានកសាងកុដិ, សាលា, ព្រះវិហារជាដើមឡើយ ។

មនុស្សប្រភេទនេះ បើទោះជារស់នៅអស់កាលដ៏យូរក្នុងលោកនេះ ក៏គ្មានន័យអ្វីដែរ ។ គឺគេទុកដូចជា ស្លាប់ទាំងនៅពេលកំពុងមានដង្ហើមចេញចូលអ៊ីចឹង ។សមដូចព្រះពុទ្ធតម្រាស់ថា: " **ន សិយា លោកវឌ្ឍនោ** "

"ចូរកុំធ្វើខ្លួនឱ្យទៅជាមនុស្សបំពៃលោក"

មានន័យថា ៖ កុំប្រព្រឹត្តអំពើអាក្រក់ ហួសហេតុ ប្រហែលនឹងព្រៃបន្លាស្អុក រឺដូចចម្រូង ដង្កត់ ឱ្យគេទើសមុខទើសក្រោយ ។

## ❒ ស្អុយទាំងស្រស់

ធម្មតាអ្វីក៏ដោយ កាលណានៅស្រស់មិនដែលធុំក្លិនស្អុយទេ ។ ប៉ុន្តែពេលនេះលោកថា ស្អុយទាំងនៅស្រស់តែម្តង ។ គឺលោកសំដៅដល់មនុស្សខ្លះកំពុងរស់នៅយ៉ាងស្រស់សង្ហា ។ ប៉ុន្តែគេមានកេរ្តិ៍ឈ្មោះស្អុយគគ្រុក ធុំក្លិនអសោចិដូចខ្មោច កំពុងហើមចេញទឹកខ្ទុះឈាម រុយរោម ដង្កូវចុះ ។ ព្រោះតែគេជាជនពុករលួយ បំផ្លិចបំផ្លាញជាតិ ។ល។

មួយវិញទៀត មានបុគ្គលខ្លះលះបង់ភេទគ្រហស្ថទៅបួសជាសង្ឃ ។ តែគេគ្រាន់តែបួសកោរសក់កុហកព្រះ រឺបោកព្រះតែប៉ុណ្ណោះ ។ ព្រោះគេឥតមានប្រតិបត្តិតាមធម៌វិន័យរបស់ព្រះអនាវរណញ្ញាណទេ ។ គឺគេបួសគ្រាន់តែយកទង់ជ័យព្រះអរហន្តមករុំខ្លួន ដើម្បីស្វែងរកលាភសក្ការៈ ដូចជា ធ្វើគាថាយន្ត មន្តកន្សែងស្នេហ៍ ខ្សែ-កខ្សែដៃ និងស្រោចទឹកឱ្យក្រមុំៗ ដែលជាពិធីក្នុងព្រហ្មញ្ញសាសនា ប្រាសចាកធម៌វិន័យក្នុងព្រះពុទ្ធសាសនាទាំងស្រុង ។

នៅមានសង្ឃអលជ្ជីខ្លះទៀត ដើរថតការស្បែតចំរៀងនិងកាស្សែតអាសអាភាស ។

បុគ្គលប្រភេទខាងលើនេះហើយ ដែលលោកអត្ថបណ្ឌិតពោលថា ជា *មនុស្សស្លាប់ទាំងរស់ ស្អុយទាំងស្រស់* ។

*ថ្ងៃទី ២៨-១១-០៩*

## ហ

# ៤១០. ហាលេបស្លាក់ ហាខ្ជាក់ស្លែង

**និយមន័យ**

ស្ទៀមមិននិយាយក៏មិនបាន និយាយចេញក៏មិនកើត

**អត្ថាធិប្បាយ**

**▢ អត្ថានុរូប**

**- ហាលេបស្លាក់**

អត្ថន័យនេះ លោកនិយាយថា ហាមាត់លេបចូលទៅមិនបាន ។ ព្រោះវាត្រូវស្លាក់ខ្ទាស់ជាប់បំពង-ក ដូចជា ស្លាក់ឆ្អឹងត្រី រឺឆ្អឹងមាន់ជាដើម ។

**- ហាខ្ជាក់ស្លែង**

ន័យនេះ លោកនិយាយថា បើខ្ជាក់របស់នៅក្នុងមាត់ចេញមកក្រៅក៏មិនកើត ព្រោះវាស្លែងពេកនាំឱ្យគេ គ្រប់គ្នាខ្ពើមរអើម ។

**▢ អត្ថប្បដិរូប**

**- ហាលេបស្លាក់**

ខ្លឹមសារនេះ លោកសំដៅយកនូវរឿងរ៉ាវទាំងឡាយណាដែលដឹងហើយតែនិយាយមិនបាន គឺត្រូវលេបរឿងហ្នឹងទុកក្នុងពោះ ។ ប៉ុន្តែ បើប្រឹងលេបទុកក៏នាំឱ្យចុកចាប់ រឺតឹងចិត្ត រឺក៏ត្រូវបែកទ្រូងស្លាប់ ។ ដូចជា ៖

កាលដើមទសវត្សរ៍ឆ្នាំ ១៩៦០ នៅទីក្រុងតាខ្មៅ មានភរិយាក្មេងម្នាក់មានរូបសម្បទ័ស្រស់ត្រកាល បានធ្វើអត្តឃាតដោយលោតពីលើផ្ទះកំពស់ពីរជាន់ ។ មូលហេតុដែលនាំឱ្យមានករណីនេះឡើង ដោយសារតែដឹងរឿងពិតប្រាកដហើយ តែនិយាយមិនចេញ ក៏ចេះតែប្រឹងលេបទុក គឺទុកទាល់តែបែកទ្រូងស្លាប់ ។ រឿងនេះបណ្ដាល មកពីគេឆក់យកស្វាមីជាទីស្រលាញ់របស់ខ្លួន ។ ឯស្រីអាសដែលឆក់យកស្វាមីរបស់នាង គឺជាម្ដាយបង្កើតរបស់នាងតែម្ដង ។

- **ហាខ្ទាក់ស្ទែង**

ខ្លឹមសារនេះ លោកសំដៅយករឿងទាំងឡាយណាដែលដឹងឮច្បាស់ហើយ បើនឹងនៅស្ងៀមមិននិយាយស្ដីក៏ពុំកើត ។ ដូច្នេះត្រូវតែនិយាយចេញឱ្យគេដឹងឮផង ។ ប៉ុន្តែ ពេលនិយាយចេញទៅវាស្ទែងពេក គឺដូចជាអាសអាភាសហួស ឬដូចជាអាក្រក់អាក្រីពេក ស្រគៀវត្រចៀកពេក ។ ម្យ៉ាងទៀត បើនិយាយចេញទៅហើយក៏នាំឱ្យមានបញ្ហា ឬមានប្រតិកម្មពីជនណាម្នាក់ជាហេតុនាំឱ្យមានទុក្ខទោសដល់ខ្លួន ដូចករណី ខាងលើនេះជាដើម ។ ន័យនេះហើយដែលលោកថា : *ពាក្យពិតវែងស្ទែងពុំពិរោះ ថា...* ៕

*ថ្ងៃទី ២៣-០៨-០៧*

# ៤១១. ហុតទឹកសម្លឹងកាក ទាញច្រវាខ្វាកសម្លឹងត្រើយ

**និយមន័យ**

ចាប់ធ្វើអ្វីមួយ ចិត្តរំពឹងគិតដល់ផលប្រយោជន៍ និងគោលដៅទៅថ្ងៃក្រោយ

**អត្ថាធិប្បាយ**

**✳ អត្ថានុរូប**

**- ហុតទឹកសំលឹងកាក**

ក្នុងន័យខាងលើនេះ អ្នកបរិភោគបាយ ពេលហុតទឹកសំល, ភ្នែកគេតែងរំពៃសំលឹងមើលសាច់ ។ ពេលដែលគេហុតទឹកសំលរួចហើយ គេនឹងចាប់យកដុំសាច់នោះមកបរិភោគទៀត ។

**- ទាញច្រវាខ្វាក សំលឹងត្រើយ**

រីឯអ្នកធ្វើដំណើរឆ្លងកាត់តាមផ្លូវទឹក ពេលឡើងលើទូក, គេតែងទាញច្រវាមកអុំភ្លាមដែរ ។ ពេលទាញច្រវា ភ្នែកគេសំលឹងមើលទៅត្រើយម្ខាងដែលជាគោលដៅ ។

**✳ អត្ថប្បដិរូប**

ពាក្យថា : *ហុតទឹកសំលឹងកាក* លោកពោលយកន័យបែបជាបុគ្គលាទិដ្ឋាន (បុគ្គលអ្នកសំរេចនូវអំពើ) ថា : បុគ្គលខ្លះធ្វើអ្វីនិមួយ សុទ្ធតែសំលឹងឃើញប្រយោជន៍

ទៅថ្ងៃក្រោយទើបធ្វើ ។ បើគេចំនាយលុយទៅលើអ្នកណាម្នាក់ រឺទៅលើអ្វីមួយ ក៏សុទ្ធតែសំលឹងឃើញផលប្រយោជន៍រួចហើយ, ប្រៀបដូចអ្នកសន្ទូច មុននឹងបិទនុយ គេសំលឹងឃើញផលគឺ " ត្រី " រួចជាស្រេច ។ ម្យ៉ាងទៀតតួយ៉ាងដូចជា :

- បុរសពោះម៉ាយម្នាក់ ឧស្សាហ៍ទិញនំ, ចំនី រឺបាយឡុកបាយឡទៅឱ្យកូនតូចម្នាក់របស់អ្នកមេម៉ាយក្មេងខ្ចី ។ នេះក៏ព្រោះតែ គេសំលឹងឃើញម្ដាយរបស់ក្មេងនោះឯង ។

- យុវជនម្នាក់ពេលឃើញទូកលិច គេប្រញាប់ប្រញាល់យកពោងទៅជួយសង្គ្រោះនារីម្នាក់ ព្រោះតែគេគិតថា យ៉ាងហោចណាស់ក៏បានត្រកងនាងនោះដែរ ។

- និយោជិតម្នាក់ ឧស្សាហ៍ចូលទៅផ្គាប់ផ្គុននិយោជករបស់ខ្លួន, ក៏ព្រោះតែគេចង់បានមុខងារអ្វីមួយទៀតក្នុងរោងចក្រនោះ ។

រាល់សកម្មភាពអ្វីក៏ដោយ ឱ្យតែធ្វើទៅ ហើយមានចិត្តសំលឹងរំពៃទៅរកផលប្រយោជន៍ទៅថ្ងៃក្រោយលោកហៅថា : " *ហុតទឹកសំលឹងកាក, ទាញច្រវាខ្វាកសំលឹងត្រើយ* " ទាំងអស់ ៕

*ថ្ងៃទី ២៤-០៨-០៧*

✿✿✿✿

# ៤១២. ហីនយសព្រោះព្រហើន

**និយមន័យ**

បាត់បង់កិត្តិយស ព្រោះគ្មានសីលធម៌

**អត្ថាធិប្បាយ**

"**យស**" មានន័យថា : អានុភាព, ឥស្សរភាព, បរិវារ, ទ្រព្យធន, កេរ្តិ៍ឈ្មោះល្អ, សេចក្តីថ្លៃថ្នូរ ។

ដូច្នេះអ្នកដែលមាន " **យស** " គឺមានភាពថ្លៃថ្នូរ និងមានគេគោរពស្រលាញ់រាប់អានច្រើន ។ ព្រោះថាអ្នកដែលមានកេរ្តិ៍ឈ្មោះល្អ មានឫកពាថ្លៃថ្នូរសមរម្យ ទោះទៅទីណាក៏ជាទីនិយមចូលចិត្តពីសំនាក់អ្នកផងទាំងពួង គឺទាំងអ្នកតូចទាំងអ្នកធំគ្រប់គ្នា ។

ប៉ុន្តែ បើអ្នកមាន "**យស**" ហើយមិនចេះថែរក្សា "**យស**" នេះឱ្យនៅគង់វង ឈ្មោះថាបាត់បង់នូវ "**កិត្តិយស**" និងបាត់បង់នូវសេចក្តីថ្លៃថ្នូរអស់រលីង ។ ទោះបីអ្នកនោះមានទ្រព្យធនច្រើនដល់ម្ល៉ាក៏ដោយ ។ យស នេះមិនទាក់ ទងនឹងបុណ្យសក្តិទេ ។

ការបាត់បង់យសនេះ ក៏ព្រោះតែអំពើអសីលធម៌ គ្មានស្គាល់គុណទោស គ្មានស្គាល់ខ្ពស់ទាប គ្មានស្គាល់សម និង គួរដែលលោកហៅថា មនុស្សព្រហើនប្រកាន់នូវអស្មិមានះ ។

កាលណាមនុស្សមានភាពក្រអឺតក្រទមបែបនេះហើយ តែងទទួលនូវសំអប់ពីមហាជនគ្រប់ទិសទី ៕

*ថ្ងៃទី ២៥-០៨-០៧*

# ៤១៣. ហុចអំបោះស្រនោះដៃ

**និយមន័យ**

ការធ្វើទានដែលមិនជ្រះស្រលះពីសន្តានចិត្ត

## អត្ថាធិប្បាយ

រាល់អំនោយទាន កាលបើគេធ្វើចំពោះនរណាម្នាក់ហើយ គេត្រូវផ្តាច់កម្មសិទ្ធិ និងសិទ្ធិរបស់ខ្លួននៅពេលដែលរបស់នោះ វត្ថុនោះចេញផុតពីដៃម្ចាស់អំនោយនៅពេលនោះដែរ ។ ដូច្នេះ ម្ចាស់កម្មសិទ្ធិថ្មីនេះ មានសិទ្ធិគ្រប់គ្រាន់នឹងប្រើប្រាស់ ឬចាយវាយតាមទំនើងចិត្តបានដោយសេរី ។ ព្រោះរបស់នោះ ជាកម្មសិទ្ធិរបស់ខ្លួនហើយ ។

ឧទាហរណ៍ :

-ទាយកម្នាក់ សាងកុដិ, សាលា, ព្រះវិហារ ។ល ។ ថ្វាយសង្ឃ ។ នៅពេលវេរថ្វាយសង្ឃរួច កុដិ, សាលានោះក្លាយទៅជារបស់សង្ឃហើយ ។ ទាយកនោះ មិនអាចនិយាយថា : ឯងខំធ្វើកុដិចង់ងាប់ គ្រាន់តែនៅស្រាប់ ក៏មិនជួយថែទាំផង មិនបានដែរ ។ ការពោលដូច្នេះ ឈ្មោះថា *ហុចអំបោះស្រនោះដៃ* ។ ម្យ៉ាងទៀត វានឹងកើតជាទោសបានបាបថែមទៀតផង ។

- បុរសម្នាក់ លក់ម៉ូតូឱ្យគេ ពេលទទួលលុយ តំលៃលក់ និងប្រគល់ម៉ូតូឱ្យគេ ...ស់ថ្មី ។ ម្ចាស់មុន លែងមានសិទ្ធិអ្វីទាំងអស់ ។

- កូនម្នាក់ ទិញឡានមួយគ្រឿងជូនឪពុក ។ ឪពុកយកឡាននោះទៅបញ្ជិះស្រីក្មេង កូនឃើញក៏ខឹងនឹងឪពុក. ត្រង់"ខឹង" នេះក៏ជាទោសដែរ គឺកូនយកបុណ្យចេញ យកបាបចូល ។ ព្រោះថា ពេលកូនជូនទៅឪពុក គឺជូនទាំងកម្មសិទ្ធ, ជូនទាំងសិទ្ធិព្រមជាមួយគ្នា, ចង់គាត់យកទៅបញ្ជិះស្រីក្មេងស្រីខ្មៅអ្វីក៏ដោយ វាជាកម្មសិទ្ធរបស់គាត់ទាំងអស់ ។ ព្រោះឡាននេះ ជាឡានរបស់គាត់ ចង់គាត់លក់ដូរ រឺ ឱ្យទៅអ្នកណា គឺជាសិទ្ធិស្របច្បាប់របស់គាត់ទាំងអស់ ។

- កូនម្នាក់ទៀត ជូនលុយឪពុក រួចប្រាប់ថាឱ្យប៉ាយកទៅធ្វើបុណ្យភ្ជុំ។ ត្រង់នេះក៏ជាទោសដែរ ។ ព្រោះដូចជាប្រើគាត់ឱ្យទៅធ្វើបុណ្យជំនួសខ្លួន ។ ម្យ៉ាងទៀត បើគាត់យកលុយនេះទៅចូលបារ រឺខារ៉ាអូខេ ចែកចាយឱ្យពួកនាង-នាង ដើម្បីជាមធ្យោបាយ ទាក់ទាញ ធ្វើឱ្យគាត់សប្បាយចិត្តរស់នៅឱ្យបានវែងបន្តិចទៀត, ក៏គ្មានបញ្ហាអ្វីដែរ ។ ម្យ៉ាងទៀត បើគាត់យកលុយកូនជូនទៅសេពសុរា រឺជក់គ្រឿងញៀនដែលជាទំរើខុសនឹង ច្បាប់រដ្ឋ ក៏គ្មានសៅហ្មងដល់កូនដែរ ។ ព្រោះថា បុណ្យនិងបាបអ្នកណាធ្វើអ្នកនោះ ទទួល( ដូចពាក្យគេថា *ក្បាលអ្នកណា សក់អ្នកហ្នឹង*) ។

- បេក្ខជនតំនាងរាស្ត្រម្នាក់ យកអំនោយទៅចែកប្រជារាស្ត្រ ដោយសំលឹងឃើញសន្លឹកឆ្នោត ។

អំនោយអ្វីក៏ដោយ ត្រូវចេះកាត់ផ្តាច់កម្មសិទ្ធិ និងសិទ្ធិឱ្យជ្រះស្រលះ ។ បើផ្ទុយពីនេះឈ្មោះថា "*ហុចអំបោះស្រនោះដៃ* ហើយ ៕

*ថ្ងៃទី ០២-០៣-១១*

❀❀❀❀

ឡ

# ៤១៤. ឡើងខ្ពស់កប់ពពក ធ្លាក់មកជ្រកអាចម៍ជន្លេន

**និយមន័យ**

ឧក្រិដ្ឋជន ពេលឡើងបុណ្យ ខ្ពស់កប់ពពក, ពេលអស់បុណ្យ ធ្លាក់មកជ្រកអាចម៍ជន្លេន

## អត្ថាធិប្បាយ

### ▢ អត្ថានុរូប

អ្វីក៏ដោយ កាលណាឡើងកាន់តែខ្ពស់ទៅក្នុងលំហអាកាស លុះដល់ពេលធ្លាក់មកផែនដីវិញ តែងតែកប់ជ្រៅទៅក្នុងដី ។ គឺជ្រៅទៅនៅពីក្រោមអាចម៍ជន្លេនទៅទៀត ។

### ▢ អត្ថប្បដិរូប

ខ្លឹមសារក្នុងទំនឹមទំនៀមខាងលើនេះ លោកពោលសំដៅទៅលើអ្នកដែលឡើងឋានៈពីក្រោមទៅលើ រឺពីក្រទៅមាន ពីតូចទៅធំ ។ ដូចជា :

- អ្នករកស៊ីរត់ពន្ធឈើម្នាក់ឡើងរហូតដល់ឧកញ៉ា
- ជាងធ្វើម៉ូតូម្នាក់ឡើងរហូតដល់ឧត្តមសេនិយ
-អ្នកបដិវត្តន៍ម្នាក់ឡើងរហូតដល់ប្រធានាធិបតី

ករណីបែបនេះ លោកហៅថាសុទ្ធតែឡើងកប់ពពកទាំងអស់ ។ ប៉ុន្តែ ៗដូចព្រះពុទ្ធអង្គត្រាស់ថា ទាប-ខ្ពស់ តូច-ធំ តែងផ្លាស់ប្តូរវេន គ្នាជានិច្ច គឺលោកឧកញ៉ាម្នាក់ ត្រូវធ្វើអត្តឃាត (ពេលអស់លក្ខណ៍) លោកឧត្តមសេនិយ ត្រូវ

ជាប់គុកអស់មួយជីវិត(ពេលអស់បុណ្យ) លោកប្រធានាធិបតីម្នាក់ត្រូវជាប់គុក និងស្លាប់(ពេលត្រូវរដ្ឋប្រហារ) ។

ការដែលធ្លាក់បុណ្យសក្តិ និងឋានៈយ៉ាងអាក្រក់អាក្រីបែបនេះលោកហៅថា *ធ្លាក់មកជ្រកអាចម៍ជន្លេនដី* ទាំងអស់ ៕

*ថ្ងៃទី ១៤-០៩-០៧*

❁❁❁❁



# ៤១៥. អយតោ មលំ ខាទតិ

## ច្រែះកើតពីដែក រមែងស៊ីដែក

**និយមន័យ**

ជនអគតិ និង ផលកម្ម

**អត្ថាធិប្បាយ**

❐ **អត្ថានុរូប**

" **ច្រែះ** " កើតពីដែក រមែងស៊ីដែកនោះវិញ ។

នេះគឺជាព្រះបន្ទូលរបស់ព្រះបរមសាស្ត្រាចារ្យនៃយើង ។

ព្រះពុទ្ធវចនៈនេះមានន័យថា : " **ដែក** " ជាបច្ច័យនាំឱ្យកើត " **ច្រែះ** " ។ កាលណាដែកបង្កើតបានជាច្រែះហើយ ច្រែះនោះឯងក៏ស៊ីកំទេចដែកនោះឱ្យពុកផុយទាល់តែរលាយបាត់រូបអស់ទៅដែរ ។

❐ **អត្ថប្បដិរូប**

បុគ្គលដែលធ្វើនូវទំរើអ្វីមួយ សុទ្ធតែមាន " **ចិត្ត** " នាំឱ្យធ្វើទាំងអស់ ព្រោះ...

" **ចិត្ត** " ជាធម្មជាតិសម្រាប់សន្សំនូវអារម្មណ៍ ឱ្យគិតធ្វើនូវទំរើដែលហៅថា " **ចេតនាកម្ម** " ។

ដូច្នេះ " **ចេតនា** " ជាគំនិតដែលនាំចិត្តឱ្យនឹកភ្នកឱ្យផ្តួចផ្តើមគិតឡើង ។

មួយវិញទៀត " **ចេតនា** " ក៏ជាតួ " **ចេតសិក** " ដែលដឹកនាំចិត្តឱ្យធ្វើនូវកម្ម អ្វីមួយដែរ ។

ព្រះពុទ្ធវចនៈនេះពោលសំដៅដល់ជនអគតិ ដែលមានចិត្តអកតញ្ញូចំពោះ អ្នកមានគុណរបស់ខ្លួន ។ ដូចជា :

- ពូសុខមានកូនម្នាក់ឈ្មោះអាខៃ ។ មួយថ្ងៃៗអាខៃគិតតែយកលុយឪពុក ដើរស៊ីចាយ ។ វាបំផ្លាញឪពុក វាទាល់តែអស់ ។ ពេលឪពុកវាអស់លុយកាក់ ទ្រព្យ សម្បត្តិហើយ អាខៃក៏ខ្សោះអស់ដែរ ។

- បញ្ញើក្អែកទំលើមែកស្វាយ ។ វាតែងបឺតស្រូបយកសារធាតុចិញ្ចឹមពីដើម ស្វាយនោះទាល់តែខ្សោះ ។ លុះស្វាយខ្សោះជីវជាតិហើយក៏ងាប់ទៅ ។ ឯបញ្ញើក្អែក ក៏ងាប់ទៅដែរ ។

- គណនេយ្យករម្នាក់ចេះតែកេងកីបប្រវ័ញ្ចប្រាក់ថៅកែ ។ យូរៗទៅថៅកែ ក៏រលំដួល អ្នកកាន់ហិបប្រាក់ ក៏អន្តរាយបាត់ទៅដែរ ព្រោះអស់ការងារធ្វើ ។

- អ្នករត់ឡានតាក់ស៊ីម្នាក់ ចេះតែប្រើល្បិចកីបថ្លៃឈ្នួល ។ ទីបំផុតថៅកែ ឡានក៏ខាតបះជើងដួលរលំទៅ ។ ឯអ្នករត់តាក់ស៊ីក៏អស់ការងារធ្វើទៅដែរ ។

- ភរិយាកញ្ញើផ្ទះម្នាក់ ចេះតែលួចលុយប្ដីលេងល្បែង និងទិញគ្រឿងអលង្ការ

ពាក់តាមចំនង់ ។ យូរៗទៅ អ្នកជាស្វាមីក៏ខ្សោះអស់រលីងពីខ្លួន ។ ឯស្រីល្អនោះក៏រលត់រលាយអន្តរធានទៅដែរ ។

- ចំហេះកើតពីសំរាម ។ កាលណាសំរាមឆេះអស់រលីងហើយ ចំហេះក៏រលត់បាត់ទៅដែរ ។

ជនអគតិដូចបានបរិយាយមកប៉ុណ្ណេះបញ្ជាក់ឱ្យឃើញថា: បើវាទៅនៅទីណា វាតែងបំផ្លាញគេនៅទីនោះ ដោយសារមានចិត្តបាបជាអ្នកដឹកនាំ ប្រៀបបាននឹង " **ច្រែះ** " ដូច្នេះឯង ៕

*ថ្ងៃទី ២០-០៧-១០*

❀❀❀❀



# ៤១៦. អូសទូកកុំឱ្យល្អាន ចាប់ត្រីបានកុំឱ្យល្អក់ទឹក

**និយមន័យ**

ធ្វើការងារបានសំរេចដោយគ្មានបញ្ហា

**អត្ថាធិប្បាយ**

**▢ អត្ថានុរូប**

- **អូសទូកកុំឱ្យល្អាន**

ការអូសទូកនៅលើដីផ្ទាល់តែងមានលំអាន គឺស្នាមដានដែលគេអូស ។ តែក្នុងន័យខាងលើនេះ លោកមិនចង់ឱ្យអូសទូកមានល្អានទេ ។ ដូច្នេះ គេត្រូវរកកំនល់ជាកំនាត់កង់ៗមានកំនាត់ដើមចេកជាដើមយកមកដាក់កល់អូស ទើបគ្មានលំអានផងគ្មាន សំណើកបាតទូកផង ។

- **ចាប់ត្រីបានកុំឱ្យល្អក់ទឹក**

ត្រីនៅក្នុងទឹក បើមានមនុស្សចុះចាប់វានឹងកករល្អក់ទឹកពុំខាន ។ តែលោកចង់ឱ្យចាប់បានហើយមិនឱ្យល្អក់ទឹកទៀត ។ ដូច្នេះគេត្រូវរកមង បបក់ និងសន្ទូចមកចាប់ទើបមិនធ្វើឱ្យទឹកល្អក់ ។

**▢ អត្ថប្បដិរូប**

- **អូសទូកកុំឱ្យល្អាន**

ការងារឯកជនក្តី រដ្ឋបាលក្តី មន្រ្តីរាជការគប្បីធ្វើការឱ្យបានសម្រេចប្រយោជន៏ ដោយពុំឱ្យមានទំនាស់នឹងនីតិវិធីដែលជាហេតុនាំឱ្យមាន បញ្ហាពិបាកដោះស្រាយតាមក្រោយទៀត ។

ឧទាហរណ៏ ៖

- នាយត្រដក់មានព្រំដីជាប់នឹងនាយត្រដោក ។ ថ្ងៃមួយនាយត្រដក់ចង់រៀបឥដ្ឋធ្វើរបង ។ នាយត្រដក់ ក៏អញ្ជើញនាយត្រដោកមកពិភាក្សាគ្នាសម្រួល ។ លុះស្រួលចិត្តគ្នាទាំងសងខាងហើយនាយត្រដក់ចាប់ធ្វើដោយគ្មានបញ្ហាអ្វីតាមក្រោយ ។

**- ចាប់ត្រីបានកុំឱ្យល្អក់ទឹក**

ន័យនេះលោកពោលសំដៅដល់សមត្ថកិច្ចដែលមានតួនាទីស៊ើបអង្កេត និង ចាប់ជនល្មើស ។ កាលណាមានវត្ថុតាងគ្រប់គ្រាន់ហើយ ។ លោកឱ្យអញ្ជើញ មុខសញ្ញាទាំងអស់មកប្រជុំ ។ លុះជួបជុំគ្នាហើយ លោកឱ្យចាប់គ្រីបតែម្តង គ្មានរញ៉ីករញ៉ៃឡើយ ៕

*ថ្ងៃទី ២៦-០៨-០៧*

❀❀❀❀

# ៤១៧. អឹមអៀម ស្ងៀមជាងស្រដី ស៊ីចេកខ្ចីជាងមាត់ទទេ

**និយមន័យ**

កាលមិនគួរនិយាយ គប្បីនៅស្ងៀមប្រសើរជាង

ធ្វើការតូចតាច ប្រសើរជាងនៅស្ងៀម

**អត្ថាធិប្បាយ**

" **អឹមអៀម** " = ការចង់និយាយបន្តិច, មិនចង់និយាយបន្តិច, គឺចិត្តរារែក អល់អែក, កន្ទះរា, ខ្មាសអៀន, មិនលុះលាញ, មិនក្លាហាន, ចិត្តកំសោយ ។

ពាក្យទំនឹមទំនៀមអ្នកចាស់បុរាណខាងលើនេះ គឺលោកចង់ប្រដៅថា : បើចិត្តអល់ឯក, ស្ទាក់ស្ទើរ, រុញរា, មិនដាច់ស្រេចសូវនៅស្ងៀមវិញប្រសើរជាង ។ ព្រោះ បើនិយាយទៅក៏មិនលះសេចក្ដីដែរ គឺ តតឹបតតុប រអាក់រអួល ចាប់ចុងព្រយុង ដើមគ្មានប្រាកដក្នុងខ្លួន ។

ម្យ៉ាងទៀត អ្នកដែលញញើតញញើមក្នុងការនិយាយស្ដីដោយចេះតែបារម្ភ ខ្លាចប៉ះពាល់ដល់អ្នកនេះ អ្នកនោះ ត្រង់នេះក៏លោកប្រាប់ថា នៅស្ងៀមវិញទៅ ប្រសើរជាងការពោលស្ដី ។

- **ស៊ីចេកខ្ចីជាងនៅមាត់ទំនេរ**

ចេកខ្ចីមិនសូវជាឆ្ងាញ់ប៉ុន្មានដែរទេ ប៉ុន្តែបើគេចេះរកគ្រឿងផ្សំដូចជាកាពិជា-ដើមចូលរួមផង ដូចជាគ្រាន់បើម្យ៉ាងដែរ ។

ក្នុងន័យនេះ លោកចង់ពោលថា បើនៅស្ងៀមឥតប្រយោជន៍ លោកឱ្យធ្វើការកំប៉ិកកំប៉ុកក្បែរផ្ទះដូចជា ជិរះស្មៅ ពូនគុម្ពចេក គុម្ពអំពៅ រឺបោសច្រាសសំអាតទីធ្លាផ្ទះជាដើម ។

លោកថា ការងារនេះទោះជាតូចតាចក៏ដោយ បើគេធ្វើទៅក៏បានផលប្រសើរជាងអង្គុយស្ងៀមដកដង្ហើមចោលដែរ ៕

*ថ្ងៃទី ២៨-០៩-០៧*





# ៤១៨. អណ្តើកនៅជើង ចាំបាច់ក្តក់ឆ្កែ

**និយមន័យ**

អ្វីដែលងាយ ពុំចាំបាច់អំពាវនាវរកជំនួយឡើយ

**អត្ថាធិប្បាយ**

**✳ អត្ថានុរូប**

អ្នកចាប់អណ្តើក តែងនាំឆ្កែប្រមាញ់៤-៥ក្បាលដើម្បីជាជំនួយក្នុងការស្វែងរកអណ្តើក ។ កាលណាគេទៅ ដល់គោលដៅហើយ ឆ្កែប្រមាញ់ក៏រត់ប្រសេចប្រសាចដើម្បីស្វែងរកអណ្តើក ។ កាលណាគេឮឆ្កែមួយកោះហើយ ម្ចាស់ដឹងថាមានអណ្តើក គេក៏ប្រញាប់ប្រញាល់ទៅចាប់អណ្តើកដាក់ទ្រុង ។

ប៉ុន្តែបើម្ចាស់ខ្លួនឯងឃើញអណ្តើកនៅក្បែរជើងហើយ ចាំបាច់អ្វីក្តក់ហៅឆ្កែមកជួយ គឺគេត្រូវចាប់អណ្តើកដាក់ទ្រុងតែម្តងទៅជាការស្រេច ។

**✳ អត្ថប្បដិរូប**

អត្ថន័យនៃទំនឹមទំនៀមនេះ លោកនិយាយថា អ្វីក៏ដោយឱ្យតែងាយស្រួលក្នុងការចាប់យក គេត្រូវតែចាប់យកភ្លាមដោយខ្លួនឯង ដោយមិនចាំបាច់ប្រកូកប្រកាសប្រាប់គេឱ្យមកជួយឡើយ ។ ព្រោះការដែលហៅគេមកជួយ គេក៏ត្រូវការយកផលចំនេញខ្លះដែលជាហេតុនាំឱ្យគេដឹងឮផង នាំឱ្យខាតប្រយោជន៍ផង ។ តួយ៉ាងដូចជា ៖

- នាយវិសេសបានជិតដិតស្និទ្ធស្នាលនឹងនាងវិសុទ្ធ ដែលគេមានចិត្តប្រតិព័ទ្ធនឹងនាងតែហាក់ដូចជានៅមិនទាន់យល់ជម្រៅចិត្តនាងសោះ ។

ក្នុងករណីបែបនេះ នាយវិសេសត្រូវតែក្លាហានសួរចិត្តនាងដោយខ្លួនឯងតែម្តងទៅ ចាំបាច់អ្វីទៅពឹងពាក់យាយសៅឱ្យជួយសួរ ។ ព្រោះនាំឱ្យខាតពេលរង់ចាំដំណឹងផង នាំឱ្យបាត់ពាក្យពេចន៍ដែលនាងនិយាយផង និងនាំឱ្យជំពាក់គុណយាយសៅផង ។

- នាយត្រដែតបានស៊ើបដឹងថា កន្លែងមួយនោះគេត្រូវការមនុស្សធ្វើការ ។ ភ្លាមៗគេត្រូវតែដាក់ពាក្យសុំចូលធ្វើការទៅ មិនចាំបាច់ពឹងពាក់អ្នកណាឱ្យមកជួយរត់ការទៀតទេ ៕

*ថ្ងៃទី ០៨-០៩-០៧*



# ៤១៩. អ្នកឡើងមិនបានបេះ អ្នកប្រលេះមិនបានស៊ី អ្នកនៅធំនេរស៊ីឆ្អែត

**និយមន័យ**

អ្នកធ្វើមិនបានកម្រៃ អ្នកនៅស្ងៀមទទួលផល

**អត្ថាធិប្បាយ**

✳ **អត្ថានុរូប**

- **អ្នកឡើងមិនបានបេះ** នៅពេលនេះលោកសំដៅយកជើងទាំងពីរដែលប្រឹងជាន់ឡើងពីគន្លាក់ទាប ទៅគន្លាក់ខ្ពស់រហូតដល់គោលដៅ ។ នៅពេលកំពុងឡើងប្រសិនណាបើជាន់ចំកន្លែងមិនល្អ អាចធ្លាក់ខ្លួនបាក់ដៃបាក់ជើង ។ ប៉ុន្តែជើងទាំងពីរនេះមិនអាចបេះបានផ្លែ ឈើមួយណាឡើយ គឺបានត្រឹមតែឡើងប៉ុណ្ណោះ ។

- **អ្នកប្រលេះមិនបានស៊ី** គឺដៃទាំងពីរដែលមមាញឹកក្នុងការបេះ ឬប្រលេះយកផល ។ ការបេះបាន ឬមិនបាន ឬក៏បេះបានតិច ឬច្រើនអាស្រ័យលើសមត្ថភាពដៃ ។ ដូច្នេះដៃមិនបានស៊ីទេ គឺបានត្រឹមតែបេះប៉ុណ្ណោះ ។

**អ្នកនៅទំនេរស៊ីឆ្អែត** គឺមាត់-មាត់នេះឥតមានជួយធ្វើអ្វីទេចាំតែ ទទួលផលស៊ីស្រាប់ៗ ។

✳ **អត្ថបរិយាយ**

**អ្នកឡើងមិនបានបេះ** លោកឱ្យន័យប្រៀបធៀបជាបុគ្គលាទិដ្ឋានទៅនឹងអ្នកដែលប្រឹងធ្វើការយ៉ាងសកម្មប្រយុទ្ធ ដើម្បីបុព្វហេតុនាយចៅហ្វាយ ។ ព្រោះពួកនេះជាពួកសេវាករ រង់ចាំតែបំរើ និងពួកកម្មករសាងសង់ ដូចជាស្ពានទាផ្លូវថ្នល់, ស្ពាន និងអាគារ ផ្សេងៗ ។ ពួកនេះមិនដែលឡើងបុណ្យសក្តិ រឺឋានៈជាខុកញ៉ាទេ ។

ក្នុងករណីនេះ បើត្រូវបានរង្វាន់ ឬឡើងបុណ្យសក្តិ គឺចៅហ្វាយនាយឯណោះទេ ។

**ឯអ្នកប្រលះមិនបានស៊ី** គឺអ្នកដែលខំប្រឹងបំពេញបែបបទផ្សេងៗយ៉ាងមមាញឹក តែមិនបានទទួលផលអ្វីដែរ ។ គឺគេបំពេញកាតព្វកិច្ចក្នុងន័យបំរើ នាយចៅហ្វាយប៉ុណ្ណោះ ។ ដូចជាធ្វើប្លង់ដី ប្លង់ផ្ទះឱ្យឯកជនជាដើម ។

**ចំនែកអ្នកនៅទំនេរស៊ីឆ្អែត** គឺអ្នកដែលនៅស្ងៀមធ្វើមិនដឹង មិនព្នងណោះវិញទេ ដែលបានទទួលផលយ៉ាងសែនត្រជាក់ចិត្ត គឺលោកនាយដែលសម្បូរអំនាច ។

ចំពោះលោកនាយនេះ ប្រសិនបើករណីណាមានអាស្រូវកើតឡើងដោយចៃដន្យនោះ លោកតែងឆ្លើយដាក់កូនចៅដែលគ្នាមិនបានលិទ្ធឯណោះទៅវិញទេ ៕

*ថ្ងៃទី ០៩-០៩-០៧*

✽✽✽✽

# ៤២០. អ្នកប្រាជ្ញជាន់ចាស់ស្មៅដុះលើដី អ្នកប្រាជ្ញជាន់ថ្មីដីដុះលើស្មៅ

**និយមន័យ**

ឧត្តមភាពនៃការរីកចម្រើនរបស់អ្នកប្រាជ្ញសម័យថ្មី

**អត្ថាធិប្បាយ**

◆ **អ្នកប្រាជ្ញជាន់ចាស់ស្មៅដុះលើដី**

ពាក្យទំនឹមទំនៀមនេះមានន័យថា អ្នកប្រាជ្ញជំនាន់មុន គឺជំនាន់វិទ្យាសាស្ត្រមិនសូវជឿនលឿនប៉ុន្មាន ។ អ្នកប្រាជ្ញជំនាន់នោះមានរបកគំហើញនៅខ្សោយជាងសព្វថ្ងៃ ។ ម្ល៉ោះហើយ ស្មៅត្រូវដុះលើដីតាមធម្មជាតិរបស់វា ឯអ្នកប្រាជ្ញជាន់ចាស់មានបច្ចេកទេសធ្វើកំនៃប្រែខ្លះដូចជា :

- យករុក្ខជាតិមកចំរាញ់ធ្វើជាថ្នាំគុលិកាសំរាប់លេប និងថ្នាំចាក់ ។
- ចេះច្នៃធ្វើ ឡានដុតធ្យូង និងកប៉ាល់ទឹកដើរដោយចំហាយ
- ចេះច្នៃធ្វើរទេះភ្លើងដុតអុស
- ចេះច្នៃធ្វើទូរសព្ទមានខ្សែ
- ចេះធ្វើវិទ្យុ
- ចេះធ្វើពុម្ពអក្សរ និងអង្គលីលេខ ។ល ។

## ◆ អ្នកប្រាជ្ញជាន់ថ្មីដីដុះលើស្មៅ

ដោយបច្ចេកទេសរបស់អ្នកប្រាជ្ញជំនាន់ថ្មីចេះតែមានការវិវត្តន៍ឈានឡើង ។ អ្វីៗត្រូវប្រែប្រួលទាំងអស់ ដែលគេយល់មិនបានស្មានមិនដល់ ។ គឺមិនត្រឹមតែរបស់ប្រើប្រាស់ទេ សូម្បីតែដើមឈើនានាក៏ឆ្លួតវង្វេងរដូវកាលលែងដឹងប្រតិទិនអស់ហើយ ព្រោះគេបង្គាប់ឱ្យផ្លែផ្កាតាមចំនង់គេទាំងអស់ ។ ដូចជា :

- ដើមស្វាយមួយដើម គេផ្សាំបំបៅមែកខ្លះពូជមួយទៅ មែកខ្លះពូជផ្សេងទៀតទៅ ។ល ។

- ពូជរុក្ខជាតិជាច្រើន គេឱ្យផ្លែរហូតលែងមានរដូវ ។

- គេដាំប៉េងប៉ោះក្នុងកែវទឹកថ្នាំ ដោយមិនបាច់មានដើមទេ គឺចេញជាផ្លែតែម្តង ។

- កុំព្យូទ័រ ជាពុម្ពអក្សរ ជាពុម្ពរូបភាពយ៉ាងទំនើបដែលអាចបំរើតាម តំរូវការរបស់មនុស្សបានសឹងតែទាំងអស់ ។

- រថយន្តទំនើបដែលអាចចាក់ប្រេងសាំង ប្រេងកាត ទឹកអប់ អាល់កុល ឧស្ម័ន...បានទាំងអស់ឱ្យតែមាន ជាតិឧស្ម័នបន្តិចនាំមុខ រហូតដល់ចាក់ទឹកទៀតផង ។ល ។

ម្យ៉ាងទៀតន័យដដែលខាងលើនេះ គេក៏ប្រើជាពាក្យចំអកឡកឡឺយឱ្យអ្នកដែលមានអំនួតហួសហេតុផងដែរ ។ ដូចជា គេតែងពោលឱ្យថា *ហ្អឹងហើយ ឯងហ្នឹងជាអ្នកប្រាជ្ញជាន់ថ្មី អ្វីៗវាត្រលប់ធាតុអស់ហើយ* ៕

*ថ្ងៃទី ០៩-០៩-០៧*

# ៤២១. អណ្តាតជាអាទិ៍កន្លង បានសុខទុក្ខផងព្រោះអណ្តាត

**និយមន័យ**

ការនិយាយស្តី នាំមកនូវសេចក្តីសុខ រឺទុក្ខ

**អត្ថាធិប្បាយ**

**អណ្តាត** គឺជាអវយវៈនៅក្នុងមាត់សំរាប់គ្រលៀស គ្រលៀវដើម្បីបង្កើតជាសំលេង ជាសំនៀង ជាភាសានិយាយ ។

ការនិយាយស្តី ការចរចារ ការសន្ទនា សុទ្ធតែពឹងលើអណ្តាតជាអាទិភាពជាដើមចមទាំងអស់ ។

ដូច្នេះបើគេនិយាយស្តីពីអ្វីដែលជាគតិបណ្ឌិត ជាកុសលវាចា ជាធមិអាថិ និងជាការអប់រំ ។ល ។ គេនឹងបានទទួលនូវការគោរព ការស្រលាញ់ ការរាប់អាន ពីសំនាក់មហាជនគ្រប់មជ្ឈដ្ឋាន ។ កាលបើមានគេគោរពស្រលាញ់រាប់អានយ៉ាងដូច្នេះ គេរមែងស្ថិតនៅជាសុខអស់កាលជានិច្ច ក៏ព្រោះតែអណ្តាតហ្នឹងឯង ។

ផ្ទុយទៅវិញ បើគេនិយាយសុទ្ធតែពាក្យអសុរោះ គ្រោតគ្រាត មិនសមរម្យដូចជា ជេរបញ្ចោរ ច្រាសឆ្អេះ គ្មានពាក្យសមគួរ និងគ្មានស្គាល់គុណទោសខ្ពស់-ទាបគឺជាសម្តីដែលគ្មានគុណធមិ ។ កាលបើគេពោលតែពាក្យ អសីលធមិដូច្នេះ គេរមែងទទួលនូវសំអប់គ្រប់ទិសទី ។

ម្យ៉ាងទៀត បើគេនិយាយតែពាក្យរោយរាយ ចាក់ដោតឆ្កឹះឆ្កៀលពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ។ គេនឹងបានទទួលនូវទុក្ខទោសដល់ខ្លួន ក៏ព្រោះតែអណ្តាតហ្នឹងឯង ៕

*ថ្ងៃទី ០៩-០៩-០៧*

# ៤២២. អាវែក គេស៊ីក្រោមភ្នែក អាវែកមិនដឹង

**និយមន័យ**

មនុស្សអវិជ្ជា គ្មានដឹងអ្វីទាំងអស់

**អត្ថាធិប្បាយ**

❖ **អត្ថានុរូប**

"**វែក**" គឺជាវត្ថុមានដង និងមានផ្លែធ្វើអំពីត្រលោកដូង រឺលោហធាតុ សំរាប់ដួសបាយ សំល រឺដួសអ្វីដែលគេត្រូវការ ។

**វែក**នេះ ទោះបីគេដាក់ត្រាំក្នុងឆ្នាំងសំលដ៏មានរសជាតិឆ្ងាញ់ពិសា យ៉ាងយូរក៏ដោយ ក៏វាគ្មានដឹងរសជាតិអ្វីបន្តិចដែរ ។ ព្រោះវាជាវត្ថុឥតវិញ្ញាណ ។

❖ **អត្ថប្បដិរូប**

ពាក្យទំនឹមទំនៀមនេះ លោកពោលប្រៀបធៀបទៅលើមនុស្សដែលមានប្រពន្ធផិតក្បត់ លបលួចមានសហាយ ។ គេរស់នៅជាមួយប្រពន្ធចើករាប់ឆ្នាំអស់កាលដ៏យូរ ។ ប៉ុន្តែ គេឥតបានដឹងពីអំពើផិតក្បត់របស់ប្រពន្ធគេបន្តិចសោះ ។ ជួនកាលទៀតប្រពន្ធចើកនោះ យកសហាយឡើងមកប្រព្រឹត្តអំពើអនាចារលើផ្ទះទៀតផងក៏មាន ។ បើប្តីសង្ស័យ ស្រីនោះថា បងប្អូននៅស្រុកឆ្ងាយមកលេង ។ ប្តីវែកនោះក៏ជឿទៅ ហើយថែមទាំងរាក់ទាក់ គួរសម រៀបចំបាយទឹកឱ្យស៊ីទៀត ។

ហេតុនេះហើយ បានជាមានពាក្យចំអកថា "**អាវែក គេស៊ីក្រោមភ្នែក អាវែកគ្មានដឹងអី**" ៕

*ថ្ងៃទី ១២-០៩-០៧*

# ៤២៣. អូសសំរាស់ ប្រទះពាក្យ

**និយមន័យ**

ការនិយាយប៉ះពារ ទៅលើរឿងហេតុដែលនាំឱ្យទាក់សំដីគ្នាដោយអចេតនា

**អត្ថាធិប្បាយ**

**សំរាស់** នៅពេលនេះ លោកសំដៅយកអ្នកដែលនិយាយស្ដីដោយពុំបានគិត រឺដោយពុំមានបំនង ។ ស្រាប់តែជួនជាប៉ះពារទៅលើរឿងពិត រឺហេតុពិតដែលនាំឱ្យមានការទាក់សំដីគ្នា រួចក៏បង្កើតទៅជារឿងរ៉ាវប្រកែកជជែកគ្នា ។ ប៉ុន្តែការណ៍ពិតសុទ្ធតែជារឿងកើតឡើងដោយចៃដន្យសុទ្ធសាធ ។ ដូចជា :

- នាយកុយ និយាយថា អញស្អប់អ្នកផឹកស្រាណាស់ ។ គាប់ជួនពេលនោះនាយ ចយ .កាន់ដបស្រាដើរមកដល់បានឮពាក្យនោះក៏ពោលថា អញផឹកលុយអញ គ្មានសុំ គ្មានជឿអាណាទេវើយ កុំមកដៀមដាមឱ្យអញ ។ ការជជែក និងប្រកាន់ពាក្យសំដីក៏កើតមានឡើង ។

- អ្នក សយ និយាយថា អញស្អប់មនុស្សណាជំពាក់លុយគេមិនចង់សង អ្នកសុននៅជិតនោះឮហើយ ឆ្លើយថា បើខ្ញុំជំពាក់ក៏មិនមែនជំពាក់អ្នកឯងដែរ ។ អ្នកសយតបវិញថា ទេ! ខ្ញុំមានថាឱ្យអ្នកសុនឯងឯណា ខ្ញុំនិយាយតែខ្ញុំទេតើ ។ ការជជែកគ្នា ក៏កើតមានឡើង ។

ការណ៍ពិតទៅ អ្នកនិយាយមុនគ្មានបំនងថាឱ្យអ្នកណាទេ គ្រាន់តែចង់និយាយតាមឆន្ទៈរបស់ខ្លួនប៉ុណ្ណោះ ៕

*ថ្ងៃទី ១២-០៩-០៧*

# ៤២៤. អាវៀចធ្វើកង់ អាត្រង់ធ្វើកាំ

**និយមន័យ**

ការប្រើមនុស្សទៅតាមសមត្ថភាព រឺជំនាញ

**អត្ថាធិប្បាយ**

❖ **អត្ថានុរូប**

ជាងឈើយ៉ាងស្ទាត់ជំនាញម្នាក់ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការរើសឈើមកធ្វើរទេះ ដើម្បីកុំឱ្យខាតឈើឥតប្រយោជន៍ ។ គាត់ចេះមើលទំនងរាងឈើ តើត្រូវធ្វើអ្វីបាន ។ គាត់បានយកឈើដែលវៀចកោងធ្វើខ្នងកង់រទេះ ឯឈើណាដែលត្រង់ៗធ្វើជាកាំ ។ គឺគាត់ឥតមានចោលឈើមួយកំនាត់ណាឡើយ ។

❖ **អត្ថប្បដិរូប**

នាយចៅហ្វាយដ៏ឆ្លាតវាងវៃម្នាក់ ដែលគ្រប់គ្រងពលទាហានមានបច្ចេកវិធីក្នុងការប្រើមនុស្សទៅតាម សមត្ថភាព និងតាមអត្តចរិត គឺគាត់ប្រើទាំងអ្នកអត្តចរិតល្អ និងអ្នកខិលខូចបានទាំងអស់ ដោយសារគាត់ចេះចាត់តាំងឱ្យបំពេញមុខការត្រូវតាមសមត្ថភាព តួយ៉ាងដូចជា :

- អ្នកមានចំនេះដឹងផ្នែករប្បធមិទូទៅត្រូវចាត់ឱ្យ ធ្វើការនៅការិយាល័យ
- អ្នកជំនាញកលយុទ្ធ ជាមេដឹកនាំពួកពលចូលសមរភូមិ
- អ្នកមានសមត្ថភាពផ្នែកគណនេយ្យ ត្រូវធ្វើជាគណនេយ្យករ
- អ្នកស្មោះត្រង់ ត្រូវគ្រប់គ្រងសម្ភារៈ
- អ្នកក្លាហាន រឺអ្នករាងខិលខូចជាកងឈ្លបស៊ើបការណ៍ ។

មនុស្សប្រភេទណាក៏ប្រើការបាន លោកថា *អាវៀចធ្វើកង់ អាត្រង់ធ្វើកាំ* ៕

*ថ្ងៃទី ១៣-០៩-០៧*

# ៤២៥. អង្គុយលើចង្អេរលើកខ្លួនឯង

**និយមន័យ**

មោទកភាពខ្លួនឯងខ្លាំងពេក

## អត្ថាធិប្បាយ

### ❖ អត្ថានុរូប

បើគេយកចង្អេរមួយមកដាក់អង្គុយពីលើ រួចហើយខំប្រឹងលើកចង្អេរនោះដោយខ្លួនឯងទៀត ។ គេជឿថា ទោះបីជាខំប្រឹងលើកទាល់តែស្លាប់ខ្លួនទៅទៀត ក៏មិនអាចលើករួចដែរ ។ ព្រោះទម្ងន់ខ្លួននៅលើចង្អេរ ឯកំលាំងប្រឹងដើម្បីលើកក៏នៅលើចង្អេរទៀត តើលើកម្ដេចរួច ។

### ❖ អត្ថប្បដិរូប

ពាក្យទំនឹមទំនៀមនេះ លោកឱ្យន័យថា មនុស្សដែលមានមោទកភាពខ្លួនឯងខ្លាំងពេក ខំប្រឹងនិយាយអួតសរសើរតែពីគុណសម្បទ៍ គុណធមិរបស់ខ្លួនដោយខ្លួនឯងបែបនេះ ប្រាកដជាគ្មានន័យអ្វីទេ ។ ព្រោះអ្នកពោលអួតពីសមត្ថភាព ពីសមិទ្ធិផលពីគុណធមិរបស់ខ្លួន រឺរបស់បក្សពួកខ្លួនក្ដែងៗគ្រប់ច្រកល្ហក លោកប្រៀបថា មិនខុសពីអង្គុយលើចង្អេរលើកខ្លួនឯងឡើយ បើអ្នកដទៃក្រៅពីខ្លួន គេសរសើរលើកតំកើងទើបជាការគួរ ៕

*ថ្ងៃទី ១៣-០៩-០៧*

❀❀❀❀

# ៤២៦. អ្នកហ៊ានស្បែកដាច អ្នកខ្លាចស្បែកស្អិត

**និយមន័យ**

អ្នកក្លាហានស្បែកសុទ្ធតែស្នាមរបួស អ្នកខ្លាចស្បែកស្អាត

**អត្ថាធិប្បាយ**

អ្នកហ៊ានស្បែកដាច គឺអ្នកដែលក្លាហានគ្មានខ្លាចនរណា ។ អ្នកក្លាហាន ឬអ្នកហ៊ាននេះ នៅតាមស្បែកនៃរាងកាយរបស់គេតែងមានស្នាមដាច់ដាច រឺស្នាមរបួសដោយសារការវាយប្រហារពីភាគីម្ខាងទៀត ។

ម្យ៉ាងទៀតសូម្បីតែខ្លួនគេក៏តែងពោលថា ក្បាលគេមានស្នាមដេរជាច្រើនកន្លែង ព្រោះតែមិនចេះខ្លាចនរណាម្នាក់ឡើយ ។ សមដូចពាក្យគេប្រៀបធៀបថាឆ្កែកាច ស្លឹកត្រចៀកវារហែកជានិច្ច ព្រោះត្រូវឆ្កែឯទៀតខាំ ។

ហេតុនេះហើយបានជាលោកពោលថា ហ៊ានខ្លាំងរបួសក៏ខ្លាំងដែរ ហាក់ដូចស្បែកគេផុយឆាប់ដាច់ឆាប់រហែក ។

ឯអ្នកដែលខ្លាចគេស្បែកស្អិត គឺស្បែករបស់គេពុំមានដាច់ដាច រឺរបួសស្នាមទេ មើលទៅហាក់ដូចស្បែករបស់គេស្អិតកាប់មិនមុតដុតមិនឆេះអ៊ីចឹង ។ ប៉ុន្តែ ការណ៍ពិតគឺគេមិនដែលហ៊ានចេញមុខទៅតតាំងនឹងភាគីជម្លោះណាឡើយ ៕

*ថ្ងៃទី ១៣-០៩-០៧*

❀❀❀❀

# ៤២៧. អន្ទង់វែង កុំរកឆ្នាំងវែង

**និយមន័យ**

ការខ្លី រីងាយ កុំធ្វើឱ្យវែង រីឱ្យពិបាក

**អត្ថាធិប្បាយ**

## ❖ អត្ថានុរូប

"**អន្ទង់**" ជាទីឃជាតិ ខ្លួនវែងសណ្ឋានពស់តែគ្មានពិស រាប់បញ្ចូលក្នុងពួកមច្ឆជាតិ( ពពួកត្រី) ។

កាលណា គេចង់ធ្វើម្ហូប, គេកាត់ឱ្យខ្លីតាមចំនង់ចំនូលចិត្ត, បើឆាខ្ញីត្រូវហាន់ឱ្យស្ដើងល្មម, បើអាំងមិនបាច់កាត់ទេ គ្រាន់តែពត់ពែនចុះឡើងដាក់ថ្ញៀបក្នុងតំបុតជាការស្រេច ។

## ❖ អត្ថប្បដិរូប

អត្ថន័យពាក្យទំនឹមទំនៀមនេះ លោកពោលថា : រឿងរ៉ាវទាំងឡាយណាដែលមើលទៅឃើញស្មុគស្មាញ និងវែងអន្លាយនោះ ។ លោកប្រាប់ថា ត្រូវកាត់ៗរីសង្ខេបឱ្យខ្លីៗទៅ ដើម្បីជាការងាយស្រួលក្នុងទំរើដែលត្រូវធ្វើ និង ឱ្យបានឆាប់ដល់គោលដៅ ។ ការណ៍ពិត បើគេធ្វើតាមបែបបទជាការត្រឹមត្រូវហើយ តែត្រូវចំនាយពេលវេលា និងប្រាក់កាសច្រើនពេក ។ ដូចជា :

- ពូសុក ត្រូវរៀបការកូន ។ ប្រពន្ធគាត់ថា ត្រូវរៀបចំទៅតាមទំនៀមទំលាប់ប្រពៃណីពីដូនតាមក ។ ប៉ុន្តែពូសុកថា " *កុំអន្ទង់វែង ឆ្មាំងវែងពេក* " សង្ខេបៗទៅបានហើយ ។ បើធ្វើតាមប្រពៃណីឃើញថា ខាតពេល និងអស់លុយកាក់ច្រើនណាស់ ។

- ពូសៅ ចង់នាំកូនឱ្យចូលរៀន ។ គាត់ថា ត្រូវនាំកូនទៅធ្វើបញ្ជីជាតិ រួចទៅសុំសំបុត្រពេទ្យបញ្ជាក់ពីសុខភាព និងថតរូប ។ ពេលនោះពូ សាន ឆ្លើយថា " *កុំអន្ទង់វែង ឆ្មាំងវែងពេក* " យកកូនទៅចុះឈ្មោះឱ្យវាចូលរៀនសិនទៅ រួចសឹមបំពេញបែបបទទៅតាមក្រោយ ។

ការវែង រឺការពិបាក ស្មុគស្មាញ កាត់មកឱ្យជាការខ្លី រឺការងាយស្រួលបែបនេះលោកថា បើអន្ទង់វែង កុំរកឆ្មាំងវែងតាមវានាំឱ្យខាតពេលវេលាទេ ៕

*ថ្ងៃទី ២៥-០៦-១០*

❀❀❀❀

# ៤២៨. អាគមផ្សំអាយុ

**និយមន័យ**

ជំនួយផ្លូវចិត្តបូកផ្សំនឹងអាយុមិនទាន់អស់ធ្វើឱ្យមនុស្សស្រន់ជម្ងឺ រឹរស់បានបន្តិចទៀតដែរ

## អត្ថាធិប្បាយ

"**អាគម**" (អានថាអាគុំ) គឺជាឈ្មោះឧទ្ទាមជនម្នាក់ក្នុងរជ្ជកាលព្រះបាទអង្គចន្ទទី១ ។

សេចក្ដីដំនាលថា អាគមនេះជាឧទ្ទាមជនដែលតែងតែដើររាតត្បាតគ្រប់ភូមិគ្រប់ស្រុកតាមដោយទំនើងចិត្តរបស់វា ។ នៅសម័យកាលនោះ អ្នកស្រុកគ្រប់ភូមិស្ថានតែងខ្លាចរអារនឹងអាគមនេះណាស់ ។ បើវាចូលទៅដល់ទីណាវាតែងវាយប្រហារកាប់សំលាប់ឥតត្រាប្រណីដោយគ្មាននរណាហ៊ានតតាំងនឹងវាទេ ។ ព្រោះកាលនោះអ្នកស្រុកតែងជឿថា អាគម នេះចេះមន្តវិជ្ជាការកាប់មិនមុតដុតមិនឆេះ ។

លុះកាលក្រោយមក ដែលអ្នកស្រុកជឿថា ដល់ពេលវាអស់លក្សណ៍ ។ ក្រុមអាជ្ញាហ្លួងក៏ចាប់បានអាគមនេះមក ។ ពេលចាប់បានវាមក គេឃើញនៅតាមដងខ្លួនវាមានសុទ្ធតែសក្ដិយ័ន្តមន្តគាថាមន្តអថ៌នស្មើរតែគ្មានសល់សាច់ ។ គេជឿថា ហេតុនេះហើយបានជាវាមានឥទ្ធិឫទ្ធិខ្លាំងពូកែយ៉ាងសម្បើមនោះ ។

អាស្រ័យលើជំនឿនេះហើយ ទើបអ្នកស្រុកណាដែលចង់ឱ្យខ្លួនខ្លាំងពូកែសក្តិសិទ្ធិក៏បានទៅសុំរៀនមន្តវិជ្ជាការ មន្តសិល្ប៍ មន្តគាថា មន្តអថ៌ន ពីអាគមគ្រប់ៗគ្នា ។ បន្ទាប់មក គេនាំគ្នាហៅមន្តគាថានេះថា មន្តអាគមគាថាជាប់រហូតមក ។

តាមអត្ថន័យខាងលើនេះ លោកចង់និយាយថា បើមានមនុស្សឈឺនៅសម័យនោះ គេនិយមមន្តអាគមឱមអាមស្តោះផ្លុំឱ្យអ្នកជំងឺ ។ លុះអ្នកជំងឺបានស្រន់បន្តិចហើយ គេថាមកពីបានមន្តអាគមគាថាលោកគ្រូឱមអាម ស្តោះផ្លុំ ។ ជួនកាលទៀតអ្នកផឹកថ្នាំឆ្នាំងហាក់ដូចមិនសូវកបសោះ គេថា ម៉េចមិនទៅរកគ្រូ(គ្រូឱមអាម)ជួយមើលឱ្យផង តើវាមានខុសខាងណា មេបាចាស់ទុំ រឺអស់លោកអ្នកតា បង់បត់ មេមត់កន្ទោងខ្មៅ ជំទាវតី រឺក៏ខ្មោចល្បាក់សា ជួរចំបូរខាងម្តាយ រឺឪពុក តើរូបមួយណាមិនសប្បាយចិត្ត ។ គេថា ចេះតែផ្សំគ្នាទៅ គេថា អាគមផ្សំអាយុ គឺបើអាយុមិនទាន់អស់បូកផ្សំនឹងជំនួយខាងផ្លូវចិត្តផង ជម្ងឺពិតជាស្រាកស្រាន្តមិនខាន ៕

*ថ្ងៃទី ១៦-០៩-០៧*

# ៤២៩. អ្នកក្រត្រដររស់ក្បែរអ្នកមាន

**និយចន័យ**

អ្នកសម្ភារៈនិយម ហាក់ដូចជាអ្នកមានភោគទ្រព្យ

**អត្ថាធិប្បាយ**

ខ្លឹមសារក្នុងនិយមន័យខាងលើនេះ ជាសំដីមោទកភាពរបស់ជនមួយចំនួនដែលជាអ្នកសំភារៈនិយម ។ គឺ ជាអ្នកដែលចូលចិត្តប្រើប្រាស់សំភារៈទាន់សម័យ បើទោះជាមិនបានថ្មីស្រលាងចេញពីហាង រឺហែកពីកេះក៏ដោយ ក៏គេមានឈ្មោះថា អ្នកមានសំភារៈប្រើប្រាស់ទាន់សម័យដូចជាអ្នកមានភោគទ្រព្យច្រើនដែរ ។ ដូចជា :

- មានទូរសព្ទទំនើប
- មានទូរទស្សន៍ពណ៌
- មានគ្រឿងភ្លេង
- មានម៉ូតូ រឺ រថយន្ត
- សំភារៈប្រើប្រាស់ផ្សេងៗទៀតសុទ្ធតែទាន់សម័យ

អ្នកសំភារៈនិយមប្រភេទនេះ មិនសូវជាអួតអាងប៉ុន្មានទេ ។ បើមានគេសរសើរលើកទឹកចិត្ត គេតែងពោលថា កុំមាត់ខ្ញុំប្រើប្រាស់របស់អស់ទាំងនេះ មើលទៅហាក់ដូចជាអ្នកមានភោគទ្រព្យច្រើនអីចឹង ។ ប៉ុន្តែ ការណ៍ពិតសុទ្ធតែជារបស់ជំនំៗមួយទឹកពីរទឹកទេ ។ តែអ្វីដែលល្អសំរាប់ខ្ញុំ គឺខ្ញុំមានទៅតាមលទ្ធភាពដែលរកបាន គឺឥតមានកេងប្រវ័ញ្ច និងជឿបុលនរណា រឺក៏ពុករលួយឡើយ ។ ខ្ញុំហ្នឹងហើយដែលគេហៅថា *អ្នកក្រត្រដររស់ក្បែរអ្នកមាន* ៕

*ថ្ងៃទី ១៧-០៩-០៧*

# ៤៣០. អាយុមិនអស់ មិនស្លាប់

**និយមន័យ**

បើមិនទាន់ដល់ពេលស្លាប់ មានគ្រោះថ្នាក់ក៏មិនស្លាប់ដែរ

## អត្ថាធិប្បាយ

នៅក្នុងសង្គមខ្មែរ គេតែងជឿថា មនុស្សគ្រប់គ្នាដែលមានជីវិតរស់នៅបានសុទ្ធតែរស់ទៅតាមចំណារព្រហ្មលិខិតទាំងអស់ ។ គឺថា បើព្រហ្មលិខិតកំនត់ឱ្យមនុស្សស្លាប់នៅអាយុប៉ុន្មាន បើមិនទាន់ដល់កំនត់នោះទេ គឺគេមិនទាន់ស្លាប់ឡើយ ។ ដូចជា :

- នៅឆ្នាំ ១៩៧០ ពួកខ្មាំងបានចាប់ទាហានរដ្ឋាភិបាល ១៥ នាក់ ។ ក្រោយពីបានពិចារណារួចវាឱ្យឈរតម្រង់ពីរជួរ ។ ជួរខាងឆ្វេងត្រូវកំទេច ជួរខាងស្តាំត្រូវដោះលែង ។ ពេលនោះទាហានម្នាក់នៅជួរខាងឆ្វេង ដកបារីពីហោប៉ៅដើរទៅសុំភ្លើងដុតពីអ្នកជួរខាងស្តាំ ។ ពេលកំពុងដុតបារី ខ្មាំងបានស្រែកឱ្យជួរខាងស្តាំត្រលប់ទៅផ្ទះ ។ អ្នកដុតបារីក៏ដើរទៅជាមួយគេរួចខ្លួនទៅ ។ ទៅតាមផ្លូវគេស្រែកក្អេងក្អាងថា *អាយុមិន ទាន់អស់ មិនស្លាប់ទេ* ។

- កាលទសវត្សរ៍ឆ្នាំ ៩០ មានយន្តហោះមួយគ្រឿងត្រូវផ្ទុះធ្លាក់នៅ ខាងលិចពោធិចិនតុង ។ អ្នកជិះយន្តហោះនោះត្រូវស្លាប់ទាំងអស់ សល់តែកូនក្មេងប្រុសម្នាក់

អាយុប្រមាណមួយខួបកន្លះ ។ គេថា ក្មេងនោះអាយុមិនទាន់អស់ទេ ។

- កាលឆ្នាំ ៨៤ នៅមុខផ្សារអូឡាំពិក មានក្មេងម្នាក់អាយុប្រមាណបីឆ្នាំធ្លាក់ពីលើផ្ទះថ្មមួយជាន់កន្លះមកលើកម្រាលថ្ម ។ បន្ទាប់ពីធ្លាក់មកក្មេងនោះក្រោកឡើងរត់រ៉ុយ ។ គេបាននាំក្មេងនោះទៅមន្ទីរពេទ្យ ។ ក្រោយពី ពិនិត្យសព្វគ្រប់រួចពេទ្យប្រាប់ថាគ្មានឃើញអ្វីគួរកត់សម្គាល់ទេ ។

ពេលនោះអ្នកខ្លះថា បានជាក្មេងនោះមិនស្លាប់ ព្រោះផែនដីលោកទ្រ ។ អ្នកខ្លះថា មកពីអាយុមិនទាន់អស់ អ្នកខ្លះថា ម៉េចថាស្លាប់កើត បើអាយុវា រីជីវិតវានៅមាន ៕

*ថ្ងៃទី ១៦-០៩-០៧*

❀❀❀❀

# ៤៣១. អ្នកដទៃ បើស្និទ្ធទុកជាញាតិ ញាតិបើឃ្លាត ទុកជាជាតិអ្នកដទៃ

**និយមន័យ**

ភាពសិទ្ធស្នាល គឺជាបងប្អូន គំលាតធ្វើឱ្យបែកញាតិ

**អត្ថាធិប្បាយ**

- **អ្នកដទៃបើស្និទ្ធទុកជាញាតិ**

ការស្រលាញ់រាប់អានគ្នាស្មោះអស់ពីពោះពុង និងមានទំនាក់ទំនងយ៉ាងជិតដិតស្និទ្ធស្នាលនឹងគ្នាខ្លាំង និងចេះជួយទុក្ខធុរៈគ្នាទៅវិញទៅមក ។ សមដូចពាក្យគេថា បានអ្វីបន្តិចក៏រំលែកចែកគ្នាដែរ ។ សកម្មភាពបែបនេះហើយដែលគេថា រួមសុខរួមទុក្ខជាមួយគ្នា គឺបើម្នាក់មានទុក្ខ ម្នាក់ទៀតក៏មានទុក្ខ បើម្នាក់បានសុខ ម្នាក់ទៀតក៏សប្បាយចិត្តដែរ ។

ករណីបែបនេះ ប្រសិនបើអ្នកនោះជាអ្នកដទៃសុទ្ធសាធ គ្មានជាប់ជាញាតិអ្វីបន្តិចក៏ដោយ ក៏លោកប្រាប់ថា ហ្នឹងហើយជាញាតិ ជាបងប្អូន ជាសាច់សាលោហិតរបស់ខ្លួន ។ ញាតិបែបនេះគេហៅថា *ញាតិពន្ធ* ។

- **ញាតិបើឃ្លាត ទុកជាជាតិអ្នកដទៃ**

បងប្អូនដែលជាប់វង្សត្រកូលជាមួយគ្នា គឺជាប់ខ្សែស្រលាយហូរហែមក រីក៏

បងប្អូនបង្កើតរួមឧទរជាមួយគ្នាក៏ដោយ ប្រសិនបើឃ្លាតគ្នាពុំសូវបានទឹកគិតដល់គ្នា និងពុំសូវមានទំនាក់ទំនងគ្នា គឺហាក់ដូចជាបោះបង់ចោលគ្នា ។ និយាយដោយហោចទៅ សូម្បីតែធ្វើបុណ្យសុទ្ធទានអ្វីក៏ពុំបានទឹកនាដល់គ្នាដែរ ។

វិការដ្ឋានបែបនេះ លោកថាទុកជាជាតិអ្នកដទៃ ព្រោះគេបាត់បង់អស់នូវទំនាក់ទំនងផ្លូវចិត្ត និងផ្លូវសកម្មភាព ។

គំលាតឆ្ងាយនេះ លោកមិននិយាយយោងទៅដល់គំលាតឆ្ងាយផ្លូវកាយផងទេ ។ ព្រោះគំលាតនេះ ទោះបីគេឃ្លាតឆ្ងាយនៅរំលងទ្វីបរំលងសមុទ្រក៏ដោយ បើទំនាក់ទំនងគ្នានៅតែមាន ក៏ទុកដូចជានៅជិតដែរ ។

គំលាតទាំងផ្លូវចិត្ត ទាំងផ្លូវសកម្មភាពបែបខាងលើនេះលោកថាញាតិបែបនេះ *ទុកជាជាតិអ្នកដទៃ*។

*ថ្ងៃទី ១៨-០៩-០៧*

❀❀❀❀

# ៤៣២. អង្ករក្លាយជាបាយ

**និយមន័យ**

កំលាយបាត់បង់ភាពដើមកែលែងបាន

**អត្ថាធិប្បាយ**

ពាក្យទំនឹមទំនៀមនេះ ទើបនឹងលេចឮក្នុងទសវត្សរ៍ថ្មីៗនេះទេ ។ គឺប្រហែលនៅក្នុងទសវត្សរ៍ ១៩៩០ នេះឯង ។

គោលបំនងរបស់លោកអ្នកបង្កើតពាក្យនេះឡើង គឺចង់និយាយពីករណីណាដែលបានធ្វើជ្រុលហួសទៅហើយនោះ ហើយរកមធ្យោបាយទប់ទល់ រឺដោះស្រាយតាមការជាក់ស្តែង ។ ដូចជា :

- នាយសំរូប យកអង្ករទៅផ្ញើនឹងនាយ សរិត ។ នាយសរិត ក៏យកអង្ករនោះទៅដាំបាយ អាស្រ័យអស់ទៅ ស្រាប់តែនាយសំរូបមកទារយកអង្ករ ។ សរិតថា ធ្វើម៉េចបើអង្ករអ្នកឯងក្លាយជាបាយទៅហើយ ។ ដូច្នេះ ចាំខ្ញុំចេញថ្លៃអង្ករសងវិញចុះ ។

- ជាងឈើម្នាក់ធ្វើតុមួយរាងបួនជ្រុងស្មើ ពេលម្ចាស់បញ្ជាមកយក គេថា ម៉េចក៏ធ្វើបួនជ្រុងស្មើ ខ្ញុំឱ្យធ្វើបួនជ្រុងទ្រវែងទេតើ ។ ជាងថា ធ្វើម៉េច អង្ករក្លាយជាបាយទៅហើយ ចាំខ្ញុំលក់តុនេះយកលុយទិញឈើធ្វើតុរាងទ្រវែងជូន ។

- ឪពុកម្តាយកូនប្រុសនិយាយនឹងម៉ែឪកូនស្រីថា ធ្វើម៉េចទៅបើអង្ករក្លាយជាបាយទៅហើយ មានតែរៀបការឱ្យវាតែម្តងទៅបានទេ ? ការចំនាយក្នុងពិធីនេះស្រេចលើខ្ញុំខាងប្រុសទៅចុះ ។

ករណីដែលជ្រុលហួស បាត់បង់ភាពដើមក្លាយទៅជាភាពមួយទៀតបែបនេះហើយហៅថា **អង្ករក្លាយជាបាយ** ៕

*ថ្ងៃទី ១៨-០៩-០៧*

✿✿✿✿

# ៤៣៣. អ្នកក្រមិនហ៊ាន អ្នកមានមិនចូល

**និយមន័យ**

ស្ទាក់ស្ទើរ ទាំងលើទាំងក្រោម

## អត្ថាធិប្បាយ

នៅក្នុងសហគមខ្មែរ ការរៀបអាពាហ៍ពិពាហ៍ដើម្បីបង្កើតជាគ្រួសារមួយ គឺជាប្រពៃណីខ្មែរតាំងពីបុរាណកាល ។ គេសង្កេតឃើញថា ទោះបីយុវជន យុវនារី នោះមានសម្ផស្សរាងខ្សោយបន្តិចក៏ដោយ ក៏ចេះតែមានគូស្រករទាំងអស់ ។ ព្រោះថា បើម្នាក់មិនត្រូវ ក៏មានម្នាក់ទៀតត្រូវដែរ ។

ប៉ុន្តែ ខ្លឹមសារខាងលើនេះ លោកចង់និយាយពីនារីមួយចំនួនតូចដែលស្ថិតនៅក្នុងភាពក្រមុំរហូតអស់មួយជីវិត ។ នារីប្រភេទនេះ ភាគច្រើនៗរស់នៅក្នុងស្ថានភាពគ្រួសារថ្នាក់កណ្តាល ។ជួនថែមមានទាំងសោភណភាពស្រស់ទៀតផង ។ ប៉ុន្តែឥតមានបុរសណាចូលមកចែចូវសោះ ជួនកាលនាងនោះមានទ្រព្យច្រើនតែរូបអាក្រក់ក៏មាន ។

- **អ្នកក្រមិនហ៊ាន**

អ្នកក្រពេលនេះ លោកសំដៅយកបុរសណាដែលមានធនធានទាបជាងនារីដែលជាកម្មវត្ថុក្នុងន័យខាងលើនេះ ។ បុរសថ្នាក់ទាបជាងនេះ ចេះតែមានការស្ទាក់ស្ទើររារែកក្នុងចិត្តមិនហ៊ានចូលស្តី ទោះបីខ្លួនស្រលាញ់ពេញចិត្តយ៉ាងណាក៏ដោយ ។

ព្រោះគេនឹកបារម្ភថា ក្រែងឪពុកម្តាយ រឺសាមីខ្លួននាងនោះមិនគាប់អធ្យាស្រ័យ ព្រោះឯងក្រជាងគេ ។

ម្ល៉ោះហើយ គេបានត្រឹមតែលួចស្រលាញ់តែម្នាក់ឯង រួចហើយក៏ហឺទៅ ។

- **អ្នកមានមិនចូល**

អ្នកដែលមានភោគទ្រព្យច្រើនជាងនាង គេសំលឹងមើលឃើញនាងហ្នឹងហាក់ដូច ជាក្រជាងខ្លួន ។ ដូច្នេះគេសំលឹងរកនាងណាដែលមានធនធានដែលគេយល់ថាល្មម សមនឹងខ្លួនគេ ។ ម្ល៉ោះហើយគេក៏មើលរំលងហួសនាងទៅទៀត ។

កម្មវត្ថុដែលស្ថិតនៅត្រង់ចន្លោះអ្នកមាន និងអ្នកក្រជាងបែបនេះ តំរូវឱ្យនាងនៅយូរ រឺនៅលីវរហូត ។ *ព្រោះតែអ្នកក្រមិនហ៊ាន អ្នកមានមិនចូល* ៕

*ថ្ងៃទី ១៨-០៩-០៧*

❀❀❀❀

# ៤៣៤. អូសឫស្សីបញ្ច្រាសចុង

**និយមន័យ**

ភាពរឹងរូសដែលគេពិបាកទូន្មានប្រៀនប្រដៅ

**អត្ថាធិប្បាយ**

ឫស្សីពេលនេះលោក សំដៅយកឫស្សីទាំងដើមទាំងចុងដែលគេមិនទាន់លួសមែក និងស្លឹក គឺនៅច្រងេងច្រងាង ។

❖ **អត្ថានុរូប**

បើគេចាប់ចុងឫស្សីអូសបញ្ច្រាសដូចអត្ថន័យខាងលើនេះ ។ គេប្រាកដជាពិបាកអូសណាស់ ។ ព្រោះមែក ច្រងេងច្រងាងប្រទីងប្រទាំងទាក់ចាក់ដី ធ្វើឱ្យអំនូសនេះមានភាពតឹងដោយសារតែមែកវាត្របាំងបាស់ ។

❖ **អត្ថប្បដិរូប**

លោកបានធ្វើបំរៀបធៀបអំនូសឫស្សីបញ្ច្រាសចុងនេះទៅលើ មនុស្សណារបឹងរឹងរូសដែលគេអប់រំ រឺទូន្មានប្រៀនប្រដៅបានដោយលំបាក ។ ព្រោះមនុស្សរបឹងនេះ មានអស្មិមានះមិនងាយស្តាប់ដំបូន្មានជនណាឡើយ ម្ល៉ោះហើយអ្នកប្រៀនប្រដៅមានការតានតឹងក្នុងចិត្តជាខ្លាំង ។ សមដូចពាក្យលោកថា *តឹងដូចអូសឫស្សីបញ្ច្រាសចុងអីចឹង* ៕

*ថ្ងៃទី ២៦-០៩-០៩*

❀❀❀❀

# ៤៣៥. អ្នកមានសក្តិ មិនស្មើអ្នកមានយស

**និយមន័យ**

អ្នកមានបុណ្យសក្តិ បើគ្មានគេស្រលាញ់ចាញ់អ្នកសាមញ្ញមានគេរាប់អានច្រើន

**អត្ថាធិប្បាយ**

អ្នកមានសក្តិ សំដៅយកអ្នកដែលមានឋានន្តរសក្តិជាមន្ត្រីថ្នាក់នេះ ថ្នាក់នោះ តាំងពីថ្នាក់ទាបរហូតដល់ថ្នាក់លើមែនទែន ។

ធម្មតាអ្នកមានបុណ្យសក្តិ តែងមានមហាជនគោរពកោតក្រែងរអែងចេស្តាណាស់ ។ ព្រោះអ្នកមានបុណ្យសក្តិតែងមានអំនាច ។ បើគេកាន់តែធំ អំនាចគេក៏កាន់តែខ្លាំងក្លាណាស់ដែរ ។ ដូច្នេះអ្នកមានបុណ្យសក្តិណាដែលធ្វើឱ្យគេខ្លបខ្លាចរអារដូចខ្លាចសត្វខ្លាសាហាវនោះ រមែងទទួលនូវសំអប់ជាច្រើនពីមហាជនទូទៅ ដូចជាពេលជួបមុខ គេអោនលំទោនគោរពខ្លបខ្លាច ពេលទៅហួសផុតគេពេបមាត់ ជួនគេលួចជេរម្រ៉ាយតាមក្រោយទៀតផង ។

រីឯអ្នកមានយសវិញមិនបាច់មានបុណ្យសក្តិធំទេ សូម្បីតែមន្ត្រីតូចតាចក៏មានគេគោរពស្រលាញ់រាប់អានគ្រប់គ្នាដែរ ។ ទោះគេទៅទីណាក៏មិនខ្វះអ្នកចោមរោមអបអរសាទរស្នេហ៍ស្និទ្ធគ្រមេត្រីឡើយ ។

អ្នកមានយស មិនចាំបាច់មានមុខងារជាមន្ត្រីទេ សូម្បីតែជនសាមញ្ញធម្មតាក៏ដោយ ឱ្យតែមានគេស្រលាញ់រាប់អានច្រើន លោកថាមាន **យស** ហើយ ៕

*ថ្ងៃទី ១៨-០៩-០៧*

❀❀❀❀

# ៤៣៦. អ្នកមានរក្សាខ្សត់ ដូចសំពត់ព័ទ្ធពីក្រៅ អ្នកប្រាជ្ញរក្សាខ្លៅ ដូចសំពៅនូវសំប៉ាន

**និយមន័យ**

អ្នកមាន និង អ្នកក្រត្រូវមានការប្រស្រ័យនឹងគ្នា

**អត្ថាធិប្បាយ**

អ្នកមាននៅពេលនេះ លោកសំដៅយកអ្នកដែលមានភោគទ្រព្យច្រើន ។

ពាក្យស្លោកខាងលើនេះ លោកពោលថា អ្នកមានទ្រព្យសម្បត្តិប្រើប្រាស់ច្រើន គឺអ្នកមានធនធានស្តុកស្តម្ភ និងជាអភិជន ក៏ត្រូវតែធ្វើខ្លួនឱ្យបានជាទីពឹងដល់អ្នកក្រខ្សត់ទុគ៌តដែរ ។

លោកប្រៀបថា អ្នកក្រខ្សត់ទុកដូចជាសំពត់ខោអាវដែលរុំព័ទ្ធរាងកាយ ។ ព្រោះថា បើទោះជាគេមាន រូបរាងកាយស្អាតស្រស់សង្ហាយ៉ាងណាក៏ដោយ បើអត់មានសំលៀកបំពាក់បិទបាំងរាងកាយទេ ។ ពេលគេដើរទៅណាមកណាទាំងរាងកាយអាក្រាតនន្ទលគក ។ គេជឿថា ប្រាកដជាឆ្កែព្រូសបែកបំពង់-កងាប់មិនខាន ព្រោះ វាស្មានថា បរជីវតួប្រែតរដូវបុណ្យភ្ជុំមករកស៊ីអន្សម ។

ដូច្នេះ អ្នកមានភោគទ្រព្យត្រូវរាប់អានអ្នកក្រខ្សត់ឱ្យបានល្អ ។ ព្រោះជនប្រភេទនេះហើយដែលការពារ និងហែហមជាបរិវារឱ្យអ្នកមានឱ្យបានប្រសើររុងរឿងមានកិត្តិនាមទៅបាន ។ សមដូចពាក្យចាស់លោកថា *នាយថ្មើងដ្បិតពលរក្សាឱ្យសុខ* ។

ខួបកំណើត លី សុដានី *ថ្ងៃទី ២០-០៩-០៧*

# អ្នកប្រាជ្ញរក្សាខ្លៅ ដូចសំពៅនូវសំប៉ាន

**និយមន័យ**

បញ្ញវន្ត ត្រូវមានការប្រស្រ័យល្អនឹងអ្នកអវិជ្ជា

**អត្ថាធិប្បាយ**

**សំពៅ** = នាវាសមុទ្ទមានមាឌធំមានស្លាបក្តោងច្រើន លឿនដោយសារចរន្ត ខ្យល់ មិនអាចចតនៅទឹករាក់បានទេ ។

**សំប៉ាន** = ទូកអុំតំលើងក្តា ៥សន្លឹក ក្បាលនិងកន្សៃរាង-ង មានសណ្ឋានដូច ទូកផ្កាចារដែរ ។

**អ្នកប្រាជ្ញរក្សាខ្លៅ** ពាក្យនេះ ពុំមានន័យថា : អ្នកប្រាជ្ញត្រូវរក្សាអ្នកខ្លៅ អោយនៅតែខ្លៅរហូតនោះទេ ។ គឺមានន័យថា : ត្រូវរាប់អានប្រស្រ័យ និងជួយផ្គត់ផ្គង់គ្នាផង ។

អ្នកប្រាជ្ញទុកដូចជាសំពៅដែលមានមាឌធំផ្ទុកទំនិញបានច្រើន ។ ប៉ុន្តែ បានតែ នៅលើទឹកជ្រៅទេ បើនឹង ចូលចតដល់ច្រាំងគឺមិនបានសោះឡើយ ។ ដូច្នេះ ធ្វើម្តេច បានទំនិញទៅដល់គោក ទាល់តែពឹងសំប៉ានឱ្យជញ្ជូនជាបន្តទៅទៀត ។

បំរៀបធៀបម្យ៉ាងទៀតថា អ្នកប្រាជ្ញដូចជាវិស្វករគូរប្លង់ផ្ទះ ។ ឯអ្នកល្ងង់ ខ្លៅដូចជាកម្មករសំនង់ ។ ពួកកម្មករនេះហើយជាអ្នកដឹកជញ្ជូនសំភារៈ រឺជាអ្នក សាងសង់។ ម្ល៉ោះហើយអ្នកទាំងពីរពួកនេះតោងប្រស្រ័យគ្នា ទើបធ្វើសំនង់បាន។ ព្រោះ បើឱ្យអ្នកល្ងង់គូរប្លង់ផ្ទះប្រាកដជាវង្វេងហើយ មិនដឹងជាត្រូវដាក់អ្វីត្រង់ណាទេ។ ឯ អ្នកប្រាជ្ញក៏មិនអាចមកជញ្ជូនឥដ្ឋកើតដែរ ។

អាស្រ័យហេតុនេះហើយ បានជាលោកថា អ្នកប្រាជ្ញត្រូវតែមានទំនាក់ទំនង នឹងអ្នកល្ងង់ខ្លៅផងដែរ ៕ *ថ្ងៃទី ២១-០៩-០៧*

❀❀❀❀

# ៤៣៧. អាមិនដឹងខ្យល់

**និយមន័យ**

អ្នកមិនឈ្លាសវៃតាមព្រឹត្តិហេតុដែលកើតមានជាក់ស្តែងនៅចំពោះមុខ និងមិនចេះបត់បែនតាមសភាពការណ៍

## អត្ថាធិប្បាយ

**- អាមិនដឹងខ្យល់**

នេះគឺជាពាក្យជំនេររបស់ចាស់បុរាណ ដែលបង្កប់នូវន័យយ៉ាងជ្រៅសំរាប់ឱ្យអនុជនជំនាន់ក្រោយលើកយកមកត្រិះរិះពិចារណា ។

" **ខ្យល់** " នៅពេលនេះ គឺសម្គាធខ្យល់អំនាចនៃអ្នកឈ្នះ ។ ធម្មតាអ្នកឈ្នះពេលឡើងកាន់អំនាច គេតែងជំរះបញ្ជីចាស់ចោល គឺវាយប្រហារកាប់សំលាប់នូវអ្នកចាញ់ និងអ្នកជាគូបដិបក្សណាដែលមិនសំរបខ្លួនតាម ចរន្តខ្យល់អំនាចរបស់គេ ។

ដូច្នេះជំនេរនេះ លោកពោលសំដៅមនុស្សណាដែលល្ងង់មិនយល់នូវព្រឹត្តិការណ៍ដែលកំពុងកើតមានជាក់ស្តែងនៅចំពោះមុខ ។ ព្រោះថា ការមិនយល់ រឺយល់មិនទាន់សភាពការណ៍ដែលកំពុងមាន រឺក៏បត់បែនមិនស្របនឹងសភាពការណ៍ នឹងនាំមកនូវការវិនាសអន្តរាយដល់ខ្លួន ជួន រហូតដល់បាត់បង់ជីវិតទៀតផងក៏មាន ។ ដូចជា :

- ពេលមានរដ្ឋប្រហារដណ្តើមអំនាចគ្នាម្តងៗ អ្នកឈ្នះឥតញញើតដៃនឹងសំលាប់អ្នកចាញ់ និងអ្នកណាដែលរត់បញ្ច្រាសនឹងចរន្តខ្យល់ជោគជ័យរបស់គេ ។

- ពេលបដិវត្តន៍របស់ពួកទមិឡឥតសាសនា បីឆ្នាំប្រាំបីខែដប់ប្រាំបួនថ្ងៃ ដប់ពីរម៉ោង និងសាមសិបនាទី ។ ពួកវាកាប់សំលាប់យ៉ាងសាហាវជាទីបំផុត ដូចជាចាប់ជើងកូនក្មេងបោកផ្ទប់នឹងគល់ឈើ អារ-ក, កប់ទាំងរស់, រុំចំបើងដុតទាំងរស់ ចងដៃចងជើង វះពោះបារយកពោះវៀន អារ-កនឹងធាងត្នោត និងចោះខ្នងកាត់យកប្រមាត់ ត្រាំស្រាផឹក ។ល ។

អំពើយង់ឃ្នង់យ៉ាងព្រៃផ្សៃនេះ វាធ្វើទៅលើអ្នកដែលជាគូបដិបក្ស និងអ្នកដែលមិនចេះសំរបខ្លួនទៅតាមបណ្តោយចរន្តខ្យល់អំនាចរបស់វា ។ ព្រោះវាមានពាក្យស្លោកថា កង់ប្រវត្តិសាស្ត្រវិលទៅមុខហើយ អ្នកណាតាមមិនទាន់នឹងទៅចោលហើយ ។ ឯអ្នកណាដែលចង់រារាំងកង់ប្រវត្តិសាស្ត្រសុទ្ធតែគ្រោះថ្នាក់ទាំងអស់ (សម្លាប់) បើហ៊ានលូកដៃ-ដាច់ដៃ បើហ៊ានលូកជើង-ដាច់ជើង ។ល ។

អ្នកដែលដើរបញ្ច្រាសចរន្តអំនាចរបស់វានេះហើយដែលលោកជេរថា **អា មិនដឹងខ្យល់** ៕

*ថ្ងៃទី ២៣-០៩-០៧*

✿✿✿✿

# ៤៣៨. អំបិលកំពុងស្អុយ

**និយមន័យ**

អ្វីដែលគ្រប់គ្នាជឿថាល្អ សុក្រិត្យបែរជាលាមក

**អត្ថាធិប្បាយ**

ពាក្យទំនឹមទំនៀមនេះ ទើបតែនឹងលេចឮឡើងនៅចុងទសវត្សរ៍ឆ្នាំ ២០០១ នេះដោយលោកអគ្គបណ្ឌិត **ម៉ុត សារ៉ាវន្ត** ។

**អំបិល** គឺជាសារធាតុម្យ៉ាងមានរសជាតិប្រៃសំរាប់ប្រលាក់សាច់ រឺផ្លែឈើដើម្បីទប់ស្កាត់ភាពរលួយស្អុយ ។

គោលបំនងរបស់លោកដែលបង្កើតពាក្យនេះឡើងគឺក្នុងន័យរិះគន់ រឺតិះដៀលនូវជនណាដែលគេជឿថា ជាអ្នកធ្លាប់ប្រព្រឹត្តតែភាវៈល្អ សុក្រិត្យ ប្រកាន់ខ្ជាប់ព្រហ្មវិហារធម៌ស្រាប់តែបែរមកប្រព្រឹត្តអំពើលាមកថោកទាបគួរឱ្យខ្ពើមឆ្អើម ។ ដូចជា :

- បព្វជិតអលជ្ជីខ្លះ( អ្នកបួសឥតកេរ្តិ៍ខ្មាស ) ដែលមកជ្រកក្នុងព្រះពុទ្ធសាសនាបែរមកប្រព្រឹត្តអំពើអនាចារដូចជា :

- ដើរថតចំរៀងស្នេហា ខារ៉ាអូខេ និងរូបភាពអាសអាភាសដាក់ទូរសព្ទ វីស៊ីឌី យកទៅមើលលេង ។

- អ្នកបួសខ្លះ ចិញ្ចឹមជីវិតតាមបែបប្រព្រឹត្តអនេសនៈ២១ និងបាបធម៌ ៥ យ៉ាង ( ការស្វែងរកលាភខុសនឹងពុទ្ធប្បញ្ញត្តិ ) ដូចជាធ្វើគ្រូមន្តអាគមអូមអាមជាដើម ។

- អ្នកបួសខ្លះ ចេះញ៉ោះញ៉ោះ និងស្រ្តីភេទរហូតឈានទៅដល់បរាជិកភាព ។

- មន្ត្រីរាជការខ្លះ ប្រព្រឹត្តអំពើពុករលួយកេងប្រវ័ញ្ច និងលួចយកសម្បត្តិរដ្ឋ រឺសម្បត្តិរួមមកធ្វើជាសម្បត្តិផ្ទាល់ខ្លួន ។

អ្នកដែលតែងទូន្មានអប់រំគេឱ្យប្រព្រឹត្តអំពើល្អ អំពើសុចរិតគ្រប់ពេល ។ ប៉ុន្តែខ្លួនឯងបែរមកប្រព្រឹត្តអំពើ អនាចារ អសីលធម៌ អំពើលាមកយ៉ាងថោកទាប ។

លោកអគ្គបណ្ឌិត *ប៊ុត សាវង្ស* បង្កើតពាក្យពំនោលនេះឡើងក្នុងគោលបំនងជួយកែតម្រូវអ្នកដែលដើរខុសផ្លូវច្បាប់ និងប្រាសចាកផ្លូវពុទ្ធសាសន៍ឱ្យបានដឹងខ្លួនឡើងវិញ ៕

*ថ្ងៃទី ២៥-១១-០៧*

❀❀❀❀



# ៤៣៩. អសារក្ដីបី បណ្ដាំមេ-ជី ព្រេងព្រឹទ្ធប្រដៅ អន្តរ-សសុទ្ធ ចំអិនឱ្យឆៅ ពិសីហើយខ្លៅ ប្រាជ្ញឥតមារយាទ

**និយមន័យ**

មនុស្សបីប្រភេទដែលឥតខ្លឹមសារ

**អត្ថាធិប្បាយ**

**✳ អសារក្ដីបី**

**- អសារៈ** គឺអ្វីដែលឥតខ្លឹមសារ, ឥតប្រយោជន៍, ឥតអំពើ, ឥតបានការ, ឥតបានផល, ឥតតំលៃ ។ល ។

ក្នុងន័យខាងលើនេះ *ព្រះរាជសម្ភារ* ទ្រង់ត្រាស់សំដៅយកមនុស្សបីប្រភេទថាជាមនុស្សឥតខ្លឹមសារ ។

**✳បណ្ដាំមេ-ជី ព្រេងព្រឹទ្ធប្រដៅ**

**មេ-ជី ( មេបា + ជីដូនជីតា)**

ក្នុងន័យខាងលើនេះ គឺជាពាក្យផ្ដែផ្ដាំប្រៀនប្រដៅរំលឹកទូន្មានរបស់ព្រឹទ្ធាចារ្យតាំងពីបុរាណកាលមក គឺលោកពោលសំដៅយកមនុស្សបីប្រភេទ ដូចខាងក្រោមនេះ

**✳ អង្ករ-សសុទ្ធ ចំអិនឱ្យឆៅ**

- **អង្ករ-សសុទ្ធ** : នៅពេលនេះ ទ្រង់ត្រាស់សំដៅយកអង្ករដែលគ្មានល្បាយ និង មានសំបុរ-ស ស្មើរជាអង្ករដើម ។ វាមានគ្រាប់រលូន សឹងតែគ្មានបាក់មួយគ្រាប់ណាសោះ ពោលគឺជាអង្ករ ល្អប្រណីត...

- **ចំអិនឱ្យឆៅ** : ក្នុងន័យនេះដែរ ទ្រង់ត្រាស់យោងទៅដល់មនុស្សខ្លះដែលបានរបស់ល្អហើយតែល្ងង់ មិនចេះប្រើប្រាស់ឱ្យសមស្របទៅតាមតំលៃ រឺគុណភាពរបស់នោះ ។ ដូចជា :

- អ្នកខ្លះយកឈើ បេង នាងនួន ផ្ចឹក សុក្រម យកទៅធ្វើដងអំបោសជណ្ដើរផ្ទះ រឺសសរខ្ទមជាដើម ។

- អ្នកខ្លះ បានវត្ថុល្អដូចជា " ទូរសព្ទដៃ " យ៉ាងទំនើបទាន់សម័យតែមិនចេះប្រើ ។ គេប្រឹងចុចចុះចុចឡើង ទីបំផុតក៏ខូចអស់ទៅ ។

- អ្នកខ្លះជាមេកោយគេ ដែលមានបុគ្គលិកក្រោមឱវាទជាអ្នកចេះដឹងច្រើនតែខ្លួនឯងល្ងង់មិនចេះចាត់តាំងឱ្យធ្វើការទៅតាមសមត្ថភាព ឬជំនាញរបស់គេ ។

ពំនោលដូចខាងលើនេះ សុទ្ធសឹងតែជាអ្នកបាន*អង្ករ-សសុទ្ធចំអិនឱ្យឆៅទាំងអស់* ។

**✳ ពិសីហើយខ្លៅ ប្រាជ្ញឥតមារយាទ**

**ពិសីហើយខ្លៅ** : ទ្រង់ត្រាស់ទៅលើនារីណាដែលមានរូបសម្ផ័ទស្អាតស្រស់ប្រិមប្រិយគួរជាទីគយគន់ ។ ប៉ុន្តែ បែរជាល្ងង់ខ្លៅទៅវិញ ពោលគឺគ្មានចេះគេហកិច្ច

និងគ្មានចំនេះដឹងទាំងផ្លូវលោក ទាំងផ្លូវធម៌មិនសោះឡើយ ។ សមដូចពាក្យបុរាណាចារ្យ ពោលថា : *ស្អាតតែរូប តែម្ហូបមិនឆ្ងាញ់* ។

**គ/ប្រាជ្ញឥតមាយាទ** : ន័យនេះ ទ្រង់សំដៅយកមនុស្សដែលមានចំនេះដឹងខ្ពស់គួរជាទីកោតក្រែងពីមហាជន ។ ប៉ុន្តែគេបែរជាមានមារយាទទាប មិនថ្លៃថ្នូរ គឺគេប្រព្រឹត្តតែអំពើអនាចារ អសីលធម៌ ពោលគឺ គ្មានចរិយាសម្ប័ទ និងសុជីវធម៌ដូចជា : ដើរលេងស៊ីផឹក ឡូឡាឥតសណ្តាប់ធ្នាប់ គឺគេរស់នៅក្នុងសហគមន៍ ហាក់ដូចជាមនុស្សបំព្រៃលោក ។ គឺធ្វើឱ្យលោកទៅជាព្រៃស្អុក ។

ពំនោលទាំងបីគឺ : *អង្គរ-សសុទ្ធ ចំអិនឱ្យឆៅ ពិសីហើយខ្លៅ និងប្រាជ្ញឥតមារយាទ នេះឯងហើយ ដែលលោកថា អសារក្តីបី* ៕

*ថ្ងៃទី ២៣-០៥-១០*

❀❀❀❀






# ៤៤០. អន្ទិតគោលោត

**និយមន័យ**

អ្នកដែលសឹកពីបួស តែជាមនុស្សកញ្ឆោត និងឡើងជំនោរ ដោយស្រី១ បញ្ឆោរ

## អត្ថាធិប្បាយ

ពំនោលនេះ គឺជាពាក្យបង្អាប់ចំពោះអ្នកដែលសឹកពីបួសតែឆោត ជាពិសេស គឺស៊ីខ្សែជោរនឹងស្រី១ ។ អន្ទិតនោះស្រី១បញ្ឆោត និងបញ្ឆោរបានដោយងាយបំផុត ។ ដូចមានរឿងដំនាលថា :

មានអន្ទិតម្នាក់ទើបសឹកពីបួសមកធ្វើចំការដាំពោត ។ នៅពេលដែលពោត កំពុងពេញសាច់ ក៏មានស្ត្រីក្រមុំរូបស្រស់ម្នាក់មកញ៉េះញ៉ោះលែបខាយពាក្យសំដី និយាយថា : លោកបងអើយ លក់ពោតក្នុងចំការនេះឱ្យខ្ញុំសិនមក ។ ចាំសណ្តែកខ្ញុំទុំ ខ្ញុំលក់យកលុយសងលោកបងឯងវិញ ។ អ្នកអន្ទិតនោះក៏ព្រមលក់ជឿឱ្យនាងនោះទៅ ។ លុះដល់នាងនោះច្រូតសណ្តែកលក់ នាងនោះនិយាយទៀតថា លោកបងអើយ សណ្តែកខ្ញុំស្កកច្រើនណាស់ មកពីខ្ញុំជាស្រីមិនសូវចេះធ្វើចំការ មិនដូចលោកបងឯង ជាប្រុស ប៉ិនធ្វើចំការយ៉ាងចំនាប់គួរឱ្យស្រលាញ់ នាងណាបានលោកបងឯងធ្វើប្តី ពិតជា មានសំនាងធំហើយ ។ ដោយស៊ីខ្សែជោរស្រាប់ អន្ទិតនោះក៏នៅស្ងៀមជាសញ្ញា យល់ព្រម ។ ក្រោយមកគេឥតបានលុយថ្លៃពោតនោះសោះ ។

អ្នកផងទាំងពួង កាលបើបានដឹងរឿងនេះហើយ ក៏នាំគ្នាសើចចំអក និងបង្អាប់ថា : អន្ទិតគោលោតអើយ អីក៏ឆោតល្ងង់ម្លេះ ។ ចាប់តាំងពីថ្ងៃនោះមក ពាក្យថា អន្ទិតគោលោតក៏ចាប់ឮជារបហូតមក ។ បន្ទាប់មកបុរាណាចារ្យក៏ចងជាពាក្យស្លោកថា : " **អន្ទិតគោលោត ឱ្យស្រីបញ្ឆោត អស់ពោតមួយចំការ**( ពាក្យស្លោក វចនានុក្រមខ្មែរ ) " ៕

*ថ្ងៃទី ២៥-១០-០៩*

❀❀❀❀



# ៤៤១. អក្កោធេន ជិនេ កោធំ

**និយមន័យ**

" **ពៀរ** " រម្ងាប់ដោយការមិនចង **ពៀរ**

## អត្ថាធិប្បាយ

ព្រះអនាវរណញ្ញាណ ជាអម្ចាស់ ទ្រង់ក្រាលសំនាញ់ញាណប្រមើលមើលនូវឧបនិស្ស័យ វេនេយ្យសត្វ គឺសត្វដែលអាចទូន្មានបាន ជាមុនសិន ទើបស្ដេចយាងទៅប្រោសសត្វនោះ ។

នៅពេលនេះ ព្រះបរមសាស្ដ្រាចារ្យនៃយើង ទ្រង់បង្រៀនដល់ពុទ្ធបរិស័ទទាំងឡាយថា : " *បើកាលណាបុគ្គលមានសេចក្ដី ក្រោធ កើតឡើងហើយ. មោហៈ គឺសេចក្ដីវង្វេងក៏កើតឡើងព្រមពេលបន្ទាប់គ្នា* ។ កាលណាមោហៈកើតឡើងហើយសត្វលោកតែងកើតគំនិតចងគំនុំព្យាបាទគ្នា. សងសឹកគ្នា. ប្រទូសរ៉ាយគ្នា ។ ទាល់តែបានសងសឹកគ្នារួច ទើបអារម្មណ៍ គេនៅស្ងៀមលែងស្កុះពុះកញ្ជ្រោលបាន ។

ប៉ុន្តែ ភាគីម្ខាងទៀតនោះ គេក៏មិនអាចតាំងចិត្តនៅឱ្យស្ងប់ស្ងៀមបានឡើយ ។ ម្ល៉ោះហើយគេក៏ប្រឹងរិះរកមធ្យោបាយយ៉ាងណា ដើម្បីប្រទូស្តតបត្រលប់មកវិញជាមិនខាន ៕

*ថ្ងៃទី ៣០-១១-១០*

✿✿✿✿

# ៤៤២. អំពិលអំពែកទំមែកព្រុទ្រា ព្រឹតៗគ្រប់គ្នាថាឯងភ្លឺ ឫស្សីឥតថ្នាំង គោំងលែងលឺ ទោចខែភ្លឺ ខ្លីតងទឹតសួន្យ

**និយមន័យ** : ភ្លើតភ្លើនភ្លេចអត្តសញ្ញាណខ្លួន និងទំរើប្រាសចាកទំលាប់តាម ទំនើង

## អត្ថាធិប្បាយ

ពាក្យទំនីមទំនៀមខាងលើនេះ លោកពោលបែបជាបុគ្គលាធិដ្ឋាន គឺពោលសំដៅយកបុគ្គលជាទីតាំង និងពោលសំដៅយកបុគ្គលអ្នកសំរេចនូវអំពើទាំងពួង ។

**ក/អំពិលអំពែក** : ពួកសត្វតូចសន្តានដង្កូវ មានពន្លឺព្រាកៗនៅក្រោមពោះត្រង់ចុងកន្ទុយ ភ្លឺតែក្នុងវេលាយប់ងងឹត. ឈ្មោលមានស្លាបហើរបាន. ញីឥតស្លាបទេ គឺជាពពួកសត្វរាត្រីចរ ។

**ខ/មែកព្រុទ្រា** : ជាទីតាំងដែលវាចូលចិត្តរស់នៅ. ព្រោះទីនោះសំបូរទៅដោយចំនីរបស់វា ។

**គ/ព្រឹតៗគ្រប់គ្នាថាឯងភ្លឺ** : នៅវេលាយប់វាបញ្ចេញពន្លឺព្រោងព្រាតដើម្បីបំភ្លឺរកចំនីស៊ី ។

**ឃ/ឫស្សីឥតថ្នាំង** : ជាធម្មតាឫស្សីតែងមានថ្នាំងខណ្ឌៗហួរហែតាមដើម រហូតបង្កើតបានជាបន្ទប់ខ្យល់នាំឱ្យវាអណ្តែតលើទឹកបាន និងនាំឱ្យវាមានជំហរ រឹងពឹងបានផង ។

**ខ/រគាំង** : វត្ថុសិតពីលង្ហិនរាងសំប៉ែតមូលដូចវង់ខែ ខ្លះមានបាមជាកណ្ដាប់ជុំវិញ ខ្លះលាតស្មើ។ តែមានដោះតូចនៅចំកណ្ដាលដូចគ្នា។ ដោះនេះ សំរាប់គោះឱ្យលឺសំលេងស្រួយរនន់ គឺសូរសព្ទញ័ររន្ទាន់ (Vibration)។

សូរសព្ទរគាំង ជាសញ្ញាដង្ហោយហៅ និមន្ត អញ្ជើញ ចូលរួមប្រកបពិធីផ្សេងៗ សូត្រធម៌ ឆាន់ចង្ហាន់ ។ល។ ក្រោយមក ដោយគ្មានអ្នកផលិតរគាំង គេក៏យកបន្ទះលោហៈអ្វីក៏ដោយឱ្យតែគោះទៅលឺសំលេងខ្លាំងបាន ដូចជាបន្ទះដែកធំ ខ្នងកង់ឡាន... គេសន្មតថាជារគាំងទាំងអស់។

រគាំងនេះ គេតែងលឺសំលេងជាញឹកញាប់នៅក្នុងវត្តអារាមព្រះពុទ្ធ សាសនា។

**ច/រនោចខែភ្លឺ ខ្នើតខទឹតសូន្យ** : ជាប្រក្រតី រនោច គឺពន្លឺដួងខែរោចទៅ ហោចទៅ ថយទៅ តិចទៅ។ ឯខ្នើត ដួងខែមានពន្លឺ ផ្ទុយពីរនោច គឺកាន់តែចំរើនឡើង ភ្លឺឡើងរហូតដល់ពេញវង់ ហៅថាខែពេញបូរមី។

## សំយោគមតិ

✳ *អំពិលអំពែក* លោកប្រៀបទៅនឹងជនខ្លះ ដែលធ្លាប់តែខ្សោយធនធាន ខ្សោយបុណ្យសក្តិ ខ្សោយចំនេះដឹង។

✳ *ទំមែកពុទ្រា* : មែកពុទ្រាលោកទុកដូចជាខ្នង ឬបង្អែករបស់ជនអ្នកប្រាថ្នាលាភ ឬបុណ្យសក្តិ។

✳ *ព្រើត១គ្រប់គ្នាថាឯងភ្លឺ* : ជនកំសោយទាំងគ្រប់ខាងលើនេះ លោតែ

លក់ដីកេរបាន លោតែឡើងបុណ្យសក្តិបន្តិចបន្តួចបាន គេច្រើនតែភ្លើតភ្លើនភ្លេចខ្លួន ជ្រើមនឹងធនធាន ជ្រើមនឹងបុណ្យសក្តិ។ បើទោះជាធនធាន ឬបុណ្យសក្តិនោះ បានមកដោយអំពើទុច្ចរិតបែបណាក៏ដោយ ក៏គេពុំខ្វល់ដែរ។

បុគ្គលដែលភ្លើតភ្លើននឹងឋានៈបុណ្យសក្តិទ្រព្យធនខ្លាំងពេកទៅ គេភ្លេចអស់នូវអត្តសញ្ញាណជាតិ ភ្លេចជាតិកំនើត ភ្លេចគោត្រត្រកូលរបស់ខ្លួនដែលធ្លាប់តែតូចទាបអស់រលីង។ បុគ្គលខ្លះទៀត កាលបើបានឡើងធ្វើជាអ្នកគ្រាន់បន្តិចទៅ ស្រាប់តែស្ទុះកញ្ច្រោលហួសនឹម ហួសចន្ទោល។ ហេតុការណ៍នេះបណ្តាលមកពីគេជ្រើមតាមគ្នា បង្អួតគ្នាពីធនធាន ពីបុណ្យសក្តិ។ ព្រោះគេគិតថា "គ្មានអ្នកស្មើ"។

អាកប្បកិរិយាបែបនេះហើយ ដែលលោកប្រៀបប្រដូចទៅនឹងសត្វអំពិលអំពែកថា "ព្រើត១គ្រប់គ្នាថាឯងភ្លឺ"។

* *ឫស្សីឥតថ្នាំង* : លោកចង់ឱ្យន័យថា "ច្បាប់ក្តី ប្រពៃណីក្តី ទំនៀមទំលាប់ក្តី ឱ្យតែកាលណាមនុស្សទំនើបនិយមជ្រុល បរទេសនិយមជ្រុល សំភារៈនិយមជ្រុល គឺគេលែងគោរពប្រតិបត្តិ លែងថែរក្សាប្រពៃណីជាតិ។ ពេលនោះ អត្តសញ្ញាណជាតិនឹងសាបសូន្យរលត់រលាយអស់ហើយ គឺវាមិនខុសពីដើមឫស្សីឥតថ្នាំង ដែលមិនអាចរក្សាជំហររបស់ខ្លួនអោយរឹងពឹងបានរីដូច "ឈើប៉ុដងវែង តាខេ"ដែលគ្មានខ្វង់គឺរលាយខ្វង់ ដូច្នោះឯង។

* *រតាំងលែងលី* : រតាំងដែលធ្លាប់តែដង្ហោយហៅមនុស្សអោយមកសូត្រធមិ

អោយមកប្រកបការងារតាមលំអានព្រះពុទ្ធសាសនាក៏លែងលឺដែរ ។ ការណ៍នេះបញ្ជាក់អោយដឹងថាប្រពៃណីក្នុងសាសនាចុះខ្សោយ ហើយធុរៈកិច្ចផ្សេងៗក្នុងសាសនាគេលែងសូវប្រតិបត្តិអស់ហើយ ។

✳ *រនោចខែភ្លឺ* : ធម្មតាខែរនោចដែលធ្លាប់តែងងឹត ត្រលប់បែរជាភ្លឺទៅវិញ គឺមានន័យសំដៅចំពោះជនអវិជ្ជាដែលធ្លាប់តែស្ថិតនៅថ្នាក់ក្រោម នៅស្រទាប់បាតស្រាប់តែឡើងធ្វើអ្នកគ្រាន់ អ្នកដឹកនាំទៅវិញ តួយ៉ាងដូចនៅក្នុងសម័យខ្មែរក្រហមជាដើម ។

✳ *ខ្មើតងងឹតសូន្យ* : អ្នកបញ្ញវន្ត បណ្ឌិត វិស្វករ ស្ថាបត្យករ អ្នកចេះដឹងខ្ពស់ អ្នកមានបទពិសោធន៍ច្រើន និងអ្នកមានអភិបាលកិច្ចល្អ ស្រាប់តែត្រលប់ធាតុ ក្លាយទៅជាអ្នកស្រទាប់បាតក្រោម ជំនួសពួកអវិជ្ជាទៅវិញ ។

នេះហើយដែលលោកថាបរិយាកាសពុករលួយ និងបរិយាកាសដ៏សែនឆ្កួតលីលារបស់ពួកខ្មែរក្រហមដែលយកពួកបញ្ញវន្តទៅសំលាប់ចោល រួចតាំងពួកអវិជ្ជាអោយធ្វើជាអ្នកដឹកនាំ ។

ទំរើបែបនេះហើយដែលលោកថា "ខ្មើតងងឹតសូន្យ" ជនជាអ្នកចេះដឹងបែរជាងងឹតងងុល ក្លាយជាមនុស្សអត់ប្រយោជន៍ទៅវិញ ។

**បញ្ជាក់**

ការបរិយាយខាងលើនេះ ជាវត្ថុបំនងរបស់បុរាណចារ្យ ដែលបានលើកពាក្យ

ទំនឹមទំនៀមនេះឡើង។ ប៉ុន្តែបើមានបំនកស្រាយទីទៃពីនេះ ដើម្បីតំរូវទៅតាមចំនូលចិត្ត របស់គេ វាជាសិទ្ធិរបស់អ្នកវោហារសាស្ត្រទេ ៕

១៩. ៦. ១១

❀❀❀❀

"ជនមិនធ្លាប់អប់រំខ្លួនស្ងួនសុចរិត ធ្លាប់ប្រព្រឹត្តតែកំហុសខុសឃោរឃៅ
បានកំពស់យសកំប៉ិចបន្តិចទៅ ឡើងសន្ធៅធំសន្ធឹកជាន់គ្នាឯង"។

**ខ្ញុំម. ណាគ្រី**

# ៤៤៣. អ្នកបួសឥតក្រិត្យ ចាស់ឥតប្រព្រឹត្ត ខ្សត់ច្រើនប្រមាទ ភរិយាផ្ទុយផ្ទាយ ចាយវាយឥតខ្ជាត ពលពាលសុទ្ធសាធ ប្រដៅក្រឋាន ៦

**និយមន័យ**

ពួកជនឥតកាន់ក្រិត្យក្រម

**អត្ថាធិប្បាយ**

✳ អ្នកបួសឥតក្រិត្យ ចាស់ឥតប្រព្រឹត្ត ខ្សត់ច្រើនប្រមាទ ព្រះរាជសម្ភារ ទ្រង់ត្រាស់ថា ពួកជនដែលឥតកាន់ក្រិត្យក្រម គឺ :

ក/ អ្នកបួសឥតក្រិត្យ : គឺអ្នកបួសដែលមិនប្រតិបត្តិតាមពុទ្ធដីកា, មិនប្រព្រឹត្តិតាមធម៌វិន័យរបស់ព្រះសម្មាសម្ពុទ្ធ រឺក៏មិនគោរពតាមពុទ្ធបញ្ញត្តិ ។

ខ/ ចាស់ឥតប្រព្រឹត្តិ : ទ្រង់ពោលសំដៅយកមនុស្សចាស់ណាដែលឥតដឹងខ្លួនថា "ខ្លួនឯងចាស់" ។ ឯពាក្យថា : ឥតប្រព្រឹត្តិ គឺពោលសំដៅយកការប្រព្រឹត្តិអំពើ ជាកុសល ។ មនុស្សចាស់នេះ មានអាកប្បកិរិយាជាជនពាល មានការដើរស៊ីផឹក ស្រវឹងខ្ជួប និងគ្មានបែបបទជាចាស់មានសីលធម៌, គុណធម៌ និង គុណវុឌ្ឍិ ពោលគឺចាស់អន់ថយ ។

គ/ ខ្សត់ច្រើនប្រមាទ : ទ្រង់ពោលទៅលើជន ខ្សត់ខ្សោយថា ពួកជននេះ

ច្រើនតែជាជនប្រមាទ គឺធ្វេសប្រហែសក្នុងការងារគ្រប់យ៉ាង មានការងាររកស៊ី ចិញ្ចឹមជីវិត និងជាជនខ្ជិលច្រអូស

✳ ភរិយាផុយផាយ-ពលពាលសុទ្ធសាធ ប្រដៅក្រុបាន

ក/ *ភរិយាផុយផាយ* : គឺភរិយាដែលមិនគត់មត់ក្នុងកិច្ចការជាស្រី *មេផ្ទះ*. មានចរិយាមារយាទមិនប្រក្រតី ។ របស់របរ រឺប្រាក់កាស ដែលប្ដីរកបានមក គ្មានគំនិតចេះរៀបចំ សន្សំទុកដាក់ អោយមានសណ្ដាប់ធ្នាប់ និងចាយវាយគ្មានដឹមុខក្រោយ ។ ជួនកាលទិញរបស់ដែលមិនចាំបាច់ ។ ជាស្ត្រីរឡេះរឡោះ ចូលចិត្តដើរលេងសើចតាមផ្ទះគេ ។ ជួនកាលទៀត យកប្រាក់កាសដែលប្ដីរកបែកញើសហូរញើស ទៅលេងល្បែងស៊ីសងទៀតផង ជាពិសេសទៅទៀត គេមានចរិយាជាស្រីចិត្តចើក ។

ខ/ *ពលពាលសុទ្ធសាធ ប្រដៅក្រុបាន* : គឺពពួកពាលសាមាន្យអប្រិយ ដែលដើរតែប្រព្រឹត្តិអំពើអនាចារ មានការស៊ីផឹក. ការលួច. ប្លន់. ឆបោក. កេងប្រវ័ញ្ច ។ល។ ពួកជនអស់ទាំងនេះ មិនងាយមានគ្រូអាចារ្យណាប្រដៅបានឡើយ ។ បើមានគ្រូប្រដៅ អប់រំ ក៏មិនខ្ចីស្ដាប់ដែរ ៕

សុជានី ចូលគេងពេទ្យកុមារជាតិ ១៥-៩-១១

| |
|---|
| មិត្តអាក្រក់ប្រៀបដូចធ្យូងខ្មៅ ពេលវាឆេះក្ដៅរលាកដៃ<br>ពេលវាត្រជាក់ក៏ចង្រៃ កាន់ប្រលាក់ដៃពុំជាឡើយ ។<br>*ល.ថ.ល* |

# ៤៤៤. អោយត្រាប់កុកសាប់ កុំត្រាប់កុកស

**និយមន័យ**

ត្រូវចេះផ្លាស់ប្តូរឥរិយាបថតាមកាលៈទេសៈនិងកុំធ្វើអ្វីដែលមិនស្របតាមពេលវេលា

## អត្ថាធិប្បាយ

### អត្ថានុរូប

-"កុកសាប់" ជាញាតិសន្តានទឹងកុកគ្រោង, កុកក្រក, កុកស ដែរ ប៉ុន្តែវាមានលក្ខណៈពិសេស ត្រង់ដែលវាមានអំនោយពីធម្មជាតិ ដែលបានចងដៃអោយវានូវសារធាតុម្យ៉ាង ដែលអាចផ្លាស់ប្តូរពិណសំបុរស្លាបរបស់វា ទៅតាមមជ្ឈដ្ឋានដែលវាស្ថិតនៅជាស្វ័យប្រវត្តិ ។ ដូចជា :

បើវាស្ថិតនៅកន្លែងណាដែលមានពណ៌ខ្មៅ មានភក់ជាដើម សំបុរស្លាបវាក៏ខ្មៅតាម, បើវាទៅទំលើមែកឈើ មានសំបុរពិណបៃតងចាស់ រឺ ខ្ចី ស្លាបវាក៏ប្តូរពណ៌ទៅតាមស្លឹកឈើទាំងនោះដែរ, បើវាហើរទៅលើអាកាស ដែលមានពពកសំបុរ-ស ស្លាបវាក៏មានសំបុរ-ស ដូចពពកដែរ ។

៦ "កុក-ស" ការណ៍ដែលវាប្រែប្រួលសំបុរស្លាប ទៅតាមទីកន្លែងដែលវាទំគឺជាកិច្ចមួយបន្លំភ្នែក កុំឱ្យសត្រូវមើលឃើញ ។

### អត្ថប្បដិរូប

បុរាណាចារ្យ បានលើកយកពំនោលនេះឡើង គឺក្នុងស្មារតីជួយបង្រៀនដល់

អនុជនជំនាន់ក្រោយអោយ "ចេះរស់ក្នុងមជ្ឈដ្ឋាននានា" ។ បើទីកន្លែងនោះ គេមានទំលាប់ដូចម្ដេច គប្បីបង្អោនឥរិយាបថខ្លួនទៅតាមសហគមន៍ ដែលរស់នៅទើបជា ការល្អ។ ប៉ុន្តែ មិនមែនធ្វើខ្លួនអោយទៅជាជន "វេនិយម" ដូចចុងស្រល់នោះទេ ។

ម្យ៉ាងទៀត ន័យនេះក៏មិនយោងទៅយកតម្រាប់អ្វីដែលជាអំពើអាក្រក់ និងខុសច្បាប់នោះដែរ ដូចជា : កាប់បំផ្លាញព្រៃឈើ, រត់ពន្ធ, ជក់គ្រឿងញៀន, ចោរកម្ម, ពាលាអាវ៉ាសែជាដើម ។

ការណ៍ដែលចេះសម្របខ្លួនទៅតាមកន្លែងរស់នៅដូចកុកសាប់ គេនឹងបានសេចក្ដីសុខ ព្រោះចេះចូលស្ទឹងតាមបត់ គឺមិនឈ្លើយ មិនឆ្គងខុសគេ ដូចពាក្យលោកថា "នៅឯណាមិនច្រលំនឹងគេដុចកុក-ស" គឺត្រូវធ្វើខ្លួនអោយច្រលំនឹងគេ ដូចកុកសាប់ ទើបជាការប្រពៃ ។

នេះគឺជាមេរៀនដែលបុរាណាចារ្យ បានប្រដៅទុកមកអោយអនុជនប្រតិបត្តិតាម ៕

១៥-០៨-២០១១

❀❀❀❀

# សិល្បៈខ្មែរ

## កាន់តែខឹង កាន់តែញញឹម សំដីទន់ភ្លន់ ចាត់ដៃត្រជាក់ តែបេះដូងក្តៅ

**និយមន័យ**

បច្ចេកវិធីលាក់ពុត របស់ភាគី១ ទៅលើភាគីម្ខាងទៀត

### អត្ថាធិប្បាយ

ពំនោលនេះ គឺជាពាក្យស្លោករបស់អ្នកនយោបាយ ដែលលើកឡើង ដើម្បីជាល្បិចគំនិតស៊ុជរៅក្នុងកិច្ចការរបស់គេ ។ តែពេលនេះ យើងលើកយកសំលោកនេះមកបរិយាយដើម្បីជាសិល្បវិធីក្នុងប្រជាសហគមន៍ធម្មតាវិញ ។

សឹងតែជាប្រពៃណីទៅហើយ នៅក្នុងជីវភាពរស់នៅរបស់ប្រជាសហគមន៍រមែងតែងមានបក្សពួក និងក្រុមដោយឡែក-ដោយឡែកពីគ្នា ។

ដូច្នេះ កាលណាមានបក្សមានក្រុម ក៏រមែងមានគំនិតចង់យកឈ្នះ យកប្រៀបលើគ្នាជានិច្ច ។ ម្ល៉ោះហើយក្រុមនិមួយៗចេះតែខំរាវរកសិល្បវិធីប្លែកៗ ដើម្បីលើកយកមកបោកបញ្ឆោត រឹបន្លំភ្នែក និងបំភ័ន្តគំនិតគ្នា បានសេចក្តីថា : "ចិត្តផ្សេងអាការៈខាងក្រៅផ្សេង" ។ តួយ៉ាងដូចខាងក្រោមនេះ :

## ☞ កាន់តែខឹង កាន់តែញញឹម

ពាំនោលនេះ មានន័យថា ត្រូវចេះលាក់ការណ៍ពិតកុំឱ្យគេដឹង គឺបើខឹងនឹងអ្នកណាម្នាក់ជាខ្លាំងយ៉ាងណាក៏ដោយ គេត្រូវធ្វើអាការៈហាក់ដូចជាមិនខឹងសោះ ។ គឺគេត្រូវប្រើទឹកមុខយ៉ាងណា រឺត្រូវបង្ខំចិត្តដូចម្ដេចធ្វើជាញញឹមញញែមយ៉ាងសាមញ្ញធម្មតាហាក់ដូចជាមិនមានហេតុការណ៍អ្វីមួយកើតឡើងឡើយ ។ ព្រោះថា ទំរើចិត្តឱ្យកាន់តែត្រជាក់ នៅពេលខឹងក្រេវក្រោធ គេនឹងស៊ីជំរៅកាន់តែខ្លាំងដែរ សមដូចពាក្យទំនឹមទំនៀមខ្មែរមួយចែងថា : "*ក្ដៅស៊ីរាក់ ត្រជាក់ស៊ីជ្រៅ* រឺក៏ថា : *លាក់ការណ៍ខ្លស់ រស់បានយូរ* " ដូច្នោះឯង ។ ព្រោះដោយសារតែ អ្នកម្ខាងទៀត ឥតបានយល់ បានដឹងពីល្បិចកិច្ចកលអាថិកំបាំងរបស់គេឡើយ ។ ការណ៍ដែលចេះធ្វើឱ្យគេភន្តច្រលំ រឺស្មានខុសពីជំរៅចិត្តគំនិតអាថិកំបាំងរបស់គេហ្នឹង អាចចាត់ទុកថា ជាជោគជ័យរបស់គេមួយជំហានយ៉ាងប្រសើរទៅហើយ ។

## ☞ សំដីទន់ភ្លន់ បាតដៃត្រជាក់

ពាំនោលនេះ ក៏មានន័យប្រហាក់ប្រហែលនឹងខ្លឹមសារខាងលើដែរ ។ គឺគេគ្រាន់តែ បន្ថែមន័យឱ្យបានកម្មបទពីរទៀតគឺ *វចីកម្ម* និង *កាយកម្ម* ។

- **សំដីទន់ភ្លន់** ក៏ជាសិល្បវិធីយ៉ាងស៊ីជំរៅមួយដែរ គឺគេត្រូវចេះប្រើសំដីផ្អែមល្ហែម, លើកដាក់, ផ្ទាក់ផ្ទមសំដីយ៉ាងសែនត្រជាក់ ដើម្បីបិទបាំងនូវគំនិតអាថិកំបាំងរបស់គេ ។

- **បាតដៃត្រជាក់** បាតដៃត្រជាក់នេះ ក៏ជាកាយវិការមួយបញ្ជាក់ថា ៖ រាល់ទំរើទាំងឡាយ កុំធ្វើតូងតាង, ឆុងឆាំង, ក្តុងក្តាំង ដូចពាក្យលោកថា ៖ *ដៃភ្លើង ជើងមាន់* ឱ្យសោះ ។ ព្រោះថា រាល់ការងារអ្វីក៏ដោយ កាលណាធ្វើតក្កហលខ្លាំងពេក វានឹងធ្វើឱ្យខូចការអសារបង់ជាមិនខាន ។ សមដូចពាក្យទំនឹមទំនៀមខ្មែរបុរាណពោលថា ៖ "*សន្សឹមកុំបំពោល ក្រែងពុំដល់ដូចប្រាថ្នា រឺថា ៖ តូងតាងដេកផ្លូវ*" ។

***តែបេះដូងក្តៅ**

ពាក្យថា "**តែ**" ជាពាក្យខណ្ឌន័យទាំងពីរខាងលើ គឺពីសភាពទន់ភ្លន់ មកសភាពរឹងពឹង, មុឹងម៉ាត់, ប្រាកដនិយម ។

បេះដូងក្តៅ គឺជាគោលបំនង និងជាទិសដៅដែលត្រូវធ្វើឱ្យបានសំរេច បើទោះជាមានឧបសគ្គយ៉ាងណា ក៏ត្រូវតែតាំងចិត្តប្តេជ្ញា ពុះពារគ្រប់ឧបសគ្គទាំងអស់ រហូតដល់បានជោគជ័យជាស្ថាពរ ។

ម្យ៉ាងទៀត ក្នុងខ្លឹមសារខាងលើនេះ គេអាចយកទៅប្រើក្នុងសិល្បវិធី "ប្រលោមស្នេហ៍" ក៏បានដែរ ។ ព្រោះសុទ្ធតែជាផ្លូវដែលគេត្រូវដើរប្រើល្បិចសំងាត់ "*ឆ្មាលាក់ក្រចក*" រឺក្នុងន័យ "លាក់ពុត" ដូចគ្នាទាំងអស់ ៕

*ថ្ងៃទី ២២-១១-១០*

គ្រោះថ្នាក់ស្លាប់ ៣៥៣ នាក់ របួស ៣៩៤នាក់ នៅស្ពានកោះពេជ្រ ភ្នំពេញ

# ផ្គាប់មនុស្សបីពួក

**ផ្គាប់អ្នកធំ ដោយគ្មានបន្ទន់ប្រាណ**
**ផ្គាប់អ្នកក្លាហាន ដោយទំលាយ**
**ផ្គាប់អ្នកតូច ដោយអោយបាយទឹក**

**និយមន័យ**

វិធីសាស្ត្រក្នុងការផ្គាប់មនុស្ស

## អត្ថាធិប្បាយ

ការយកភាពឈ្នះ លើបុគ្គលទាំងបីពួក គឺ : ថ្នាក់លើ ថ្នាក់កណ្ដាល និង ថ្នាក់ក្រោម ។ លោកឱ្យប្រើវិធីសាស្ត្រក្នុងការផ្គាប់ទៅតាមឋានៈមនុស្ស ។ ព្រោះថា : ការយកភាពឈ្នះលើមនុស្សដែលមានឋានៈខុសគ្នា, សិល្បវិធីក៏មានលក្ខណៈ ខុសគ្នាដែរ ដូចជា :

### ក, ផ្គាប់អ្នកធំ ដោយគ្មានបន្ទន់ប្រាណ

ពាក្យថា "*អ្នកធំ* " នៅពេលនេះ សំដៅយកអ្នកដែលមានបណ្ដាសក្ដិ និងអ្នកដែលមានទ្រព្យសម្បត្តិ ។ បើគេចង់យកភាពឈ្នះលើបុគ្គលពួកនេះ គឺត្រូវប្រើ អាកប្បកិរិយាទន់ភ្លន់, ចេះគោរព, ចេះគួរសម, ចេះអោនលំទោន ។ បើឃើញគេនៅ កន្លែងណា បើអាចធ្វើបាន ត្រូវដើរទៅជិតៗ ក្បែរៗគេ ដើម្បីអោយគេឃើញមុខ

និងឃើញអាកប្បកិរិយា សុភាពរាបសារ និង អោនលំទោន ដប់ដង, ម្ដេដង គង់គេនឹងចាប់អារម្មណ៍ម្ដងមិនខាន។ កាលបើគេហៅរក ឈ្មោះថាជាការយក ភាពឈ្នះបានហើយ ។

## ខ, ផ្ចាញ់អ្នកក្លាហាន ដោយទំលាយ

អ្នកក្លាហាន នៅពេលនេះ សំដៅយកអ្នកដែលមិនចេះខ្លាចអ្នកណា, មិនចេះ យកចិត្តអ្នកណា គឺកេទុកអ្នកផងមិនស្មើនឹងខ្លួន ។ បើគេក្រលេកមើលអ្នកជុំវិញខ្លួន គេឃើញអ្នកផងហាក់ដូចជានៅតូចទាបជាងគេទាំងអស់ ។ ម្ល៉ោះហើយ គេពើងទ្រូង និង មោទកភាព នឹកថាគ្មានអ្នកស្មើ ។

ក្រៅពីអញ គឺមានតែអញ ។ មនុស្សបែបនេះ មិនបាច់ទៅត្រុនៗ អោន លំទោនអ្វីទេ បើហ៊ានតែធ្វើខ្លបខ្លាច គឺគេដើរជាន់បណ្ដោយ ។

ដូច្នេះ គេត្រូវរកមធ្យោបាយបែបណា ទំលាយអោយឃើញថា : ខ្លួនយើងក៏ មិនធម្មតាដែរ គឺមានសមត្ថភាពគ្រប់គ្រាន់ មិនមែន "ម៉ាស្រុកមានតែឯងម្នាក់ទេ គឺមានអញម្នាក់ទៀតដែរ អាភឿន ! " ។

ការណ៍ដែលនិយាយបែបនេះ គឺនិយាយចំពោះតែអ្នកដែលក្លាហានដែរទេ ។ ចំពោះ អ្នកដែលញ៉ាបៗ "*សុំតែសុខ*" នោះ សូមក្ដោប "ប្រដាប់" ដើរចេញអោយឆ្ងាយ ទៅចុះ។

## គ, ផ្ចាញ់អ្នកតូច ដោយអោយបាយទឹក

អ្នកតូច នៅពេលនេះ សំដៅយកអ្នកដែលខ្សត់ខ្សោយទ្រព្យសម្បត្តិ ។

មានអ្នកខ្សត់ខ្សោយខ្លះ ច្រើនចិញ្ចឹម "ចិត្តធំ, ចិត្តខ្លាំង និងចិត្តមានះ "។ ពួកជនប្រភេទនេះ តែងពោលដោយអំនួតថា : បើអញក្រ ក្រតែអញទេតើ មានទើសក្បាលអាណា ! ។ ពួកអស់នេះ សុទ្ធតែប្រដៅបានដោយលំបាក ។ ព្រោះ គេក្រឥតដឹងខ្លួនថាក្រ, ល្ងង់ក៏មិនដឹងខ្លួនថា ល្ងង់ ។ ដូច្នេះ បើគេចង់ផ្ចាញ់ពួកអស់នេះ លោកថា : អោយឧស្សាហ៍ហៅរក និងអោយអ្វីៗជាអាហារស៊ីចុក មានបាយ-សំល ជាដើម ។ មិនយូរប៉ុន្មាន មនុស្សបែបនេះ នឹងដោះមួក ដើរអោនៗមករកយើង ។ ត្រង់ហ្នឹងហើយដែលលោកថា : ភាពឈ្នះអ្នកតូច ដោយអោយបាយ-ទឹក ៕

៤-១០-១១

❀❀❀❀



# កុំជឿងដោយខ្យល់ កុំឱនពាក្យពល កុំខ្វល់ដោយស្រី កុំកាន់ពិសយង់ គប់នឹងស្ត្រី សមណៈជនជី កុំអោយក្តីត្រូវ ៗ

**និយមន័យ**

បទហាមមិនអោយធ្វើ, ព្រោះជាបច្ច័យនាំមកនូវផលវិបាក និងមិនសមគួរ

## អត្ថាធិប្បាយ

ពំនោលនៃតម្រាស់របស់ព្រះរាជសម្ភារ ក្នុងសំលោកខាងលើនេះ គឺជាបទបង្ហាញផ្លូវដែលនាំអោយមានបញ្ហាទៅថ្ងៃក្រោយ ។

✳ កុំជឿងដោយខ្យល់ កុំឱនពាក្យពល កុំខ្វល់ដោយស្រី

ក/ កុំជឿងដោយខ្យល់ :

-ជឿង = ទ្រឹងគិតមិនលេច

-ខ្យល់ = ពេលនេះ គឺ "សំដីព្យួហ៍"ដែលធ្វើអោយភ័ន្ត

-ព្យួហ៍ = ឧបាយកលបោកបញ្ឆោតអោយលង់គំនិត

សរុបន័យ : បើកាលណាលឺសំដីដែលគេនិយាយព្យួហ៍, ទ្រង់ប្រាប់ថាត្តទុកដាក់ និងវង្វេងវង្វាន់ភន្តច្រលំ នាំអោយកើតកង្វល់ក្នុងចិត្ត ។

ខ/ កុំឱនពាក្យពល ៖

អ្នកដែលជា"មេកោយ"គេ ជាពិសេស មេទ័ព មិនត្រូវយកពាក្យពល គឺពាក្យកូនចៅដែលម្នាក់ថាយ៉ាងនេះ, ម្នាក់ទៀតថាយ៉ាងនោះ មកជាអារម្មណ៍ រឺយកមកគិតនាំអោយមានកង្វល់ទេ ។ ពិសេស មិនត្រូវបង្អោនទៅតាមពាក្យពលទេ គឺត្រូវបញ្ជាដាច់ណាត់ ។

គ/ កុំខ្វល់ដោយស្រី ៖

ន័យរបស់ពាក្យនេះ ក៏មានខ្លឹមសារប្រហាក់ប្រហែល និងដូចសំលោកខាងលើដែរ គ្រាន់តែមួយជា "ពល" មួយទៀតជា "ស្រី" ប៉ុណ្ណោះ ។

* *កុំកាន់ពិសយង់ គប់នឹងស្ត្រី*

*សមណៈ,ជនជី កុំក្តីអោយត្រូវ*

ក/ *កុំកាន់ពិសយង់ គប់នឹងស្ត្រី* ៖

ពិសយង់ = ពិសខ្លាំង, ពិសកាចសាហាវ

តាមន័យនេះ ការភប់ប្រសព្វនឹងស្ត្រី គឺការស្ម័គ្រស្មាគមនឹងស្ត្រីជាហេតុនាំមកនូវគ្រោះថ្នាក់ធ្ងន់ធ្ងរ ប្រៀបដូច កាន់-កពស់ ដែលមានពិសកំនាចដូច្នោះដែរ ។ ព្រោះស្ត្រីខ្លះជា កូនក្រមុំគេ, ខ្លះជាសង្សារគេ និងខ្លះជាប្រពន្ធគេ... ។ ដូច្នេះហើយ បានជាទ្រង់ត្រាស់ថា បើស្និទ្ធនឹងស្ត្រីណាម្នាក់ខ្លាំង គឺមិនខុសពីយក

អាសិរ្តិស មករុំ-ក លេង ដូច្នោះឯង ។

*ខ/ សមណៈ,ជនជី កុំអោយក្តីត្រូវ ៖*

សមណៈ = អ្នកបួស, ជនជី = តាជី យាយជី, ក្តី = ជម្លោះ

ន័យនេះ ទ្រង់បានធ្វើការហាមប្រាមថា ៖ ជាមួយនឹងព្រះសង្ឃ, តាជី, ដូនជី កុំទៅបង្ករឿងជម្លោះអ្វីមួយអោយសោះ ។ ព្រោះជនទាំងអស់នេះ គឺជាជនទ្រទ្រង់នូវសីល, ប្រតិបត្តិនូវធម៌អាចិក្នុងសាសនាព្រះជិនស្រី ។ ដូច្នេះ គប្បីចៀសជម្លោះតូច-ធំ ពីពួកជនទាំងអស់នេះ ដែលទ្រង់ត្រាស់ថា ៖ កុំអោយក្តីត្រូវ ៕

២៩-៩-២០១១

❀❀❀





ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៩